# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកោះកុង

# របាយការណ៍
## ស្តីពី
## ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង
## ប្រចាំឆមាសទី១ ឆ្នាំ២០២៦

ព.ស.២៥៦៩-២៥៧០ ឆ្នាំ២០២៦

# មាតិកានុក្រម

ទំព័រ

សេចក្ដីផ្ដើម ........ ១
ផ្នែកទី១៖សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត ........ ២
១.១-ការងាររដ្ឋបាល ........ ២
១.១.១-ការងាររបៀប និងឯកសារ ........ ២
១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន ........ ២
១.១.៣-ការងារទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ ........ ៣
១.១.៤-ការងារសរុប និងព័ត៌មាន ........ ៤
១.១.៥-ការងារលេខាធិការក្រុមប្រឹក្សា ........ ៤
១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា ........ ៥
១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ........ ៥
១.២-ការងារផែនការ និងវិនិយោគ ........ ៧
១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ........ ៧
១.២.២-ការគាំទ្រមូលដ្ឋាន ........ ៧
១.២.៣-ការវិនិយោគ ........ ៨
១.២.៤-ការងារសេវាសង្គម ........ ៩
១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប. ........ ៩
១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា ........ ១០
១.៣-ការគ្រប់គ្រងធនធានមនុស្ស ........ ១១
១.៣.១-ការងារគ្រប់គ្រងបុគ្គលិក ........ ១១
១.៣.២-ការងារកសាងសមត្ថភាព ........ ១២
១.៤-ការងារអន្តរវិស័យ ........ ១៣
១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច ........ ១៣
១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់ ........ ១៤
១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ ........ ១៤
១.៤.៤-ការងារគ្រប់គ្រងកាកសំណល់ ........ ១៤
១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ ........ ១៤
១.៦-ការងារការិយាល័យប្រជាពលរដ្ឋ(សម្រុះសម្រួលដោះស្រាយបណ្ដឹង) ........ ១៥
១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត ........ ១៦
១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន ........ ១៦
១.៨.១-ច្រកទ្វារព្រំដែនដែលកំពុងដំណើរការ ........ ១៦
១.៨.២-សន្តិសុខ និងសណ្ដាប់ធ្នាប់តាមព្រំដែន ........ ១៦
១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ) ........ ១៧
១.៨.៤-ការផ្លាស់ប្ដូរទំនិញ ........ ១៧
១.៨.៥-កិច្ចសហប្រតិបត្តិការ ........ ១៧
១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ ........ ១៨

១.៩.១-ការងារហិរញ្ញវត្ថុ ...... ១៨
១.៩.២-ការងារគណនេយ្យ ...... ១៨
១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ ...... ១៩
១.១០-ការងារលទ្ធកម្ម ...... ១៩
១.១១-ការងារសុខាភិបាល ...... ២០
១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល ...... ២១
១.១៣-ការងារផ្សេងៗ ...... ២១
ផ្នែកទី២៖ សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ ...... ២៤
២.១-ផ្នែកសេដ្ឋកិច្ច ...... ២៤
២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ...... ២៤
២.១.២-ការងារធនធានទឹក និងឧតុនិយម ...... ២៨
២.១.៣-ការងារអភិវឌ្ឍជនបទ ...... ២៩
២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ...... ៣០
២.១.៥-ការងាររ៉ែ និងថាមពល ...... ៣១
២.១.៦-ការងារពាណិជ្ជកម្ម ...... ៣២
២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ ...... ៣៣
២.១.៧.១-ការងារហិរញ្ញវត្ថុ ...... ៣៣
២.១.៧.២-ការងារពន្ធដារ ...... ៣៣
២.១.៧.៣-ការងារគយ និងរដ្ឋាករ ...... ៣៣
២.១.៨-ការងារទេសចរណ៍ ...... ៣៤
២.១.៩-ការងារផែនការ ...... ៣៦
២.១.១០-ការងារផ្សេងៗ ...... ៣៨
២.១.១០.១-ការងារសាខាធនាគារជាតិ ...... ៣៨
២.១.១០.២-ការងាររតនាគារ ...... ៣៨
២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ...... ៣៩
២.២-ផ្នែកសង្គមកិច្ច ...... ៤០
២.២.១-ការងារអប់រំ យុវជន និងកីឡា ...... ៤០
២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ...... ៤២
២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម ...... ៤៣
២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ...... ៤៣
២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម ...... ៤៥
២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ ...... ៤៥
២.២.៥-ការងារព័ត៌មាន ...... ៤៧
២.២.៦-ការងារកិច្ចការនារី ...... ៤៩
២.២.៧-ការងារអធិការកិច្ច ...... ៥០
២.២.៨-ការងារធម្មការ និងសាសនា ...... ៥១
២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍ ...... ៥២

២.២.១០-ការងារមុខងារសាធារណៈ ............................................................. ៥២
២.២.១១-ការងារផ្សេងៗ ............................................................. ៥៤
២.២.១១.១-ការងារសាលាដំបូងខេត្ត ............................................................. ៥៤
២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ ............... ៥៤
២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ............................................................. ៥៤
២.៣.២-ការងារបរិស្ថាន ............................................................. ៥៥
២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន ............................................................. ៥៥
២.៣.៤-ការងារផ្សេងៗ ............................................................. ៥៧
២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ............................................................. ៥៧
២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ............................................................. ៥៧
២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍ ............................................................. ៦០
២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត ............................................................. ៦៥
២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ ............................................................. ៧០
២.៤.៥-ការងារផ្សេងៗ ............................................................. ៧១
ផ្នែកទី៣៖បញ្ហាប្រឈម និងសំណើដោះស្រាយ ............................................................. ៧១
ផ្នែកទី៤៖ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់ ............................................................. ៧២
ឧបសម្ព័ន្ធ
ឧបសម្ព័ន្ធទី១៖ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំឆមាសទី១ ឆ្នាំ២០២៦
ឧបសម្ព័ន្ធទី២៖ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំឆមាសទី១ ឆ្នាំ២០២៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកោះកុង**

លេខ...................

ថ្ងៃ.......................ខែ............ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ខេត្តកោះកុង ថ្ងៃទី.........ខែ........ឆ្នាំ២០២៦

# របាយការណ៍

## ស្តីពី

## ការអនុវត្តការងាររបស់រដ្ឋបាលខេត្តកោះកុង ប្រចាំឆមាសទី១ ឆ្នាំ២០២៥

### សេចក្តីផ្តើម

ខេត្តកោះកុង មានទីតាំងស្ថិតនៅភាគនិរតីនៃប្រទេសកម្ពុជា ចម្ងាយ២៨៩គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ និងមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ខាងលិច និងខាងត្បូងជាប់នឹងឈូងសមុទ្រថៃ និងជាប់ព្រំដែនគោកប្រទេសថៃ ខាងជើងជាប់នឹងខេត្តពោធិ៍សាត់ និងមានផ្ទៃដីសរុប ១០.០៤៥,៥៨គ.ម² មានក្រុង១ ស្រុក៦ ឃុំ២៦ សង្កាត់៣ និងមានភូមិសរុបចំនួន១១៩ភូមិ។

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រឹត្យលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ និងព្រះរាជក្រឹត្យលេខ នស/រកត/០៦២៤/៥៨៤ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២៤ ត្រាស់បង្គាប់ទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៤។ ក្រុមប្រឹក្សាខេត្តកោះកុង ក្នុងអាណត្តិទី៤ មានសមាសភាព១៩រូប ស្រី៣រូប ប្រធាន១រូបប្រុស និងមានគណៈកម្មាធិការកាតព្វកិច្ចចំនួន៣រួមមាន៖ ១).គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ២).គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ និង៣).គណៈកម្មាធិការលទ្ធកម្ម។ ក្រៅពីគណៈកម្មាធិការជាកាតព្វកិច្ចទាំង៣នេះ ក្រុមប្រឹក្សាខេត្ត ក៏មានគណៈកម្មាធិការជាជម្រើសចំនួន១ គឺ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត។

ដោយមានស្ថានភាពភូមិសាស្ត្រអំណោយផលពីធម្មជាតិ នាំឱ្យខេត្តកោះកុង មានសក្តានុពលដ៏សម្បូរបែបអាចបម្រើដល់វិស័យជាច្រើន ជាពិសេសវិស័យទេសចរណ៍ រួមមាន ៖ តំបន់ធម្មជាតិដ៏ស្រស់ត្រកាលគ្របដណ្តប់ដោយព្រៃភ្នំជ្រលងដងអូរ តំបន់អេកូទេសចរណ៍ធម្មជាតិព្រៃកោងកាងទំហំ១២.០០០ហ.ត តំបន់ព្រំដែនមានសណ្ឋាគារលំដាប់ផ្កាយ៥ជាប់មាត់សមុទ្រ តំបន់សេដ្ឋកិច្ចពិសេសកោះកុង តំបន់កោះទាំង២៣ មានប្រជុំកោះ៩ ដែលមានផ្កាថ្មដ៏ស្រស់ស្អាត និងតំបន់ឆ្នេរសមុទ្រមានប្រវែង២១៧គីឡូម៉ែត្រ លាតសន្ធឹងពីចំណុចជ្រោយស្វាយ ស្រុកស្រែអំបិល រហូតដល់ចំណុចចាំយាម ស្រុកមណ្ឌលសីមា ស្មើនឹង៤៩% នៃប្រវែងឆ្នេរសមុទ្រ៤៤០គីឡូម៉ែត្រ នៃព្រះរាជាណាចក្រកម្ពុជា។ តំបន់វិស្សមកាលតារាសាគរកោះស្តេចដែលមានទីលានវាយកូនហ្គោលខ្នាតអន្តរជាតិ តំបន់កសិ-ឧស្សាហកម្មចម្រុះ និងទំនប់វារីអគ្គិសនីចំនួន៤កន្លែង។ ក្រៅពីនេះខេត្តកោះកុង មានផែព្រែកធំៗចំនួន៥ បានរួមចំណែកក្នុងការរុញច្រានកំណើនសេដ្ឋកិច្ចខេត្ត រួមមាន ព្រែកកោះប៉ោ ព្រែកតាតៃ ព្រែកត្រពាំងរូង ព្រែកអណ្តូងទឹក និងព្រែកស្រែអំបិល។

ក្រុមប្រឹក្សាខេត្ត រួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន ដើម្បីសម្រេចចក្ខុវិស័យ គោលបំណង គោលដៅ ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍៥ឆ្នាំ ក្នុងការលើកកម្ពស់អភិបាលកិច្ច និងអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានស្របតាមច្បាប់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តនានា ដោយផ្តោតលើគោលដៅអភិវឌ្ឍន៍ដូចជា៖ ហេដ្ឋារចនាសម្ព័ន្ធផ្លូវ ថ្នល់ លូ ស្ពាន សួនច្បារ សួនកម្សាន្ត សំណង់អគារ រមណីយដ្ឋានទេសចរណ៍ អគ្គិសនី ទឹកស្អាត វប្បធម៌ សាសនា និងការអភិវឌ្ឍធនធានមនុស្ស ព្រមទាំងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

## ផ្នែកទី១÷សមិទ្ធផលការងារតាមអង្គភាពចំណុះរចនាសម្ព័ន្ធរដ្ឋបាលខេត្ត

### ១.១-ការងាររដ្ឋបាល

#### ១.១.១-ការងាររបៀប និងឯកសារ

- បានរៀបចំកែសម្រួលបញ្ជីទុកដាក់លិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធ ដើម្បីឆ្លើយតបតាមការណែនាំរបស់គណៈអភិបាលខេត្ត
- បានកត់ត្រា និងដំណើរការចរន្តឯកសាររដ្ឋបាល ជូនថ្នាក់ដឹកនាំ និងមន្ទីរ អង្គភាពពាក់ព័ន្ធបានល្អប្រសើរ
- បានទំនាក់ទំនង សម្របសម្រួល និងតាមដានរាល់លិខិតចេញ ចូលរបស់រដ្ឋបាលខេត្តជាប់ជាប្រចាំ។

**តារាងទី១៖លិខិតបទដ្ឋាន និងឯកសារប្រជាពលរដ្ឋ**

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ដីកាដែលបានដាក់ចេញ | ០ | ២៥ | ២៥ |
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ០ | ៣៨ | ៣៨ |
| ៣ | លិខិតដែលបានដាក់ចេញ | ០ | ២.០៨៨ | ២,០៨៨ |
| ៤ | លិខិតចូល | ០ | ១.៩៥៨ | ១.៩៥៨ |
| ៥ | ឯកសារដែលបានធ្វើនីត្យានុកូលកម្ម | ០ | ៤១ | ៤១ |
| ៦ | អនុស្សរណៈឬកិច្ចព្រមព្រៀង | ០ | ២ | ២ |
| ៧ | សៀវភៅគ្រួសារ | ០ | ១៩៤ | ១៩៤ |
| ៨ | អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ | ០ | ១២.៤៣៣ | ១២.៤៣៣ |

#### ១.១.២-ការងារស្ថិតិប្រជាពលរដ្ឋ និងអត្រានុកូលដ្ឋាន

- បានស្រាវជ្រាវពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬខូចដោយយថាហេតុ តាមការស្នើសុំរបស់សាមីខ្លួនចំនួន៥០នាក់ (ក្រុងខេមរភូមិន្ទចំនួន៣២នាក់ ស្រុកមណ្ឌលសីមាចំនួន១៦នាក់ និងស្រុកកោះកុងចំនួន២នាក់)
- បានស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈមេឃុំចៅសង្កាត់ចំនួន៩៥នាក់ (ក្រុងខេមរភូមិន្ទចំនួន៤៧នាក់ ស្រុកមណ្ឌលសីមាចំនួន៤៤នាក់ ស្រុកកោះកុងចំនួន៣នាក់ និងស្រុកបូទុមសាគរចំនួន១នាក់)
- បានបញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.crdepartment.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋបានចំនួន៤៣ច្បាប់។

**តារាងទី២៖ស្ថិតិប្រជាពលរដ្ឋ**

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | គ្រួសារសរុប | ៣៧.៣៣៣ | |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៥.៦៣១ | |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១.៧០២ | |
| ៤ | ស្ត្រីជាមេគ្រួសារ | ៦.៤៩៩ | |
| ៥ | ប្រជាពលរដ្ឋសរុប | ១៥៨.៧៥៦ | ៧៩.៧៨៤ |
| ៦ | កុមារអាយុក្រោម៦ឆ្នាំ | ១៣.១៣៥ | ៦.៥០៥ |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៧ | កុមារអាយុពី៦ឆ្នាំដល់ក្រោម១៨ឆ្នាំ | ៤០.០៥៨ | ១៩.២០៩ |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ១០៥.៥៦៣ | ៥៤.០៧០ |
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | ៦.៤៥៧ | ៣.១៨៤ |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | ១.៥៧៧ | ៩៦៣ |

**តារាងទី៣៖អត្រានុកូលដ្ឋាន**

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ស្ថិតិចុះបញ្ជីកំណើត | | ១.៥១៣ | ១.៥១៣ |
| ២ | បញ្ជាក់កំណើត | | ០ | ០ |
| ៣ | បញ្ជីមរណភាព | | ២៦៥ | ២៦៥ |
| ៤ | អាពាហ៍ពិពាហ៍(ខ្មែរនិងខ្មែរ) | | ១.១៧៧ | ១.១៧៧ |
| ៥ | អាពាហ៍ពិពាហ៍(ខ្មែរនិងបរទេស) | | ៧ | ៧ |

### ១.១.៣-ការងារទំនាក់ទំនងសាធារណៈនិងសហប្រតិបត្តិការអន្តរជាតិ

- បានសម្របសម្រួលការងារដូចខាងក្រោម៖
  - ធ្វើលិខិតអញ្ជើញជូនគណៈប្រតិភូនៃ រដ្ឋបាលខេត្តកោះកុង និងកងកម្លាំងប្រដាប់អាវុធទាំងបីក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជនជាតិវៀតណាម-ចិន
  - រៀបចំសារលិខិតជូនពរទៅកាន់ខេត្តអានហ្សាងនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងខេត្តកាម៉ាវ ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជនជាតិវៀតណាម-ចិន
  - ពិធីចុះហត្ថលេខាលើ អនុស្សរណៈ នៃការយោគយល់គ្នា (MOU) ក្រោមគម្រោងផ្តល់ផលហើសសម្រាប់ការសាងសង់អគារមត្តេយ្យសិក្សា នៅសាលាបឋមសិក្សាពាមកាយ ស្ថិតក្នុងភូមិភ្ញីមាស ស្រុកគិរីសាគរក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំ "ក" សាលាខេត្ត
  - ពិធីជួបសួរសុខទុក្ខ អបអរសាទរ និងជូនពរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ជាមួយប្រតិភូ ខេត្តអានហ្សាងនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំ "ខ" សាលាខេត្ត
  - ពិធីជួបសួរសុខទុក្ខ អបអរសាទរ និងជូនពរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ជាមួយប្រតិភូខេត្តកាម៉ាវ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ក្រោមអធិបតីភាព**លោក ទៀ សុះផ័យ** អភិបាលស្តីទី នៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំ "ខ" សាលាខេត្ត
  - កិច្ចជំនួបសម្តែងការគួរសម ពិភាក្សាការងារ និងជូនពរឆ្នាំថ្មីប្រពៃណីជាតិខ្មែរ ជាមួយប្រតិភូការិយាល័យកុងស៊ុលចិន ប្រចាំខេត្តព្រះសីហនុ ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា អភិបាល** នៃគណៈអភិបាលខេត្តកោះកុង នៅបន្ទប់ទទួលភ្ញៀវ សាលាខេត្ត
  - កិច្ចជំនួបសួរសុខទុក្ខ សម្តែងការគួរសម និងណែនាំខ្លួន របស់ប្រតិភូ នៃស្ថានទូតសិង្ហបូរី ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំ "ក" សាលាខេត្ត
  - កិច្ចជំនួបសួរសុខទុក្ខសម្តែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធនឹងបញ្ហាជនជាតិប៉ាគីស្ថានដែលកំពុងជាប់ឃុំនៅពន្ធនាគារខេត្តកោះកុង ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលប្រជុំ "ខ" សាលាខេត្ត។

### តារាងទី៤៖ការងារទំនាក់ទំនងសាធារណៈ

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សាធារណជនមកទំនាក់ទំនងនៅសាលាខេត្ត | ០ | ១.៩៥៤ | ១.៩៥៤ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ០ | ៨ | ៨ |

### ១.១.៨-ការងារសរុប និងព័ត៌មាន

- បានរៀបចំសេចក្តីព្រាងរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខេត្តប្រចាំខែ និងឆមាស ឆ្នាំ២០២៦ សម្រាប់ដាក់ជូនគណៈអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្តអនុម័តមុននឹងផ្ញើទៅក្រសួងមហាផ្ទៃ
- បានប្រមូលផ្តុំព័ត៌មានអំពីមតិសាធារណៈ និងហេតុការណ៍ផ្សេងៗសម្រាប់ជាមូលដ្ឋានរៀបចំព័ត៌មានជូនក្រុមប្រឹក្សាខេត្ត និងគណៈអភិបាលខេត្តដើម្បីធ្វើការដោះស្រាយទាន់ពេលវេលា
- បានផ្សព្វផ្សាយព័ត៌មានអំពីសកម្មភាពការងាររបស់គណៈអភិបាលខេត្ត សមិទ្ធផលនានា សេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្ត និងលិខិតបទដ្ឋានគតិយុត្តនានាជាប្រចាំដល់សាធារណជន តាមរយៈ facebook page channel telegram និងwebsite ផ្លូវការរបស់រដ្ឋបាលខេត្ត
- បានចូលរួមរាល់គ្រប់សកម្មភាពរបស់ថ្នាក់ដឹកនាំ ដើម្បីថតផ្តិតយករូបភាព វីដេអូ សម្រាប់ចងក្រងជាឯកសារ និងបានរៀបចំសម្របសម្រួលកិច្ចការបច្ចេកទេសព័ត៌មានវិទ្យានៅក្នុងកិច្ចប្រជុំសំខាន់ៗរបស់ថ្នាក់ដឹកនាំ។

### តារាងទី៥៖ការផ្សព្វផ្សាយព័ត៌មាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | វិទ្យុ | ០ | ១៣០ | ១៣០ |
| ២ | ទូរទស្សន៍ | ០ | ១៧៤ | ១៧៤ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ០ | ១០ | ១០ |
| ៤ | បណ្តាញសង្គម (គេហទំព័ររដ្ឋបាលខេត្ត) | ០ | ៩.៤៤៦ | ៩.៤៤៦ |
| ៥ | ព្រឹត្តិបត្រព័ត៌មាន ទស្សនាវដ្តី និងសារព័ត៌មាន | ០ | ០ | ០ |

### ១.១.៩-ការងារលេខាធិការក្រុមប្រឹក្សា

- បានសម្របសម្រួលដំណើរការកិច្ចប្រជុំ និងរៀបចំសេចក្តីព្រាងកំណត់ហេតុនៃកិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសាមញ្ញ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំសេចក្តីប្រកាសព័ត៌មានស្តីពីកិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសាមញ្ញ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- បានរៀបចំសេចក្តីព្រាងរបៀបវារៈ និងលិខិតអញ្ជើញសម្រាប់កិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសាមញ្ញ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលកិច្ចប្រជុំសាមញ្ញរបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ របស់ក្រុមប្រឹក្សាខេត្ត
- បានចាត់ចែងទុកដាក់ និងថែរក្សារាល់ឯកសារដែលបានអនុម័តរួចដោយក្រុមប្រឹក្សាខេត្ត
- បានសម្របសម្រួលរាល់លិខិត និងឯកសារនានាដែលចរាចរចេញ ចូលពាក់ព័ន្ធជាមួយក្រុមប្រឹក្សាខេត្ត បានទាន់ពេលវេលា។

### តារាងទី៦៖ការរៀបចំវេទិកា (ពុំទាន់ដល់ពេលរៀបចំ)

| ល.រ | ឈ្មោះវេទិកា | កាលបរិច្ឆេទ | អ្នកចូលរួម | |
|---|---|---|---|---|
| | | | សរុប | ស្រី |
| ១ | | | | |
| សរុប | | | | |

### ១.១.៦-ការងារគណៈអភិបាល និងគណៈកម្មាធិការនានា

ក)-ការងារគណៈអភិបាល

**១. អភិបាល នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងភ្ញៀវកិត្តិយសក្នុងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្រៅប្រទេសសរុបចំនួន២៧៤លើក។

**២. អភិបាលរង នៃគណៈអភិបាលខេត្ត**

- បានចូលរួមជាអធិបតី គណៈអធិបតី និងភ្ញៀវកិត្តិយសក្នុងពិធីផ្សេងៗទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងក្រៅប្រទេសសរុបចំនួន៨៥០លើក។

**តារាងទី៧៖កិច្ចប្រជុំគណៈអភិបាល**

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ០ | ៨ | ៨ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ០ | ១ | ១ |
| ៣ | កិច្ចប្រជុំផ្សេងៗរបស់គណៈអភិបាល | ០ | ១៧ | ១៧ |

ខ)-ការងារគណៈកម្មាធិការនានា

**តារាងទី៨៖កិច្ចប្រជុំគណៈកម្មាធិការនានា**

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ០ | ៣ | ៣ |
| ២ | កិច្ចប្រជុំគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ | ០ | ០ | ០ |
| ៣ | កិច្ចប្រជុំគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ០ | ០ | ០ |
| ៥ | ផ្សេងៗ...... | | | |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត | ០ | ២ | ២ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាប្រឡងប្រណាំងការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ខេត្ត | ០ | ២ | ២ |
| | -កិច្ចប្រជុំលេខាធិការដ្ឋាន នៃគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត | ០ | ៤ | ៤ |

### ១.១.៧-ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

#### ១.១.៧.១-ការងារក្រុមប្រឹក្សា

- បានដំណើរការកិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសាមញ្ញ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត
- បានពិនិត្យ និងអនុម័តលើឯកសារពាក់ព័ន្ធនានាតាមរបៀបវារៈនៃកិច្ចប្រជុំវិសាមញ្ញ និងកិច្ចប្រជុំសាមញ្ញ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្ត។

#### ១.១.៧.២-ការងារគណៈកម្មាធិការនានា

- **គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ**
  - បានចូលរួមប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី៤ បានចំនួន៦លើក

- បានចូលរួមប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី៤ បានចំនួន១លើក
- បានរៀបចំកិច្ចប្រជុំសាមញ្ញរបស់គ.ក.ស.កខេត្តកោះកុង អាណត្តិទី៤ ចំនួន៦លើក នៅសាលប្រជុំសាលាខេត្តកោះកុង (នៅមន្ទីរកិច្ចការនារីចំនួន១លើក)
- បានចុះផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គ.ក.ស.ក ក្រុង ស្រុកនិងសមាជិក គ.ក.ន.ក ឃុំសង្កាត់ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុក បានចំនួន៧ក្រុង ស្រុក ដែលមានអ្នកចូលរួមចំនួន២១០នាក់ ស្រី១២៧នាក់
- បានចុះប្រជុំផ្សព្វផ្សាយ ដល់សហគមន៍ស្តីពីសុខភាពនិងអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន១០០នាក់ ស្រី៨៤នាក់នៅភូមិដីទំនាប១លើក និងភូមិអន្លង់វ៉ាក់១លើក
- បានចុះប្រជុំប្រឹក្សាយោបល់ដល់ស្ត្រីនិងកុមារដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារកំព្រាឪពុកម្តាយ កុមារមានឪពុកម្តាយជាប់ពន្ធនាគារ កុមារដែលមានឪពុកម្តាយមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ កុមារមានផ្ទុកមេរោគអេដស៍នៅមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋខេត្តកោះកុង និងនៅមណ្ឌលជីវិតថ្មី ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន៦០នាក់ ស្រី២៦នាក់
- បានចុះប្រជុំផ្សព្វផ្សាយដល់សហគមន៍ស្តីពីកិច្ចការពារកុមារ ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន១០០នាក់ ស្រី៨៩នាក់
- បានដំណើការកិច្ចប្រជុំសាមញ្ញរបស់គ.ក.ស.ក ក្រុង/ស្រុក ចំនួន២លើក (ស្រុកមណ្ឌលសីមា១លើក និងក្រុងខេមរភូមិន្ទ១លើក។

○ **គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស**

- បានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ ២០២៥-២០២៩ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ២០២៥-២០២៧ របស់រដ្ឋបាលខេត្ត មានអ្នកចូលរួមចំនួន៧៧រូប ស្រី១៤រូប នៅសាលមហោស្រពខេត្ត។

○ **គណៈកម្មាធិការលទ្ធកម្ម**

- បានចូលរួមកិច្ចប្រជុំបញ្ចប់សុពលភាពធានាគុណភាពសំណង់ឆ្នាំ២០២៤ ចំនួន៤លើក ស្មើនឹង៧គម្រោង
- បានបើកកិច្ចប្រជុំចុះពិនិត្យទីតាំង និងវឌ្ឍនភាពគម្រោងលទ្ធកម្មឆ្នាំ២០២៦
- បានជូនប្រតិភូសវនកម្មជាតិចុះពិនិត្យគម្រោងសម្រាប់ឆ្នាំ២០២៥នៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ
- បានដឹកនាំក្រុមការងារចុះពិនិត្យផ្សារក្តាម និងផ្លូវភ្លោះ(វិថីម្ហូបអាហារ)
- បានប្រជុំ និងចុះពិនិត្យទីតាំងផ្លូវក្នុងក្រុងខេមរភូមិន្ទដែលជាគម្រោងលទ្ធកម្មឆ្នាំ២០២៥ និងត្រូវបានជួសជុលរួចរាល់ស្អាត
- ជូនប្រតិភូសវនកម្មក្រសួងមហាផ្ទៃចុះពិនិត្យគម្រោងលទ្ធកម្មនៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ។

○ **គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខេត្ត**

- ពុំមានសកម្មភាព។

តារាងទី៩៖កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ០ | ៦ | ៦ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០ | ១ | ១ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ០ | ៦ | ៦ |
| ៦ | កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម | ០ | ៨ | ៨ |
| ៧ | ផ្សេងៗ............ | ០ | ០ | ០ |

## ១.២-ការងារផែនការ និងវិនិយោគ

### ១.២.១-ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

- បានសម្របសម្រួលរៀបចំសិក្ខាសាលាសមាហរណកម្មកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ក្រុង ស្រុក ឆ្នាំ២០២៥ ដែលមានអ្នកចូលរួមសរុបចំនួន៥២៩នាក់ ស្រី១១៤នាក់។

តារាងទី១០៖ការអនុវត្តគម្រោងវិនិយោគ(មានការគាំទ្រ)

| ល.រ. | ផ្នែក | សរុប | តម្លៃគម្រោង (លានរៀល) | ស្ថានភាពនៃការអនុវត្ត | | |
|---|---|---|---|---|---|---|
| | | | | មិនទាន់ | កំពុង | បញ្ចប់ |
| ១ | សេដ្ឋកិច្ច | ១១ | ១៤.២២១,៨០ | ១១ | ០ | ០ |
| ២ | សង្គមកិច្ច | ១៤ | ៩១៤,៣០ | ១៤ | ៦ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ១ | ១៩៣,០០ | ១ | ១ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២ | ១៩០,០០ | ២ | ១ | ០ |
| **សរុប** | | ២៨ | ១៤.៩០២,៦០ | ២៨ | **៨** | **០** |

### ១.២.២-ការគាំទ្រមូលដ្ឋាន

#### ១.២.២.១-ការគាំទ្ររដ្ឋបាលក្រុង ស្រុក

**តារាងទី១១៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលក្រុង ស្រុក**

| ល.រ | ការបរិយាយ | ចំនួនក្រុង ស្រុក | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ៦ | ១ |
| ២ | ជំហានទី២ | ០ | ៧ |
| ៣ | ជំហានទី៣ | ០ | ៧ |

**តារាងទី១២៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងក្រុង ស្រុក**

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ១៤ | ១៤ | ០ | ០ |
| ២ | សង្គមកិច្ច | ០ | ០ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាលសន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ | ៣ | ៣ | ០ | ០ |
| **សរុប** | | **១៧** | **១៧** | **០** | **០** |

#### ១.២.២.២-ការគាំទ្ររដ្ឋបាលឃុំ សង្កាត់

- ការគាំទ្រការអនុវត្តគម្រោង ឃុំ សង្កាត់ ឆ្នាំ២០២៦
  - គម្រោងឃុំ សង្កាត់ដែលបានស្នើឡើងមាន ចំនួន៤៦គម្រោង
  - គម្រោងដែលបានបញ្ចប់ការសិក្សាមាន ចំនួន៤៣គម្រោង

- គម្រោងដែលបានដេញថ្លៃរួចមាន ចំនួន០០គម្រោង
- គម្រោងដែលបានចុះកិច្ចសន្យារួចមាន ចំនួន០០គម្រោង

– ការគាំទ្រការរៀបចំគម្រោងក្រុង ស្រុក ឆ្នាំ២០២៦
- គម្រោងក្រុង ស្រុក ដែលបានស្នើឡើងមាន ចំនួន១៧គម្រោង
- គម្រោងដែលកំពុងសិក្សាមាន ចំនួន១៧គម្រោង
- គម្រោងដែលបានបញ្ចប់ការសិក្សាមាន ចំនួន០០គម្រោង។

**តារាងទី១៣៖ការតាមដាន និងការគាំទ្រលើការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់**

| ល.រ. | ការបរិយាយ | ចំនួនឃុំ សង្កាត់ | |
|---|---|---|---|
| | | បានបញ្ចប់ | មិនទាន់បានបញ្ចប់ |
| ១ | ជំហានទី១ | ២៤ | ៥ |
| ២ | ជំហានទី២ | ០ | ២៩ |
| ៣ | ជំហានទី៣ | ០ | ២៩ |

**តារាងទី១៤៖ការតាមដាន និងការគាំទ្រលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់**

| ល.រ | ផ្នែក | សរុប | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | ការអនុវត្តវិធីសាស្ត្រលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | ៤២ | ៣៩ | ០ | ០ |
| ២ | សង្គមកិច្ច | ២ | ២ | ០ | ០ |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ០ | ០ | ០ | ០ |
| ៤ | រដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ | ២ | ២ | ០ | ០ |
| **សរុប** | | **៤៦** | **៤៣** | **០** | **០** |

### ១.២.៣-ការវិនិយោគ

– បានចូលរួមកិច្ចប្រជុំពិនិត្យមើលវឌ្ឍនភាព និងបញ្ហាប្រឈមពាក់ព័ន្ធនឹងការចុះបញ្ជីគម្រោងវិនិយោគឯកជនដែលមានទុនវិនិយោគសមមូលនឹងប្រាំលានដុល្លារអាមេរិកចុះ នៅទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម សួសប្រាថ្នា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ។

– បានចូលរួមកិច្ចប្រជុំពិភាក្សាលើការងារពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍ និងការប្រមូលថ្លៃឈ្នួលទីតាំងវិនិយោគនៅតាមបណ្តាកោះ ក្នុងខេត្តព្រះសីហនុ និងខេត្តកោះកុង នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ជា វុទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (ក.អ.ក)

– បានចុះពិនិត្យការអនុវត្តគម្រោងវិនិយោគរបស់បណ្តាក្រុមហ៊ុនមួយចំនួន ដែលបានចុះកិច្ចសន្យាជួលកោះឆ្នេរ និងរមណីយដ្ឋាននានាជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) ដូចខាងក្រោម៖
- កោះទទឹង របស់ក្រុមហ៊ុន DEN NOKOR
- ប្រជុំកោះអំពិល របស់ក្រុមហ៊ុន Full Moon Island

ជាលទ្ធផល គម្រោងវិនិយោគបានសាងសង់ ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ ផ្ទះស្នាក់ និងភោជនីយដ្ឋាន។

– បានចូលរួមបំពេញទស្សនកិច្ចផ្លូវការទៅរាជធានីប៉េកាំង និងទីក្រុងស៊ីអាននៃសាធារណរដ្ឋប្រជាមានិតចិន ដើម្បីពិភាក្សាអំពីការផ្លាស់ប្តូរបទពិសោធន៍វិស័យកសិកម្ម សក្តានុពលនៃការវិនិយោគ និងកិច្ចសហប្រតិបត្តិការគូភាគី

- បានចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំកែសម្រួលប្លង់មេអភិវឌ្ឍន៍កោះត្រេះ ខេត្តព្រះសីហនុ និងសេចក្តីព្រាងរបាយការណ៍លទ្ធផល នៃការចុះពិនិត្យការអនុវត្តគម្រោងវិនិយោគតាមបណ្តាកោះក្នុងខេត្តកែប ខេត្តព្រះសីហនុ និងខេត្តកោះកុង នៅទីស្តីការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រោមអធិបតីភាព**ឯកឧត្តម ជា វុទ្ធី** អគ្គលេខាធិការគណៈកម្មាធិការវិនិយោគកម្ពុជា
- បានចូលរួមកិច្ចប្រជុំពិភាក្សា និងចុះពិនិត្យទីតាំងស្នើសុំសិទ្ធិវិនិយោគ និងអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រកោះខ្យង ស្ថិតនៅភូមិខ្សាច់ក្រហម ឃុំជីខក្រោម ស្រុកស្រែអំបិល នៅសាលាឃុំជីខក្រោម។

### ១.២.៤-ការងារសេវាសង្គម

- បានរៀបចំកិច្ចប្រជុំសាមញ្ញរបស់គ.ក.ស.កខេត្តកោះកុង អាណត្តិទី៤ ចំនួន៦លើក នៅសាលប្រជុំសាលាខេត្តកោះកុង (នៅមន្ទីរកិច្ចការនារីចំនួន១លើក)
- បានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់គ.ក.ស.កខេត្តកោះកុងអាណត្តិទី៤ ចំនួន០លើក
- បានចុះផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គ.ក.ស.ក ក្រុង ស្រុកនិងសមាជិក គ.ក.ន.ក ឃុំសង្កាត់ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុកបានចំនួន៧ក្រុង ស្រុក ដែលមានអ្នកចូលរួមចំនួន ២១០នាក់ ស្រី១២៧នាក់
- បានចុះប្រជុំផ្សព្វផ្សាយដល់សហគមន៍ស្តីពីសុខភាព និងអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន១០០នាក់ ស្រី៨៤នាក់ (នៅភូមិដីទំនាប១លើក និងភូមិអន្លង់វ៉ាក់១លើក)
- បានចុះប្រជុំប្រឹក្សាយោបល់ដល់ស្ត្រីនិងកុមារដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារកំព្រាឪពុកម្តាយ កុមារមានឪពុកម្តាយជាប់ពន្ធនាគារ កុមារដែលមានឪពុកម្តាយមានផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ កុមារមានផ្ទុកមេរោគអេដស៍នៅមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋខេត្តកោះកុង និងនៅមណ្ឌលជីវិតថ្មីចំនួន២លើក ដែលមានអ្នកចូលរួមចំនួន៦០នាក់ ស្រី២៦នាក់
- បានចុះប្រជុំផ្សព្វផ្សាយដល់សហគមន៍ស្តីពីកិច្ចការពារកុមារ ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន១០០នាក់ ស្រី៨៩នាក់។

### ១.២.៥-ការអនុវត្តផែនការសកម្មភាព និងថវិការបស់ គ.ជ.អ.ប

- បានរៀបចំឯកសារ ស្តីពីការបញ្ចប់សេចក្តីសម្រេចរួមឆ្នាំ២០២៥ រវាង គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត និងបានបញ្ជូនទៅលេខាធិការដ្ឋាន គ.ជ.អ.ប. រួចរាល់
- បានរៀបចំឯកសារ ស្តីពីសេចក្តីសម្រេចរួមឆ្នាំ២០២៦ រវាង គ.ជ.អ.ប. និងរដ្ឋបាលរាជធានី ខេត្ត និងបានបញ្ជូនទៅលេខាធិការដ្ឋាន គ.ជ.អ.ប. រួចរាល់
- បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆមាសទី១នៃផែនការសកម្មភាពនិងថវិកាឆ្នាំ២០២៦ ជូនទៅលេខាធិការដ្ឋាន គ.ជ.អ.ប រួចរាល់។

**តារាងទី១៥៖លទ្ធផលសម្រេចបាន**

| ល.រ | ឈ្មោះលទ្ធផល | ស្ថានភាព | % សម្រេច | % ចំណាយ |
|---|---|---|---|---|
| ១ | ការពង្រឹងយន្តការដឹកនាំកំណែទម្រង់ ដើម្បីបន្តជំរុញកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិឱ្យកាន់តែមានការរីកចម្រើនទៅមុខប្រកបដោយសមធម៌ និងបរិយាប័ន្ន | កំពុងអនុវត្ត | ៥០% | ៥០% |
| ២ | ការផ្សព្វផ្សាយចក្ខុវិស័យ គោលបំណង គោលដៅ និងសមិទ្ធផលនានានៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សំដៅបង្កើនការយល់ដឹង និងការគាំទ្រយ៉ាងទូលំទូលាយដោយក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា | កំពុងអនុវត្ត | ៥០% | ៥០% |

| | | | | |
|---|---|---|---|---|
| ៣ | ការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព | កំពុងអនុវត្ត | ៥០% | ៥០% |
| ៤ | ការពង្រឹងការអនុវត្តមុខងារបច្ចុប្បន្នរបស់រដ្ឋបាល ក្រុង/ស្រុក ឃុំ/សង្កាត់ | កំពុងអនុវត្ត | ៥០% | ៥០% |
| ៥ | ការពង្រឹងទំនាក់ទំនងការងារ និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះប្រជាពលរដ្ឋ | កំពុងអនុវត្ត | ៤០% | ៤០% |
| ៦ | ការពង្រឹងលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៥០% | ៥០% |
| ៧ | ការចូលរួមរបស់ប្រជាពលរដ្ឋត្រូវបានលើកកម្ពស់ ដើម្បីធានាដល់ជំនឿទុកចិត្តរបស់ប្រជាពលរដ្ឋមកលើរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៦០% | ៦០% |
| ៨ | ការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំ និងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធឌីជីថល | កំពុងអនុវត្ត | ៥០% | ៥០% |
| ៩ | ការរៀបចំ និងដាក់ឱ្យអនុវត្ត ប្រព័ន្ធគ្រប់គ្រងផ្អែកលើសមិទ្ធកម្មនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៤០% | ៤០% |
| ១០ | ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៤០% | ៤០% |
| ១១ | ការលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ និងមុខតំណែងគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៥០% | ៥០% |
| ១២ | ការវាយតម្លៃអំពីតម្រូវការអភិវឌ្ឍសមត្ថភាព និងការរៀបចំផែន ការអភិវឌ្ឍសមត្ថភាពត្រូវបានពង្រឹងនិងកំណត់យ៉ាងច្បាស់លាស់ | កំពុងអនុវត្ត | ៤០% | ៤០% |
| ១៣ | ការពង្រឹងការប្រើប្រាស់ទិន្នន័យសម្រាប់ការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ | កំពុងអនុវត្ត | ៤០% | ៤០% |
| ១៤ | ការពិនិត្យ កែលម្អ និងពង្រឹង ការអនុវត្តយន្តការច្រកចេញចូលតែមួយសម្រាប់ផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាដល់ការផ្តល់សេវារដ្ឋបាលឱ្យកាន់តែមានភាពសាមញ្ញ ងាយស្រួលឆាប់រហ័ស ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព ព្រមទាំងជំរុញការរៀបចំ និងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន | កំពុងអនុវត្ត | ៤០% | ៤០% |
| ១៥ | ការរៀបចំបញ្ជីមូលដ្ឋានអាជីវកម្ម ឬសហគ្រាសនៅតាមមូលដ្ឋាន | កំពុងអនុវត្ត | ២០% | ២០% |
| ១៦ | ការវិនិយោគសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងហានិភ័យពីគ្រោះមហន្តរាយ និងជំងឺឆ្លងកាចសាហាវនានា | កំពុងអនុវត្ត | ២០% | ២០% |

### ១.២.៦-ការងារសហប្រតិបត្តិការជាមួយនឹងដៃគូអភិវឌ្ឍ និងគម្រោងនានា

- **ការអនុវត្តគម្រោងអាហារូបត្ថម្ភនៅកម្ពុជា ខេត្តកោះកុង**
  - ក្រុមការងារអ្នកវាយតម្លៃការអនុវត្តគម្រោងអាហារូបត្ថម្ភថ្នាក់ជាតិ បានចុះធ្វើការវាយតម្លៃលទ្ធផលនៃការបំពេញការងាររបស់ក្រុមការងារដឹកនាំអនុវត្តគម្រោងអាហារូបត្ថម្ភរបស់រដ្ឋបាលខេត្ត សម្រាប់មូលនិធិគាំទ្រការផ្តល់សេវារដ្ឋបាលឃុំ សង្កាត់ប្រចាំឆមាសទី២ ឆ្នាំ២០២៥។ ជាលទ្ធផលសម្រាប់ការវាយតម្លៃទទួលបានពិន្ទុ១០០/១០០
  - បានចុះអនុវត្តការវាយតម្លៃការអនុវត្តគម្រោងអាហារូបបត្ថម្ភរបស់រដ្ឋបាលក្រុងស្រុកប្រចាំឆមាសទី២ ឆ្នាំ២០២៥ នៅស្រុកថ្មបាំង ស្រុកបូទុមសាគរ ស្រុកស្រែអំបិល ស្រុកកោះកុង ស្រុកគិរីសាគរ ក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា
  - បានចុះតាមដាន និងបង្វឹកក្រុមអ្នកវាយតម្លៃក្រុង ស្រុកត្រៀមកិច្ចការងារសម្រាប់ចុះអនុវត្តការវាយតម្លៃថ្នាក់ឃុំ

សង្កាត់សម្រាប់ឆមាសទី២ ឆ្នាំ២០២៥ អ្នកទទួលការបង្វឹក១៣នាក់ ស្រី៦នាក់

- បានចុះតាមដាន និងបង្វឹកដល់អ្នកអនុវត្តសំខាន់នៅថ្នាក់ឃុំ សង្កាត់ អំពីរបៀបប្រមូលព័ត៌មាន កត់ត្រា និងដោះស្រាយ ឆ្លើយតបមតិយោបល់ត្រឡប់របស់ប្រជាជន ទាំង២៩ឃុំ សង្កាត់ មានអ្នកចូលរួម៦២នាក់ ស្រី២១នាក់
- បានផ្តល់ប្រឹក្សាយោបល់ជាមួយអ្នកអនុវត្តសំខាន់ៗ នៅឃុំជីខលើ ឃុំពាមក្រសោប ឃុំជីខក្រោម ឃុំអណ្តូងទឹក ឃុំត្រពាំងរូង និងឃុំភ្ញីមាស ដែលមានអ្នកចូលរួមសរុបចំនួន២៨នាក់ ស្រី៧នាក់។
- បានចុះតាមដាន និងហ្វឹកហ្វឺនអ្នកអនុវត្តសំខាន់ៗថ្នាក់ឃុំ ក្នុងការរៀបចំសកម្មភាពដូចខាងក្រោម៖
  - ផែនការកម្មវិធីឃុំ សង្កាត់សម្រាប់ស្ត្រី និងកុមារ ប្រចាំឆមាសទី១ ឆ្នាំ២០២៦
  - ការត្រៀមរៀបចំព្រឹត្តិការណ៍សហគមន៍សម្រាប់ស្ត្រី និងកុមារ
  - ចុះតាមដាន និងគាំទ្រការអនុវត្តសកម្មភាពការងាររបស់ក្រុមទ្រទ្រង់សុខភាពនៅតាមភូមិ។
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយការណែនាំស្តីពីការបិទគម្រោងអាហារូបត្ថម្ភនៅកម្ពុជា និងការធានានិរន្តរភាពសកម្មភាព និងលទ្ធផលរបស់គម្រោងបន្ទាប់ពីការបិទបញ្ចប់ នៅសាលមហោស្រពខេត្តកោះកុង។

## ១.៣-ការគ្រប់គ្រងធនធានមនុស្ស

### ១.៣.១-ការងារគ្រប់គ្រងបុគ្គលិក

- បានរៀបចំបេសកកម្មជូនក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីសាលាខេត្ត និងមន្ទីរ អង្គភាពជុំវិញខេត្ត ក្នុងឆមាសទី១ ឆ្នាំ២០២៦ សរុបចំនួន៨០០លេខ
- បានរៀបចំដីកាសរុបចំនួន២៤លេខ ស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការចំនួន៥លេខ, ស្តីពីការទទួលស្គាល់មន្ត្រីជាប់កិច្ចសន្យារបស់រដ្ឋបាលខេត្ត ក្រុង ស្រុក សម្រាប់ឆ្នាំ២០២៥ចំនួន១លេខ, ស្តីពីការផ្លាស់ប្តូរ និងទទួលស្គាល់មន្ត្រីជាប់កិច្ចសន្យាសម្រាប់ឆ្នាំ២០២៥ចំនួន២លេខ, ស្តីពីការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ តាមវេនអតីតភាពជូនដល់មន្ត្រីរាជការ នៃរដ្ឋបាលខេត្ត និងមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន២លេខ, ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍តាមកាលកំណត់ចំនួន៦លេខ, ស្តីពីការអនុញ្ញាតឱ្យមន្ត្រីរាជការចូលបម្រើការងារនៅក្នុងអង្គភាពដើមវិញចំនួន៣លេខ, ស្តីពីការលុបឈ្មោះមន្ត្រីរាជការ ចំនួន៤លេខ និងដីកាស្តីពីការផ្ទេរមន្ត្រីរាជការ ចំនួន១លេខ។

**តារាងទី១៦៖ស្ថិតិក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិក**

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា(ចំនួនក្រុមប្រឹក្សាដែលកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត) | ១៩ | ៣ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | ០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០ | ០ |
| ៤ | អភិបាល | ១ | ១ |
| ៥ | អភិបាលរង | ១០ | ១ |
| ៦ | នាយករដ្ឋបាល | ១ | ០ |
| ៧ | នាយករងរដ្ឋបាល | ៥ | ១ |
| ៨ | នាយកទីចាត់ការ/ប្រធានអង្គភាព | ៧ | ១ |
| ៩ | ប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ១ | ០ |
| ១០ | នាយករងទីចាត់ការ/អនុប្រធានអង្គភាព | ១១ | ៣ |
| ១១ | អនុប្រធានមន្ទីរ ឬអង្គភាព(ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត) | ២ | ១ |
| ១២ | ប្រធានការិយាល័យ | ១៥ | ៣ |
| ១៣ | អនុប្រធានការិយាល័យ | ១២ | ៦ |
| ១៤ | មន្ត្រីការិយាល័យ | ៩ | ៤ |

| ល.រ. | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១៥ | បុគ្គលិកកិច្ចសន្យា | ៣៩ | ២១ |

- ស្ថិតិការិយាល័យប្រជាពលរដ្ឋខេត្ត

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ០ |
| ២ | អនុប្រធានការិយាល័យប្រជាពលរដ្ឋ | ១ | ១ |
| ៣ | ប្រធានផ្នែក | ១ | ០ |
| ៤ | អនុប្រធានផ្នែក | ៣ | ០ |
| ៥ | មន្ត្រី | ០ | ០ |

- ស្ថិតិបុគ្គលិកមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង

| ល.រ | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រធានមជ្ឈមណ្ឌល | ១ | ០ |
| ២ | មន្ត្រីជាប់កិច្ចសន្យា | ១ | ១ |

### ១.៣.២-ការងារកសាងសមត្ថភាព

- បានសហការជាមួយក្រុមការងារកម្មវិធីអាហារូបករណ៍ Australia Awards រៀបចំសិក្ខាសាលាផ្សព្វផ្សាយ ចែករំលែកព័ត៌មាន និងបែបបទនានាក្នុងការដាក់ពាក្យសុំអាហារូបករណ៍សិក្សាភាសាអង់គ្លេស និងអាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សានៅប្រទេសអូស្ត្រាលី នៅសាលមហោស្រពខេត្ត
- បានសម្របសម្រួលនិស្សិតថ្នាក់បរិញ្ញាបត្រគិលានុបដ្ឋាក ជំនាន់ទី១៦ ឆ្នាំទី៤ ក្រុមBN42 ចុះកម្មសិក្សានៅមន្ទីរពេទ្យបង្អែកខេត្តកោះកុង ចាប់ពីថ្ងៃទី១០ ខែមករា-ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៥
- បានសម្របសម្រួលមន្ត្រីរាជការចំនួន១៣រូប ស្រី២រូប ចូលរួមវគ្គបណ្តុះបណ្តាលបន្តនៅក្រសួង ស្ថាប័ន
- បានសម្របសម្រួលលិខិតអនុញ្ញាតជូនមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តក្នុងការចាត់បញ្ជូនមន្ត្រីសុខាភិបាល នៃរដ្ឋបាលខេត្តចំនួន៦រូប ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពី Development of Nursing Administration and Quality Improvement for Nursing Outcomes នៅព្រះរាជាណាចក្រថៃ
- បានសម្របសម្រួលមន្ត្រីនៃមជ្ឈមណ្ឌល SEAMEO TED របស់ក្រសួងអប់រំ យុវជន និងកីឡា ចុះប្រមូលទិន្នន័យស្រាវជ្រាវនៅតំបន់សេដ្ឋកិច្ចពិសេសកោះកុង ស្តីពី«តួនាទីសំខាន់ៗរបស់វិស័យឯកជន ក្នុងការជួយគាំទ្រការអប់រំបច្ចេកទេស»
- បានសម្របសម្រួលបញ្ជូនសមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់ ដែលផ្លាស់ប្តូរថ្មី និងពុំទាន់ទទួលបានការបណ្តុះបណ្តាលពីក្រសួងមហាផ្ទៃ ជូនសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ សរុបចំនួន៥២នាក់ ស្រី១៧នាក់
- បានសម្របសម្រួលលិខិតគាំទ្រវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា លើគម្រោងសិក្សាស្រាវជ្រាវដែលមានចំណងជើងថា «ការវាយតម្លៃហានិភ័យលើការឆ្លងក្នុងសហគមន៍នៃជំងឺឆ្លងជាប្រចាំច្រើនប្រភេទ ក្នុងបរិបទសុខភាពតែមួយ (RACSMEI)» និងគម្រោងសិក្សាស្រាវជ្រាវដែលមានចំណងជើងថា «ការសិក្សាស្រាវជ្រាវរួមបញ្ចូលសម្រាប់ការយល់ដឹង និងពង្រឹងការបង្ការជំងឺផ្តៃឆ្កួតនៅកម្ពុជា (VIRAGE)»
- បានសម្របសម្រួលលិខិតស្តីពីការផ្តល់វគ្គបណ្តុះបណ្តាលស្តីពី Introduction Course on Field Empidemiology and Biostatistics and Data Analysis 27th Batch of International Field Empidemiology Training Program នៅព្រះរាជាណាចក្រថៃ ជូនមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត
- បានសម្របសម្រួលលិខិត ស្តីពីការជ្រើសរើសបេក្ខភាពចូលរួមកម្មវិធី «ព្រះអង្គម្ចាស់ក្សត្រីស្រ៊ីណាការីន នៃព្រះរាជាណាចក្រថៃសម្រាប់ឆ្នាំ២០២៥»
- បានបើកវគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការអនុវត្តការងារគនេយ្យភាពសង្គមដល់មន្ត្រីបង្គោលគណនេយ្យភាព

សង្គមក្រុង ស្រុក ទាំង៧ និងអ្នកពាក់ព័ន្ធ

- បានផ្សព្វផ្សាយអាហារូបករណ៍ថ្នាក់បណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់ផ្នែក Health Policy and Financing Capacity Building KOICA's 2025 Scholarship Program (Phase2) នៅសាកលវិទ្យាល័យ YONSEI នៃសាធារណរដ្ឋកូរ៉េ
- បានរៀបចំកិច្ចប្រជុំពិភាក្សាដើម្បីរៀបចំផែនការសកម្មភាពជាក់លាក់ ក្របខ័ណ្ឌពេលវេលា និងអង្គភាពទទួលខុសត្រូវដោះស្រាយ ដែលបានលើកឡើងតាមរយៈវេទិកា រវាងរាជរដ្ឋាភិបាល និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងបានបញ្ជូនរបាយការណ៍ជូន គ.ជ.អ.ប
- បានផ្សព្វផ្សាយសេចក្តីជូនដំណឹងជ្រើសរើសមន្ត្រីចូលរួមសិក្ខាសាលា ស្តីពី១-Seminar on Pharmaceutical Regulation and Industrial Development Cooperation for Belt and Road Countries និង២- Seminar on Medical Imaging Equipment Configuration and Management for Belt and Road Countries សិក្សានៅសាធារណរដ្ឋប្រជាមានិតចិន។

**តារាងទី១៧៖ការកសាងសមត្ថភាព**

| ល.រ | ឈ្មោះវគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា | ចំនួនថ្ងៃ | អ្នកចូលរួម | | រៀបចំដោយ |
|---|---|---|---|---|---|
| | | | សរុប | ស្រី | |
| ១ | សិក្ខាសាលាផ្សព្វផ្សាយចែករំលែកព័ត៌មាន និងបែបបទនានាក្នុងការដាក់ពាក្យសុំអាហារូបករណ៍សិក្សាភាសាអង់គ្លេស និងអាហារូបករណ៍ថ្នាក់ក្រោយឧត្តមសិក្សា នៅប្រទេសអូស្ត្រាលី | ១ព្រឹក | ១១៨ | ៣០ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស សហការជាមួយក្រុមការងារអាហារូបករណ៍ Australia Awards |
| ២ | វគ្គបណ្តុះបណ្តាលរំលឹកឡើងវិញ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ដល់មន្ត្រីបង្គោលគណនេយ្យភាពសង្គមក្រុង ស្រុកទាំង៧ និងអ្នកពាក់ព័ន្ធ | ១៤ថ្ងៃ | ២០ | ៣៧ | ទីចាត់ការគ្រប់គ្រងធនធានមនុស្ស |
| | | **១៤ថ្ងៃ ១ព្រឹក** | **១៣៨** | **៦៧** | |

## ១.៤-ការងារអន្តរវិស័យ

### ១.៤.១-ការងារសេដ្ឋកិច្ច និងសង្គមកិច្ច

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ អង្គភាពជុំវិញខេត្ត មានចំនួន១៩លេខ
- បានទទួល និងពិនិត្យសំណើពីបុគ្គលឯកជន និងក្រុមហ៊ុននានា មានចំនួន១៦លេខ។

➢ **មជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង**

- **សកម្មភាព និងលទ្ធផលការងារ ៖**
  - បានដោះស្រាយអាហារហូបចុកដល់កុមារកំព្រានៅក្នុងមណ្ឌលជាប្រចាំ ស្របតាមគោលការណ៍កំណត់
  - បានសម្របសម្រួលកិច្ចការរដ្ឋបាលប្រចាំថ្ងៃ និងការមើលថែទាំកុមារក្នុងមណ្ឌល ក្នុងការឧបត្ថម្ភគាំទ្រពីរដ្ឋបាលខេត្ត។
- **ការចូលរួមពីមន្ទីរ អង្គភាពជុំវិញខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា**
  - ក្នុងនោះមានក្រសួង ស្ថាប័នផ្សេងៗ ថ្នាក់ដឹកនាំខេត្ត មន្ទីរ អង្គការផ្សេងៗ សប្បុរសជនក្នុងស្រុក និងក្រៅស្រុក បានជួយឧបត្ថម្ភនូវគ្រឿងឧបភោគបរិភោគមានចំនួន២៩លើក

- បានជួយឧបត្ថម្ភនូវគ្រឿងសម្ភារប្រើប្រាស់ក្នុងមណ្ឌល និងសម្ភារផ្សេងៗសម្រាប់កុមារក្នុងមណ្ឌល មានចំនួន១០លើក។

**១.៤.២-ការងារគ្រប់គ្រងការអភិវឌ្ឍ និងសំណង់**

- បានទទួល និងពិនិត្យសំណើចុះបញ្ជី បណ្ដឹងទំនាស់ដីធ្លី រវាងប្រជាពលរដ្ឋជាមួយប្រជាពលរដ្ឋ ប្រជាពលរដ្ឋជាមួយក្រុមហ៊ុនអភិវឌ្ឍន៍នានា មានចំនួន៥៨លេខ
- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន១០លេខ។

**១.៤.៣-ការងារកិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ**

- បានទទួល និងពិនិត្យសំណើពីក្រសួង មន្ទីរ និងអង្គភាពនានាជុំវិញខេត្ត មានចំនួន៦លេខ
- បានទទួល និងពិនិត្យសំណើពីក្រុមហ៊ុនឯកជន សមាគម អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន មានចំនួន១៣លេខ។

**តារាងទី១៨៖ការដោះស្រាយវិវាទ**

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ករណីសម្រុះសម្រួលបញ្ចប់ដោយរដ្ឋបាលខេត្ត | ០ | ២ | ២ |
| ២ | ករណីកំពុងសម្រុះសម្រួលដោយរដ្ឋបាលខេត្ត | ០ | ៦ | ៦ |
| **សរុប** | | **០** | **៨** | **៨** |

**១.៤.៤-ការងារគ្រប់គ្រងកាកសំណល់**

- ពុំមានសកម្មភាព។

**១.៥-ការងារអង្គភាពច្រកចេញចូលតែមួយ**

- បានពង្រឹងការអនុវត្តការងាររបស់មន្ត្រីជួរមុខ និងជួរក្រោយ ឱ្យយកចិត្តទុកដាក់ក្នុងការផ្ដល់សេវាជូនប្រជាពលរដ្ឋ ឱ្យបានល្អប្រសើរតាមនីតិវិធី
- បានផ្ដល់សេវាជូនប្រជាពលរដ្ឋ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**តារាងទី១៩៖ស្ថានភាពចំនួនសេវា និងចំណូល**

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ចំនួនថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| | | នាក់ | ស្ត្រី | | |
| ១ | នីត្យានុកូលកម្ម(ថតចម្លង) | ៤១ | ១២ | ១.០០៧.៦០០ | |
| ២ | ការងាររដ្ឋបាល | ៤ | ០ | ១៤.៩៥៣.៥០០ | |
| ៣ | សុខាភិបាល | ១៣ | ៦ | ៤.៣៨០.០០០ | |
| ៤ | ទេសចរណ៍ | ៣២ | ១៦ | ១០.៥៣៥.០០០ | |
| ៥ | សាធារណការ និងដឹកជញ្ជូន | ៨១៣ | ១៥៣ | ៨២.៧៦៧.៥០០ | |
| | -ផ្លូវគោក | ៨០៦ | ១៥២ | ៨២.២១៧.៥០០ | (បង់សេវាតាមវីង) |
| | -ផ្លូវទឹក | ៧ | ១ | ៥៥០.០០០ | |
| ៦ | វប្បធម៌ និងវិចិត្រសិល្បៈ | ០ | ០ | ០ | |
| ៧ | ព័ត៌មាន | ៣០ | ៩ | ២៨.៤០០.០០០ | |
| ៨ | បរិស្ថាន | ០ | ០ | ០ | |
| ៩ | ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ១៤ | ៤ | ២.៣០០០.០០០ | |
| ១០ | រ៉ែ និងថាមពល | ១៩ | ៧ | ៧.១០០.០០០ | |

| ល.រ | ឈ្មោះវិស័យ | ចំនួនសេវា/នាក់ | | ចំនួនថវិកា | ផ្សេងៗ |
|---|---|---|---|---|---|
| | | នាក់ | ស្ត្រី | | |
| ១១ | ពាណិជ្ជកម្ម | ០ | ០ | ០ | |
| ១២ | រៀបចំដែនដី នគរូបនីយកម្ម និងសំណង់(ក)+(ខ) | ៥៣០ | ១០៦ | ១៩៦.៥២៧.៦០០ | |
| | (ក) សំណង់ | ៣៤ | ៨ | ៤០.២៥៨.២០០ | |
| | (ខ) សុរិយោដី | ៤៩៦ | ៩៨ | ១៥៦.២៦៩.៤០០ | |
| ១៣ | កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៧៩៤ | ៣៨៤ | ២១.២៦០.៣០០ | |
| ១៤ | ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ០ | ០ | ០ | |
| សរុបរួម | | ២.២៩០ | ៦៩៧ | ៣៦៩.២៣១.៥០០ | |

### ១.៦-ការងារការិយាល័យប្រជាពលរដ្ឋ

- បានប្រចាំការនៅតុពិសេស ស្ថិតក្នុងអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន៦៨លើក ស្មើនឹង២៧២ម៉ោង
- បានចុះបើកប្រអប់សំបុត្រនៅខាងមុខសាលាខេត្ត ខាងមុខអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត ខាងមុខមន្ទីរ-អង្គភាព សាលាស្រុក ក្រុង សាលាឃុំ សង្កាត់ ទូទាំងខេត្ត ចំនួន២៣លើក
- បានទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗតាមមធ្យោបាយនានាសរុបចំនួន៣៧ករណី ក្នុងនោះ ៖
  - បណ្តឹងអនាមិកក្រៅសមត្ថកិច្ចចំនួន២ករណី
  - បណ្តឹងអនាមិកក្នុងសមត្ថកិច្ចចំនួន១ករណី
  - ព័ត៌មានផ្សេងៗអនាមិកចំនួន៣៤ករណី ( ការសរសើរចំនួន២៤ករណី ការសំណូមពរចំនួន៩ករណី និងការសាកសួរព័ត៌មានចំនួន១ករណី )
- បានបញ្ជូនពាក្យបណ្តឹងក្រៅសមត្ថកិច្ច
  - ជូនប្រធានការិយាល័យប្រជាពលរដ្ឋស្រុកបូទុមសាគរចំនួន១ករណី
  - ជូនលោកអភិបាល នៃគណៈអភិបាលក្រុងខេមរភូមិន្ទចំនួន១ករណី
- បានបញ្ជូនព័ត៌មានផ្សេងៗអនាមិកជាការសំណូមពរ
  - ជូនប្រធានអង្គភាពច្រកចេញចូលតែមួយ នៃរដ្ឋបាលខេត្តចំនួន៥ករណី
  - ជូនលោកស្រី អ៊ី នារីនេត អភិបាលរង នៃគណៈអភិបាលខេត្តចំនួន២ករណី
  - ជូនលោកស្រីប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន១ករណី
  - ជូនលោកអភិបាលស្រុកស្រែអំបិលចំនួន១ករណី
- បានបញ្ជូនព័ត៌មានផ្សេងៗអនាមិកជាការសរសើរ ជូនលោកប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន២៤ករណី
- បានផ្សព្វផ្សាយនៅតាមបណ្តាញព័ត៌មានសង្គមរបស់រដ្ឋបាលខេត្តកោះកុងអំពីសកម្មភាព៖
  - ចុះបើកប្រអប់សំបុត្រនៅខាងមុខអង្គភាពច្រកចេញចូលតែមួយ ខាងមុខសាលាខេត្ត ខាងមុនមន្ទីរអង្គភាពមួយចំនួន ខាងមុខសាលាក្រុង ស្រុក និងខាងមុខសាលាឃុំ សង្កាត់ចំនួន២២លើក
  - កិច្ចប្រជុំស្តីពីការសម្រាំងពាក្យបណ្តឹង និងព័ត៌មានផ្សេងៗចំនួន៦លើក
  - កិច្ចប្រជុំស្តីពីការត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំខែចំនួន៦លើក
  - វគ្គបណ្តុះបណ្តាលតម្រង់ទិស ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័យបណ្តឹង និងព័ត៌មានផ្សេងៗ របស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត នៅសាលប្រជុំសាលាខេត្តកំពង់ធំ ចំនួន១លើក
- រៀបចំកិច្ចប្រជុំដើម្បីធ្វើបច្ចុប្បន្នភាពការបែងចែកភារកិច្ចទទួលខុសត្រូវ និងលក្ខខណ្ឌការងារជូនថ្នាក់ដឹកនាំ និងមន្ត្រីផ្នែកទាំងពីរនៃការិយាល័យប្រជាពលរដ្ឋខេត្តសម្រាប់ឆ្នាំ២០២៦ ចំនួន១លើក

- បានរៀបចំកិច្ចប្រជុំសម្រាំងពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗ ចំនួន៧លើក
- បានប្រជុំសម្រុះសម្រួលដោះស្រាយបណ្ដឹងចំនួន១ករណី
- បានបិទផ្សាយលើក្ដារព័ត៌មានអំពីលទ្ធផលនៃការសម្រាំងពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗចំនួន៨លើក
- បានបិទផ្សាយលើប្រអប់សំបុត្រអំពីលទ្ធផលនៃការសម្រាំងពាក្យបណ្ដឹង និងព័ត៌មានផ្សេងៗចំនួន១២លើក
- ការទទួលព័ត៌មានត្រឡប់ពីស្ថាប័នមានសមត្ថកិច្ចចំនួន២ករណី ដូចខាងក្រោម ៖
  - ពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង បំភ្លឺករណីសំណូមពរ លោកជំទាវអភិបាលខេត្ត ជួយទប់ស្កាត់ទូកនេសាទពីខាងក្រៅចូលមកអូសក្នុងដែននេសាទឃុំថ្មស និងស្នើសុំស្ថាប័នជំនាញជួយសម្របសម្រួល ច្បាប់អាជីវកម្ម។
  - ពីលោកប្រធានការិយាល័យប្រជាពលរដ្ឋស្រុកបូទុមសាគរ ស្តីពីលទ្ធផលនៃការសម្រុះសម្រួលដោះស្រាយបណ្ដឹងក្រៅសមត្ថកិច្ច ករណីការមិនបំពេញការងារតាមពេលម៉ោងកំណត់របស់ស្មៀនឃុំ១រូប។

**តារាងទី២០៖ការដោះស្រាយបណ្តឹង**

| ល.រ | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| **១** | **បណ្ដឹងដែលទទួលបាន(ក្នុង និងក្រៅសមត្ថកិច្ច)** | **0** | **៣** | **៣** |
| ១.១ | បណ្ដឹងស្ថិតក្នុងសមត្ថកិច្ច | 0 | ១ | ១ |
| | - បញ្ចប់ការដោះស្រាយ | 0 | ១ | ១ |
| | - កំពុងដោះស្រាយ (នៅសល់) | 0 | 0 | 0 |
| | - បិទសំណុំរឿង | 0 | 0 | 0 |
| ១.២ | បណ្ដឹងក្រៅសមត្ថកិច្ច | 0 | ២ | ២ |
| **២** | **ព័ត៌មានផ្សេងៗ** | **0** | **៣៤** | **៣៤** |
| ២.១ | ការសរសើរ | 0 | ២៤ | ២៤ |
| ២.២ | សំណើ និងសំណូមពរ | 0 | ៩ | ៩ |
| ២.៣ | ការសាកសួរព័ត៌មាន | 0 | ១ | ១ |
| **សរុបរួម(១+២)** | | **0** | **៣៧** | **៣៧** |

## ១.៧-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បានធ្វើជាតំណាងដោយអណត្តិជូនរដ្ឋបាលខេត្តកោះកុង ក្នុងនាមជាដើមបណ្ដឹងក្នុងសំណុំរឿងលេខ០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២៦ របស់ស្នងការនគរបាលខេត្តកោះកុង។

## ១.៨-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

### ១.៨.១-ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម

- ច្រកទ្វារព្រំដែនអន្តរជាតិចាំយាមត្រូវបានបិទ ដោយសារបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ។

### ១.៨.២-សន្តិសុខ និងសណ្ដាប់ធ្នាប់តាមព្រំដែន

- មាននាវាចម្បាំងយោធាថៃចំនួន២គ្រឿង បានមកចតនៅខាងមុខកោះកូត និងត្រឡប់ចូលទៅកោះកូត ស្រុកខ្លងយ៉ៃ ខេត្តត្រាតវិញ
- មាននាវាចម្បាំងយោធាថៃចំនួន៥គ្រឿង បានរត់ពីលម្ហសមុទ្រខាងថៃ ឆ្ពោះទៅស្រុកខ្លងយ៉ៃ ខេត្តត្រាត
- មាននាវាចម្បាំងយោធាថៃចំនួន១១គ្រឿង បានរត់ពីស្រុកខ្លងយ៉ៃ ខេត្តត្រាត ឆ្ពោះទៅលម្ហសមុទ្រ រួចត្រឡប់ទៅស្រុកខ្លងយ៉ៃ ខេត្តត្រាត

- មាននាវាចម្បាំងយោធាថៃចំនួន១គ្រឿង បានរត់ពីស្រុកខ្លងយ៉ៃ ខេត្តត្រាត មកល្បាតនៅលម្ហសមុទ្រ ខាងក្រោយកាស៊ីណូចម្ងាយប្រមាណ៧គីឡូម៉ែត្រពីច្រាំង
- មាននាវាចម្បាំងយោធាថៃចំនួន២គ្រឿង បានមកល្បាតនៅភូមិសាស្ត្រចន្លោះកោះយ៉-កោះកុត និងបន្តទៅសមុទ្រក្រៅ
- មានជ្រូនចំនួន២គ្រឿង បានហោះចេញពី លម្ហសមុទ្រខាងថៃ និងបន្តហោះទៅខាងស្រុកមណ្ឌលសីមា
- មានជ្រូនចំនួន២គ្រឿង បានហោះចេញពី លម្ហសមុទ្រខាងថៃ និងបន្តហោះតាមជួរភ្នំទៅខាងខេត្តពោធិ៍សាត់
- មានជ្រូនចំនួន៥គ្រឿង បានហោះចេញពីលម្ហសមុទ្រខាងថៃ និងបន្តហោះតាមលម្ហសមុទ្រ ទៅខាងស្រុកមណ្ឌលសីមា
- មានយោធាជើងទឹកថៃ និងអ្នកសារព័ត៌មានថៃ ប្រមាណ៤០នាក់ បានមកថតរូបនៅមាត់ច្រកទ្វារព្រំដែនអន្តរជាតិហាតលេក នឹងបានបន្តទៅថតរូបតាមបណ្តោយព្រំដែនខាងភ្នំ
- មានក្រុមយោធាថៃ ប្រមាណ៣០នាក់ បានមកពិនិត្យសភាពការណ៍ និងមើលបង្គោលព្រំដែនលេខ៧៣ តំបន់ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម-ហាតលេក
- មានយោធាថៃចំនួន៨នាក់ ដឹកនាំដោយ មេបញ្ជាការយោធាថៃ ខេត្តត្រាត បានមកត្រួតពិនិត្យកម្លាំងយោធាថៃវរៈការពារព្រំដែនលេខ១៨២ នៅច្រកទ្វារព្រំដែនអន្តរជាតិហាតលេក
- មានយោធាជើងទឹកថៃ មួយក្រុមចំនួន៨នាក់ មកពីទីក្រុងបាងកក ដឹកនាំដោយលោកឧត្តមសេនីយ៍ឯក RATCHAYOT RATCHARUNGROJKUL អគ្គនាយករងព័ត៌មានកងទ័ពជើងទឹកថៃបានមកត្រួតពិនិត្យសភាពការណ៍ទូទៅនៅមាត់ច្រកទ្វារព្រំដែនអន្តរជាតិហាតលេក ( ខាងដីថៃ )
- មានយោធាថៃចំនួន១០នាក់ មកពីក្រុងបាងកក ដឹកនាំដោយ លោកឧត្តមសេនីយ៍ទោ KAJORNSAK POOLPHOTHONG ឋានៈនាយកផ្នែកសម្របសម្រួលប្រតិបត្តិការរួម នៃទីបញ្ជាការកងយោធពលខេរភូមិន្ទថៃ អមដំណើរដោយយោធាថៃវរៈការពារព្រំដែនលេខ១៨២ និងក្រុមការងារទំនាក់ទំនងថៃ សរុបចំនួន២០នាក់ បានមកពិនិត្យបង្គោលព្រំសីមាលេខ៧៣ តំបន់ច្រកទ្វារព្រំដែនអន្តរជាតិចាំយាម-ហាតលេក
- សណ្តាប់ធ្នាប់៖ បានរៀបចំសណ្តាប់ធ្នាប់ និងសម្អាតអនាម័យបរិស្ថាននៅទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិចាំយាមជាប្រចាំ។ ជាលទ្ធផល បានល្អជាងមុន ព្រោះច្រកទ្វារព្រំដែនអន្តរជាតិចាំយាមត្រូវបានបិទដោយពុំមានរថយន្តធ្វើដំណើរចេញ-ចូល។

## ១.៨.៣-ការចេញចូលឆ្លងកាត់ច្រកទ្វារព្រំដែន(មនុស្ស និងមធ្យោបាយ)

- បានពិនិត្យប្រជាពលរដ្ឋ និងជនបរទេសចេញចូលឆ្លងកាត់តាមច្រកទ្វារព្រំដែន ដូចខាងក្រោម ៖
  - ពលរដ្ឋខ្មែរចូល៖ ចំនួន០៦នាក់ ស្រី០៣នាក់
  - ជនបរទេសចូល៖ ចំនួន០០នាក់ ស្រី០០នាក់ មាន០០សញ្ជាតិ
  - ពលរដ្ឋខ្មែរចេញ៖ ចំនួន០០នាក់ ស្រី០០នាក់
  - ជនបរទេសចេញ៖ ចំនួន០០នាក់ ស្រី០០នាក់ មាន០០សញ្ជាតិ

**ជាលទ្ធផល** ប្រជាពលរដ្ឋខ្មែរ ចូលឆ្លងកាត់ព្រំដែនខាងលើមានភាពស្របច្បាប់

## ១.៨.៤-ការផ្លាស់ប្តូរទំនិញ ៖ ពុំមាន

## ១.៨.៥-កិច្ចសហប្រតិបត្តិការ

- បានសហប្រតិបត្តិការទំនាក់ទំនងល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធរវាងភាគីកម្ពុជា និងភាគីថៃក្នុងការបញ្ជូនពលករខ្មែរអោយត្រឡប់មកកម្ពុជា និងបញ្ជូនពលករថៃអោយត្រឡប់ទៅថៃវិញ ។

## ១.៩-ការគ្រប់គ្រងហិរញ្ញវត្ថុ

### ១.៩.១-ការងារហិរញ្ញវត្ថុ

- ការអនុវត្តចំណូល និងចំណាយរបស់រដ្ឋបាលខេត្តប្រចាំឆមាសទី១ ឆ្នាំ២០២៦ ទីចាត់ការហិរញ្ញវត្ថុ សម្រេចបានការងារប្រមូលចំណូល និងចំណាយដែលមានទឹកប្រាក់ ដូចខាងក្រោម ៖

**តារាងទី២១៖ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | ច្បាប់ដើមឆ្នាំ | ច្បាប់កែតម្រូវ | អនុវត្ត | ភាគរយ |
|---|---|---|---|---|---|
| | | 1 | 2 | 3 | 4=3/2 |
| **ផ្នែកចំណូល** | | | | | |
| 70 | ចំណូលសារពើពន្ធ | ៨.៦៦៧.000.000 | ៨.៦៦៧.000.000 | ៣.០១៩.៨២៩.៥២៨ | ៣៤,៨៤% |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | ២.៨៦០.១០០.000 | ២.៨៦០.១០០.000 | ២៧១.៨៨០.៨៧៨ | ៩,៥១% |
| 73 | ផលទុនលើការលក់-ជួលទ្រព្យ | ១.៩៥៦.៩០០.000 | ១.៩៥៦.៩០០.000 | ១៣៣.១០០.៦២២ | ៦,៨០% |
| 74 | ផលពីការពិន័យ និងការដាក់ | ៥.000.000 | ៥.000.000 | ៩៧០.២១៤ | ១៩,៤០% |
| 75 | ការឧត្តម្ភធន(អំណោយ) | ១៣.៥០០.000.000 | ១៣.៥០០.000.000 | ៧00.000.000 | ៥,១៩% |
| 76 | ផលហិរញ្ញវត្ថុ | - | - | - | - |
| 77 | ផលផ្សេងៗ និងផលពិសេស | - | - | - | - |
| **សរុបរួមចំណូល** | | **២៦.៩៨៩.000.000** | **២៦.៩៨៩.000.000** | **៤.១២៥.៧៨១.២៤២** | ១៥,២៩% |
| **ផ្នែកចំណាយ** | | | | | |
| 60 | ការទិញ | ២.១៩៨.000.000 | ២.១៩៨.000.000 | ១៧៣.៤១៧.៧៨០ | ៧,៨៩% |
| 61 | សេវាកម្ម | ១៥.៤៧៨.000.000 | ២៥.៤៧៨.000.000 | ៧៣៣.២៨៧.៧៣៨ | ២,៨៨% |
| 62 | អត្ថប្រយោជន៍សង្គម | ៥៩៩.000.000 | ៥៩៩.000.000 | ៤៦.៦១៣.៥00 | ៧,៧៨% |
| 63 | ពន្ធ និងអាករ | ៣.២00.000 | ៣.២00.000 | - | - |
| 64 | បន្ទុកបុគ្គលិក | ៣.៨៩០.000.000 | ៣.៨៩០.000.000 | ១.២៤០.៧៧៩.៨៧០ | ៣១,៩០% |
| 65 | ឧបត្ថម្ភធននិងជំនួយសង្គម | ១៩៣.000.000 | ១៩៣.000.000 | - | - |
| 66 | បន្ទុកហិរញ្ញវត្ថុ | | | | |
| 67 | បន្ទុកពិសេស | | | | |
| 68 | ទាយជ្ជទានឱ្យដល់រំលស់អចលនកម្ម | | | | |
| 69 | ចំណាយមិនបានគ្រោងទុក | ៥៥០.000.000 | ៥៥០.000.000 | - | - |
| 20 | អចលកម្មអរូបី | | | | |
| 21 | អចលកម្មរូបី | ១.០៨១.៨00.000 | ១.០៨១.៨00.000 | - | - |
| 23 | អចលកម្មកំពុងដំណើរការ | | | | |
| **សរុបចំណាយ** | | **២៣.៩៩៣.000.000** | **៣៣.៩៩៣.000.000** | **២.១៩៤.០៩៨.៨៨៨** | **៦,៤៥%** |

### ១.៩.២-ការងារគណនេយ្យ

- បានរៀបចំអាណត្តិបើកបៀវត្សប្រចាំខែ ឆ្នាំ២០២៦ ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការរួចរាល់
- បានរៀបចំឯកសារសម្រាប់ទូទាត់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

## ១.៩.៣-ការគ្រប់គ្រងទ្រព្យសម្បត្តិ

**តារាងទី២២៖ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ. | ការបរិយាយ | ឯកតា | ចំនួន | | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | ប្លុកយោង | |
| ១-អចលនទ្រព្យ | | | | | | |
| ១ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម២ | ១៩.០៤៧ | ០ | ១៩.០៤៧ | |
| | អគារ(សាលាខេត្តចាស់) | ខ្នង | ៣ | ០ | ៣ | |
| ២ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម២ | ១១.៤០៣ | ០ | ១១.៤០៣ | |
| | អគារ(សាលមហោស្រព) | ខ្នង | ១ | ០ | ១ | |
| ៣ | ដី ភូមិ១ ស្មាច់មានជ័យ | ម២ | ៤.៩៣៩ | ០ | ៤.៩៣៩ | |
| | អគារ(ខាងក្រោយសាលាខេត្តចាស់) | ខ្នង | ១ | ០ | ១ | |
| ៤ | ដី ភូមិ៣ ស្មាច់មានជ័យ | ម២ | ៤.១១៧ | ០ | ៤.១១៧ | |
| | អគារ(ខាងមុខវត្តថ្មី) | ខ្នង | ២ | ០ | ២ | |
| ៥ | ដី ស្ថិតនៅភូមិ១ ស្មាច់មានជ័យ | ម២ | ៩.៨០១ | ០ | ៩.៨០១ | |
| | អគារ(សាលាខេត្តថ្មី) | ខ្នង | ៣ | ០ | ៣ | |
| ២-ឧបករណ៍ សម្ភារ និងបរិក្ខារ (យានយន្ត ម៉ាស៊ីន តុ ...) | | | | | | |
| ១ | ម៉ាស៊ីនភ្លើង | គ្រឿង | ៣ | ០ | ៣ | |
| ២ | ទូបញ្ជាម៉ាស៊ីនភ្លើង | គ្រឿង | ១ | ០ | ១ | |

## ១.១០-ការងារលទ្ធកម្ម

- បានរៀបចំ និងចូលរួមកិច្ចប្រជុំបញ្ចប់សុពលភាពលទ្ធកម្មសំណង់ឆ្នាំ២០២៤ ចំនួន៤លើក
- បានរៀបចំនីតិវិធីបញ្ចប់សុពលភាពលទ្ធកម្មសំណង់ឆ្នាំ២០២៤ ចំនួន៤គម្រោង ដូចខាងក្រោម៖
  - ការងារជួសជុលផ្លូវក្រាលកៅស៊ូ AC ចំនួន១ខ្សែ ប្រវែង១.៧៨៦ម នៅលើកំណាត់ផ្លូវសេរីការ ស្ថិតនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ការងារជួសជុលនិងពង្រីកផ្លូវក្រាលកៅស៊ូ AC ចំនួន២ខ្សែ៖
    - ខ្សែទី១ ប្រវែង២.១៤០ម នៅលើវិថីតាឆែមយាយយិប
    - ខ្សែទី២ ប្រវែង២១០ម នៅលើកំណាត់ផ្លូវសេរីការ
  - ការងារជួសជុលសួនច្បារក្រាលការ៉ូក្រានីតចំនួន៣ទីតាំង៖
    - ក្រាលការ៉ូក្រានីត ស្ថិតនៅមុខចំណតរថយន្តឈ្នួល
    - ក្រាលការ៉ូក្រានីត ចាប់ពីកែងសាលាបឋមសិក្សាទីរួមខេត្ត ឆ្ពោះទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត
    - បេតុងនិងក្រាលការ៉ូថ្មើជើងចាប់ពីកែងចំណតរថយន្តឆ្ពោះមកសាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង
  - ការងារជួសជុលលូមូលដោះទឹក ចាប់ពីមុខវត្តទេពនិមិត្ត ឆ្ពោះមកផ្លូវជាតិលេខ៤៨
- បានរៀបចំនីតិវិធីដកប្រាក់កក់លទ្ធកម្មទំនិញឆ្នាំ២០២៥ ចំនួន២គម្រោង ដូចខាងក្រោម៖
  - សម្ភារ និងសង្ហារឹម
  - សម្ភារបរិក្ខារពត៌មានវិទ្យា
- បានសហការ និងសម្របសម្រួលជូនប្រតិភូសវនកម្មជាតិដើម្បីធ្វើកិច្ចសវនកម្ម នៅរដ្ឋបាលខេត្តកោះកុង
- បានជូនប្រតិភូសវនកម្មជាតិចុះពិនិត្យទីតាំងគម្រោងនានាសម្រាប់លទ្ធកម្មសំណង់ឆ្នាំ២០២៥
- បានរៀបចំឯកសារត្រៀមអនុវត្តនីតិវិធីដេញថ្លៃលទ្ធកម្មទំនិញចំនួន៣គម្រោង

- បានសហការ និងសម្របសម្រួលជូនប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីធ្វើអធិការកិច្ចលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុនៅរដ្ឋបាលខេត្តកោះកុង
- បានជូនប្រតិភូអធិការកិច្ចក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះពិនិត្យទីតាំងគម្រោងនានាសម្រាប់លទ្ធកម្មសំណង់ឆ្នាំ២០២៥
- បានចូលរួមប្រជុំ និងចុះពិនិត្យទីតាំងផ្លូវក្នុងក្រុងខេមរភូមិន្ទដែលជាគម្រោងលទ្ធកម្មឆ្នាំ២០២៥ និងត្រូវ បានជួសជុលរួចរាល់ស្អាត
- បានចូលរួមក្នុងកិច្ចប្រជុំរវាងរដ្ឋបាលខេត្តកោះកុងជាមួយប្រតិភូសវនកម្មក្រសួងមហាផ្ទៃ នៅសាលប្រជុំ(ខ)
- បានជូនប្រតិភូសវនកម្មក្រសួងមហាផ្ទៃចុះពិនិត្យទីតាំងគម្រោងនានាសម្រាប់លទ្ធកម្មសំណង់ឆ្នាំ២០២៥
- បានជូនប្រតិភូអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃចុះពិនិត្យទីតាំងគម្រោងនានាសម្រាប់លទ្ធកម្មសំណង់ ឆ្នាំ២០២៥ នៅស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទ។

## ១.១១-ការងារសុខាភិបាល

- បានពិនិត្យ និងពិគ្រោះជំងឺក្រៅសរុបចំនួន ៥២.៨៣៧ករណី (ករណីថ្មីចំនួន ៤៥.៨៨១ករណី) ជូនប្រជាជនដូចខាងក្រោម ៖
    - បង់លុយដោយខ្លួនឯងមានចំនួន ២៣.៧៤២ករណី
    - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ១៣.៧៣៩ករណី
    - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ៨.៥៦៦ករណី
    - ករណីលើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន ៦.៧៩០ករណី
- ករណីអ្នកជំងឺសម្រាកពេទ្យសរុបចំនួន ៥.៩០៤នាក់ រួមមាន៖
    - បង់លុយដោយខ្លួនឯងមានចំនួន ២.៧៤៣ករណី
    - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍មានចំនួន ១.៩១៨ករណី
    - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម (ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល មានចំនួន ១.០៧៧ករណី
    - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន ១៦៦ករណី
- ការសម្រាលកូនសរុបចំនួន ១.០៥៣នាក់ (សម្រាលនៅមណ្ឌលសុខភាពចំនួន ៣៦៧នាក់) មានដូចខាង ក្រោម ៖
    - បង់លុយដោយខ្លួនឯងមានចំនួន ៥៥៥នាក់
    - គាំទ្រក្រោមគម្រោងមូលនិធិសមធម៌ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ចំនួន ២២៨នាក់
    - គាំទ្រក្រោមគម្រោងបេឡាសន្តិសុខសង្គម(ប.ស.ស) ដែលផ្តល់មូលនិធិដោយរាជរដ្ឋាភិបាលចំនួន ២៤៥នាក់
    - លើកលែងបង់ថ្លៃសេវាតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលមានចំនួន ២៥នាក់
- បានផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះសរុបចំនួន១.៧៩៦ដូស
- បានពិនិត្យផ្ទៃពោះជូនស្ត្រីមុនសម្រាលកូនសរុបចំនួន៦.៤៥៧លើក និងក្រោយសម្រាលកូនចំនួន១.៦៣៧លើក
- បានចាក់ថ្នាំបង្ការ១១មុខ ដល់កុមារចំនួន១.០៩៣នាក់
- បានផ្តល់សេវាពន្យារកំណើតបន្ត ដល់ស្ត្រីនៅតាមមូលដ្ឋានសុខាភិបាលសរុបចំនួន១៤.៦៧៨នាក់ និងនៅសហ

គមន៍សរុបចំនួន៥.១៣០នាក់

- ក្រុមការងារចត្តាឡីស័កប្រចាំការនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម បានអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម ៖
  - បានពិនិត្យកម្មៅពលករខ្មែរខុសច្បាប់(ថៃបញ្ជូនមក)ចូលខេត្តកោះកុង សរុបចំនួន១៧៨នាក់ ស្រី៤៧នាក់ និងកុមារមកជាមួយចំនួន១នាក់
  - បានពិនិត្យកម្មៅពលករថៃខុសច្បាប់ សរុបចំនួន៧នាក់ ស្រី៣នាក់ ដែលនគរបាលអន្តោប្រវេសន៍ ប្រចាំច្រកទ្វារព្រំដែនអន្តរជាតិចាំយាម បានបញ្ជូនទៅប្រទេសថៃវិញ
  - បានពិនិត្យអ្នកជំងឺចូលខេត្តកោះកុង សរុបចំនួន៨នាក់ ស្រី២នាក់
  - បានពិនិត្យអ្នកជំងឺចេញពីខេត្តកោះកុង សរុបចំនួន១នាក់ ស្រី១នាក់(ជនជាតិថៃ)
  - បានពិនិត្យសពចូលខេត្តកោះកុង សរុបចំនួន១នាក់ប្រុស។

## ១.១២-ការងារក្រុមការងាររាជរដ្ឋាភិបាល

- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង បានចូលរួមកិច្ចប្រជុំចំនួន២៤លើក ដោយមានអ្នកចូលរួមចំនួន៧១៩នាក់ ស្រី១១១នាក់ ក្នុងនោះថ្នាក់ខេត្តប្រជុំចំនួន២៣លើក អ្នកចូលរួមសរុប៦៧៣នាក់ ស្រី១០០នាក់ និងក្រុង ស្រុកប្រជុំចំនួន១លើក អ្នកចូលរួមសរុប៤៦នាក់ ស្រី១១នាក់
- ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង បានចូលរួមសកម្មភាពនានា នៅមូលដ្ឋានចំនួន២៧៨លើក ដោយមានអ្នកចូលរួមចំនួន៤០.៩៣៥នាក់ ស្រី១៦.៧០៦នាក់ ក្នុងនោះថ្នាក់ខេត្តចំនួន១០៨លើក អ្នកចូលរួមសរុប២២.១៥១នាក់ ស្រី៨.៧២១នាក់ និងក្រុង ស្រុកចំនួន១៧០លើក អ្នកចូលរួមសរុប១៨.៧៨៤នាក់ ស្រី៧.៩៨៥នាក់។

## ១.១៣-ការងារផ្សេងៗ

រដ្ឋបាលខេត្ត បានសហការជាមួយមន្ទីរ អង្គភាពពាក់ព័ន្ធ រៀបចំកម្មវិធី និងព្រឹត្តិការណ៍សំខាន់ៗមួយចំនួន ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវថ្នាក់ដឹកនាំ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ឯកឧត្តម លោកជំទាវក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត និងប្រធានមន្ទីរ អង្គភាព ដូចខាងក្រោម៖

- ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦៖
  - ពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកោះកុង ក្រោមអធិបតីភាព**ឯកឧត្តម ប៉ុង ណារុង** ប្រធានក្រុមប្រឹក្សាខេត្តកោះកុង និង**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលមហោស្រពខេត្តកោះកុង
  - ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត បានអមដំណើរ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ អញ្ជើញចុះពិនិត្យវឌ្ឍនភាព នៃការសាងសង់ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ កោះកុង ដែលស្ថិតនៅភូមិបឹងយុនធាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦ ពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់រដ្ឋបាលខេត្តកោះកុង ក្រោមអធិបតីភាព**ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៦ ពិធីសំណេះសំណាលជាមួយសមាជិកសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជាខេត្តកោះកុង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចពិជ័យសេនា ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាអនុប្រធានសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា
- ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ ពិធីបើកសិក្ខាសាលាបិទបញ្ចប់គម្រោងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋប្រកបដោយភាពធន់ និងបន្សាំការប្រែប្រួលអាកាសធាតុ (គម្រោងការីប) និងពិធីបើកគម្រោងភាពធន់ និងការប្រែប្រួលអាកាស

ជាតុក្នុងវិស័យអប់រំ (BRACE) និងគម្រោងបង្កើនកាលានុវត្តភាពសម្រាប់អភិវឌ្ឍវិស័យសាកវប្បកម្ម(GROWTH) ក្រោមអធិបតីភាព **លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្ត នៅសាលមហោស្រពខេត្ត

- ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៦ កិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាព នៅតាមទីតាំងរស់នៅប្រមូលផ្តុំ របស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមអធិបតីភាព **លោកជំទាវ ឈី វ៉ា អភិបាល** នៃគណៈអភិបាលខេត្ត នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០២៦ កិច្ចប្រជុំតម្រង់ទិសលើការងារវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមអធិបតីភាព**ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ ពិធីចែកវិញ្ញាបនបត្រសម្គាល់អចលនវត្ថុ និងមោឃភាពនៃបណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៦ កិច្ចប្រជុំផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ក្រោមអធិបតីភាព **លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្ត នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៦ កិច្ចប្រជុំបូកសរុបសកម្មភាព និងលទ្ធផលការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានប្រចាំឆ្នាំ ២០២៥ និងទិសដៅការងារបន្តឆ្នាំ២០២៦ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកោះកុង ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ ទៀ សីហា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦ ពិធីប្រកាសសមាសភាពប្រធានគណៈកម្មាធិការអតីតយុទ្ធជន ក្រោមអធិបតីភាព **ឯកឧត្តមកិត្តិសង្គហបណ្ឌិត គន់ គីម ទេសរដ្ឋមន្ត្រី និងជាអគ្គលេខាធិការសមាគមអតីតយុទ្ធជន និងនិវត្តជនកម្ពុជា** នៅសាលមហោស្រពខេត្ត
- ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ ពិធីអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៦ ក្រោមប្រធានបទ "សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ" ក្រោមអធិបតីភាព**ឯកឧត្តម ថុង ណារ៉ុង ប្រធានក្រុមប្រឹក្សាខេត្ត** និង**លោកជំទាវ ឈី វ៉ា អភិបាល នៃគណៈអភិបាលខេត្ត** នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៦ ពិធីបើកទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៨ ឆ្នាំ២០២៦ ក្រោមប្រធានបទ "យុវជនដើម្បីវប្បធម៌ជាតិ" ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា អភិបាល នៃគណៈអភិបាលខេត្ត** នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៦ ពិធីក្រុងពាលីសុំសេចក្តីសុខចម្រើនក្នុងពិធីបុណ្យចូលឆ្នាំថ្មី ក្រោមអធិបតីភាព **ឯកឧត្តម ថុង ណារ៉ុង** ប្រធានក្រុមប្រឹក្សាខេត្ត និង**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្ត នៅសួនច្បារមុខសាលាខេត្ត
- ថ្ងៃទី៩ ខែមេសា ឆ្នាំ២០២៦ ពិធីសូត្រមន្ត ប្រោះព្រំ លើករាសី និងរាប់បាត្រ ក្រោមអធិបតីភាព**ឯកឧត្តម ថុង ណារ៉ុង** ប្រធានក្រុមប្រឹក្សាខេត្ត និង**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្ត នៅសាលប្រជុំ "ខ" សាលាខេត្ត
- ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៦ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីកិច្ចសហប្រតិបត្តិការក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទរវាងអាជ្ញាធរជាតិដោះស្រាយក្រៅប្រព័ន្ធតុលាការ និងរដ្ឋបាលខេត្តកោះកុង ក្រោមអធិបតីភាព **ឯកឧត្តមបណ្ឌិត ជិន ម៉ាលីន** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ និងជាអនុប្រធានប្រចាំការ នៃអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) នៅសាលប្រជុំ "ខ" សាលាខេត្តកោះកុង
- ថ្ងៃទី១៤ ខែមេសា ឆ្នាំ២០២៦ ពិធីទទួលទេវតាឆ្នាំថ្មី អបអរសាទរពិធីបុណ្យចូលឆ្នាំថ្មី **ឯកឧត្តម ថុង ណារ៉ុង** ប្រធានក្រុមប្រឹក្សាខេត្ត និង**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្ត នៅសាលមហោស្រពខេត្ត។
- ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២៦ កិច្ចប្រជុំពិភាក្សាលើការរៀបចំផែនការចុះត្រួតពិនិត្យ និងវាយតម្លៃទីតាំងសង្ស័យ និងទីតាំងដែលត្រូវបង្ក្រាប និងបិទសៀល ពាក់ព័ន្ធនឹងករណីឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្រោមអធិបតីភាព **ឯកឧត្តម**

**យ៉េត វិណែល** អនុប្រធានលេខាធិការដ្ឋាន (គ.ប.ធ.ប) និងជាប្រធានក្រុមការងារទី២ នៃក្រុមការងារចម្រុះ ចំណុះលេខាធិការដ្ឋាន(គ.ប.ធ.ប) នៅសាលមហោស្រពខេត្តកោះកុង

- ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៦៖
  - កិច្ចប្រជុំត្រួតពិនិត្យ និងជំរុញការអនុវត្តគោលនយោបាយភូមិ-ឃុំ-មានសុវត្ថិភាព ប្រចាំត្រីមាសទី១ និងលើកទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាព**ឯកឧត្តម នៅ លក្ខណា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅសាលមហោស្រពខេត្តកោះកុង
  - កិច្ចប្រជុំផ្សព្វផ្សាយផែនការស្តីពីការបន្តនិរន្តរភាពយុទ្ធនាការសម្អាតការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្រោមអធិបតីភាព**ឯកឧត្តម នៅ លក្ខណា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៦៖
  - ពិធីបុណ្យចម្រើនព្រះជន្មថ្វាយព្រះករុណាព្រះបាទ**សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ក្រោមអធិបតីភាពលោកជំទាវ **ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង
  - កិច្ចប្រជុំផ្សព្វផ្សាយផែនការអន្តរស្ថាប័នស្តីពីកិច្ចការងារការពារសន្តិសុខពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ស្តូបអនុស្សាវរីយ៍ឈ្នះ ឈ្នះ ខេត្តកោះកុង ក្រោមអធិបតីភាពលោក **ហាក់ ឡេង** អភិបាលរង នៃគណៈអភិបាលខេត្ត នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២៦ ទិវានៃការចងចាំ ២០ ឧសភា ឆ្នាំ២០២៦ ក្រោមអធិបតីភាព **លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅវត្តដោតញ្ញាណ និងវត្តទេពនិមិត្ត
- ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០២៦ កម្មវិធីរត់ប្រណាំង ដើម្បីអបអរសាទរពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ ខេត្តកោះកុង" ក្រោមអធិបតីភាព**ឯកឧត្តម ប៊ុន លើត** រដ្ឋលេខាធិការក្រសួងការពារជាតិ និង**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង
- ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៦ មីទ្ទីញអបអរសាទរខួបទី១៣ ទិវាពិភពលោកកាកបាទក្រហមកម្ពុជា អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០២៦ ក្រោមអធិបតីភាព**លោកជំទាវ ឈី វ៉ា** អភិបាល នៃគណៈអភិបាលខេត្តកោះកុង នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២៦ ពិធីក្រុងពាលី និងចម្រើនព្រះបរិត្ត សម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ កោះកុង ក្រោមអធិបតីភាព**សម្តេចពិជ័យសេនា ទៀ បាញ់ ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានមូលនិធិទ្រទ្រង់ការកសាងវិមាន ស្តូបឈ្នះ ឈ្នះ និងលោកជំទាវ**
- ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៦ ពិធីសម្ពោធស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ កោះកុង ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ទៀ សីហា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ និងលោកជំទាវ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវបណ្ឌិត។**
- ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៦ ពិធីសម្ពោធស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ កោះកុង ក្រោមអធិបតីភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ប៊ុន លើត រដ្ឋលេខាធិការក្រសួងការពារជាតិ និងជាប្រធានគណៈកម្មការអន្តរក្រសួង និងលោកជំទាវ**
- ថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការប្រតិបត្តិលើកទី២ របស់សមាគមក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់ ក្រោមអធិបតីភាព **ឯកឧត្តម សំរិទ្ធ អេង** អនុប្រធានសមាគមន៍ក្រុមប្រឹក្សាថ្នាក់មូលដ្ឋាន នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំផ្សព្វផ្សាយពីសកម្មភាពបញ្ជ្រាបយេនឌ័រ និងលើកកម្ពស់តួនាទីស្ត្រីក្នុងភាពជាអ្នកដឹកនាំ ក្រោមអធិបតីភាព **លោកជំទាវ អុង សុភាវី** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងារយេនឌ័រ និងលើកកម្ពស់តួនាទី ភារកិច្ចស្ត្រី ក្នុងភាពជាអ្នកដឹកនាំ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ របស់ក្រុមការងារយេនឌ័រ ក្រសួងមហាផ្ទៃ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំបូកសរុប និងដាក់ទិសដៅបន្ទាន់ក្រោមកិច្ចសហការរវាងគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តកោះកុង និងក្រុមការងារទី២ នៃក្រុមការងារចម្រុះចំណុះលេខាធិការដ្ឋាន គ.ប.ធ.ប ក្រោមការ

ដឹកនាំរបស់**ឯកឧត្តម យ៉េត វីណែល** អនុប្រធានលេខាធិការដ្ឋាន គ.ប.ធ.ប. និងជាប្រធានក្រុមការងារទី២ នៃក្រុមការងារចម្រុះចំណុះលេខាធិការដ្ឋាន គ.ប.ធ.ប. នៅសាលមហោស្រពខេត្តកោះកុង

- ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំផ្សព្វផ្សាយដើម្បីលើកកម្ពស់ការយល់ដឹងស្តីពីបទដ្ឋានគតិយុត្ត យន្តការគ្រប់គ្រង និងបទដ្ឋានបច្ចេកទេសសម្រាប់អាជីវកម្មខ្សាច់ ក្រោមការដឹកនាំ**ឯកឧត្តម អាន ពេជ្រហត្ថដា** រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានលេខាធិការដ្ឋាន នៃគណៈកម្មាធិការគ្រប់គ្រងធនធានខ្សាច់ នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០២៦ កិច្ចប្រជុំផ្សព្វផ្សាយអំពីគោលការណ៍បែបបទ និងវិធីសាស្ត្រក្នុងការប្រមូលទិន្នន័យនិងព័ត៌មាន ក្រោមការដឹកនាំ**ឯកឧត្តម អ៊ុំ ចំរើន** អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល នៅសាលមហោស្រពខេត្តកោះកុង
- ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៦ ពិធីផ្សព្វផ្សាយច្បាប់ស្តីពីការហាមឃាត់អាវុធគីមី អាវុធនុយក្លេអ៊ែរ ក្រោមការដឹកនាំ **លោកជំទាវ ឧត្តមសេនីយ៍ សុខុន ស្រីល័ក្ខ** នាយក នៃនាយកដ្ឋានហ្វឹកហ្វឺន និងបណ្តុះបណ្តាលជំនាញនៃអគ្គលេខាធិការដ្ឋានអាជ្ញាធជាតិអាវុធគីមី នៅសាលមហោស្រពខេត្តកោះកុង។

## ផ្នែកទី២÷សមិទ្ធផលការងារតាមមន្ទីរ និងអង្គភាពជំនាញ

## ២.១-ផ្នែកសេដ្ឋកិច្ច

### ២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

#### ក. ការងារកសិកម្ម

- ចលនាដឹកនាំសត្វ និងផលិតផលមានដើមកំណើតពីសត្វសរុបចំនួន១៧.២១៩ក្បាល និង៥១០គ.ក្រ
- ចាក់ថ្នាំការពារសត្វសរុបបានចំនួន១៥.៦៤៦ក្បាល
- ព្យាបាលសត្វសរុបបានចំនួន១.៦៧៨ក្បាល
- សត្វងាប់ដោយជំងឺសរុបមានចំនួន១.២៥៥ក្បាល
- ស្ថិតិពិឃាដសត្វសរុបមានចំនួន៣១.៧៤៩ក្បាល
- ការងារភ្ជួររាស់អនុវត្តបានសរុបចំនួន៣.៣៩៧ហ.ត(គ្រឿងចក្រ)
- សាបសំណាបអនុវត្តបានសរុបចំនួន២៨៨ហ.ត
- ដំណាំស្រូវអនុវត្តបានសរុបចំនួន៣.៦០០ហ.ត (ស្រូវកណ្តាល ២.៧៧២ហ.ត, ស្រូវធ្ងន់ ៣៣១ហ.ត, ស្រូវចម្ការ ៤៩៧ហ.ត)
- ដំណាំបន្លែអនុវត្តបានសរុបចំនួន១៦៨ហ.ត
- ដំណាំឈើហូបផ្លែអនុវត្តបានសរុបចំនួន១៦០ហ.ត
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១៦២ហ.ត
- បរិមាណកសិផលនាំចេញ និងប្រើប្រាស់ក្នុងខេត្តសរុបបានចំនួន៤.២៦៩តោន និងផ្លែដូងចំនួន១២.៩០០ផ្លែ
- បានចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចំនួន១២វគ្គ មានអ្នកចូលរួមចំនួន៣១៦នាក់ ស្រី១៣៧នាក់៖
    - ប្រព័ន្ធកសិកម្មចម្រុះចំនួន៤វគ្គ អ្នកចូលរួមចំនួន១០៧នាក់ ស្រី៥៨នាក់
    - ដំណាំទុរេនចំនួន១វគ្គ អ្នកចូលរួមចំនួន៥៥នាក់ ស្រី១៤នាក់
    - ចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារចំនួន២វគ្គ អ្នកចូលរួមចំនួន៣៨នាក់ ស្រី២៦នាក់
    - ពង្រឹងភ្នាក់ងារសុខភាពសត្វភូមិចំនួន១វគ្គ អ្នកចូលរួមចំនួន១៦នាក់ ស្រី៦នាក់
    - ជួសជុល និងការថែទាំគ្រឿងយន្តកសិកម្ម ចំនួន២វគ្គ អ្នកចូលរួមចំនួន៥០នាក់ ស្រី៥នាក់
    - ការរៀបចំផែនការមុខរបរចំនួន១វគ្គ អ្នកចូលរួមចំនួន២៥នាក់ ស្រី១៣នាក់
- ការប្រមូលផលដំណាំបន្លែ ការកែច្នៃ និងសុវត្ថិភាពចំណីអាហារចំនួន១វគ្គ អ្នកចូលរួមចំនួន២៥នាក់ ស្រី១៥នាក់

- បានចុះផ្សព្វផ្សាយ និងណែនាំបច្ចេកទេស ចំនួន៨លើក មានអ្នកចូលរួមចំនួន១៧៧នាក់ ស្រី៧៥នាក់ ក្នុងនោះ៖
  - ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មចំនួន១លើក អ្នកចូលរួមចំនួន៣០នាក់ ស្រី១៤នាក់
  - ការការពារ និងព្យាបាលជម្ងឺលើដំណាំកៅស៊ូចំនួន២លើក អ្នកចូលរួមចំនួន២១នាក់ ស្រី៧នាក់
  - ច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វចំនួន១លើក អ្នកចូលរួមចំនួន១៩នាក់ ស្រី១២នាក់
  - ការគ្រប់គ្រងជម្រកសុវត្ថិភាពត្រីកាម៉ុងចំនួន២លើក អ្នកចូលរួមចំនួន៧០នាក់ ស្រី២៥នាក់
  - សេចក្តីជូនដំណឹងការធ្វើអាជីវកម្ម(វារីវប្បកម្ម)ចំនួន១លើក អ្នកចូលរួមចំនួន១២នាក់ ស្រី៤នាក់
  - ប្រព័ន្ធអេកូឡូស៊ីរបស់សត្វផ្សោតឃ្លៀចចំនួន១លើក អ្នកចូលរួមចំនួន២៥នាក់ ស្រី១៣នាក់
- បានសហការជាមួយអង្គការ Save The Children (គម្រោងការីប) ចុះតាមដាន ត្រួតពិនិត្យបច្ចុប្បន្នភាពកសិករដាំដំណាំបន្លែក្នុងផ្ទះសំណាញ់ ការដាំបន្លែក្នុងផ្ទះសំណាញ់តាមបណ្តាសាលាបឋមសិក្សា និងការតម្លើងផ្ទះសំណាញ់ដោយមានបដិភាគពីកសិករ នៅតាមតំបន់ទីជម្រកសុវត្ថិភាព ជនភៀសសឹក បានចំនួន៤ទីតាំង និងគ្រួសារកសិករចំនួន៤គ្រួសារ នៅស្រុកកោះកុង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- អនុវត្តគម្រោងជលផលសមុទ្រ និងតំបន់ឆ្នេរប្រកបដោយចីរភាព (SCMF) បាន ៖
  - ចុះសម្របសម្រួលវគ្គបណ្តុះបណ្តាលស្តីពី ការត្រួតពិនិត្យគុណភាពទឹក ជាតិពុលក្នុងទឹក (Biotoxin) និងបច្ចេកទេស ក្នុងការធ្វើវារីវប្បកម្មគ្រំចំពុះទា និងអយស្ទ័រចំនួន២វគ្គ ដល់សហគមន៍នេសាទ ព្រែកខ្សាច់ និងសហគមន៍នេសាទថ្មស មានអ្នកចូលរួមសរុបចំនួន៣៥នាក់ ស្រី១០នាក់
  - ចូលរួមកិច្ចប្រជុំ និងសិក្សាស្តីពីការរៀបចំរបាយការណ៍វាយតម្លៃផលប៉ះពាល់បរិស្ថានដំបូង (IEIA) សម្រាប់គម្រោងសាងសង់កំពង់ផែនេសាទកោះខ្យង និងផែនេសាទចំការលើ មានអ្នកចូលរួមសរុបចំនួន២៦នាក់ ស្រី៩នាក់
  - ចុះសិក្សា និងពិនិត្យអនុគម្រោងថ្មីទៅលើទិដ្ឋភាពបរិស្ថាន ស្របតាមក្របខ័ណ្ឌនៃការវាយតម្លៃ និង បរិស្ថាន EARF នៅសហគមន៍នេសាទសម្រស់កោះស្តេច សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រថ្មស សហគមន៍នេសាទព្រែកខ្សាច់ និងសហគមន៍នេសាទជ្រោយស្វាយ មានអ្នកចូលរួមសរុបចំនួន៥០នាក់ ស្រី៧នាក់
  - សម្របសម្រួលកិច្ចប្រជុំពិភាក្សាផ្ទៀងផ្ទាត់ ពិនិត្យស្រទាប់បាត និងកំណត់ទីតាំងទម្លាក់ប្រអប់ជម្រកត្រីសិប្បនិម្មិតចំនួន២លើក នៅសហគមន៍នេសាទសម្រស់កោះស្តេច និងសហគមន៍នេសាទជ្រោយប្រស់ មានអ្នកចូលរួមសរុបចំនួន៥៨នាក់ ស្រី១៦នាក់
  - ចុះសម្របសម្រួលជាមួយក្រុមការងារ MCC ក្នុងការពង្រាយសំណង់ជម្រកត្រីសិប្បនិម្មិតចំនួន១លើក ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រសហគមន៍នេសាទជ្រោយស្វាយចំនួន៥០ប្រអប់ ស្មើនឹង១.០០០ដុំ មានអ្នកចូលរួមសរុបចំនួន១២នាក់ ស្រី១នាក់
  - ចុះសម្របសម្រួលកិច្ចប្រជុំពិភាក្សាកំណត់ទីតាំងធ្វើវារីវប្បកម្ម កន្លែងអភិរក្សជលផល និងប្រមូល ជាតុចូលសម្រាប់រៀបចំផែនការគ្រប់គ្រងសហគមន៍នេសាទចំនួន៤លើក នៅក្នុងសហគមន៍នេសាទ ជ្រោយស្វាយ សហគមន៍នេសាទកោះខ្យង សហគមន៍នេសាទជ្រោយប្រស់ សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកណ្តោល និងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រតាមាឃ មានអ្នកចូលរួមសរុបចំនួន៧៥នាក់ ស្រី២៦នាក់
  - ចូលរួមជាមួយនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍នេសាទ ប្រជុំផ្សព្វផ្សាយផែនការកន្លែងសហគមន៍នេសាទចំនួន១លើក នៅសហគមន៍នេសាទជ្រោយស្វាយ មានអ្នកចូលរួមសរុបចំនួន២០នាក់ ស្រី៦នាក់
  - ប្រជុំពិភាក្សាស្តីពី ការកំណត់មុខរបរអាទិភាពក្នុងការកែច្នៃផលផលិតផលជលផល ក្នុងសហគមន៍ នេសាទតំបន់ឆ្នេរសមុទ្រថ្មស (ភូមិចំការលើ) និងសហគមន៍នេសាទកោះខ្យង មានអ្នកចូលរួមសរុបចំនួន១៦នាក់ ស្រី១៥នាក់

- ចុះផ្សព្វផ្សាយក្ដាមសេះ ក្ដាមថ្មពងក្រៅស្នូក ដល់សហគមន៍នេសាទ ចំនួន ២លើក នៅសហគមន៍ នេសាទ តំបន់ឆ្នេរសមុទ្រថ្មស សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រកោះខ្យង និងសហគមន៍នេសាទជ្រោយស្វាយ មានប្រជានេសាទចូលរួមសរុបចំនួន៧០នាក់ ស្រី២៣នាក់
- ចុះពិនិត្យ និងតាមដានការចិញ្ចឹមសាកល្បងគ្រំចំពុះទាចំនួន១លើក នៅក្នុងសហគមន៍នេសាទព្រែកខ្សាច់ មានអ្នកចូលរួមសរុបចំនួន១១នាក់ប្រុស
- ចុះពិនិត្យពិនិត្យ និងតាមដានការចិញ្ចឹមសាកល្បងអយស្ទ័រចំនួន១លើក នៅក្នុងសហគមន៍នេសាទជ្រោយ-ប្រស់ មានអ្នកចូលរួមសរុបចំនួន៩នាក់ប្រុស

– បានចុះពិនិត្យ តាមដាន ផ្ដល់បច្ចេកទេសដាំដុះដំណាំបន្លែដល់កសិករបានចំនួន៥លើក ស្មើនឹង១៦គ្រួសារ នៅស្រុកបូទុមសាគរ ស្រុកកោះកុង ស្រុកស្រែអំបិល និងស្រុកថ្មបាំង
– ចុះពិនិត្យតាមដានការដាំដុះដំណាំកាហ្វេរបស់កសិករចំនួន១លើក បានចំនួន១២គ្រួសារ នៅឃុំឫស្សីជ្រុំ ឃុំតាទៃលើ និងឃុំថ្មដូនពៅ ស្រុកថ្មបាំង
– បានចុះពិនិត្យទីតាំងចិញ្ចឹមសត្វជាលក្ខណៈគ្រួសារបានចំនួន១ទីតាំង នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ក្រុមការងារបានចែកថ្នាំព្យាបាល និងណែនាំពីរបៀបប្រើប្រាស់ថ្នាំ
– បានចុះពិនិត្យអនាម័យសាច់ និងផលិតផលសាច់សត្វដែលដាក់តាំងលក់បានចំនួន៦កន្លែង នៅផ្សារអណ្ដូងទឹក ឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ
– បានចុះពិនិត្យទីតាំងលក់បសុឱសថ និងចំណីសត្វបានចំនួន២ដេប៉ូ នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
– បានចូលរួមជាមួយវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសត្វ និងផលិតកម្មសត្វ និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ចុះយកសំណាកឈាមគោ ក្របី ជ្រូក មាន់ ទា បានចំនួន១៦០សំណាក នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ និងឃុំជីផាត ស្រុកថ្មបាំង មានអ្នកចូលរួមសរុបចំនួន១៦នាក់ ស្រី៣នាក់
– បានចុះពិនិត្យទីតាំងពិឃាតគោរបស់ឈ្មោះ រុន ឯក ស្ថិតនៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។ ក្រុមការងារបានធ្វើកិច្ចសន្យាជាមួយម្ចាស់ទីតាំងសត្តឃាតដ្ឋាន ឱ្យធ្វើការផ្លាស់ប្ដូររកទីតាំងថ្មីឈប់ពិឃាតសត្វនៅទីតាំងចាស់ទៀត
– បានចុះចែកវ៉ាក់សាំងការពារជម្ងឺសារទឹក ថ្នាំព្យាបាល និងស៊ីរ៉ាំង ជូនដល់ភ្នាក់ងារសុខភាពសត្វភូមិចំនួន២នាក់ ដើម្បីចុះអន្តរាគមន៍ចាក់ថ្នាំការពារជម្ងឺឆ្លងសត្វពាហនៈជូនកសិករ នៅស្រុកកោះកុង
– បានចូលរួមជាមួយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ចុះត្រួតពិនិត្យបង្កើនការយល់ដឹងពីការធ្វើរោគវិនិច្ឆ័យលើជម្ងឺសត្វ និងការព្យាបាលជម្ងឺសត្វ នៅស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន១០នាក់ ស្រី៣នាក់
– បានចុះតាមដានត្រួតពិនិត្យដេប៉ូថ្នាំកសិកម្ម និងជីកសិកម្មចំនួន៣លើក បានចំនួន១២ដេប៉ូ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកថ្មបាំង ពុំបានប្រទះថ្នាំកសិកម្ម ឬជីកសិកម្មល្មើសច្បាប់ឡើយ
– បានចុះស្រង់ទិន្នន័យគ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធបន្លែចំនួន៣លើក នៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន២២នាក់ ស្រី៤នាក់
– បានចុះស្រាវជ្រាវករណីសង់ខ្ទមគ្រោងឆ្អឹងដែក ទំហំ៧ម x ៥ម ដំបូលប្រក់ស័ង្កសី ចំនួន១ខ្ទម ដោយខុសច្បាប់ របស់ឈ្មោះ វ៉ុន ខុម ភេទប្រុស អាយុ៥៦ឆ្នាំ និងប្រពន្ធឈ្មោះ ចក់ ធារី អាយុ៤៨ឆ្នាំ មុខរបរលក់ឥវ៉ាន់ចាប់ហួយ រស់នៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង នៅត្រង់ចំណុចនិយាមកា UTM ( 301966 ; 1255778) លើដីសម្បទានសេដ្ឋកិច្ច ក្រុមហ៊ុន ហ្វ្រីនរីច គ្រុប នៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង មានអ្នកចូលរួមចំនួន៨នាក់។ ជាលទ្ធផល ម្ចាស់ខ្ទមមិនបាន សហការជាមួយសមត្ថកិច្ចក្នុងការរុះរើខ្ទមនោះទេ។ ក្រុមការងារក៏បានចងក្រងសំណុំរឿង និងបានបញ្ជូនទៅ អយ្យការអមសាលាដំបូងខេត្តកោះកុង ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់

- បានសហការជាមួយក្រុមការងារលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះពិនិត្យវាយតម្លៃ និងពង្រឹងលើដំណើរការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច ក្នុងខេត្តកោះកុង លើគម្រោងសម្បទានដីសេដ្ឋកិច្ចចំនួន៤ក្រុមហ៊ុនរួមមានក្រុមហ៊ុនកោះកុង ស៊ូហ្គើរ អ៊ិនដាស ស្ទ្រី ខមផេនី លីមីធីត, ក្រុមហ៊ុន កោះកុង ផ្លេនថេសិន ខមផេនី លីមីធីត, ក្រុមហ៊ុន ហ្គ្រីន រីច គ្រុប ខូអិលធីឌី និង ក្រុមហ៊ុន ខេម៉ាហ្គ្រោ អ៊ិនវេសមេន គ្រុប មានអ្នកចូលរួមសរុបចំនួន១៥នាក់ ស្រី២នាក់
- បានចុះត្រួតពិនិត្យទីតាំងដីលំនៅដ្ឋាន និងធ្វើក្រោលគោ-ក្របី ដែលប្រជាពលរដ្ឋសាងសង់ដោយខុសច្បាប់លើដី សម្បទានសេដ្ឋកិច្ចក្រុមហ៊ុន កោះកុង ផ្លេនថេសិន ខមផេនី លីមីធីត ស្ថិតក្នុងឃុំកណ្តោល ស្រុកបូទុមសាគរ ខេត្តកោះកុង។ ជាលទ្ធផលឃើញថាមានខ្ទមចំនួន១ខ្នង និងក្រោលគោ-ក្របី ចំនួន១៧ក្រោល ដែលសង់អំពីសសរ កូនឈើ ដំបូលប្រក់ស័ង្កសី និងរបងបង្គោលកូនឈើ មានទំហំចាប់ពី ៤ម x ៦ម រហូតដល់ ១០ម x ១៥ម សង់ ប្រឋតាមមាត់អូរ។ ប្រជាពលរដ្ឋម្ចាស់ក្រោលគោ-ក្របី សំណូមពរសុំប្រើប្រាស់ក្រោល គោ-ក្របី រហូតដល់ចុង រដូវវស្សា ឆ្នាំ២០២៦នេះ បន្ទាប់មកនឹងរុះរើប្រគល់ដីជូនក្រុមហ៊ុនវិញ
- បានចុះសម្របសម្រួលមហាសន្និបាតប្រចាំឆ្នាំ២០២៥ចំនួន២លើក ដល់សហគមន៍កសិកម្មអង្គរភ្នំខ្លុង និង សហគមន៍អភិវឌ្ឍន៍កសិកម្មសាមគ្គីធម៌ នៅស្រុកស្រែអំបិល មានអ្នកចូលរួមសរុបចំនួន៦៧នាក់ ស្រី៤៥នាក់
- បានចុះធ្វើបញ្ជីសំណួរអង្កេតទិន្នន័យសហគមន៍កសិកម្ម ប្រចាំឆ្នាំ២០២៥ ក្រោយពីបានធ្វើមហាសន្និបាតប្រចាំ ឆ្នាំរួចរាល់ចំនួន២លើក ក្នុងសហគមន៍អភិវឌ្ឍន៍កសិកម្មសាមគ្គីធម៌ (ឃុំបឹងព្រាវ ស្រុកស្រែអំបិល) និងសហគមន៍ កសិកម្មអង្គរភ្នំខ្លុង (ឃុំស្រែអំបិល ស្រុកស្រែអំបិល) មានអ្នកចូលរួមសរុបចំនួន១៥នាក់ ស្រី៥នាក់។

**ខ.ការងារខណ្ឌរដ្ឋបាលជលផល**

- បានចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសក្នុងដែនសមត្ថកិច្ចចំនួន១៨លើក ជួបប្រទះបទល្មើសចំនួន១៥ករណី ក្នុងនោះ៖
  - អប់រំ និងណែនាំទូកនេសាទលបកន្ទុយកណ្ដុរចំនួន១៤គ្រឿង ស្មើនឹង១៤ករណី
  - អប់រំ និងណែនាំទូកអូសក្នុងកន្លែងសហគមន៍ចំនួន១គ្រឿង ស្មើនឹង១ករណី
- ផលនេសាទទឹកសាបអនុវត្តបានចំនួន១៥តោន
- ផលនេសាទសមុទ្រអនុវត្តបានចំនួន២៣.៩៦០តោន (សិប្បកម្មចំនួន២០៣៩៥តោន)
- ការកែច្នៃផលិតផលជលផលអនុវត្តបានចំនួន៩៤២តោន និងផលិតទឹកត្រីអនុវត្តបាន២២.០០០លីត្រ
- ផលវារីវប្បកម្មអនុវត្តបានចំនួន៣.០៨៦តោន
- ការផលនេសាទនាំចេញទៅតាមបណ្ដារាជធានី/ខេត្តសរុបចំនួន១៧.៤២៥តោន (ផលកែច្នៃចំនួន៨៦៥តោន)
- បានដាក់មេក្ដាមពងចូលក្នុងធនាគារក្ដាមចំនួន២១៤ក្បាល ស្មើនឹង១៨គីឡូក្រាម
- បានលែងសត្វសមុទ្រចំនួន៤ក្បាល ទម្ងន់៥២,៧០គីឡូក្រាម ក្នុងនោះ៖
  - អណ្ដើកសមុទ្រ (ប្រភេទក្រាស) ចំនួន២ក្បាល ទម្ងន់៤,៧០គីឡូក្រាម
  - អណ្ដើកសមុទ្រ (ប្រភេទល្មិច) ចំនួន១ក្បាល ទម្ងន់៣៧គីឡូក្រាម
  - ប្រគល់អណ្ដើកហ្លួងចំនួន១ក្បាលទម្ងន់១១គីឡូក្រាម ជូនមជ្ឈមណ្ឌលអភិរក្សសត្វល្មូន។

**គ. ការងារខណ្ឌរដ្ឋបាលព្រៃឈើ**

- បានថែទាំកូនឈើគគីរក្នុងថ្នាលបណ្ដុះចំនួន១.០០០ដើម
- បានប្ដូរថង់កូនឈើគគីរបានចំនួន៨០០ដើម
- បានច្រកដីដាក់ថង់សម្រាប់បណ្ដុះកូនឈើចំនួន១.២០០ថង់
- បានផ្ដល់កូនឈើចំនួន១៥០ដើម (កូនឈើគ្រញូង ដូងថៃម ឈើទាល កកោះ និងគគីរ) ដល់គណៈកម្មការ រៀបចំបុណ្យរំលឹកពូជបុរាណ សម្រាប់តាំងបង្ហាញ និងចែកជូនបងប្អូនសហគមន៍មូលដ្ឋាន នៅបរិវេណវត្តមុន្នី ជីខលើ ឃុំជីខលើ ស្រុកស្រែអំបិល

- បានចូលរួមជាមួយក្រុមការងារគម្រោងសហប្រតិបត្តិការរវាងរដ្ឋបាលព្រៃឈើ និងអង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (AfoCO) ចុះធ្វើការថែទាំកូនឈើចន្ទន៍ក្រស្នាផ្ទៃដីទំហំ១៦,៩ហិកតា និងធ្វើរបងការពារសត្វពាហនៈនៅតាមចំណុចសត្វពាហនៈឆ្លងកាត់ ដោយប្រើបង្គោលកូនឈើ និងខ្សែលួសបន្លាបានប្រវែង៤៤០ម៉ែត្រ ក្នុងដីព្រៃសហគមន៍ សាមគ្គីព្រែកជីក ស្ថិតនៅភូមិឈូក ឃុំជីខលើ ស្រុកស្រែអំបិល
- បានចុះយកចំណុចនិយាមកាកំណត់ព្រំប្រទល់ និងធ្វើការបោះបង្គោលព្រំបណ្ដោះអាសន្ន នៅតាមព្រំដីស្ថានីយ៍ផ្សព្វផ្សាយ និងស្ដារព្រៃឈើជីផាត ឃុំជីផាត ស្រុកថ្មបាំងបានចំនួន៥៩បង្គោល
- បានចូលរួមជាមួយក្រុមការងារអគ្គនាយកដ្ឋានព្រៃឈើ និងសត្វព្រៃ ចុះផ្ទៀងផ្ទាត់ និងពង្រឹងការងារកត់ត្រាទិន្នន័យឈើដាំ និងការធ្វើអាជីវកម្មឈើដាំចន្ទន៍ក្រស្នាផ្ទៃដីទំហំ២៨០ហិកតា របស់ឈ្មោះ សុធី សុវិត្យា ដែលបានចុះបញ្ជីជាព្រៃឯកជន និងកំពុងដំណើរការកាប់ប្រមូលដើមឈើចន្ទន៍ក្រស្នា ចូលរោងសិប្បកម្មឡចំហុយយកប្រេងចន្ទន៍ក្រស្នា ស្ថិតនៅឃុំជីខក្រោម ស្រុកស្រែអំបិល។ ក្រុមការងារបានណែនាំ ម្ចាស់ព្រៃឯកជន បន្តអនុវត្តឱ្យបានត្រឹមត្រូវទៅតាមលក្ខណ្ឌដូចមានចែងនៅក្នុងសៀវភៅបន្ទុក
- បានចូលរួមជាមួយមន្ត្រីរដ្ឋបាលព្រៃឈើថ្នាក់កណ្ដាល ចុះត្រួតពិនិត្យវាយតម្លៃទីតាំងស្នើសុំចុះបញ្ជីថែរក្សាសត្វត្រចៀកកាំជាលក្ខណៈគ្រួសាររបស់ប្រជាពលរដ្ឋបានចំនួន៦ទីតាំង ស្ថិតក្រុងខេមរភូមិន្ទ មានអ្នកចូលរួមសរុបចំនួន៥នាក់ ស្រី៣នាក់
- បានចូលរួមជាមួយក្រុមការងារអគ្គនាយកដ្ឋានព្រៃឈើ និងសត្វព្រៃ ចុះពិនិត្យ និងសិក្សាធនធានឈើអាកាស្យាលើផ្ទៃដីទំហំ១.០០០ហិកតា សម្រាប់ការស្នើសុំគោលការណ៍នាំចេញទៅបរទេសនូវផលិតផលឈើអារ និងចំណាំងកម្ទេចឈើពីដើមអាកាស្យា របស់ក្រុមហ៊ុន ហ្គ្រីន វីច គ្រុប និងក្រុមហ៊ុនដៃគូ ស្ថិតនៅស្រុកកោះកុង។ ជាលទ្ធផល ឃើញថាក្នុងផ្ទៃដី១ហិកតា មានដើមឈើអាកាស្យាចំនួន១.២៦៥ដើម ស្មើនឹង៤៨៨,៦៧ស្ទែរ ឬស្មើនឹង៣៧១,៨៨តោន (១ស្ទែរ មានទម្ងន់ ៧៦១គីឡូក្រាម)
- បានចូលរួមជាមួយក្រុមការងារថ្នាក់ខេត្ត ចុះពិនិត្យវាយតម្លៃ វាស់វែងផល អនុផលព្រៃឈើ ក្នុងបាតអាងស្តុកទឹកនៃគម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្ដាល ឃុំតាទៃលើ ស្រុកថ្មបាំង រួមមានឈើហ៊ុបមូលចំនួន១.២៤២កំណាត់ ស្មើនឹង១.៣៥៩ម៣០០៣, កូនឈើចម្រុះប្រភេទអង្កត់ផ្ចិតគល់ទំហំពី១៥ស.ម ទៅ៣០ស.ម ចំនួន៤៣.៩៨២ដើម, កូនឈើប្រភេទប្រណិតអង្កត់ផ្ចិតគល់ទំហំតូចជាង១៥ស.ម ចំនួន២០០ដើម, កូនឈើចម្រុះប្រភេទអង្កត់ផ្ចិតគល់ទំហំតូចជាង១៥ស.ម ចំនួន២០.០៣២ដើម និងអុសចំនួន២០.០០០ស្ទែរ
- បានចេញលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើបានចំនួន៣២៨លេខ ក្នុងបាតអាងស្តុកទឹកនៃគម្រោងវារីអគ្គិសនីក្នុងស្រុកថ្មបាំងខេត្តកោះកុង ទៅកាន់គោលដៅប្រើប្រាស់ក្នុងខេត្តកោះកុង ព្រះសីហនុ កំពត តាកែវ កំពង់ស្ពឺ កណ្ដាល កំពង់ចាម កំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ ត្បូងឃ្មុំ ព្រៃវែង ស្វាយរៀង និងរាជធានីភ្នំពេញ រួមមាន៖
    - ចេញពីគម្រោងវារីអគ្គិសនីស្ទឹងតាតៃលើចំនួន១០៦លេខ ក្នុងនោះកូនឈើចម្រុះប្រភេទចំនួន១០.៣១៣ដើម, អុសចម្រុះចំនួន២២៨ស្ទែរ និងឈើអារប្រភេទលេខ១(ដូងចែម)ចំនួន៣៧ម៣៥៧៩ និងសសរជ្រុងឈើប្រភេទលេខ៣ (ត្រមែង) ចំនួន២៧ដើម
    - ចេញពីគម្រោងវារីអគ្គិសនីស្ទឹងឫស្សីជ្រុំកណ្ដាលចំនួន១១៧លេខ ក្នុងនោះកូនឈើចម្រុះប្រភេទ ចំនួន១១.៦៥២ដើម, អុសចំនួន៧២០ស្ទែរ និងឈើអារចម្រុះប្រភេទចំនួន១.៧៥៤ម៣៩៤៤។

## ២.១.២-ការងារធនធានទឹក និងឧតុនិយម

- បានចុះពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្ដោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្ដោល ឃុំកណ្ដោល ស្រុកបូទុមសាគរ
- បានប្រមូលទិន្នន័យឧតុនិយមនៅតាមបណ្ដាស្រុក ដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម
- បានជួសជុល និងថែទាំជាប្រចាំសម្រេចបាន១០០% ដូចខាងក្រោម៖
    - ទំនប់ការពារទឹកប្រៃបឹងព្រាវ ប្រវែង១២.០០០ម ស្ថិតនៅឃុំបឹងព្រាវ ស្រុកស្រែអំបិល

- ទំនប់ការពារទឹកប្រៃជ្រោយស្វាយ ប្រវែង៤.១៣០ម ស្ថិតនៅឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
- ទំនប់ការពារទឹកប្រៃដងពែង១ ប្រវែង៤.៣០០ម ស្ថិតនៅឃុំដងពែង ស្រុកស្រែអំបិល
- ទំនប់ការពារទឹកប្រៃតានី ប្រវែង ២.០០០ម ស្ថិតនៅឃុំជីខលើ ស្រុកស្រែអំបិល
- ទំនប់ការពារទឹកប្រៃតាំកន់ ប្រវែង៦.៦៥០ម ស្ថិតនៅឃុំកណ្ដោល ស្រុកបូទុមសាគរ
- ទំនប់ការពារទឹកប្រៃកណ្ដោល ប្រវែង១១.០០០ម ស្ថិតនៅឃុំកណ្ដោល ស្រុកបូទុមសាគរ
- ទំនប់ការពារទឹកប្រៃជីមាល ប្រវែង៣.៤៨៩ម ស្ថិតនៅឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ
- ទំនប់ការពារទឹកប្រៃជីត្រេះ ប្រវែង៦.៨០០ម ស្ថិតនៅឃុំអណ្ដូងទឹក ស្រុកបូទុមសាគរ

– បានជួសជុសំណង់លូភ្លោះទី៣ អង្កត់ផ្ចិត១ម៉ែត្រមានសន្ទះភ្ជាប់ទ្វារទឹក ក្នុងឃុំដងពែង ស្រុកស្រែអំបិល សម្រេចបាន១០០%

– បានស្ដារប្រឡាយតាមបណ្ដោយទំនប់ការពារទឹកប្រៃកណ្ដោល២ ប្រវែង៣.៦៥០ម ស្ថិតនៅឃុំកណ្ដោល ស្រុកបូទុមសាគរ សម្រេចបាន១០០%។

## ២.១.៣-ការងារអភិវឌ្ឍជនបទ

– បានចុះធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវនិងសំណង់សិល្បការ្យ ដើម្បីរៀបចំបញ្ជីសារពើភ័ណ្ឌនិងមូលដ្ឋាន ទិន្នន័យផ្លូវជនបទបានចំនួន៣៧ខ្សែ ប្រវែងសរុប៣៩៩,៧០គ.ម ស្ថិតនៅស្រុកគីរីសាគរ ស្រុកថ្មបាំង ស្រុកកោះកុង និងស្រុកស្រែអំបិល ជាលទ្ធផលសម្រេចបាន១០០%

– បានចុះរាប់ចរាចរណ៍យានយន្ត១០លើកមានចំនួន១៤ខ្សែប្រវែងសរុបចំនួន៣៣០គ.ម ស្ថិតនៅក្នុងស្រុកស្រែអំបិល និងស្រុកថ្មបាំង ខេត្តកោះកុង

– បានចុះសិក្សាផ្លូវបេតុងចំនួន១ខ្សែ ប្រវែង២.៤៧០ម ទទឹង៧ម កម្រាស់២០០ម.ម និងស្ពានបេតុង១កន្លែង ប្រវែង១៨ម ទទឹង៨ម ស្ថិតនៅក្នុងឃុំកោះកាពិ ស្រុកកោះកុង

– បានចូលរួមប្រគល់ទទួលសុពលភាពផ្លូវក្រាលកៅស៊ូពីរជាន់ (DBST) ១ខ្សែ ប្រវែង៤គ.ម ជាមួយកងវិស្វកម្មតំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថិតនៅក្នុងឃុំជ្រោយប្រស់ ស្រុកកោះកុង ខេត្តកោះកុង សម្រេចបានលទ្ធផលការងារ១០០%

– បានចុះត្រួតពិនិត្យនិងវាយតម្លៃ លើការងារស្ដាបនាផ្លូវមានដូចខាងក្រោម៖
   - ការងារសាងសង់ផ្លូវកម្រាលកៅស៊ូពីរជាន់ (DBST) ចំនួន១ខ្សែ ប្រវែង១៦,១គ.ម ទទឹង៦ម ស្ថិតនៅឃុំកណ្ដោល ស្រុកបូទុមសាគរ និងឃុំជីផាត ស្រុកថ្មបាំង ជាលទ្ធផលបានសម្រេច១០០%
   - ការងារសាងសង់ផ្លូវកម្រាលកៅស៊ូពីរជាន់(DBST)ចំនួន១ខ្សែ ប្រវែង១៦គ.ម ទទឹង៦ម ស្ថិតនៅឃុំឫស្សីជ្រុំ និងឃុំជំនាប ស្រុកថ្មបាំង ស្រុកថ្មបាំង ជាលទ្ធផលបានសម្រេច៩៥%

– បានចុះត្រួតពិនិត្យការងារស្ដាបនាផ្លូវល្បាយថ្មភ្នំចំនួន១ខ្សែប្រវែង ៦៧០ម ទទឹង៨ម កម្រាស់២០០ម.ម ស្ថិតនៅក្នុងភូមិឡាំដាំ ឃុំកោះកាពិ ស្រុកកោះកុង ជាលទ្ធផលបានសម្រេច១០០%

– បានចុះត្រួតពិនិត្យទីតាំងតាមមណ្ឌលជនភៀសសឹកដែលត្រូវផ្ដល់សម្ភារបង្គន់អនាម័យ នៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ និងស្រុកកោះកុង ចំនួន២លើក

– បានចុះធ្វើបច្ចុប្បន្នភាពទិន្នន័យទឹកស្អាត ការសម្អាត និងអនាម័យជនបទ នៅស្រុកថ្មបាំង ស្រុកកោះកុង ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល សរុបចំនួន១០លើក

– បានចុះប្រមូលទិន្នន័យ និងសិក្សាទីតាំងសាងសង់អណ្ដូងស្នប់អាហ្វ្រីដេវ (Afredev) ចំនួន៣អណ្ដូង ជូនប្រជាពលរដ្ឋភៀសសឹក ស្ថិតនៅឃុំបឹងព្រាវ ស្រុកស្រែអំបិល

– បានចុះត្រួតពិនិត្យកាងារសាងសង់អណ្ដូងស្នប់ (Afridev) ចំនួន២អណ្ដូង ស្ថិតនៅឃុំស្រែអំបិល ស្រុកស្រែអំបិល ជាលទ្ធផលសម្រេចបាន១០០%

- បានចុះសិក្សាទីតាំងសាងសង់អណ្តូងស្នប់(Afridev) ចំនួន១០អណ្តូង ស្ថិតនៅឃុំឫស្សីជ្រុំ ឃុំតាទៃលើ ស្រុកថ្មបាំងនិងឃុំបឹងព្រាវ ស្រុកស្រែអំបិល
- បានដឹកនាំក្រុមការងារទឹកស្អាត និងអនាម័យជនបទ និងក្រុមការងារប្រតិភូជនជាតិជប៉ុន ចុះសិក្សាអំពីស្ថានភាពប្រព័ន្ធចែកចាយទឹកតាមបណ្តាញបំពង់ទុយោខ្នាតតូចសហគមន៍ ទឹកកខ្វក់ និងស្ថានភាពអនាម័យ (WASH) ដើម្បីលើកកម្ពស់សុខភាពសាធារណៈនៅតំបន់ជនបទមានចំនួន៤ទីតាំង រួមមានសាលាឃុំជីផាត មណ្ឌលសុខភាពជីផាត សាលាបឋមសិក្សាជីផាត អនុវិទ្យាល័យ និងវិទ្យាល័យជីផាត ស្រុកថ្មបាំង
- បានចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ (គ.អ.ភ) បានចំនួន១០ភូមិ នៅឃុំបឹងព្រាវ និងឃុំស្រែអំបិល ស្រុកស្រែអំបិល ដែលមានសមាជិកសរុបចំនួន៩៧នាក់ ស្រី២៦នាក់
- បានសហការជាមួយក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទចុះសិក្សា និងផ្ទៀងផ្ទាត់លក្ខណៈសម្បត្តិភូមិគំរូគន្លឹះសម្រាប់ឆ្នាំ២០២៦ នៅភូមិជីផាត ឃុំជីផាត ស្រុកថ្មបាំង និងភូមិប្រៃ ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- បានសហការជាមួយក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ ក្រសួងអភិវឌ្ឍន៍ជនបទ ចុះប្រមូលទិន្នន័យភូមិគំរូគន្លឹះសម្រាប់ផែនការឆ្នាំ២០២៧-២០២៨ ស្ថិតនៅភូមិត្រពាំងកណ្តោល ឃុំជីខលើ ភូមិខ្សាច់ក្រហម ឃុំជីក្រោមស្រុកស្រែអំបិល និងភូមិត្រពាំងខ្នារ ឃុំតាទៃលើ ភូមិត្រពាំងឈើត្រាវ ឃុំឫស្សីជ្រុំ ភូមិព្រែកស្វាយ ឃុំថ្មដូនពៅ ភូមិប្រកបឫស្សី ឃុំជំនាប់ ស្រុកថ្មបាំង
- បានចុះស្រង់វប្បធម៌ប្រពៃណី និងភាសារបស់សហគមន៍ជនជាតិដើមភាគតិចជង បានចំនួន៣លើក នៅឃុំប្រឡាយ ស្រុកថ្មបាំង
- បានចុះធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការសហគមន៍ជនជាតិដើមភាគតិចជង បានចំនួន១លើក នៅភូមិព្រែកស្វាយ និងភូមិកោះ ឃុំថ្មដូនពៅ ស្រុកថ្មបាំង
- បានចុះធ្វើការវាយតម្លៃសហគមន៍ជនជាតិដើមភាគតិច(ជង)ចំនួន២លើកនៅឃុំប្រឡាយ ស្រុកថ្មបាំង។

## ២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ដៃបាញ់ប្រេងឥន្ធនៈ ក្នុងស្រុកគិរីសាគរ ស្រុកបូទុមសាគរ និងស្រុកស្រែអំបិល ចំនួន១៤មូលដ្ឋាន មានដៃបាញ់ប្រេងសរុបចំនួន១២៣ដៃ។ ជាលទ្ធផលក្រុមការងារពិនិត្យឃើញថា ដៃបាញ់ប្រេងចំនួន១១៧ដៃ អនុលោមតាមបទប្បញ្ញត្តិបច្ចេកទេស ដែលអាចអនុញ្ញាតឲ្យធ្វើអាជីវកម្មបាន និង៦ដៃទៀត ជាដៃខូចត្រូវបានម្ចាស់ដេប៉ូស្នើសុំឈប់ប្រើប្រាស់
- បានចុះអធិការកិច្ចលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន៦មូលដ្ឋាន
- បានចុះត្រួតពិនិត្យ ទីតាំងរោងចក្រ សហគ្រាស/សិប្បកម្ម ៖
  - ស្នើសុំច្បាប់អនុញ្ញាតបង្កើតសហគ្រាស/សិប្បកម្ម បានចំនួន៤មូលដ្ឋាន
  - ស្នើសុំវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការសហគ្រាស/សិប្បកម្ម (ថ្មី) ចំនួន៣មូលដ្ឋាន
  - ស្នើសុំវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការសហគ្រាស/សិប្បកម្ម (បន្ត) ចំនួន៥មូលដ្ឋាន
  - ស្នើសុំពង្រីកខ្សែសង្វាក់ផលិតកម្ម លើមុខផលិតផលចាស់របស់សិប្បកម្មចំនួន១មូលដ្ឋាន
- បានសហការជាមួយក្រុមការងារជំនាញរបស់ក្រសួង ដើម្បីចុះធ្វើអធិការកិច្ចលើភាពអនុលោមនៃការអនុវត្តន៍ច្បាប់ និងលក្ខណបច្ចេកទេសលើសហគ្រាស/សិប្បកម្ម ចំនួន៣មូលដ្ឋាន
- បានចេញសេចក្តីសម្រេចបង្កើត រោងចក្រ សហគ្រាស/សិប្បកម្ម ចំនួន៤មូលដ្ឋាន
- បានចេញវិញ្ញាបនបត្រអនុញ្ញាតឱ្យដំណើរការ សហគ្រាស/សិប្បកម្ម (ថ្មី) ចំនួន៣មូលដ្ឋាន និង(បន្ត) ចំនួន៥មូលដ្ឋាន
- បានចេញលិខិតឯកភាព លើការស្នើសុំពង្រីកខ្សែសង្វាក់ផលិតកម្ម លើមុខផលិតផលចាស់របស់សិប្បកម្មចំនួន១មូលដ្ឋាន

- បានយកសំណាកផលិតផលទៅវិភាគគុណភាពនៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ បានចំនួន៨មូលដ្ឋាន ស្មើនឹង១០ប៉ាន់គំរូ ។ ជាលទ្ធផលអនុលោមតាមគុណភាពស្តង់ដារដែលបានកំណត់។

## ២.១.៨-ការងាររ៉ែ និងថាមពល

- បានចុះពិនិត្យទីតាំងកាយដីកយកអាចម៍ដី អានាធិបតេយ្យដោយគ្មានច្បាប់អនុញ្ញាតនៅស្រុកស្រែអំបិល ស្រុកបូទុមសាគរ ស្រុកគិរីសាគរ ស្រុកកោះកុង ស្រុកមណ្ឌលសីមា និងក្រុងខេមរភូមិន្ទចំនួន៧លើក ជាលទ្ធផលបានបញ្ឈប់សកម្មភាពនិងណែនាំស្នើសុំច្បាប់តាមនីតិវិធី
- បានចុះពិនិត្យបោះពោងកំណត់ទីតាំងដែនអាជ្ញាបណ្ណធ្វើអាជីវកម្មបូមខ្សាច់របស់ក្រុមហ៊ុន ស៊ី មីនើរ៉ល អិចផ្លរេសិន ប្រូសេស៊ីង អ៊ឹមផត អ៊ិចផត ឯ.ក នៅស្រុកគិរីសាគរ ចំនួន១លើក
- បានសហការជាមួយក្រុមការងារក្រសួងរ៉ែ និងថាមពល មន្ទីរ អង្គភាពពាក់ព័ន្ធ ចុះពិនិត្យអនុវត្តគម្រោងសិក្សាភូគព្ភសាស្ត្រ និងសន្ទស្សរ៉ែ នៅក្នុងឃុំជីផាត ស្រុកថ្មបាំង បានចំនួន២លើក
- បានចូលរួមសហការជាមួយក្រុមការងាររដ្ឋបាលខេត្ត អាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ ចុះពិនិត្យ និងវាយតម្លៃទីតាំងស្នើសុំធ្វើអាជីវកម្មបូមខ្សាច់ចំនួន៥ទីតាំង ដូចខាងក្រោម៖
  - លោកស្រី តេង រចនា ស្ថិតនៅតំបន់ព្រៃកតាចាន់ ភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង
  - លោក ប៉ាង សុខ ស្ថិតនៅតំបន់ព្រៃកតាចាន់ ភូមិត្រពាំងរូង ឃុំត្រពាំងរូង ស្រុកកោះកុង
  - លោក អ៊ឹង ដេវីន ភូមិ បឹងយុនឆាង សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
  - លោកស្រី ប៊ីវ ង៉ាម ស្ថិតនៅតំបន់ព្រែកកោះប៉ោ ភូមិ កោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - លោកស្រី ហ៊ិន សាវ ស្ថិតនៅតំបន់ព្រែកកោះប៉ោ ភូមិ កោះប៉ោ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា

  ជាលទ្ធផល ក្រុមការងារបានធ្វើរបាយការណ៍ជាក់ជូនលោកជំទាវអភិបាលខេត្ត ដើម្បីពិនិត្យនិងសម្រេចចេញអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែ
- ការងារការប្រមូលចំណូល និងកៀរគរចំណូលសរុប ១៤៤.៥៦៩,៥៤ $ និង ៣១.៥០០.០០០ ៛
  - សួយសារផលិតផលរ៉ែចំនួន ១២៦.៦១៥,៧៤ $
  - កម្រៃឈ្នួលដីសរុបចំនួន ១៦៥ $
  - ប្រាក់ពិន័យអន្តរការណ៍ចំនួន ៧៩៥,៩៧ $ និង ៣១.៥០០.០០០ ៛
  - មូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍មូលដ្ឋានចំនួន ១២.៨៦៦,៧៦ $
  - មូលនិធិរ៉ែសម្រាប់ការគ្រប់គ្រងកសាងសមត្ថភាពចំនួន ៤.១២៦,០៧ $
- បានចុះពិនិត្យការពង្រីកបណ្តាញអគ្គិសនីរបស់ក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប នៅចំនុចផ្លូវបំបែកវត្តព្រែកស្វាយ ក្នុងភូមិព្រែកស្វាយ សង្កាត់ស្ទឹងវែង ក្រុមខេមរភូមិន្ទ
- បានចុះពិនិត្យការដាក់ខ្សែបណ្តាញ និងរៀបចំដាក់ប្រអប់នាឡិកាអគ្គិសនីរបស់ក្រុមហ៊ុន អិល វ៉ាយ ភី គ្រុប នៅចំណុចគល់ស្ពាន ភូមិ២ សង្កាត់ដងទង់ ក្រុមខេមរភូមិន្ទ
- បានចូលរួមសហការជាមួយបុគ្គលិកស្នាក់ការអគ្គិសនី ចុះត្រួតពិនិត្យបង្គោល និងខ្សែបណ្តាញអគ្គិសនីចាប់ពីចំណុចនៅក្នុងក្រុងខេមរភូមិន្ទ ដល់ស្រុកមណ្ឌលសីមា ដើម្បីត្រៀមរៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះកោះកុង នៅខេត្តកោះកុង
- បានទទួលពាក្យស្នើសុំបន្តវិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពសម្រាប់ស្ថានីយប្រេងឥន្ទនៈរួមមាន៖
  - ឈ្មោះ អ៊ុក ថាំង មានទីតាំងនៅភូមិ ស្ទឹងឆាយ ឃុំបឹងព្រាវ ស្រុកស្រែអំបិល ខេត្តកោះកុង(តេលា)
  - ឈ្មោះ អ៊ុក កញ្ញា មានទីតាំងនៅភូមិ គគីជ្រុំ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង (តេលា)
  - ឈ្មោះ វុន ប៊ុនវិសិដ្ឋ មានទីតាំង នៅភូមិ ចាំយាម ឃុំប៉ាកខ្លង ស្រុក មណ្ឌលសីមា (តូតាល់)

- ឈ្មោះ ម៉ោ ទូច មានទីតាំងនៅភូមិ ព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ (តេលា)
- ឈ្មោះ ហ៊ី សឿង មានទីតាំងនៅភូមិ ត្រពាំងរូង ឃុំ ត្រពាំងរូង ស្រុកកោះកុង (តេលា)
- ឈ្មោះ ទៀ វិចិត្រ មានទីតាំង នៅភូមិ បឹងព្រាវ ឃុំបឹងព្រាវ ស្រុក ស្រុកស្រែអំបិល (PEACE)
- ឈ្មោះ ម៉ន ង៉ុល មានទីតាំងនៅភូមិ កៀនក្រឡាញ់ ឃុំ ភ្ញីមាស ស្រុក គិរីសាគរ (លឹម លុង)
- ឈ្មោះ ដឹក ហួរ មានទីតាំងនៅភូមិ ស្រែអំបិល ឃុំ ស្រែអំបិល ស្រុកស្រែអំបិល (តេលា)
- ឈ្មោះ មុំ រិទ្ធី មានទីតាំងនៅភូមិ សិលាម្នាង ឃុំ បឹងព្រាវ ស្រុកស្រែអំបិល (តេលារិទ្ធី)
- ឈ្មោះ សួន សម្បត្តិ មានទីតាំងនៅភូមិ ស្ទឹងឆាយ ឃុំ បឹងព្រាវ ស្រុកស្រែអំបិល (តេលាសម្បត្តិ)
- ឈ្មោះ សួស មិថុនា មានទីតាំងនៅភូមិ ឫស្សីជ្រុំ ឃុំឫស្សីជ្រុំ ស្រុកថ្មបាំង (តេលា)
- ឈ្មោះ ទ្រី វណ្ណី មានទីតាំងនៅភូមិ តាផង ឃុំ ដងពែង ស្រុកស្រែអំបិល (សូគីម៉ិច)
- ឈ្មោះ គង់ សំអុល មានទីតាំងនៅភូមិ ២ ឃុំ ប៉ាក់ខ្លង ស្រុកមណ្ឌលសីមា (លឹម លុង)

– បានពិនិត្យនិងបញ្ជូនពាក្យស្នើសុំរបស់ម្ចាស់ស្ថានីយ ទៅអគ្គនាយកដ្ឋានប្រេងកាតនៃក្រសួងរ៉ែ និងថាមពលដើម្បីផ្តល់វិញ្ញាបនបត្របញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយបន្តសុពលភាព

– បានចូលរួមសហការជាមួយមន្ទីរពាណិជ្ជកម្ម និងសាខា កបប ខេត្តកោះកុង ចុះពិនិត្យតម្លៃលក់ប្រេង នៅតាមស្ថានីយប្រេងឥន្ធនៈ តាមបណ្តាក្រុង/ស្រុក ខេត្តកោះកុងបានចំនួន៧លើក ជាលទ្ធផល គ្រប់ស្ថានីយប្រេងឥន្ធនៈទាំងអស់ បានអនុវត្តត្រឹមត្រូវតាមសេចក្តីណែនាំរបស់ក្រសួងពាណិជ្ជកម្ម។

### ២.១.៦-ការងារពាណិជ្ជកម្ម

– បានចុះបំពេញប្រតិវេទន៍ប្រចាំឆ្នាំសរុបចំនួន៥ក្រុមហ៊ុន ដូចខាងក្រោម៖
  - ក្រុមហ៊ុន អូ.អេច អូស្មានីយ៉ាស់ អ៊ីដ អាហ្គារ៉ូដ អលយ៍ ប្រសេសស៊ីង (ខេមបូឌា) ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជីនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ក្រុមហ៊ុន អិល.វ៉ាយ.អេ អាហ្គាយ៉ា ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី នៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ
  - ក្រុមហ៊ុនទឹម រិនរតនៈ ខនស្ត្រាក់សិន ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី នៅភូមិ១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
  - ក្រុមហ៊ុន ម៉ុត គេន ខនស្ត្រាក់សិន ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី នៅភូមិ១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
  - ក្រុមហ៊ុន កក់ ស៊ុនសេង ខនស្ត្រាក់សិន ឯ.ក អាសយដ្ឋានទីស្នាក់ការចុះបញ្ជី នៅភូមិសាលាម្នាង ឃុំបឹងព្រាវ ស្រុកស្រែអំបិល

– បានផ្ញើសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈតាមប្រព័ន្ធសារអេឡិចត្រូនិក(Telegram) ឱ្យទៅតាមបណ្តាស្ថានីយ និងដេប៉ូលក់ប្រេងឥន្ធនៈសរុបចំនួន៤៩ស្ថានីយ/ដេប៉ូ ក្នុងនោះមាន៖
  - ក្រុងខេមរភូមិន្ទ ចំនួន១២ស្ថានីយ
  - ស្រុកមណ្ឌលសីមា ចំនួន៦ស្ថានីយ
  - ស្រុកកោះកុង ចំនួន៣ស្ថានីយ
  - ស្រុកបូទុមសាគរ ចំនួន៥ស្ថានីយ
  - ស្រុកថ្មបាំង ចំនួន៤ស្ថានីយ
  - ស្រុកគិរីសាគរ ចំនួន៥ស្ថានីយ
  - ស្រុកស្រែអំបិល ចំនួន១៤ស្ថានីយ

– បានតាមដានតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយលក់ប្រេងឥន្ធនៈនៅក្នុងខេត្តរៀងរាល់ថ្ងៃ

- បានសហការជាមួយនាយកដ្ឋានកម្មសិទ្ធិបញ្ញានៃក្រសួងពាណិជ្ជកម្ម រៀបចំមហាសន្និបាតកំណើតដំបូងរបស់សមាគមអ្នកអភិរក្សក្ដាមថ្មកោះកុង ដើម្បីពិនិត្យ និងអនុម័តលើលក្ខន្តិកៈសមាគម សៀវភៅបន្ទុកម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ "ក្ដាមថ្មកោះកុង" និងការបោះឆ្នោតជ្រើសរើសប្រធាន អនុប្រធាន និងសមាជិកសមាគម
- បានចូលរួមទិវាកម្មសិទ្ធិបញ្ញាពិភពលោក ឆ្នាំ២០២៦ និងពិធីសម្ពោធគម្រោង និងប្រគល់វិញ្ញាបនបត្រចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ រួមមានក្ដាមថ្មកោះកុង សូត្រមាសភ្នំស្រុក ស្វាយឧត្តរមានជ័យ និងស្វាយចន្ទីកំពង់ធំ នៅទីស្តីការក្រសួងពាណិជ្ជកម្ម
- បានចូលរួមកម្មវិធីសម្ពោធនិងចូលរួមតាំងផលិតផល ក្នុងពិព័រណ៍ពាណិជ្ជកម្មខេត្តកំពង់ស្ពឺ លើកទី១៤ ឆ្នាំ ២០២៦ នៅបរិវេណសម្ដេចព្រះសង្ឃរាជ ជួន ណាត ខេត្តកំពង់ស្ពឺ
- បាននាំយកផលិតផលសក្ដានុពលខេត្តចូលរួម "ទិវាជាតិលើកកម្ពស់ការប្រើប្រាស់ផលិតផលខ្មែរ" នៅខេត្តកំពង់ធំ
- បានសហការជាមួយរដ្ឋបាលខេត្តក្នុងការរៀបចំពិព័រណ៍ផលិតផលសក្ដានុពលក្នុងខេត្ត ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ នៅបរិវេណសួនច្បារមុខសាលាខេត្តកោះកុង
- បានសហការជាមួយរដ្ឋបាលខេត្តក្នុងការរៀបចំតាំងបង្ហាញផលិតផលសក្ដានុពលខេត្ត ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះ កោះកុង
- បានចូលរួមជាភ្ញៀវកិត្តិយស និងនាំយកផលិតផលសក្ដានុពលខេត្តដាក់តាំងបង្ហាញក្នុងពិធីបើកសម្ពោធ "យុទ្ធការផលិតផលជាតិ" (MadeInCambodia) នៅបរិវេនសម្ដេចព្រះសង្ឃរាជ ជួន ណាត ខេត្តកំពង់ស្ពឺ
- បានសហការជាមួយសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្រ្កាបការក្លែងបន្លំខេត្ត(ក.ប.ប) ចុះផ្សព្វផ្សាយច្បាប់ និងត្រួតពិនិត្យគុណភាព សុវត្ថិភាពម្ហូបអាហារ និងទំនិញហួសកាលបរិច្ឆេទប្រើប្រាស់ សរុបចំនួន១៧លើក។

## ២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

### ២.១.៧.១-ការងារហិរញ្ញវត្ថុ

- ចំណូលថវិកាពីមន្ទីរជំនាញ មានចំនួន ៣០២.៥៤៧.៤៨៧ រៀល
- ចំណាយថវិការបស់មន្ទីរជំនាញ មានចំនួន ២១.២៤៦.៧៣៤.៥៨៥ រៀល
- ចំណូលមិនមែនសារពើពន្ធ មានចំនួន ៦០.៨៥៥.០០០ រៀល
- ចំណូលថវិការបស់ក្រុង ស្រុក មានចំនួន ៣២.១០៩.៤៤៧.៧៨០ រៀល
- ចំណាយថវិការបស់ក្រុង ស្រុក មានចំនួន ១៤.៤០៤.៦៩៦.៧៧១ រៀល
- បានពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈជាប្រចាំ
- បានរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ជាប្រចាំ។

### ២.១.៧.២-ការងារពន្ធដារ

- បានប្រមូលចំណូលពន្ធដើម្បីបែងចែកចូលថវិកាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ៧.០៣៣.៦៦៣.០០៣រៀល ស្មើនឹង៥៥,៤៤% នៃផែនការឆ្នាំ ក្នុងនោះ ៖
    - ចំណូលបង់ចូលថវិកាថ្នាក់ជាតិមានចំនួន៤.០១៣.៨៣៣.៤៧៥រៀល ស្មើនឹង៩៩,៨៧% នៃផែនការឆ្នាំ
    - ចំណូលបង់ចូលថវិកាថ្នាក់ក្រោមជាតិមានចំនួន ៣.០១៩.៨២៩.៥២៨រៀល ស្មើនឹង៣៤,៨៤% នៃផែនការឆ្នាំ។

### ២.១.៧.៣-ការងារគយ និងរដ្ឋាករ

- ប្រមូលចំណូលសរុបបានចំនួន៧.១៨៧.៩៩១.៥០០រៀល ស្មើនឹង៩៩,៨៣% នៃផែនការប្រចាំឆមាស ប្រៀបធៀបនឹងឆមាសទី១ ឆ្នាំ២០២៥ ចំនួន៨៦.៥៤៤.៧២៩.៤០០រៀល ថយចុះ៩១,៦៨%
- បានពង្រឹងការគ្រប់គ្រងឯកសារប្រតិវេទន៍គយ គ្រប់គ្រងការបិទតែមគយ និងត្រួតពិនិត្យទំនិញបានហ្មត់ចត់
- បានពង្រឹងការធ្វើប្រតិវេទន៍គយឱ្យបានសុក្រឹតតាមការណែនាំរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា។

### ២.១.៨-ការងារទេសចរណ៍

- បានផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្តតាមរយៈសៀវភៅផ្ទត់ គេហទំព័រ Mobile App (Visit Cambodia) និងហ្វេសប៊ុក ដល់ភ្ញៀវទេសចរ
- បានចុះស្រង់ទិន្នន័យស្ថិតិភ្ញៀវទេសចរមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២៥៖
  - ភ្ញៀវទេសចរជាតិស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៥២៤.១៨៦នាក់ កើនឡើងចំនួន៩.២៧៣នាក់ ស្មើនឹង២%
  - ភ្ញៀវទេសចរបរទេសស្នាក់នៅ និងមកកម្សាន្តតាមរមណីយដ្ឋានទេសចរណ៍ចំនួន៣០.៥២៩នាក់ ថយចុះ ៣.៥៥៤នាក់ ស្មើនឹង-១០%
  - ➢ សរុបភ្ញៀវទេសចរជាតិ និងបរទេសចំនួន៥៥៤.៤១៥នាក់ កើនឡើង៥.៧១៩នាក់ ស្មើនឹង១%
- ភ្ញៀវទេសចរមកកម្សាន្តតាមសហគមន៍៖
  - ភ្ញៀវទេសចរជាតិ មានចំនួន១២០.៧៩២នាក់ ថយចុះ១៩.៤៣៧នាក់ ស្មើនឹង-១៣%
  - ភ្ញៀវទេសចរបរទេស មានចំនួន៤.០៤០នាក់ ថយចុះ២៧១នាក់ ស្មើនឹង-៦%
- បានផ្តល់អាជ្ញាបណ្ណជូនអាជីវករចំនួន១១៨កន្លែង តាមរយៈក្រសួងទេសចរណ៍ អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ទាំង៧ ដូចខាងក្រោម៖
  - ក្រសួងទេសចរណ៍
    - សណ្ឋាគារ ចំនួន ២ កន្លែង (បន្ត១, ថ្មី១)
    - ផ្ទះសំណាក់ ចំនួន ៣ កន្លែង (បន្ត)
    - រមណីយដ្ឋានទេសចរណ៍កែច្នៃ ចំនួន ២ កន្លែង (បន្ត)
  - អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត
    - ផ្ទះសំណាក់ ចំនួន ១៩ កន្លែង (បន្ត)
    - បឹងហ្គាឡូ ចំនួន ៤ កន្លែង (បន្ត)
    - ម៉ាស្សាសុខភាព ចំនួន ១ កន្លែង (បន្ត)
    - ខារ៉ាអូខេ ចំនួន ១ កន្លែង (បន្ត)
    - ហៀហ្គាឌិន ចំនួន ២ កន្លែង (បន្ត)
    - សណ្ឋាគារ ចំនួន ១ កន្លែង (បន្ត)
    - ភោជនីយដ្ឋាន ចំនួន ៣ កន្លែង (បន្ត២, ថ្មី១)
    - ការស្នើសុំប្តូរម្ចាស់អាជីវកម្មបឹងហ្គាឡូ ចំនួន ១ កន្លែង
  - ការិយាល័យច្រកចេញចូលតែមួយក្រុងខេមរភូមិន្ទ
    - ខារ៉ាអូខេ ចំនួន ២ កន្លែង (បន្ត)
    - ផ្ទះសំណាក់ ចំនួន ៣ កន្លែង (បន្ត)
    - ម៉ាស្សាសុខភាព ចំនួន ២ កន្លែង (ថ្មី)
    - អាហារដ្ឋាន ចំនួន ១ កន្លែង (ថ្មី)
    - ស្នូកឃ័រ ចំនួន ១ កន្លែង (បន្ត)
    - បន្ទប់ជួល ចំនួន ៤ កន្លែង (បន្ត)
  - ការិយាល័យច្រកចេញចូលតែមួយស្រុកមណ្ឌលសីមា
    - ផ្ទះសំណាក់ ចំនួន ៤ កន្លែង (បន្ត២, ថ្មី២)
    - ម៉ាស្សាសុខភាព ចំនួន ១ កន្លែង (បន្ត)
    - បន្ទប់ជួល ចំនួន ៥ កន្លែង (បន្ត២, ថ្មី៣)

- ការិយាល័យច្រកចេញចូលតែមួយស្រុកកោះកុង
  - ផ្ទះសំណាក់ ចំនួន ៣ កន្លែង (បន្ត២, ថ្មី១)
  - ភោជនីយដ្ឋាន អាហារដ្ឋានទេសចរណ៍ ចំនួន ១ កន្លែង (បន្ត)
  - ខារ៉ាអូខេ ចំនួន ១ កន្លែង (បន្ត)
- ការិយាល័យច្រកចេញចូលតែមួយស្រុកគិរីសាគរ
  - ផ្ទះសំណាក់ ចំនួន ៣៦ កន្លែង (បន្ត៣៥, ថ្មី១)
  - ខារ៉ាអូខេ ចំនួន ២ កន្លែង (បន្ត)
  - បន្ទប់ស្នាក់នៅ ចំនួន ២ កន្លែង (បន្ត)
  - ស្ទូកយ៉រ ចំនួន ១ កន្លែង (បន្ត)
  - អាហារដ្ឋានទេសចរណ៍ ចំនួន ២ កន្លែង (បន្ត១, ថ្មី១)
- ការិយាល័យច្រកចេញចូលតែមួយស្រុកស្រែអំបិល
  - ផ្ទះសំណាក់ ចំនួន ២ កន្លែង (បន្ត)
  - អាហារដ្ឋាន ចំនួន ១ កន្លែង (ថ្មី)
  - ម៉ាស្សាសុខភាព ចំនួន ២ កន្លែង (បន្ត១, ថ្មី១)
  - ខារ៉ាអូខេ ចំនួន ១ កន្លែង (ថ្មី)
- ការិយាល័យច្រកចេញចូលតែមួយស្រុកថ្មបាំង
  - ផ្ទះសំណាក់ ចំនួន ២ កន្លែង (បន្ត១, ថ្មី១)

– បានចុះថតរូបភាព និងវីដេអូតំបន់គោលដៅទេសចរណ៍ក្នុងស្រុកគិរីសាគរចំនួន៤ទីតាំង រួមមាន កោះស្ដេចរីសត កោះទទឹងរីសត, រីសត Royal Beach Resort & Residence និងតាមបណ្ដោយវិថីសាយភូថងទៅកាន់កំពង់ផែទេសចរណ៍ពយជប៉ុន

– បានចូលរួមរៀបចំស្តង់ពិពរណ៍ និងផ្សព្វផ្សាយសមិទ្ធផលផលិតផល និងសេវាកម្មទេសចរណ៍មន្ទីររាជធានី-ខេត្ត និងសហគមន៍ទេសចរណ៍ក្នុងពិធីសន្និបាតបូកសរុបលទ្ធផលការងារវិស័យទេសចរណ៍ឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងទេសចរណ៍ នៅសណ្ឋាគារសុខាភ្នំពេញរ៉េស៊ីដង់

– បានចូលរួមរៀបចំស្តង់ពិព័រណ៍បង្ហាញពីសក្ដានុពលទេសចរណ៍ និងរត់ប្រណាំងកម្សាន្ត ក្នុងព្រឹត្តិការណ៍អបអរសាទរពិធីសម្ពោធស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះឈ្នះ កោះកុង

– បានចុះធ្វើសម្រង់ស្ថិតិ ផ្សព្វផ្សាយ App Nodrug, ការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% និងសាកសួរព័ត៌មានអំពីផលប៉ះពាល់នៃបញ្ហាព្រំដែនមកលើ អាជីវកម្ម សេវាកម្មទេសចរណ៍ ក្នុងក្រុងខេមរភូមិន្ទ ចំនួន៥៨ទីតាំង ស្រុកមណ្ឌលសីមា ចំនួន៣០ទីតាំង ស្រុកបូទុមសាគរ ចំនួន១៥ទីតាំង និងស្រុកកោះកុង ចំនួន១០ទីតាំង

– បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ ចុះវាយតម្លៃបឋម និងបិទQR សម្រាប់សាធារណជន ចូលរួមវាយតម្លៃសម្រាប់បេក្ខភាពបង្គន់សាធារណៈកម្ពុជាស្អាត ឆ្នាំ២០២៥-២០២៦ ចំនួន៥ទីតាំង (ភោជនីយដ្ឋានលើទូក ភោជនីយដ្ឋានអនន្ត, រីសតសូហូ, ស្ថានីយប្រេងឥន្ធនៈភីសដងទង់ និងសួនច្បារស្តូបអនុស្សាវរីយ៍នយោបាយ ឈ្នះ ឈ្នះ កោះកុង) និងរដ្ឋបាលស្រុកស្រែអំបិលចំនួន១ទីតាំង (ភោជនីយដ្ឋានសុកមង្គល)

– បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ រៀបចំកម្មវិធីទិវាជាតិទីក្រុងស្អាតលើកទី១៣ ឆ្នាំ២០២៦ ក្រោមប្រធានបទ "សាមគ្គីដើម្បីទីក្រុងស្អាត" ដែលមានអ្នកចូលរួមសរុបប្រមាណ២៥០នាក់

– បានបើកកិច្ចប្រជុំផ្សព្វផ្សាយអំពីសហគមន៍ស្អាត និងសក្ដានុពលទេសចរណ៍ ដែលមានអ្នកចូលរួម សរុបចំនួន ២៥នាក់ ស្រី១៣នាក់ នៅសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រជ្រោយស្វាយ ស្រុកស្រែអំបិល

– បានសហការជាមួយរដ្ឋបាលស្រុកស្រែអំបិល និងគម្រោងអភិវឌ្ឍន៍ជំនាញនៃអង្គការស្វីសខនថាក់បើកសិក្ខាសាលាបច្ចេកទេសពិគ្រោះយោបល់ និងផ្សព្វផ្សាយកម្មវិធីបណ្តុះបណ្តាលបដិសណ្ឋារកិច្ចកម្ពុជា(ហូកា) ដើម្បីជ្រើស

រើសសិក្ខាកាម និងគ្រូបង្គោល ហូកា លើជំនាញ ការិយាល័យជួរមុខគេហកិច្ច សេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ធុងកាហ្វេ ចុងភៅ និងមគ្គុទ្ទេសក៍ទេសចរណ៍សហគមន៍ ក្នុងស្រុកស្រែអំបិល ដែលមានអ្នកចូលរួមសរុបចំនួន ៧១នាក់ ស្រី២២នាក់

- បានសហការជាមួយកម្មវិធីអភិវឌ្ឍន៍ជំនាញនៃអង្គការស្វីសខន់ថាក់ (Swisscontact) បើកវគ្គបណ្តុះបណ្តាលបដិសណ្ឋារកិច្ចកម្ពុជា(ហូកា) ៖
  - ជំនាញចុងភៅ(Cooking) ដែលមានសិក្ខាកាម សរុបចំនួន១២នាក់ ស្រី១២នាក់ នៅសហគមន៍អេកូទេសចរណ៍ជីផាត និងនៅសហគមន៍អេកូទេសចរណ៍ធម្មជាតិភ្ញីមាស មានសិក្ខាកាមចូលរួមសរុបចំនួន១២នាក់ ស្រី៧នាក់
  - ជំនាញសេវាកម្មម្ហូបអាហារ និងភេសជ្ជៈ ដែលមានសិក្ខាកាមចូលរួមសរុបចំនួន២១នាក់ ស្រី១៤នាក់ នៅសហគមន៍អេកូទេសចរណ៍តំបន់ស្ទឹងអារ៉ែង
  - ជំនាញគេហកិច្ចមានសិក្ខាកាមចូលរួមសរុបចំនួន១៦នាក់ ស្រី១២នាក់ នៅសហគមន៍អេកូទេសចរណ៍ជីផាត
- បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីសេចក្តីព្រាងផែនការអភិវឌ្ឍន៍ទេសចរណ៍ ឆ្នាំ២០២៦-២០៣០ ដែលមានអ្នកចូលរួមសរុបចំនួន៣៨នាក់ ស្រី១២នាក់ នៅសាលប្រជុំមន្ទីរទេសចរណ៍ខេត្តកោះកុង។

## ២.១.៩-ការងារផែនការ

- បានប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ នៅតាមបណ្តាក្រុង/ស្រុក ឃុំ/សង្កាត់ និងភូមិ ឆ្នាំ២០២៥ ខេត្តកោះកុងបានចំនួន១២០ភូមិ ២៦ឃុំ ៣សង្កាត់ ៦ស្រុក និង១ក្រុង ស្មើនឹង១០០%
- បានបញ្ចូលទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ ឆ្នាំ២០២៥ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ (CDB) Online ប្រព័ន្ធថ្នាលទិន្នន័យថ្មីបាន១២០ភូមិ ២៦ឃុំ ៣សង្កាត់ ៦ស្រុក និង១ក្រុង ស្មើនឹង១០០%
- បានបញ្ចូលទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ ឆ្នាំ២០២៥ ទៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ (CDB) Offline ប្រព័ន្ធចាស់ បានចំនួន៧ក្រុង/ស្រុក ២៩ឃុំ/សង្កាត់ និង១១៩ភូមិ ស្មើនឹង១០០%
- បានផ្ទៀងផ្ទាត់ទិន្នន័យក្នុងថ្នាលទិន្នន័យ (CDB Online Platform) បានចំនួន ៧ក្រុង/ស្រុក ២៩ឃុំ/សង្កាត់ និង ១១៩ភូមិ ស្មើនឹង១០០%
- បានសហការជាមួយទីចាត់ការផែនការ និងវិនិយោគខេត្ត រៀបចំកិច្ចប្រជុំក្រុមការងារកសាងផែនការខេត្ត ដើម្បីពិនិត្យលើសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត (២០២៦-២០២៨) បានរួចរាល់និងត្រៀមរៀបចំកិច្ចប្រជុំគណៈអភិបាល និង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត ដើម្បីពិនិត្យនិងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៦-២០២៨)
- បានសហការជាមួយទីចាត់ការផែនការ និងវិនិយោគខេត្ត រៀបចំដំណើរការចាប់ផ្តើមកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៧-២០២៩) តាមប្រតិទិនការងារ
- បានសហការជាមួយទីចាត់ការផែនការ និងវិនិយោគសាលាខេត្ត ចុះបណ្តុះបណ្តាលស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់រដ្ឋបាលក្រុង/ស្រុក និងឃុំ/សង្កាត់ តាមបណ្តាក្រុង/ស្រុក ចំនួន៦វគ្គ សរុបអ្នកចូលរួម១៧០នាក់ ស្រី២០នាក់
- បានផលិតឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ចខេត្ត និងពិន្ទុវិស័យខេត្ត (បានបោះពុម្ពចំនួន៥០ក្បាល)
- បានផលិតឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច ក្រុង/ស្រុក (បានបោះពុម្ពសៀវភៅចំនួន២១ក្បាល)
- បានដាក់លេខកូដស្តង់ដាទៅក្នុងគម្រោងដែលទទួលបានកិច្ចសន្យាបណ្តោះអាសន្ន តាមបណ្តាក្រុង/ស្រុក ឃុំ/សង្កាត់ក្នុងសិក្ខាសាលាសមាហរណកម្មបានចំនួន១ក្រុង ៦ស្រុក ២៦ឃុំ ៣សង្កាត់ ស្មើនឹង១០០%

- បានរៀបចំឯកសារចុះសម្របសម្រួលរៀបចំកិច្ចប្រជុំផ្សព្វផ្សាយឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច និងណែនាំអំពីការប្រមូលតម្រូវការអាទិភាពរបស់រដ្ឋបាលក្រុង/ស្រុក និងឃុំ/សង្កាត់ ក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៧-២០២៩)
- បានសហការជាមួយរដ្ឋបាលក្រុង/ស្រុកទាំង៧ រៀបចំកិច្ចប្រជុំផ្សព្វផ្សាយឯកសារព័ត៌មានស្ថានភាពសេដ្ឋកិច្ច-សង្គមកិច្ច និងណែនាំអំពីការប្រមូលតម្រូវការអាទិភាពរបស់រដ្ឋបាលក្រុង/ស្រុក និងឃុំ/សង្កាត់ ក្នុងដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៧-២០២៩) ចំនួន ៧លើក អ្នកចូលរួមសរុប២៥០នាក់ ស្រី៤៧នាក់
- បានចុះប្រមូលទិន្នន័យជាតុចូលពីបណ្ដាមន្ទីរជំនាញ អង្គភាពជុំវិញខេត្តគិតចាប់ពីថ្ងៃទី១-២២ ខែមិថុនា ឆ្នាំ២០២៦ មន្ទីរ អង្គភាពដែលបានបំពេញរួចចំនួន១២/២៧ មន្ទីរអង្គភាព សាខា ស្មើនឹង៤៤,៤%
- បានទទួលគម្រោងវិនិយោគជាអាទិភាពតាមបណ្តាឃុំ/សង្កាត់ (២០២៧-២០២៩) តារាង១.១ក, ១.១ខ, ១.១.គ និងបញ្ជីគម្រោងដែលប្រើប្រាស់តែមូលនិធិបានចំនួន ១ឃុំ ស្មើនឹង៣,៤%
- បានផលិតរបាយការណ៍ស្តីពីទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ ឆ្នាំ២០២៥ ខេត្តកោះកុង សម្រេចបាន៩៨% (កំពុងសម្អាត និងរៀបចំមាតិកា)
- បានចុះសម្របសម្រួលជាមួយមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត ស្តីពីការស្រង់ទិន្នន័យបឋមពលករទេសន្តរប្រវេសន៍វិលត្រឡប់ពីប្រទេសថៃ នៅសាលប្រជុំមន្ទីរការងារបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ ពលករសរុបធ្វើការនៅប្រទេសថៃ១.៩១៩នាក់ ត្រឡប់មកពីប្រទេសថៃសរុប៧៤៧នាក់ និងទិន្នន័យដែលផ្តល់ដោយឃុំ/សង្កាត់សរុប២១៥នាក់ ដែលជាក្រុមគោលដៅសម្រាប់កំណត់អត្តសញ្ញាណពលករទេសន្តរប្រវេសន៍វិលត្រឡប់ពីប្រទេសថៃ នាខែបន្ទាប់
- បានចុះបណ្តុះបណ្តាលស្តីពីការកំណត់អត្តសញ្ញាណពលករទេសន្តរប្រវេសន៍ត្រឡប់ពីប្រទេសថៃ តាមបណ្តាក្រុង/ស្រុកចំនួន៧វគ្គ សរុបអ្នកចូលរួម១១៧នាក់ ស្រី២៤នាក់
- បានចុះណែនាំ និងប្រមូលទិន្នន័យពលករទេសន្តរប្រវេសន៍ត្រឡប់ពីប្រទេសថៃ តាមបណ្តាភូមិទូទាំងខេត្ត សរុបទទួលបាន១៥០គ្រួសារ ចំនួនពលករ២៥២នាក់ ស្រី១២៨នាក់ និងបានបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យ (ID-POOR APP) រួចរាល់ស្មើនឹង១០០%
- បានចុះតាមដានត្រួតពិនិត្យ លើដំណើរការអនុវត្តនីតិវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ នៅឃុំកណ្តោល ឃុំតានូន ឃុំថ្មស ស្រុកបូទុមសាគរ និងឃុំកោះស្តេច ស្រុកគិរីសាគរ
- បានចុះតាមដានត្រួតពិនិត្យ និងសំភាសន៍សំណាកប្រចាំត្រីមាសទី២ ឆ្នាំ២០២៦ ចំនួន៧ឃុំ/សង្កាត់ ក្នុងខេត្តកោះកុង
- បានចុះផ្សព្វផ្សាយអំពីការអនុវត្តយន្តការតាមដានដែលដឹកនាំដោយសហគមន៍(Community-Led Monitoring CLM) និងពិភាក្សាលើលទ្ធផលនៃទិន្នន័យដែលជាព័ត៌មានត្រឡប់របស់សហគមន៍ក្នុងកម្មវិធីអេដស៍ និងសេវាពាក់ព័ន្ធកាន់តែប្រសើរឡើង នៅសាលាសង្កាត់ស្មាច់មានជ័យ ដែលមានអ្នកចូលរួមចំនួន៤៥នាក់ ស្រី២០នាក់
- បានសហការជាមួយនាយកដ្ឋានអត្តសញ្ញាណកម្មគ្រួសារក្រីក្រក្រសួងផែនការ រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពដល់មន្ត្រីមន្ទីរផែនការរាជធានីខេត្តចំនួន៨ សរុបអ្នកចូលរួម៧០នាក់ ស្រី២៤នាក់
- បានរៀបចំតារាងចំនួនគ្រួសារមិនប្រក្រតីតាមបណ្តាឃុំ/សង្កាត់ សរុប១.២៦៨គ្រួសារ ត្រៀមចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់តាមឃុំ/សង្កាត់
- វឌ្ឍនភាពការគ្រប់គ្រង និងការដោះស្រាយសំណូមពរបណ្ណសមធម៌ គិតត្រឹមឆមាសទី១ ឆ្នាំ២០២៦ ៖
  - ករណីបាត់បណ្ណចំនួន២៧បណ្ណ (បានផលិតជូនរួចរាល់)
  - ករណីស្នើសុំបញ្ចេញបណ្ណបន្ទាន់ចំនួន៤៥បណ្ណ
  - ករណីស្នើសុំផ្លាស់ប្តូរចំណាត់ថ្នាក់គ្រួសារងាយរងហានិភ័យទៅជាគ្រួសារក្រីក្រចំនួន២៨គ្រួសារ
  - ករណីបណ្ណសម្គាល់ថ្មីចំនួន៨៦០បណ្ណ (ផលិតថ្មី)

  ○ ករណីបណ្ណរហែកចំនួន៨គ្រួសារ
  ○ ករណីប្តូរមេគ្រួសារចំនួន១គ្រួសារ
  ○ ករណីជួយបញ្ចូលគ្រួសារដែលមានកូនអាយុក្រោម១ឆ្នាំចំនួន២៣បណ្ណ (បញ្ចូលទៅក្នុងបណ្ណសមធម៌)
- បានចុះស្រង់ទិន្នន័យ និងបញ្ចូលថ្លៃទំនិញប្រើប្រាស់ក្នុងប្រព័ន្ធតាប្លេត (CAPI) ប្រចាំឆមាសទី១ ឆ្នាំ២០២៦ នៅផ្សារដងទង់ ក្រុងខេមរភូមិន្ទ
- បានប្រមូល និងផ្ទៀងផ្ទាត់ទិន្នន័យមូលដ្ឋានឃុំ/សង្កាត់ នៅតាមបណ្តាក្រុង/ស្រុក ឃុំ/សង្កាត់ និងភូមិ ឆ្នាំ២០២៥ ខេត្តកោះកុងបានចំនួន១៣ភូមិ ៣ឃុំ
- បានបញ្ជូនមន្ត្រីចំនួន១រូប ចុះសម្ភាសន៍ និងស្រង់ទិន្នន័យអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៥ (អនុវត្តឆ្នាំ២០២៦) ក្នុងឆមាសទី១ ចំនួន៦ខេត្ត និង១៤ភូមិ
- បានបញ្ជូនមន្ត្រីចំនួន១រូប ចុះអង្កេតវាយតម្លៃគុណភាពទឹកតាមគ្រួសារអមអង្កេតសេដ្ឋកិច្ច-សង្គមកិច្ច ឆ្នាំ២០២៦ ក្នុងឆមាសទី១ ចំនួន២១គ្រួសារ
- បានបញ្ជូនមន្ត្រីចំនួន១រូប ចុះប្រមូលទិន្នន័យចំណូលចំណាយ និងទិន្នន័យតាមវិស័យជំនាញឆ្នាំ២០២៥ ដើម្បីចងក្រង និងគណនាផលិតផលក្នុងស្រុកសរុប (GDP) បានចំនួន២៩/២៩ អង្គភាពស្មើនឹង១០០% និងបានបញ្ជូនទៅនាយកដ្ឋានគណនេយ្យជាតិនៃវិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ
- បានបញ្ជូនមន្ត្រីចំនួន១រូប ចុះអង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា ឆ្នាំ២០២៦ នៅក្នុងខេត្តកោះកុង ចំនួន២០ភូមិ ស្មើនឹង៦០០គ្រួសារ
- បានស្រាវជ្រាវទិន្នន័យជំរឿនប្រជាជនឆ្នាំ១៩៩៨,២០០៨,២០១៩ ដើម្បីចងក្រងសៀវភៅរបាយការណ៍ស្ថានភាពប្រជាជន និងបម្រែបម្រួលប្រជាសាស្ត្រខេត្តកោះកុង ឆ្នាំ២០២៤ សម្រេចបាន១០០%
- បានធ្វើរបាយការណ៍ស្រាវជ្រាវទិន្នន័យសហគមន៍ សម្រេចបាន១០០%
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រជាជននិងអភិវឌ្ឍ ដើម្បីផ្សព្វផ្សាយ និងប្រមូលធាតុចូលសម្រាប់រៀបចំផែនការសកម្មភាពអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ ខេត្តកោះកុង នៅសាលប្រជុំមន្ទីរផែនការខេត្ត
- បានចុះប្រមូលធាតុចូល សម្រាប់រៀបចំចងក្រងសេចក្តីព្រាងផែនការសកម្មភាពអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ នៅតាមបណ្តាមន្ទីរ អង្គភាព សាខាជុំវិញខេត្ត សរុបចំនួន១៦
- បានចុះប្រមូលព័ត៌មានទិន្នន័យជនជាតិដើមភាគតិចជង ចំនួន៤ឃុំ រួមមានឃុំតាទៃលើ, ឃុំប្រឡាយ, ឃុំជំនាប់ និងឃុំថ្មដូនពៅ នៅស្រុកថ្មបាំង។

### ២.១.១០-ការងារផ្សេងៗ

#### ២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- ចំណូលជាប្រាក់រៀលសរុបចំនួន ៤១.០៥៣.០២៤.៩៥០រៀល បើប្រៀបធៀបទៅនឹងឆមាសមុនថយ ៨,៨៩%
- ចំណូលជាប្រាក់ដុល្លារសរុបចំនួន ៣៣.៧៥០.៥៣៨ ដុល្លារ បើប្រៀបធៀបទៅនឹងឆមាសមុនថយ ៥៦,៨០%
- ចំណាយជាប្រាក់រៀលសរុបចំនួន ៧២.៩៧១.៤៨៧.៣០០រៀល បើប្រៀបធៀបទៅនឹងឆមាសមុនថយ ៥,៣៦%
- ចំណាយជាប្រាក់ដុល្លារចំនួន ១៧.៨៨៣.000 ដុល្លារ បើប្រៀបធៀបទៅនឹងឆមាសមុនកើន ៣,៧៣%
- បានប្តូរប្រាក់រៀល ចាស់ រហែក ទក់ សរុបចំនួន ៩.០២៩.៤០០.០០០រៀល
- បានចេញលិខិតអនុញ្ញាតអាជីវកម្មប្តូរប្រាក់មានសុពលភាពចុងគ្រាសរុបចំនួន៤៧ច្បាប់។

#### ២.១.១០.២-ការងាររតនាគារ

- បានពង្រឹងការអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធ FMIS ជូនមន្ត្រីជំនាញជាបន្តបន្ទាប់
- បានពង្រឹងការអនុវត្តការកត់ត្រាចំណូលចំណាយតាមប្រព័ន្ធ FMIS ជូនមន្ត្រីបានកាន់តែប្រសើរ

- បានពង្រឹងការអនុវត្តសារាចរណែនាំស្តីពីការអនុវត្តនីតិវិធីបើកផ្តល់ប្រាក់បៀវត្សរាល់២សប្តាហ៍ម្តងក្នុងខែនីមួយៗជូនមន្ត្រីរាជការបានទាន់ពេលវេលា
- បានពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល( FMIS Portal )ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានកាន់តែប្រសើរ
- ចំណូលសរុបមានចំនួន១១១.២៤៥លានរៀល ក្នុងនោះ៖
    - ចំណូលពីអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន៩១.១២៨លានរៀល
    - ចំណូលមូលដ្ឋានមានចំនួន២០.១១៧លានរៀល
- ចំណាយសរុបមានចំនួន១១០.៧២២លានរៀល ក្នុងនោះ៖
    - ផ្ទេរទៅអគ្គនាយកដ្ឋានរតនាគារជាតិ មានចំនួន១៩.៧៤៩លានរៀល
    - ចំណាយមូលដ្ឋានមានចំនួន៩០.៩៧៣លានរៀល។

### ២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បានចុះត្រួតពិនិត្យធ្វើតេស្តបឋមលើម្ហូបអាហារគ្រឿងសមុទ្រ និងបានយកសំណាកគំរូ១៤៨ ដើម្បីធ្វើតេស្តបឋមរកសារជាតុគីមីហាមឃាត់ដូចជា ហ្វ័រម៉ាលីន សូដ្យូមអ៊ីដ្រូស៊ុលហ្វីត និងបូរ៉ាក់ ចំនួន៥ទីតាំង ដូចខាងក្រោម ៖
    - នៅផ្សារដេងទង់ ក្រុងខេមរភូមិន្ទ បានយកសំណាកគំរូចំនួន១២គំរូ ជាលទ្ធផល ពុំបានរកឃើញសារជាតុគីមីហាមឃាត់ខាងលើនោះទេ។ ប៉ុន្តែបានរកឃើញ និងដកហូតទំនិញហួសកាលបរិច្ឆេទចំនួន៩,០១គ.ក្រ
    - នៅផ្សារភូមិថ្មី ស្រុកមណ្ឌលសីមា បានយកសំណាកគំរូចំនួន២៩គំរូ ជាលទ្ធផល ពុំបានរកឃើញសារជាតុគីមីហាមឃាត់ខាងលើ និងដកហូតទំនិញខូចគុណភាពនោះទេ
    - នៅផ្សារប៉ាក់ខ្លង ស្រុកមណ្ឌលសីមា បានយកសំណាកគំរូចំនួន២៩គំរូ ជាលទ្ធផល ពុំបានរកឃើញសារជាតុគីមីហាមឃាត់ខាងលើ និងដកហូតទំនិញខូចគុណភាពនោះទេ
    - នៅផ្សារអណ្តូងទឹក ស្រុកបូទុមសាគរ បានយកសំណាកគំរូចំនួន១៤គំរូ ជាលទ្ធផល ពុំបានរកឃើញសារជាតុគីមីហាមឃាត់ខាងលើ និងដកហូតទំនិញខូចគុណភាពនោះទេ
    - នៅផ្សារស្រែអំបិល ស្រុកស្រែអំបិល បានយកសំណាកគំរូចំនួន១២គំរូ ជាលទ្ធផល ពុំបានរកឃើញសារជាតុគីមីហាមឃាត់ខាងលើ និងដកហូតទំនិញខូចគុណភាពនោះទេ
- បានយកសំណាកគំរូទឹកបរិសុទ្ធដែលផលិតក្នុងតំបន់(ខេត្តកោះកុង) ៥ប្រភេទម៉ាកផ្សេងគ្នា បញ្ជូនទៅមន្ទីរពិសោធន៍នៃអគ្គនាយកដ្ឋាន ក.ប.ប គោលបំណងវិភាគរកនូវគុណភាពអនាម័យ និងសារជាតុស្តង់ដារមួយចំនួនដើម្បីលើកកម្ពស់ និងកែតម្រូវទាន់ពេល
- បានចុះត្រួតពិនិត្យគុណភាពសុវត្ថិភាពទំនិញម្ហូបអាហារតាមហាងលក់ទំនិញ ម៉ាត និងតាមផ្ទះ ដូចខាងក្រោម៖
    - ស្រុកមណ្ឌលសីមាចំនួន៨ទីតាំង ជាលទ្ធផលពុំបានរកឃើញទំនិញខូចគុណភាព និងហួសកាលបរិច្ឆេទប្រើប្រាស់ទេ
    - ក្រុងខេមរភូមិន្ទចំនួន២០ទីតាំង ជាលទ្ធផលបានរកឃើញ និងដកហូតទំនិញហួសកាលបរិច្ឆេទប្រើប្រាស់សរុបចំនួន២១.៩៤គ.ក្រ
    - ស្រុកស្រែអំបិលចំនួន១៩ទីតាំង ជាលទ្ធផលបានរកឃើញទំនិញខូចគុណភាព និងហួសកាលបរិច្ឆេទប្រើប្រាស់ចំនួន៤.១២គ.ក្រ
    - ស្រុកថ្មបាំងចំនួន១៤ទីតាំង ជាលទ្ធផលបានរកឃើញទំនិញខូចគុណភាព និងហួសកាលបរិច្ឆេទប្រើប្រាស់ចំនួន៤២.៣៤គ.ក្រ
- បានចុះផ្សព្វផ្សាយតាមសាលាចំនួន៥លើកស្មើនឹង១៨សាលារៀន ដើម្បីផ្សព្វផ្សាយស្តីពី "សុវត្ថិភាពម្ហូបអាហារ និងច្បាប់កិច្ចការពារអ្នកប្រើប្រាស់ និងបទប្បញ្ញត្តិពាក់ព័ន្ធនានា" ដល់សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងអាជីវករ

ដែលមានអ្នកចូលរួម សរុបចំនួន២៣៤២នាក់ ស្រី១២៥៩នាក់ និងចែកផ្ទាំងរូបភាព ស្តីពីសុវត្ថិភាពម្ហូបអាហារចំនួន៩៣០ផ្ទាំង

- បានចុះអង្កេតថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ/ដេប៉ូចំនួន១០១លើក ក្នុងនោះចំនួន៧៩.៦៣%ស្ថានីយ/ដេប៉ូ លក់តម្លៃអនុលោមតាមសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្មចំនួន១៨.៧៧%ស្ថានីយ/ដេប៉ូ លក់តម្លៃទាបជាងសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្មនិងចំនួន១.៦០%ស្ថានីយ/ដេប៉ូផ្អាកលក់បណ្តោះអាសន្ន។

## ២.២-ផ្នែកសង្គមកិច្ច

### ២.២.១-ការងារអប់រំ យុវជន និងកីឡា

- ការងារទំនាក់ទំនងផ្សេងៗជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ចំនួន៣លើក
- បានចុះអធិការកិច្ចតាមកាលកំណត់ និងផ្ទៀងផ្ទាត់ វាយតម្លៃស្តង់ដាសាលារៀនគំរូ ចំនួន១៤លើក
- បានចុះពិនិត្យតាមដានការអនុវត្តកិច្ចការទីប្រឹក្សាគរុកោសល្យជំនាញ និងទីប្រឹក្សាកោសល្យប្រចាំសាលារៀនចំនួន១លើក
- បានចុះពិនិត្យតាមដាន ណែនាំការងារកិច្ចបញ្ជិការគណនេយ្យ និងការងារពាក់ព័ន្ធចំនួន១៣លើក
- បានចុះពិនិត្យតាមដាន និងណែនាំការងារបច្ចេកទេសមត្តេយ្យសិក្សាចំនួន២លើក
- បានចុះពិនិត្យតាមដាន និងណែនាំការងារបច្ចេកទេសបឋមសិក្សាចំនួន១លើក
- បានចុះពិនិត្យតាមដាន និងណែនាំការងារបច្ចេកទេសមធ្យមសិក្សាចំនួន៥លើក
- បានចុះពិនិត្យតាមដាន និងណែនាំការងារបច្ចេកទេសអប់រំក្រៅប្រព័ន្ធចំនួន៥លើក
- បានចុះពិនិត្យតាមដាន និងណែនាំការងារបច្ចេកទេសអប់រំកាយ និងកីឡាចំនួន២លើក
- បានចុះពិនិត្យតាមដាន និងណែនាំបច្ចេកទេសការងារផែនការ ទិន្នន័យ និងស្ថិតិចំនួន១២លើក
- បានចុះពិនិត្យតាមដានលើការងារគ្រប់គ្រងបុគ្គលិក និងការប្រើប្រាស់ក្របខ័ណ្ឌចំនួន៣លើក
- បានចុះគាំទ្រការអនុវត្តស្តង់ដាសាលារៀនគំរូសរុប១១លើក តាមអនុវិស័យមានដូចជាៈ
  - មធ្យមសិក្សាចំនួន២លើក
  - បឋមសិក្សា៩លើក
  - ការងារការិយាល័យគាំទ្រ៣លើក
- បានចុះគាំទ្រ និងផ្សព្វផ្សាយលើការងារអប់រំសុខភាពសិក្សាចំនួន១១លើក
- បានចុះពិនិត្យតាមដានការងារអនុវត្តគម្រោងកែលម្អការអប់រំចំណេះទូទៅ( GEIP/GEIP-AF) នៅតាមសាលាគោលដៅចំនួន១២លើក
- បានចុះបង្វឹកលើការអនុវត្តយន្តការគាំទ្រស្តង់ដាសាលារៀនគំរូរបស់គម្រោងកែលម្អការអប់រំចំណេះទូទៅ (GEIP) នៅតាមសាលាគោលដៅចំនួន១០លើក
- បានពិនិត្យតាមដាន និងចុះគាំទ្របច្ចេកទេសការប្រើប្រាស់ប្រព័ន្ធថ្នាលបឋមចំនួន១លើក ក្នុងនោះមានគ្រូ៤៧១នាក់បានចូលប្រើប្រាស់ និងចូលរៀន៤១៥នាក់
- បានពិនិត្យតាមដានការអនុវត្តកិច្ចការពារកុមារនៅសាលារៀន តាមរយៈគ្រូបតេលេក្រាម មាន១៩សាលា និងបានផ្សព្វផ្សាយចំនួន២៦៣ដង
- បានដឹកនាំកិច្ចប្រជុំជាមួយការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងសាលារៀនចំនួន២លើក
- បានរៀបចំវគ្គបច្ចេកទេសផ្សេងៗពាក់ព័ន្ធ ដល់មន្ត្រីជំនាញការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងសាលារៀន សរុបចំនួន១៥លើក មានដូចខាងក្រោមៈ
  - វគ្គបណ្តុះបណ្តាលចំនួន៩លើក
  - វគ្គសិក្ខាសាលាបំប៉នចំនួន៤លើក

- វគ្គបំប៉នចំនួន១លើក
- កិច្ចប្រជុំចំនួន១លើក

– បានធ្វើបច្ចុប្បន្នកម្មក្នុងប្រព័ន្ធអ្នកប្រើប្រាស់(ព័ត៌មានសិស្ស) ចំនួន៩៨សាលា
– បានរៀបចំបញ្ជូនពាក្យសុំចុះឈ្មោះជ្រើសរើសចូលរៀន ក្នុងវគ្គបណ្ដុះបណ្ដាលលើកកម្ពស់គុណវុឌ្ឍិគណៈគ្រប់គ្រងសាលារៀន គ្រូបង្រៀន ថ្នាក់បណ្ឌិត បរិញ្ញាបត្រ និងកម្មវិធី១៥ក្រេឌីត ៣៦ក្រេឌីត នៅសាកលវិទ្យាល័យភូមិន្ទសរុបចំនួន១១៦នាក់ ស្រី៥១
– បានអមដំណើរថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា និងក្រុមការងារគម្រោង STEP-UP របស់ធនាគារADB ពិនិត្យវាយតម្លៃមណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សម្រាប់ឆ្នាំសិក្សា២០២៥-២០២៦ សម័យប្រឡង ១០ សីហា ២០២៦ នៅមណ្ឌលប្រឡងទាំង៣ក្នុងខេត្តកោះកុង ចំនួន១លើក
– បានដឹកនាំយុវជនក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុង ចូលរួមប្រកួតភ្លេងកាយរឹទ្ធិជាតិ លើកទី៣ បន្តដល់វគ្គផ្ដាច់ព្រ័ត្រក្នុងចំណោម១៣ក្រុម មកពីរាជធានី ខេត្ត ចំនួន១លើក
– បានដឹកនាំក្រុមភ្លេងកាយរឹទ្ធិខេត្តកោះកុងហ្វឹកហាត់ជាប្រចាំ សម្រាប់ត្រៀមប្រគុំក្នុងពិធីបុណ្យជាតិ ឬពិធីផ្សេងៗ
– បានរៀបចំការប្រកួតកីឡាសិស្សបឋមសិក្សា២លើក និងមធ្យមសិក្សា១លើក ថ្នាក់ខេត្ត
– បានដឹកនាំក្រុមកីឡាករចូលរួមប្រកួតកីឡាសិស្សបឋមសិក្សា សិស្សមធ្យមសិក្សា ចំនួន២លើក និងការប្រកួតកីឡាទូកប្រពៃណីខ្នាតអន្តរជាតិ១លើក
– បានចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធមេត្រីភាពរវាងសាលាបឋមសិក្សាចរមួយ ក្នុងស្រុកវាលវែង ខេត្តពោធិ៍ចំនួន២លើក
– បានធ្វើទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍ការងារក្នុង និងក្រៅប្រទេសចំនួន៣លើក
– បានសហការជាមួយក្រសួង អង្គការដៃគូ មន្ទីរ-អង្គភាពពាក់ព័ន្ធ ក្នុងការចុះពិនិត្យ និងសង្កេតលើការងារអប់រំសុខភាពសិក្សាចំនួន៦លើក
– បានសហការជាមួយក្រសួង អង្គការដៃគូ មន្ទីរ-អង្គភាពពាក់ព័ន្ធ ក្នុងការចុះពិនិត្យ និងសង្កេតលើការងារអប់រំកុមារតូច ចំនួន៤លើក
– បានសហការចូលរួមជាមួយអង្គការដៃគូ ចុះពិនិត្យលើការគ្រប់គ្រងការងារបណ្ណាល័យចំនួន៣លើក
– បានបូកសរុបលទ្ធផលសិក្សារបស់សិស្ស គិតត្រឹមឆមាសទី១ លទ្ធផលសិស្សជាប់ ៧៩.១០% ធ្លាក់ ១៨.៩៤% សិស្សថយ ១.៩៦% ដោយមានកម្រិតនិទ្ទេស ABC=២៩.២៤% DEF=៧០.៧៦%
– បានបូកសរុបលទ្ធផលសិក្សារបស់សិស្សសាលាឯកជន សិស្សសរុប១,៤៤៩នាក់ ស្រី៧៤៦នាក់ ជាប់មធ្យមភាគ ១,២៦៧នាក់ ស្មើនឹង ១៧.៨៤% ស្រី៦២៥នាក់ ស្មើនឹង៨៣.៧៨%
– បានរៀបចំសន្និបាតបូកសរុបការងារអប់រំ យុវជន និងកីឡាឆ្នាំសិក្សា២០២៤-២០២៥ និងលើកទិសដៅការងារ ឆ្នាំសិក្សា២០២៥-២០២៦ ចំនួន១លើក
– បានចូលរួមជាគណៈមេប្រយោគ និងរៀបចំការប្រឡងផ្សេងៗ ចំនួន៤លើក
– បានប្រគល់វិញ្ញាបនបត្រមធ្យមសិក្សាបឋមភូមិបណ្ដោះអាសន្នតាមឆ្នាំសិក្សានីមួយៗ និងបញ្ជាក់ភាពត្រឹមត្រូវលើវិញ្ញាបនបត្រមធ្យមសិក្សាបឋមភូមិ ជូនអ្នកសិក្សាដែលមានតម្រូវការប្រើប្រាស់
– បានដឹកនាំសិស្សពូកែថ្នាក់ខេត្ត ចូលរួមប្រឡងសិស្សពូកែទូទាំងប្រទេស នៅថ្នាក់ជាតិ សម័យប្រឡង៖ ២៦ មេសា ២០២៦ ចំនួន១លើក
– បានរៀបចំការប្រឡងប្រជែង ការអានអត្ថបទ ស្មូតកំណាព្យ តែងនិពន្ធ និងដឹកនាំបេក្ខជនជាប់ជ័យលាភីថ្នាក់ខេត្តចូលរួមប្រឡងប្រជែងថ្នាក់ជាតិ ចំនួន៣លើក
– បានដឹកនាំសិស្សចូលរួមប្រកួតប្រជែង ការអានអត្ថបទ ស្មូតកំណាព្យ និងផ្នែកតែងនិពន្ធ សម្រាប់អបអរសាទរទិវាជាតិអំណានលើកទី១១ ថ្នាក់ជាតិ ចំនួន១លើក។

### ២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានរៀបចំស្តង់សង្គមកិច្ចសម្រាប់ផ្តល់ព័ត៌មាន និងពិគ្រោះយោបល់ដល់ពលរដ្ឋភៀសសឹក ពិសេសកុមាររងគ្រោះ ដើម្បីលើកកម្ពស់សុខភាពផ្លូវចិត្ត កាត់បន្ថយភាពតានតឹងដល់កុមារចំនួន២៣០នាក់ ស្រី១១០នាក់ ដោយមានការចូលរួមសកម្មភាពពីអង្គការ UofN Koh Kong Cambodia និងអង្គការការីតាស់ខេត្តព្រះសីហនុ បានផ្តល់សម្ភារក្មេងលេង សម្លៀកបំពាក់ និងសម្ភារសិក្សាមួយចំនួនដល់កុមារ និងកុមារកំព្រានៅជំរុំភៀសសឹក
- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ស្វែងរកសាច់ញាតិរបស់កុមារដែលបានវង្វេងសាច់ញាតិ និងបានបញ្ជូនឱ្យទៅរស់នៅជាមួយគ្រួសារវិញចំនួន២នាក់ ស្រី១នាក់
- បានបញ្ជូនជនវិបល្លាសស្មារតី ទៅទទួលសេវាថែទាំព្យាបាលនៅមជ្ឈមណ្ឌលថែទាំ និងស្តារនីតិសម្បទា ជនវិបល្លាសស្មារតី ស្ថិតនៅភូមិបារគូ ឃុំបារគូ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ចំនួន១នាក់ប្រុស
- បានចុះសួរសុខទុក្ខគ្រួសារក្រីក្រ និងកុមារដែលត្រូវបានឳពុកម្តាយធម៌ស្មុំយកមកចិញ្ចឹមចំនួន៣នាក់ ស្រី២នាក់
- បានចុះធ្វើការប៉ាន់ប្រមាណគ្រួសារដែលមានបំណងសុំកូនយកទៅចិញ្ចឹមចំនួន១គ្រួសារ
- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះប៉ាន់ប្រមាណគ្រួសារជនមានសតិមិនប្រក្រតី និងជនអនាថាដែលបង្ករអសន្តិសុខផ្សេងៗនៅតាមទីសាធារណៈ ចំនួន២នាក់ ស្រី១នាក់
- បានសហការជាមួយរដ្ឋបាលក្រុងខេមរភូមិន្ទ រដ្ឋបាលសង្កាត់ស្មាច់មានជ័យ និងរដ្ឋបាលសង្កាត់ដងទង់ ដើម្បីចុះអង្កេតអំពីស្ថានភាពជនអនាថា និងជនវិបល្លាសស្មារតីក្នុងក្រុងខេមរភូមិន្ទ ក្នុងនោះបានស្រង់ទិន្នន័យ ជនអនាថា និងជនវិបល្លាសស្មារតី តាមទីសាធារណៈ មានចំនួន១០នាក់ ស្រី៣នាក់
- បានចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន និងប្រធានសមាគមមនុស្សចាស់ នាំយកថវិការបស់សមាគមមនុស្សចាស់ប្រគល់ជូនគ្រួសារសពដែលជាសមាជិក នៃសមាគមមនុស្សចាស់ចំនួន១គ្រួសារ
- បានចុះសួរសុខទុក្ខ និងណែនាំអំពីការថែទាំសុខភាពដល់កុមាររីរងគ្រោះដោយអំពើរំលោភសេពសន្ថវៈចំនួន២នាក់ ក្នុងនោះមន្ទីរបានផ្តល់ថវិកាមួយចំនួន និងរដ្ឋបាលខេត្តបានផ្តល់គ្រឿងឧបភោគបរិភោគមួយចំនួន
- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះជួបជាមួយជនមានសតិមិនប្រក្រតី ដែលបានវង្វេងផ្ទះ នៅពេលត្រឡប់មកពីជំរុំភៀសសឹកចំនួន២នាក់ស្រី
- បាននាំយកថវិការបស់មន្ទីរ ចូលរួមរំលែកទុក្ខសពជនអនាថា និងគ្រួសារក្រីក្រចំនួន២នាក់ប្រុស
- បានចូលរួមកិច្ចប្រជុំប្រឹក្សាយោបល់ជាមួយស្ត្រី និងកុមារដែលរងគ្រោះ និងរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ កុមារកំព្រា កុមារដែលឳពុកម្តាយជាប់ពន្ធនាគារ កុមារដែលមានម្តាយផ្ទុកមេរោគអេដស៍ និងជំងឺអេសដ៍ និងកុមារបានឆ្លងមេរោគអេសដ៍ពីឳពុកម្តាយ ដែលកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារដ្ឋខេត្ត និងនៅមណ្ឌលជីវិតថ្មីស្ថិតនៅក្នុងបរិវេណវត្តទេពនិមិត្ត (ហៅវត្តថ្មី) ដោយមានកុមារចូលរួមចំនួន២០នាក់ ស្រី១១នាក់ ក្នុងនោះរដ្ឋបាលខេត្តបានផ្តល់គ្រឿងឧបភោគបរិភោគ និងថវិកាមួយចំនួន
- បានសហការជាមួយអង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) និងអាជ្ញាធរមូលដ្ឋាន ដើម្បីសមាហរណកម្មជនរងគ្រោះករណីជួញដូរផ្លូវភេទមកពីប្រទេសចិន ឱ្យត្រឡប់ទៅរស់នៅជុំគ្រួសារវិញចំនួន២នាក់ស្រី
- បានចូលរួមកិច្ចប្រជុំជាមួយប្រតិភូក្រុមការងារកំណែទម្រង់រដ្ឋការ និងវិសហមជ្ឈការ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការចុះត្រួតពិនិត្យ វាយតម្លៃគុណភាពសេវា ការអនុវត្ត មុខងារដែលបានប្រគល់ទៅឱ្យរដ្ឋបាលខេត្ត ក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមាររបស់រដ្ឋ នៅសាលប្រជុំមន្ទីរសង្គមកិច្ចខេត្ត ចំនួន១លើក មានសមាសភាពចូលរួមសរុបចំនួន១៦នាក់ ស្រី៥នាក់
- បានប្រារព្ធខួបលើកទី១៩ ទិវាអតីតយុទ្ធជន និងនិវត្តជនកម្ពុជា ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៦ នៅសាលាស្រុកបូទុមសាគរ មានអ្នកចូលរួមសរុបប្រមាណ៣០០នាក់ ក្នុងនោះ មានអតីតយុទ្ធជន និងនិវត្តជនចំនួន១៧០នាក់ ម្នាក់ៗទទួលបានអង្ករ២៥គីឡូក្រាម មីជាតិ ត្រីខកំប៉ុង ទឹកស៊ីអ៊ីវ និងថវិកាចំនួន៨០.០០០រៀល (ឧបត្ថម្ភដោយ**លោកជំទាវ ឈី វ៉ា អភិបាល** នៃគណៈអភិបាលខេត្ត)

- បានចូលរួមស្តាប់ចម្លើយអនីតិជនទំនាស់នឹងច្បាប់អាយុ១៤ឆ្នាំ ដល់១៧ឆ្នាំ គ្រប់ដំណាក់កាល នៅសាលាដំបូងខេត្ត សរុបចំនួន៥៣នាក់ ស្រី១នាក់
- បានបញ្ជូនរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនទំនាស់នឹងច្បាប់ ទៅសាលាដំបូងខេត្តចំនួន១២នាក់ ស្រី១នាក់
- បានចុះសួរសុទុក្ខ និងតាមដានអនីតិជនទំនាស់នឹងច្បាប់ដែលបានសមាហរណកម្មទៅរស់នៅជាមួយគ្រួសារក្នុងសហគមន៍វិញចំនួន១នាក់ប្រុស
- បានប្រគល់បណ្ណសំគាល់ជនមានពិការភាពដល់មន្ត្រីការិយាល័យសុខុមាលភាពសង្គមចំនួន៤ស្រុក និង១ក្រុងក្នុងខេត្តកោះកុង សរុបចំនួន៨៨បណ្ណ
- បានសម្របសម្រួល និងជំរុញដល់មន្ត្រីបង្គោលកាន់កម្មវិធីកំណត់អត្តសញ្ញាណកម្មជនមានពិការភាពតាម ក្រុង/ស្រុកទាំង៧ ដើម្បីកែសម្រួលទិន្នន័យ និងសម្ភាសន៍ឡើងវិញ
- បានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះសួរសុខទុក្ខ និងផ្តល់កញ្ចប់ឧបត្ថម្ភជូនដល់ជនមានពិការភាពជួបការលំបាកចំនួន១នាក់ស្រី
- បានសហការជាមួយក្រុមការងារមេជ្ឈមណ្ឌលស្តារលទ្ធភាពពលកម្មកាយសម្បទាចំនួន២មជ្ឈមណ្ឌល ដើម្បីចុះផ្តល់សេវាពិនិត្យ និងជួសជុលឧបករណ៍អវយវៈសិប្បនិម្មិត រណប រទេះរុញ និងគ្រឿងជំនួយ ជូនជនមានពិការភាពចំនួន៣លើក ដែលមានជនមានពិការភាពមកទទួលសេវាសរុបចំនួន១១៤នាក់ ស្រី២៨នាក់
- បានសហការជាមួយក្រុមការងារក្រសួង ចុះពិនិត្យ និងវាយតម្លៃលើការអនុវត្តកាតព្វកិច្ចស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ចំនួន២ក្រុមហ៊ុន គឺក្រុមហ៊ុន ហាណា ម៉ាយក្រូ អេឡិកត្រូនិក (ខេមបូឌា) និងក្រុមហ៊ុន ខេមកូ ម៉ូជ័រ ខមភេនី "ខេត្តកោះកុង" ស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេសកោះកុង។

## ២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

### ២.២.៣.១-ការងារ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានធ្វើបច្ចុប្បន្នភាពស្ថិតិសហគ្រាស/គ្រឹះស្ថានក្នុងខេត្តសរុបចំនួន១៤៣ ដែលមានកម្មករនិយោជិតកំពុងបម្រើការងារសរុបចំនួន១៦.៥៦៨នាក់ ស្រី៨.៤៨៣នាក់
- ពលករបរទេសដែលបានស្នើសុំធ្វើបណ្ណការងារចំនួន១.១៧៣នាក់ ស្រី១៤៩នាក់
- បានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងស្តីពីបុគ្គលិក (ចេញ-ចូល) បានចំនួន៨សហគ្រាសគ្រឹះស្ថានរួមមាន៖
    - ចលនាចេញចំនួន២.០៧៣នាក់ ស្រី១.២២១នាក់
    - ចលនាចូលចំនួន២.៦៧៨នាក់ ស្រី១.៨៨៦នាក់
- បានជំរុញដល់រោងចក្រសហគ្រាស គ្រឹះស្ថាននៅក្នុងខេត្តកោះកុង៖
    - ដែលប្រើប្រាស់កម្មករបរទេសអោយទៅធ្វើបណ្ណការងារ និងសៀវភៅការងារឱ្យបានទាន់ពេលវេលា
    - ឱ្យបន្តផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការរីករាលដាលមេរោគអេដស៍ និងប្រយុទ្ធប្រឆាំងការប្រើប្រាស់និងជួញដូរនូវគ្រឿងញៀនដល់កម្មករ និយោជិតឱ្យបានទូលំទូលាយជាប្រចាំ
- បានចុះដោះស្រាយវិវាទរួមចំនួន៥ករណីក្នុងគោលបំណងទាមទារប្រាក់ឈ្នួល៖
    - មានទីតាំងនៅតាពាសាគរ១ករណី(សះជា), នៅតំបន់សេដ្ឋកិច្ចពិសេសចេដាង២ករណី(សះជា) និងព្រែកខ្សាច់១ករណី(កំពុងតែសម្របសម្រួលបន្ត)
    - មានទីតាំងក្នុងតំបន់សេដ្ឋកិច្ចពិសេសចេដាងកោះកុង១ករណី (សះជា)
- បានចុះផ្សព្វផ្សាយតាមបណ្តារោងចក្រ សហគ្រាស គ្រឹះស្ថានអំពី៖
    - ប្រកាសលេខ ៣៥៨/២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម

- ប្រកាសលេខ០១៣/២៦ ស្តីពីការផ្តល់ប្រាក់បន្ថែមបណ្តោះអាសន្នលើសោហ៊ុយធ្វើដំណើរ និងថ្លៃស្នាក់នៅ សម្រាប់បងប្អូនកម្មករនិយោជិតផ្នែកវាយនភណ្ឌកាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិង ការបូបក្នុងអំឡុងពេលនៃវិបត្តិប្រេងឥន្ធនៈជាសាកល
- ប្រកាសលេខ ០១៤/២៦ ស្តីពីការអនុវត្តការឈប់សម្រាកក្នុងពិធីបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំមមី អដ្ឋ ស័ក ព.ស.២៥៧០ គ.ស ២០២៦
- ប្រកាសលេខ ១៧៩/២៦ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើកកម្ពស់លក្ខខណ្ឌ ការងារសម្រាប់កម្មករនិយោជិតវ័យក្មេង នៅក្នុងតំបន់សេដ្ឋកិច្ចពិសេសចេជាងកោះកុង និងតំបន់សេដ្ឋកិច្ច ពិសេសនាងកុកកោះកុង
- ប្រកាសស្តីពីការដាក់ឲ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាម ប្រព័ន្ធស្វ័យប្រវត្តិកម្ម
- សេចក្តីជូនដំណឹងលេខ ០១៧/២៦ ស្តីពីកាតព្វកិច្ចអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធ ស្វ័យប្រវត្តិកម្ម ក្នុងខែឆមាសទី១ឆ្នាំ ២០២៦
- សេចក្តីណែនាំលេខ ០៤៥/២៦ ស្តីពីការជំរុញការប្រើប្រាស់ស្រោមអនាម័យឱ្យបាន១០០% ដើម្បីរួមគ្នា បញ្ចប់ជំងឺអេដស៍
- សេចក្តីណែនាំស្តីពីការអនុវត្តប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិ តស្បែកជើង និងផលិតផលធ្វើដំណើរនិងការបូប សម្រាប់ឆ្នាំ២០២៦ ដល់រដ្ឋបាលរោងចក្រក្នុងតំបន់សេដ្ឋ កិច្ចពិសេសនាងកុក កោះកុង និងតំបន់សេដ្ឋកិច្ចពិសេសចេជាង
- ជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងដល់រោងចក្រ សហគ្រាស គ្រឹះស្ថាននៅក្នុងតំបន់សេដ្ឋកិច្ច ពិសេសចេជាងកោះកុង និងតំបន់សេដ្ឋកិច្ចពិសេសនាងកុកកោះកុង

ការផ្សព្វផ្សាយនេះមានគោលបំណងជំរុញឱ្យរោងចក្រ សហគ្រាស គ្រឹះស្ថានទាំងអស់យល់ដឹង និងអនុវត្តតាម បទប្បញ្ញត្តិពាក់ព័ន្ធឱ្យបានត្រឹមត្រូវ និងមានប្រសិទ្ធភាព

- បានធ្វើយុទ្ធនាការចុះផ្សព្វផ្សាយដល់ទីតាំងស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ និងលើក កម្ពស់ការងារសមស្របសម្រាប់យុវជននៅតាមទីតាំងកសិ-ឧស្សាហកម្មចំនួន៣ក្រុមហ៊ុនដូចខាងក្រោម៖
  - កោះកុង ផ្លេនថេសិន ខមភេនី លីមីតធីត ស្ថិតក្នុងស្រុកស្រែអំបិល
  - កោះកុង រ៉ាប់ប៊ឺរ ផ្លេនថេសិន ស្ថិតក្នុងស្រុកគិរីសាគរ
  - ស៊ី អិន អេស៊ា អេហ្គ្រីខលឈ័រ ស្ថិតក្នុងស្រុកបូទុមសាគរ មានអ្នកចូលរួមសរុប២១៦នាក់ ស្រី៩២នាក់
- បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងលើកទិសដៅការងារបន្ត ដែលមន្ទីរការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកោះកុង បានសហការជាមួយ វិទ្យាស្ថានពហុបច្ចេកទេសខេត្តកោះកុង និងបេឡា ជាតិសន្តិសុខសង្គមសាខាខេត្ត នៅសាលប្រជុំបេឡាជាតិសន្តិសុខសង្គមសាខាខេត្តកោះកុង មានសមាសភាព ចូលរួមសរុបប្រមាណ៧០នាក់
- បានរៀបចំពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៤០ នៃទិវាពលកម្មអន្តរជាតិ ១ ឧសភា ឆ្នាំ២០២៦ ក្រោម ប្រធានបទ «រួមគ្នាកសាងភាពធន់ដើម្បីការងារសមរម្យ» នៅរោងចក្រយ៉ាហ្សាគី ក្នុងតំបន់សេដ្ឋកិច្ចពិសេស នាងកុកកោះកុង អ្នកចូលរួមប្រមាណជាង២៨០នាក់
- បានសហការជាមួយមូលនិធិក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងការរៀបចំវគ្គបណ្តុះបណ្តាលស្តីពី "នីតិវិធីដោះស្រាយ វិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល និងបច្ចេកទេសក្នុងការរៀបចំសំណុំរឿង" អ្នកចូលរួមសរុបចំនួន ៣០នាក់ ស្រ្តី១២នាក់ នៅសាលប្រជុំ ប.ស.ស

- បានណែនាំដល់រដ្ឋបាលរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសនាងកុក កោះកុង និងតំបន់សេដ្ឋកិច្ចពិសេសចេដាង យកចិត្តទុកដាក់ដល់កម្មករដែលមានផ្ទៃពោះចាប់ពីបីខែអោយចេញមុនម៉ោង១៥នាទី និងជំរុញឱ្យពួកគាត់ទៅពិនិត្យផ្ទៃពោះតាមការកំណត់របស់រាជរដ្ឋាភិបាល
- បានណែនាំបន្ថែមស្តីពីការពង្រឹងវិធានការលើកកម្ពស់សុវត្ថិភាព និងសុវត្ថិភាពការងាររបស់ កម្មករនិយោជិតក្នុងអំឡុងពេលមានការប្រែប្រួលអាកាសធាតុក្នុងរដូវប្រាំង ដល់រដ្ឋបាលរោងចក្រក្នុងតំបន់សេដ្ឋកិច្ចពិសេសនាងកុកកោះកុង
- រោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន៧បានអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង និងមានអ្នកចូលរួមចំនួនសរុប ១៨៥នាក់ ស្រី៩២នាក់។

### ២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បានចុះតាមដាន ផ្សព្វផ្សាយ និងបណ្តុះបណ្តាលសេវាសន្តិសុខសង្គមទាំងបួនផ្នែកដូចជា៖ ផ្នែកហានិភ័យការងារ ផ្នែកថែទាំ ផ្នែកសោធន (បង់ភាគទានផ្នែកសោធនស្ម័គ្រចិត្ត) និងស្វ័យនិយោជន៍ មានដូចខាងក្រោម ៖
  - បានធ្វើបច្ចុប្បន្នភាពសហគ្រាស/គ្រឹះស្ថាន ដែលបានជាប់ភាគទានឆមាសទី១ ឆ្នាំ២០២៦ មានចំនួន ២០៣សហគ្រាស/គ្រឹះស្ថាន សមាជិកសរុបចំនួន១៨.៣៤០នាក់ ស្រី១០.០៥៦នាក់
  - បានចុះបញ្ជីសមាជិកដែលជាបុគ្គលស្វ័យនិយោជន៍ និងបានបង់ភាគទានចំនួន៤.២១៧នាក់ ស្រី ២.៦៧៦នាក់ និងសមាជិកផ្នែកប្រាក់សោធនតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន២០នាក់ ស្រី១១នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកហានិភ័យការងារទទួលបានតាវកាលិកចំនួន២៣នាក់ ស្រី១៣នាក់
  - បានសម្របសម្រួលជូនជនរងគ្រោះផ្នែកថែទាំសុខភាព ទទួលបានតាវកាលិកចំនួន២៩២នាក់ ស្រី២៥៣នាក់
  - បានសម្របសម្រួលដល់សមាជិក ប.ស.ស ទាំងវិស័យសាធារណៈ និងវិស័យឯកជនជាស្ត្រីទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលមុនសម្រាល និងក្រោយសម្រាលកូនចំនួន៣.៥០៣នាក់
  - បានធ្វើបណ្ណទុតិយតាវិស័យឯកជនចំនួន៥២៦នាក់ ស្រី៣២៧នាក់
  - បានចុះបញ្ជិកាសមាជិក ប.ស.ស វិស័យឯកជន(កម្មករ)ចំនួន៣.០៥៥នាក់ ស្រី១.៦៨៦នាក់ បុគ្គលស្វ័យនិយោជន៍ចំនួន១.២៦៤នាក់ ស្រី៧៦៩នាក់ និងអ្នកក្នុងបន្ទុកចំនួន១៤៤នាក់ ស្រី៧៣នាក់
  - បានចុះបញ្ជិកាសមាជិក ប.ស.ស ជាមន្ត្រីសាធារណៈមានចំនួន៩៥នាក់ ស្រី៣៦នាក់ និងអ្នកក្នុងបន្ទុក ចំនួន២៩៣នាក់ ស្រី១៧៨នាក់។

## ២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- ការតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច វត្ថុជាតិពន្ធ និងអនុផលព្រៃឈើមួយចំនួន នៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្តកោះកុង មានភ្ញៀវចូលទស្សនាចំនួន៣០១នាក់ ស្រី១៦៣នាក់
- ភ្ញៀវចូលទស្សនាស្ថានីយអូរកីចំនួន១២០នាក់ (បរទេស) និងស្ថានីយភ្នំពៃលចំនួន១៨៥នាក់ (ខ្មែរ១០នាក់)
- បានចុះធ្វើបច្ចុប្បន្នភាពបុរាណស្ថានចេតិយ ដោយបានរៀបចំវត្ថុសិល្បៈ ព្រមទាំងបានកល់កំណល់វត្ថុសិល្បៈឱ្យមានលំនឹងល្អ បុរាណស្ថាន ថតរូប ស្ថិតនៅភូមិជីខលើ ឃុំជីខលើ ស្រុកស្រែអំបិល
- បានចុះធ្វើបច្ចុប្បន្នភាពបុរាណស្ថានភ្នំតាម៉ៅ ស្ថិតនៅភូមិទ័ពឃ្លេ ឃុំប្រឡាយ ស្រុកថ្មបាំង និងរៀបចំបរិវេណបុរាណស្ថានដែលរុំព័ទ្ធវត្ថុសិល្បៈ វាស់ទំហំ ថ្លឹងទម្ងន់ និងថតរូបវត្ថុសិល្បៈក្នុងបុរាណស្ថាន ដើម្បីទុកធ្វើបញ្ជីសារពើភណ្ឌវត្ថុបុរាណក្រៅឃ្លាំងនាពេលខាងមុខ
- ចុះធ្វើបច្ចុប្បន្នភាព និងពិនិត្យវត្ថុសិល្បៈក្នុងស្ថានីយ ដូចខាងក្រោម៖
  - ស្ថានីយភ្នំពៃល ស្ថិតនៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង
  - ស្ថានីយអូរកី ស្ថិតនៅភូមិជាំស្លា ឃុំជីផាត ស្រុកថ្មបាំង

- បានចុះពិនិត្យស្ថានភាពចេតិយយុនឆាង ទីលានទាត់សីយុនឆាងយុនផែន ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- បានចុះសម្ភាសន៍លោកស្រី សូម ឈាន អាយុ៥៩ឆ្នាំ មានចំណេះជំនាញដេរស្លឹកផ្តាំ ដើម្បីប្រក់រោងឬផ្ទះ ជារបៀបបុរាណ ស្ថិតនៅភូមិត្រពាំងខ្នារ ឃុំតាទៃលើ ស្រុកថ្មបាំង
- បានថតរូប និងត្រាំទឹកដកជាតិអំបិល វត្ថុបុរាណដែលទទួលបានពីប្រជាពលរដ្ឋ និងស្រង់វត្ថុសិល្បៈដែលត្រាំទឹកដកជាតិអំបិលទុកឱ្យស្ងួតដើម្បីពង្រឹងស្រទាប់រលោងចំនួន៩វត្ថុ
- បានរៀបចំប្តូរកញ្ច្រែងថ្មីដែលដាក់បំណែកកុលាលភាជន៍នៅឃ្លាំងការិយាល័យសារមន្ទីរ
- បានសរសេរអក្សរលើវត្ថុសិល្បៈសរសេរលេខកាត និងថតរូបវត្ថុសិល្បៈចំនួន៩វត្ថុ
- បានធ្វើតារាងស្ថិតិវត្ថុបុរាណក្រៅឃ្លាំងតាមទីតាំងដែលមិនទាន់បានចុះបញ្ជី ជូននាយកដ្ឋានបុរាណវត្ថុ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានចុះមើលកិច្ចសែនអ្នកតាចំនួន២លើក នៅភូមិត្រពាំងខ្នារ ឃុំតាទៃលើ និងភូមិច្រកឫស្សី ឃុំជំនាប់ និងបានចូលរួមពិធីចាប់ត្រីរបស់ជនជាតិដើមភាគតិចជង នៅភូមិជំនាប់ ឃុំជំនាប់ ស្រុកថ្មបាំង
- បានចុះសិក្សាចងក្រងប្រវត្តិគ្រឹះប្រាសាទបុរាណ នៅវត្តអង្គរភ្នំខ្លុង ស្រុកស្រែអំបិល
- បានរៀបចំកិច្ចប្រជុំស្តីពីបញ្ហាដីបុរាណ ដែលត្រូវកំណត់ដែនការពារ និងវាស់វែងក្នុងភូមិសាស្ត្រខេត្តកោះកុង ដែលមានការសម្របសម្រួលពីរដ្ឋបាលខេត្តកោះកុង និងចូលរួមពីមន្ទីរនិងរដ្ឋបាលស្រុក ដែលពាក់ព័ន្ធ
- បានចុះស្រង់ទិន្នន័យសាស្ត្រាស្លឹករិត បានចំនួន៣ស្រុក៖
  - ស្រុកស្រែអំបិលចំនួន៥វត្ត គឺវត្តមាគ៌ាគិរីស្រែអំបិល វត្តសាលាម្នាង វត្តរស្មីសាមគ្គីគិរីទ័ពជាង វត្តអង្គត្នោត (ហៅវត្តដងពែង) និងវត្តមុនីជីខលើ (ហៅវត្តជីខលើ) សរុបចំនួនស្លឹករិត៧ខ្សែ វាន៦៩ក្បាល ក្រាំង១០ក្បាល សៀវភៅព្រះត្រៃបិដក៧៤៧ក្បាល និងអបិកថា៥៧០ក្បាល
  - ស្រុកកោះកុងចំនួន១វត្ត គឺវត្តពោធិគិរីមនោរម្យ (វត្តតាតៃ) ស្ថិតនៅភូមិអន្លង់វ៉ាក់ ឃុំតាតៃ ស្រុកកោះកុង
  - ស្រុកមណ្ឌលសីមា វត្តរុក្ខសិលារាម(វត្តតាចាត) ស្ថិតនៅភូមិតាចាត ឃុំទួលគគីរ ស្រុកមណ្ឌលសីមា
- បានចុះស្រង់ទិន្នន័យសម្ពាងការនៅក្នុងក្រុងខេមរភូមិន្ទ បានចំនួន៦ទីតាំង
- បានចុះស្រង់ស្ថិតិ និងធ្វើបច្ចុប្បន្នភាពបណ្ណាគារនិងតូបលក់សៀវភៅ ក្នុងក្រុងខេមរភូមិន្ទ ក្នុងនោះមានតូបលក់សៀវភៅថ្មី២ និងកាហ្វេរីដេអូភាពយន្តចំនួន៤ទីតាំង ជាអាជីវកម្មចាស់ នៅបើកដំណើរការធម្មតា ក្នុងនោះមានក្រុងខេមរភូមិន្ទចំនួន៣អាជីវកម្ម និងស្រុកមណ្ឌលសីមាចំនួន១អាជីវកម្ម
- បានផ្តល់សេវានៅការិយាល័យច្រកចេញ-ចូលតែមួយក្រុងខេមរភូមិន្ទ ចំនួន៤សេវា គឺលើកស្លាកយីហោ
- បានចុះស្រង់ទិន្នន័យជាងទងនៅក្នុងផ្សារដងទង់ បានចំនួន៣៧ទីតាំង
- បានចុះត្រួតពិនិត្យ តាមដាន និងស្រង់ទិន្នន័យសិល្បៈសូនរូប និងសិប្បកម្ម៖
  - ក្រុងខេមរភូមិន្ទ បានចំនួន៦ទីតាំង និងអាជីវករបានបិទចំនួន១ទីតាំង
  - ស្រុកស្រែអំបិល បានចំនួន១០ទីតាំង
- បានចុះត្រួតពិនិត្យ តាមដាន សិប្បកម្មធ្វើគ្រឿងសង្ហារឹមចំនួន៣ទីតាំង និងទីតាំងផលិតឥដ្ឋស៊ីម៉ង់ បានបិទ១ទីតាំង នៅសង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
- បានចុះស្រង់ទិន្នន័យចម្លាក់ឈើចំនួន២ទីតាំង នៅសង្កាត់ស្មាច់មានជ័យ និងសង្កាត់ស្ទឹងវែង
- បានចុះស្រង់ទិន្នន័យសិប្បកម្មធ្វើពីរុក្ខជាតិចំនួន១១ទីតាំង នៅសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- បានចុះផ្សព្វផ្សាយសេចក្តីប្រកាសរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈលេខ១៧២ បានចំនួន១ទីតាំង
- បានចុះផ្សព្វផ្សាយនិងបំផុសស្មារតីដល់សិស្សានុសិស្ស ឱ្យចូលរួមលេល្បែងប្រជាប្រិយខ្មែរ អំឡុងពេលមុនចូលឆ្នាំថ្មី ប្រពៃណីជាតិ ចំនួន៤សាលា គឺវិទ្យាល័យចំណេះទូទៅនិងបច្ចេកទេសតេជោសែនកោះកុង, អនុវិទ្យាល័យជាស៊ីមស្មាច់មានជ័យ, វិទ្យាល័យហ៊ុនសែនចាំយាម និងសាលាបឋមសិក្សាមណ្ឌលសីមា

- បានចុះស្រង់ទិន្នន័យលើកស្លាកយីហោថ្មី នៅក្នុងក្រុងខេមរភូមិន្ទចំនួន២១ទីតាំង និងនៅក្នុងស្រុកមណ្ឌលសីមាចំនួន១២ទីតាំង
- បានចុះស្រាវជ្រាវភ្លេងការក្នុងខេត្តកោះកុង ដោយបានសម្ភាសន៍អាចារ្យ អ្នកផ្លុំ អ្នកភ្លេង និងអ្នកចម្រៀង
- បានចុះផ្សព្វផ្សាយស្តីពីមហោស្រពសិល្បៈថ្នាក់ខេត្តឆ្នាំ២០២៦ តាមបណ្តាសាលារដ្ឋ និងសាលាឯកជន បានចំនួន១៣សាលា
- បានបង្ហាត់ក្បាច់បាត និងរបាំថ្វាយព្រះពរដល់សិស្ស នៅរៀងរាល់ថ្ងៃអាទិត្យ ចំនួន៣៨នាក់ (ប្រុស៥នាក់)
- បង្ហាត់ក្បាច់បាត និងរបាំគោះត្រឡោក ដល់សិស្សនៅមជ្ឈមណ្ឌលកុមារកំព្រាខេត្តកោះកុង ហាត់ចំនួន៣ថ្ងៃក្នុងមួយសប្តាហ៍ ចំនួន១១នាក់(ប្រុស៥នាក់)
- បានបង្ហាត់របាំជូនពរ របាំគោះត្រឡោក របាំទិវាប្រពៃ និងចម្រៀងកាយវិការ ដល់សិស្សត្រៀមសម្តែងក្នុងទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៨ ឆ្នាំ២០២៦
- បានសហការជាមួយរដ្ឋបាលខេត្តកោះកុង រៀបចំប្រារព្ធទិវាវប្បធម៌ជាតិ ៣មីនា លើកទី២៨ ឆ្នាំ២០២៦ នៅសាលមហោស្រពខេត្តកោះកុង
- បានសម្តែងរបាំជូនពរ របាំខ្លាក្តាម ក្នុងកម្មវិធីអបអរសាទរពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ ស្តូបអនុស្សាវរីយ៍នយោបាយឈ្នះ ឈ្នះកោះកុង។

### ២.២.៥-ការងារព័ត៌មាន

- អ្នកសារព័ត៌មានមកយកព័ត៌មានក្នុងខេត្តកោះកុងសរុបចំនួន១នាក់ ក្នុងនោះ មកពីអង្គភាពសារព័ត៌មានNINA NEWS
- បានពិនិត្យ និងផ្តល់សេវាបើក និងផ្តល់ថ្មី ជូនអតិថិជនដើម្បីផ្សព្វផ្សាយពាណិជ្ជកម្ម តាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន៣០សេវា រួមមាន ផ្ទាំងប៉ាណូ១៦សេវា អាហ្វីស១៤សេវា
- **ការចុះជំរុញយកព័ត៌មានតាមរយៈការថតវីដេអូ បានចំនួន១៧៤ព័ត៌មាន និងបានផ្សាយ ៖**
    - តាមរយៈទូរទស្សន៍ជាតិកម្ពុជា (ទទក) បានចំនួន៧៣ព័ត៌មាន
    - តាមរយៈទូរទស្សន៍បាយ័នបានចំនួន១០១ព័ត៌មាន
    - រាយការណ៍ជូនគ្រុបព័ត៌មាន និងសាធារណមតិរបស់ក្រសួងព័ត៌មានបានចំនួន៩៦១ព័ត៌មាន
- **ផ្សាយបន្តផ្ទាល់ពីវិទ្យុជាតិ៖**
    - ព័ត៌មានជាតិបានចំនួន២.៧៨៦ព័ត៌មាន
    - ព័ត៌មានអន្តរជាតិបានចំនួន៨១៩ព័ត៌មាន
    - ព័ត៌មានពីវិទ្យុជាតិចំនួន២៤ព័ត៌មាន
    - កម្មវិធីសន្ទនាមតិ "ជីវិតយើងសង្គមយើង" បានចំនួន១០២លើក
    - កម្មវិធីសុវត្ថិភាពចរាចរណ៍ផ្លូវគោកចំនួន១៦លើក
- **ព័ត៌មានផ្សាយរបស់វិទ្យុសាគរកោះកុង៖**
    - ព្រឹត្តិការណ៍សំខាន់ៗចំនួន៨ព័ត៌មាន
    - សន្និសីទសារព័ត៌មានចំនួន៨ព័ត៌មាន
    - ព័ត៌មានក្នុងខេត្តចំនួន១៣០ព័ត៌មាន
    - ព័ត៌មានជាតិចំនួន១៩៨ព័ត៌មាន
    - ព័ត៌មានអន្តរជាតិចំនួន១៨៩ព័ត៌មាន
    - ព័ត៌មានពេលព្រឹកចំនួន២១០ព័ត៌មាន
    - ព័ត៌មានថតផ្សាយជាសំឡេងចំនួន៣៧០ព័ត៌មាន

- សេចក្តីជូនដំណឹងផ្សេងៗចំនួន៣៩អត្ថបទ
- នាទីព្រះពុទ្ធសាសនាចំនួន៩០ម៉ោង
- នាទីកម្សាន្តមរតកដើមរួមមាន អាយ៉ៃ យីកេ ល្ខោនបាសាក់ និងល្ខោននិយាយចំនួន១៨០ម៉ោង

– **អំពីការផ្សាយតាមរយៈបណ្តាញសង្គមនានារបស់មន្ទីរព័ត៌មានខេត្ត ៖**
- ផ្សាយតាមរយៈផេកហ្វេសប៊ុកមន្ទីរព័ត៌មានខេត្តកោះកុងចំនួន១.៤៤៥ព័ត៌មាន
- ផ្សាយតាមរយៈផេកហ្វេសប៊ុកវិទ្យុសាគរកោះកុងចំនួន១.៨៤៧ព័ត៌មាន
- ផ្សាយតាមរយៈផេកហ្វេសប៊ុកទូរទស្សន៍ជាតិខេត្តកោះកុងសរុបចំនួន១.៥៩៣ព័ត៌មាន
- ផ្សាយប្រសាសន៍សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចធិបតី ហ៊ុន ម៉ាណែត ចំនួន ២០៧លើក
- ផ្សាយព័ត៌មានដែលបានផលិតចំនួន៣៧០ព័ត៌មាន
- ផ្សាយព័ត៌មានបន្ត សេចក្តីជូនដំណឹង និងលិខិតបទដ្ឋានផ្សេងៗចំនួន១.០១៦លើក

– **ឆ្លើយឆ្លងព័ត៌មានពេលព្រឹក និងរាយការណ៍គ្រឿងញៀនតាមវិទ្យុសាគរកោះកុង ៖**
- ព័ត៌មានតាមWhatsApp ជូនលេខាធិការដ្ឋាន នៃគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្ត ចំនួន ១៣៤លើក
- ព័ត៌មានតាមហ្វេសប៊ុកចំនួន៤៣លើក

– **ផ្សព្វផ្សាយសារអប់រំ និងស្ប៉ូតៈ**
- សារអប់រំ និងស្ប៉ូតស្តីពីគ្រោះថ្នាក់នៃគ្រឿងញៀនបានចំនួន៣,៦00លើក
- សារអប់រំ និងស្ប៉ូតស្តីពីពិសាគ្រឿងស្រវឹងសូមកុំបើកបរ និងច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន៣.៦00លើក
- សារអប់រំអំពីបញ្ហាជំងឺអេដស៍បានចំនួន១.៨០០លើក
- សារអប់រំអំពីជំងឺគ្រុនចាញ់បានចំនួន១.៨០០លើក
- ស្ប៉ូតសុខភាព (ញ៉ាំសាប) បានចំនួន៩០០លើក
- ស្ប៉ូតស្តីពី ការបញ្ឈប់អំពើហិង្សាលើស្ត្រីបានចំនួន១.៨០០លើក
- ស្ប៉ូតអប់រំក៏ដូចជាវិធីការពារជំងឺកូវីដ-១៩ បានចំនួន២.៧០០លើក
- សារអប់រំស្តីពី ការជួញដូរមនុស្សជាអំពើខុសច្បាប់បានចំនួន១.០៨០លើក
- ស្ប៉ូតអប់រំស្តីពី វិធានការការពារជំងឺអឹមផក (M POX) បានចំនួន៩០០លើក
- ស្ប៉ូតអប់រំស្តីពី ឆ្លាតវៃមិនប្រើប្រាស់ផលិតផលថែទាំសុខភាពអនឡាញបានចំនួន៩០០លើក
- ស្ប៉ូតអប់រំស្តីពី គ្រឿងស្រវឹងមិនមានកម្រិតសុវត្ថិភាពបានចំនួន៩០០លើក
- ស្ប៉ូតអប់រំស្តីពី យើងកាត់បន្ថយការទទួលទានអំបិល ដើម្បីបង្ការជំងឺលើសសម្ពាធឈាម និងគ្រោះថ្នាក់សរសៃឈាមខួរក្បាលបានចំនួន៩០០លើក
- ស្ប៉ូតអប់រំស្តីពី គិតដល់ជីវិតអ្នក និងអ្នកដទៃ ស្រវឹងសូមកុំបើកបរបានចំនួន៩០០លើក
- ស្ប៉ូតរបស់ក្រសួងសុខាភិបាល ស្តីពីការប្រើប្រាស់ប័ណ្ណសមធម៌ (ប.ស.ស) បានចំនួន៣៦០លើក
- ស្ប៉ូតកូវីដបានចំនួន៣៦០លើក
- ស្ប៉ូតរូបភាពណែនាំពីជំងឺកូវីដ-១៩ បានចំនួន៣៦០លើក
- ស្ពតស្តីពី ព័ត៌មានក្លែងក្លាយ ដកស្រង់ចេញពីទូរទស្សន៍ជាតិបានចំនួន១.២៦០លើក
- ស្ពតស្តីពី ព័ត៌មានក្លែងក្លាយផលិតដោយមន្ទីរព័ត៌មានខេត្តបានចំនួន១៩៨ឃ្លីប

– **ទីភ្នាក់ងារសារព័ត៌មានកម្ពុជាៈ**
- បានបញ្ជូនព័ត៌មានជូនអគ្គនាយកដ្ឋានទីភ្នាក់ងារសារព័ត៌មានកម្ពុជានៃក្រសួងព័ត៌មាន ដើម្បីផ្សព្វផ្សាយតាម APP ចំនួន១២៦ព័ត៌មាន

- បានចុះថតយកព័ត៌មានចំនួន៤៣លើក
- បានផ្សាយព័ត៌មានតាមរយៈផេកហ្វេសប៊ុក AKP នៃមន្ទីរព័ត៌មានខេត្តចំនួន៣៤២ព័ត៌មាន

– **ការងារព័ត៌មាននិងសាធារណមតិ៖**
- បានផលិតឃ្លីបព័ត៌មានសរុបចំនួន៣៩៧ព័ត៌មាន
- បានសម្រង់ព័ត៌មានជូនថ្នាក់ដឹកនាំក្រសួងព័ត៌មាននិងរដ្ឋបាលខេត្តកោះកុងសរុបចំនួន៩៥៤ព័ត៌មាន
- បានវាយត្រាលើព័ត៌មានក្លែងក្លាយសរុបចំនួន៣២ព័ត៌មាន។

**២.២.៦-ការងារកិច្ចការនារី**

– បានដឹកនាំស្ត្រី៣រូបមកពីសហគមន៍ផលិតចេកឆាប ស្រុកថ្មបាំង ទៅទស្សនកិច្ចសិក្សាចំនួន១លើក នៅសិប្បកម្មខេត្តកណ្តាល ក្នុងគោលបំណង ដកស្រង់បទពិសោធន៍ពីដំណើរការនៃការផលិតចេកឆាបស្វែងយល់ពីវិធីរក្សាគុណភាពចេកឆាបឱ្យបានយូរ និងការវេចខ្ចប់ឱ្យកាន់តែមានសោភ័ណ្ឌភាព ដើម្បីមកចែករំលែកចំណេះដឹងបន្តដល់ក្រុមស្ត្រីក្នុងសហគមន៍ នៅស្រុកថ្មបាំង

– បានចុះទស្សនកិច្ចក្រុមស្ត្រីធ្វើកាបូប និងវត្ថុអនុស្សាវរីយ៍ ច្នៃពីខ្សែព្រួរ និងមងចាស់ៗ ចំនួន១លើក នៅឃុំកោះស្តេច ស្រុកគិរីសាគរ ក្នុងគោលបំណង ស្វែងយល់ពីដំណើរការនៃការផលិតការកែច្នៃ និងជួយរកទីផ្សារជូនពួកគាត់បន្ថែមតាមរយៈការផ្សព្វផ្សាយដល់ភ្ញៀវទេសចរណ៍ជាដើម

– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើអំបោសស្មៅត្រែងដល់ស្ត្រីក្រីក្រ និងក្មេងស្រីបោះបង់ការសិក្សា ចំនួន១លើក មានអ្នកចូលរួមសរុប១៦នាក់ ស្រី១៤នាក់ នៅមន្ទីរកិច្ចការនារីខេត្ត ក្នុងគោលបំណង ផ្តល់ជំនាញបំនិនជីវិតដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងក្មេងស្រី តាមសហគមន៍ ឱ្យគាត់យកចំណេះ និងជំនាញដែលទទួលបាន ទៅប្រកបរបរដើម្បីបង្កើនប្រាក់ចំណូលក្នុងគ្រួសារ

– បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការធ្វើផែនការអាជីវកម្មខ្នាតតូច ដល់អាជីវករ និងកសិករចំនួន១លើក នៅភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង មានអ្នកចូលរួមចំនួន២៥នាក់ ស្រី២២នាក់ ក្នុងគោលបំណង បង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការកត់ត្រាចំណូល-ចំណាយ សម្រាប់គ្រប់គ្រងអាជីវកម្មឱ្យទទួលបានជោគជ័យ

– បានរៀបចំការផ្សព្វផ្សាយស្តីពីការលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដល់សិស្សានុសិស្ស ចំនួន១លើក មានអ្នកចូលរួមសរុប៧០នាក់ ស្រី៣៦នាក់ នៅវិទ្យាល័យ ហ៊ុន សែន ប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ក្នុងគោលបំណង រួមចំណែកធ្វើឱ្យប្រសើរឡើងនូវសីលធម៌សង្គម តាមរយៈការអប់រំដល់សិស្សានុសិស្សពីសីលធម៌រស់នៅក្នុងសង្គមឱ្យមានលក្ខណៈល្អប្រសើរ

– បានរៀបចំវេទិកាផ្សព្វផ្សាយស្តីពី «សារៈសំខាន់នៃកិច្ចការពារកុមារ ដល់ប្រជាពលរដ្ឋ» ក្រោមអធិបតីភាព **លោកជំទាវ ចេង វន្នី** ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ចំនួន២លើក មានអ្នកចូលរួមសរុប១១៥នាក់ ស្រី៨៩នាក់ នៅភូមិកោះប៉ោ និងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ក្នុងគោលបំណងលើកកម្ពស់ការយល់ដឹង និងផ្លាស់ប្តូរឥរិយាបថសង្គម ក្នុងការប្រព្រឹត្តបែបវិជ្ជមានចំពោះកុមារគ្រប់ទីកន្លែង

– បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី «សុខភាពអាហារូបត្ថម្ភរបស់ស្ត្រី និងកុមារ» ដល់ប្រជាពលរដ្ឋ ក្រោមអធិបតីភាព **លោកជំទាវ ចេង វន្នី** ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្តចំនួន២លើក នៅភូមិដីទំនាប ឃុំត្រពាំងរូង និងភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង មានអ្នកចូលរួមសរុប៩៥នាក់ ស្រី៨៣នាក់

– បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី «ការលើកកម្ពស់សុខភាព អាហារូបត្ថម្ភ សម្រាប់ស្ត្រី និងក្មេងស្រី» ដល់ការិយាល័យពាក់ព័ន្ធថ្នាក់ស្រុក អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អ្នកទ្រទ្រង់សុខភាពភូមិ និងប្រជាពលរដ្ឋចំនួន១លើក នៅឃុំតាតៃក្រោម ស្រុកកោះកុង សរុប៤១នាក់ ស្រី២៤នាក់ ក្នុងគោលបំណង ជម្រុញការិយាល័យពាក់ព័ន្ធ អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អ្នកទ្រទ្រង់សុខភាពភូមិ និងមេភូមិ-អនុភូមិ ក្នុងការ

ជានាប្រសិទ្ធភាព និងបន្តផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋ ជាពិសេសស្ត្រី និងក្មេងស្រីឱ្យយកចិត្តទុកដាក់ទៅលើអាហារូបត្ថម្ភឱ្យបានគ្រប់គ្រាន់ និងទៅទទួលសេវាសុខភាព នៅតាមមន្ទីរពេទ្យ មណ្ឌលសុខភាព ឬប៉ុស្តិ៍សុខភាព

- បានសម្របសម្រួល និងប្រឹក្សាយោបល់ ករណីអំពើហិង្សាក្នុងគ្រួសារ ចំនួន២ករណី (ក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា)
- បានស្នើសុំមេធាវី នៃគណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា ជួយការពារក្តីជូនជនរងគ្រោះ១ករណី (ប៉ុនប៉ងរំលោភ និងរំលោភសេពសន្ថវៈជាមួយអនីតិជនក្រោមអាយុ១៥ឆ្នាំ) នៅភូមិ១ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ។ បច្ចុប្បន្ន ជនសង្ស័យត្រូវបានឃុំខ្លួន និងបញ្ជូនសុំណុំរឿងទៅសាលាដំបូងខេត្ត ដើម្បីដំណើរការតាមនីតិវិធីបន្ត
- បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយស្តីពីការផ្តល់ជំនួយផ្នែកច្បាប់ ជូនស្ត្រីក្រីក្រ និងក្មេងស្រីងាយរងគ្រោះ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ក្រោមជំនួយឧបត្ថម្ភរបស់រាជរដ្ឋាភិបាលកម្ពុជា ដល់ការិយាល័យពាក់ព័ន្ធ ចំនួន២លើក នៅស្រុកថ្មបាំង និងស្រុកកោះកុង មានអ្នកចូលរួមសរុប១០២នាក់ ស្រី៦៥នាក់។ ជាលទ្ធផល អ្នកពាក់ព័ន្ធថ្នាក់ស្រុក ឃុំ បានយល់ដឹងបន្ថែមអំពីសេវាមេធាវីជួយការពារក្តីជូនស្ត្រី និងក្មេងស្រីក្រីក្រ និងកិច្ចការពារជនរងគ្រោះ និងជម្រុញឱ្យគាត់ជួយផ្សព្វផ្សាយបន្ត
- បានរៀបចំវគ្គបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព គ.ក.ស.ក ក្រុង/ស្រុក និង គ.ក.ន.ក ឃុំ/សង្កាត់ ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារសម្រាប់រដ្ឋបាលក្រុង ស្រុកទាំង៧ នៃខេត្តកោះកុង មានអ្នកចូលរួមសរុប១៩៦នាក់ ស្រី១២៣នាក់។ គោលបំណងជម្រុញដល់សាលាបឋមសិក្សានីមួយៗក្នុងការអភិវឌ្ឍសមត្ថភាព ការផ្សារភ្ជាប់ទំនាក់ទំនង និងកិច្ចសហការឱ្យកាន់តែប្រសើរឡើងរវាងយន្តការកិច្ចការពារកុមារនៅក្នុងសាលារៀន និងយន្តការកិច្ចការពារកុមារនៅក្នុងសហគមន៍
- បានរៀបចំពិធីសំណេះសំណាលខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៦ ក្រោមប្រធានបទ « សន្តិសុខ និងសន្តិភាពសម្រាប់ស្ត្រី និងគ្រួសារ » ក្រោមអធិបតីភាព **ឯកឧត្តម ថុង ណារ៉ុង** ប្រធានក្រុមប្រឹក្សាខេត្ត និងលោកជំទាវ និង **លោកជំទាវ ឈី វ៉ា អភិបាល** នៃគណៈអភិបាលខេត្ត និងស្វាមី នៅសាលមហោស្រពខេត្ត ដែលមានអ្នកចូលរួមសរុប២៥០នាក់ ស្រី២០៩នាក់
- បានរៀបចំកិច្ចប្រជុំប្រឹក្សាយោបល់ជាមួយស្ត្រី និងកុមារ ដែលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ ឪពុក/ម្តាយ ផ្ទុកមេរោគអេដស៍ ជំងឺអេដស៍ កុមារកំព្រា កុមារមានឪពុក/ម្តាយជាប់ពន្ធនាគារ ក្រោមអធិបតីភាព **លោកជំទាវ ចេង វន្នី** ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារខេត្ត ចំនួន១លើក មានអ្នកចូលរួមសរុប៥០នាក់ ស្រី២៦នាក់ នៅមណ្ឌលថែទាំកុមាររបស់រដ្ឋខេត្ត
- បានចុះគាំទ្រដល់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្នុងការបញ្ជ្រាបយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គម ទាក់ទងនឹងការអនុវត្ត តួនាទី ភារកិច្ច របស់ គ.ក.ស.ក និង គ.ក.ន.ក ឃុំ សង្កាត់ ស្តីពីការផ្តល់សេវាសង្គមដល់ប្រជាពលរដ្ឋ និងការផ្ទេរមុខងារ ដល់រដ្ឋបាលក្រុង ស្រុក ចំនួន១លើក មានអ្នកចូលរួមសរុប៤០នាក់ ស្រី២២នាក់ នៅស្រុកកោះកុង។ ក្នុងគោលបំណង ដើម្បីជួយជម្រុញដល់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ អនុវត្តមុខងារ និងភារកិច្ចឱ្យឆ្លើយតបនឹងតម្រូវការរបស់ស្ត្រី និងកុមារ ក្នុងមូលដ្ឋាន។

## ២.២.៧-ការងារអធិការកិច្ច

- បានចូលរួមពិធីបិទផ្សាយជាសាធារណៈនូវឯកសារនៃការ វិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធចំនួន១ភូមិ នៅភូមិ វាលត្បូង ឃុំស្រែអំបិល ស្រុកស្រែអំបិលខេត្តកោះកុង នៅសាលាឃុំស្រែអំបិល
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយអនុក្រឹត្យស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ របស់រាជរដ្ឋាភិបាលកម្ពុជា
- បានចូលរួមពិធីផ្សព្វផ្សាយច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការប្រឆាំងអំពើពុករលួយ

- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយគោលនយោបាយជាតិ ស្តីពីការអភិវឌ្ឍជនបទ ឆ្នាំ២០២៥-២០២៣៥
- បានចូលរួមប្រជុំផ្សព្វផ្សាយសារាចរណ៍ណែនាំ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៦
- បានចូលរួមកិច្ចប្រជុំត្រីមាសទី១ ឆ្នាំ២០២៦ របស់គណៈកម្មាធិការបណ្តុះបណ្តាលខេត្តកោះកុង ស្តីពីវឌ្ឍនភាពការងារសម្រេចបានត្រីមាសទី១ ឆ្នាំ២០២៦ និងលើកទិសដៅការងារបន្តរបស់គណៈកម្មាធិការបណ្តុះបណ្តាលខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំគណៈកម្មាធិការប្រជាជន និងអភិវឌ្ឍន៍ខេត្តដើម្បីផ្សព្វផ្សាយនិង ប្រមូលធាតុចូលសម្រាប់រៀបចំ ផែនការសកម្មភាពក្នុងការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជា ឆ្នាំ២០២៤-២០៣០ របស់ខេត្តកោះកុង
- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ ថវិកាឆ្នាំ២០២៧-២០២៩ និងការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៧
- បានចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រឹតការ ស្តីពីវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ
- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយស្តីពី "គោលការណែនាំការគ្រប់គ្រងហិរញ្ញវត្ថុ សាធារណៈ" របស់ក្រសួងអធិការកិច្ច (FMM)។

## ២.២.៨-ការងារធម្មការនិងសាសនា

- បានដឹកនាំកិច្ចប្រជុំ៖
  - ដើម្បីត្រៀមការប្រឡងធម្មវិន័យថ្នាក់ ត្រី ទោ ឯក ចំនួន១លើក
  - ស្តីពីការណែនាំគណៈកម្មការប្រឡងធម្មវិន័យ ត្រី ទោ ឯក ចំនួន១លើក
  - រៀបចំនិងពិនិត្យមើលការ ប្រឡងធម្មវិន័យថ្នាក់ ត្រី ទោ ឯក ចំនួន១លើក
  - កែវិញ្ញាសាប្រឡងធម្មវិន័យថ្នាក់ ត្រី ទោ ឯក ចំនួន១លើក
- បានចូលរួម៖
  - សិក្ខាសាលាផ្សព្វផ្សាយនានាថ្នាក់ក្រសួងចំនួន៩លើក
  - កម្មវិធីដង្ហែបុណ្យមាឃបូជាចំនួន២វត្ត និងកម្មវិធីដង្ហែបុណ្យវិសាខបូជាចំនួន២វត្ត
  - កិច្ចប្រជុំតាមបណ្តាវត្ត ចំនួន៨លើក
  - កិច្ចប្រជុំ zoom ថ្នាក់ដឹកនាំក្រសួង និងរដ្ឋបាលខេត្តចំនួន៦លើក
  - កិច្ចប្រជុំ និងសកម្មភាពនានាថ្នាក់ដឹកនាំរដ្ឋបាលខេត្តចំនួន១៨លើក
  - ពិធីប្រកាសតែងតាំងព្រះគ្រូសង្ឃាភទោ ឥន រស្សា ជាព្រះគ្រូចៅអធិការស្តីទីចំនួន១លើក
  - កិច្ចប្រជុំពិធីសម្ពោធស្តូបអនុស្សាវរីយ៍ នយោបាយឈ្នះ ឈ្នះ កោះកុង ចំនួន២លើក
  - សហការរៀបចំ ទិវាជាតិនៃការចងចាំ ២០ ខែឧសភា ឆ្នាំ២០២៦ ២កន្លែងចំនួន២លើក
  - ប្រជុំផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹង អំពីបទដ្ឋានគតិយុត្តិ យន្តការគ្រប់គ្រង និងបទដ្ឋានបច្ចេកទេស សម្រាប់ការធ្វើអាជីវកម្មខ្សាច់ប្រកបដោយការទទួលខុសត្រូវចំនួន១លើក
  - ពិធីផ្សព្វផ្សាយ អនុក្រឹត្យ លេខ៦៧ អនក្រ.បក.ក្រមធស ចំនួន១លើក
  - ពិធីប្រគេនសិក្ខាប្បករ (សម្ភារសិក្សា) ទេយ្យទាន និងបច្ច័យ ដល់សមណសិស្សចំនួន១លើក
  - សកម្មភាពនានាជាមួយកិច្ចការពាហិរសាសនា ( ឥស្លាម-គ្រីស្ទ) ចំនួន៦លើក
  - ពិធីចែកអំណោយពីសប្បុរសជនក្នុងខេត្តកោះកុងចំនួន៩លើក
  - ពិធីសម្ពោធឆ្លងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ផ្លូវបេតុង និងភ្លើងបំភ្លឺផ្លូវចំនួន១លើក
  - សហការចុះពិនិត្យពីវឌ្ឍនភាពបុណ្យមាឃបូជាចំនួន១លើក
  - បើក-បិទសន្និបាតក្រសួងធម្មការនិងសាសនាចំនួន១លើក
  - កិច្ចប្រជុំរៀបចំកោះកុងសង្ក្រាន្តចំនួន១លើក

- បានសហការជាមួយៈ
  - រដ្ឋបាលខេត្តរៀបចំពិធីក្រុងពាលីកោះកុងសង្ក្រាន្តចំនួន១លើក
  - ព្រះមន្ត្រីសង្ឃ អាជ្ញាធរដែនដី និងសប្បុរសជននានា ក្នុងកិច្ចការភៀសសឹកចំនួន១៥ថ្ងៃ។

## ២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បញ្ជូនបញ្ញើក្នុងនិងក្រៅប្រទេស សរុប៧៦.៥៧៩បញ្ញើ/ច្បាប់ ស្មើនឹង១១៥.៥៥៧,៨៨គីឡូក្រាម
- ទទួលបញ្ញើក្នុងនិងក្រៅប្រទេស សរុប៥.៦៧៥បញ្ញើ/ច្បាប់ ស្មើនឹង៤.១៧៩,៣០គីឡូក្រាម
- បានចេញលិខិតអនុញ្ញាតសេវាបញ្ញើឆាប់រហ័សជាតិ-អន្តរជាតិ (ថ្មី) ចំនួន១ទីតាំង គឺសាខាក្រុមហ៊ុន វៀតធេល ចំនួន១ទីតាំង ស្ថិតនៅក្រុងខេមរភូមិន្ទ
- បានចេញលិខិតអនុញ្ញាត សេវាបញ្ញើឆាប់រហ័សអន្តរជាតិ (បន្ត) ចំនួន៤ទីតាំង មានដូចខាងក្រោមៈ
  - សាខាក្រុមហ៊ុន វីរៈប៊ុនថាំ ចំនួន២ទីតាំង ស្ថិតនៅក្រុងខេមរភូមិន្ទ និងស្រុកស្រែអំបិល
  - សាខាក្រុមហ៊ុន គ្លូបិល ជេត ចំនួន១ទីតាំង ស្ថិតនៅក្រុមខេមរភូមិន្ទ
  - សាខាក្រុមហ៊ុន ហ្សេតជីអូ ចំនួន១ទីតាំង ស្ថិតនៅក្រុងខេមរភូមិន្ទ
- បានចេញលិខិតអនុញ្ញាតបើកអាជីវកម្មសាលបម្រើអ៊ិនធឺណែតកាហ្វេ ជូនអតិថិជនចំនួន២ទីតាំង(ក្នុងនោះ១ទីតាំងបានបង់ក្នុងឆ្នាំចាស់រួចរាល់ហើយ)
- បានចេញលិខិតអនុញ្ញាតប្រើប្រាស់ហ្វ្រេកង់វិទ្យុទាក់ទង UHF ចំនួន១០គ្រឿង
- បានចុះជំរុញសាខាក្រុមហ៊ុនធ្វើអាជីវកម្មគ្មានលិខិតអនុញ្ញាតចំនួន២ទីតាំង ចុះអនុវត្តចំនួន៤លើក
- បានធ្វើរបាយការណ៍ប្រចាំខែ ត្រីមាសទី២ និងឆមាសទី១ ឆ្នាំ២០២៦ ស្តីពីការទប់ស្កាត់និងបង្ក្រាបសារធាតុញៀនតាមបញ្ញើប្រៃសណីយ៍ជូនស្នងការដ្ឋាននគរបាលខេត្ត និងជូនឯកឧត្តមប្រធានក្រុមការងារចំណុះអនុគណៈកម្មការទទួលបន្ទុកទប់ស្កាត់ និងបង្ក្រាបសារជាតុញៀនតាមបញ្ញើប្រៃសណីយ៍ នៃក្រសួង ប.ទ
- បានចុះស្ទង់មតិពីស្ថានភាពតម្រូវការសេវាផ្ដាយរណប នៅតាមមន្ទីរ សាលារៀន វារីអគ្គិសនី និងសណ្ឋាគារចំនួន១០ទីតាំង
- បានចុះត្រួតពិនិត្យបណ្តាញខ្សែកាបទូរគមនាគមន៍ ដែលប្រតិបត្តិករក្រុមហ៊ុនបានភ្ជាប់សេវាអ៊ីនធឺណិតក្នុងអគារក្រុមហ៊ុនចិនដើម្បីប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យា ( ONLINE SCAMS ) ខុសច្បាប់ចំនួន៤ទីតាំង
- បានចុះត្រួតពិនិត្យការសាងសង់ស្ថានីយ៍បង្គោលអង់តែនទូរសព្ទ ក្រុមហ៊ុនថេឡេម៉ូបាយចំនួន១ទីតាំង
- បានចុះធ្វើការវាស់ស្ទង់សេវាទូរសព្ទក្នុងអាគារក្រុមហ៊ុនចិនចំនួន១ទីតាំង
- បានចុះត្រួតពិនិត្យទីតាំងអគារបម្រើ ONLINE SCAMS ខុសច្បាប់ដែលខូចខាតសៀល និងកំណត់ទីតាំងដំឡើងកាំមេរ៉ាសុវត្ថិភាពចំនួន៣ទីតាំង
- បានចុះត្រួតពិនិត្យការជួសជុលបណ្តាញខ្សែកាបទូរគមនាគមន៍របស់ក្រុមហ៊ុនអង្គរជាតា ក្រុមហ៊ុន អេស អាយគ្រុប ក្រុមហ៊ុន តែលកូថេក ក្រុមហ៊ុនវៀតធេល និងក្រុមហ៊ុនស៊ីហ្វុកចំនួន៥ទីតាំង
- បានចុះពិនិត្យការរុះរើស្ថានីយ៍បង្គោលអង់តែនទូរសព្ទរបស់ក្រុមហ៊ុនសែលខាត, ថេឡេម៉ូបាយ, ស៊ីនវ៉េ ចំនួន៤ទីតាំង
- បានចុះធ្វើបច្ចុប្បន្នភាពស្ថានីយ៍បង្គោលអង់តែនទូរសព្ទក្រុមហ៊ុនស្មាត, វៀតធេល, សែលខាត ចំនួន២៩ទីតាំង ម៉ៃក្រូវ៉េវ៣៩គ្រឿង
- បានផ្សព្វផ្សាយ បង្ហោះសកម្មភាពការងាររបស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត និងបានផ្សព្វផ្សាយ ចែករំលែកបន្តនូវផេករបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គេហទំព័ររដ្ឋបាលខេត្តកោះកុង ពីសកម្មភាពការងារប្រចាំថ្ងៃអំពីសមិទ្ធផលនានាតាមប្រព័ន្ធបណ្តាញសង្គមសរុបចំនួ២៩២លើក។

## ២.២.១០-ការងារមុខងារសាធារណ:

- គិតត្រឹមថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២៦ តាមតារាងទូទាត់ប្រាក់បៀវត្សប្រចាំខែមិថុនា ឆ្នាំ២០២៥ មន្ត្រីរាជការស៊ីវិល នៅខេត្តកោះកុង មានចំនួន២.៦៨៦នាក់ ស្រី១.០៥៧នាក់
    - ចំនួនរាយតាមប្រភេទក្របខ័ណ្ឌ៖
        - ក្របខ័ណ្ឌប្រភេទ "ក" ចំនួន៦២៩នាក់ ស្ត្រី១៨២នាក់
        - ក្របខ័ណ្ឌប្រភេទ "ខ" ចំនួន១.០០០នាក់ ស្ត្រី៣៦៩នាក់
        - ក្របខ័ណ្ឌប្រភេទ "គ" ចំនួន១.០៥០នាក់ ស្ត្រី៥០០នាក់
        - ក្របខ័ណ្ឌមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារចំនួន៧នាក់ ស្រី៦នាក់
- បានត្រួតពិនិត្យទិដ្ឋាការលើសំណើសុំឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលប្រចាំឆមាសទី១ ឆ្នាំ២០២៦ ជូនមន្ទីរ អង្គភាពជុំវិញខេត្ត ដូចខាងក្រោម ៖

| ល.រ. | បរិយាយ | ដើមគ្រា | ក្នុងគ្រា | បូកយោង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ក្របខ័ណ្ឌថ្មី | ០ | ០ | ០ | |
| ២ | តាំងស៊ប់ | ០ | ២ | ២ | |
| ៣ | ប្តូរប្រភេទក្របខ័ណ្ឌ | ០ | ០ | ០ | |
| ៤ | ឡើងថ្នាក់ និងឋានន្តរស័ក្តិ | ០ | ២៦៨ | ២៦៨ | |
| ៥ | និយ័តកម្មថ្នាក់ | ០ | ០ | ០ | |
| ៦ | តែងតាំង | ០ | ១៧ | ១៧ | |
| ៧ | ប្តូរប្រាក់មុខងារ | ០ | ៣ | ៣ | |
| ៨ | បញ្ចូល និងបន្ថយកូន | ០ | ១១១ | ១១១ | |
| ៩ | បញ្ចូល និងបន្ថយប្រពន្ធ | ០ | ៣៩ | ៣៩ | |
| ១០ | ចូលនិវត្តន៍ និងឧបត្ថម្ភចូលនិវត្តន៍ | ០ | ៣៦ | ៣៦ | |
| ១១ | ផ្ទេរចូល | ០ | ៦ | ៦ | |
| ១២ | ផ្ទេរចេញ | ០ | ១៣ | ១៣ | |
| ១៣ | នៅក្រៅក្របខ័ណ្ឌដើម | ០ | ០ | ០ | |
| ១៤ | ទំនេរគ្មានបៀវត្ស | ០ | ២ | ២ | |
| ១៥ | លុបឈ្មោះ | ០ | ៩ | ៩ | |
| ១៦ | ប្តូរកន្លែងការងារ | ០ | ០ | ០ | |
| ១៧ | ស្នើសុំ និងដកប្រាក់តំបន់ | ០ | ១៥ | ១៥ | |
| ១៨ | ចូលបម្រើការងារវិញ | ០ | ៥ | ៥ | |
| ១៩ | រំលឹកប្រាក់ | ០ | ០ | ០ | |
| ២០ | ថ្នាក់ពីរពេល | ០ | ០ | ០ | |
| ២១ | ថ្នាក់គួបពីរកម្រិត និងបីកម្រិត | ០ | ៣២ | ៣២ | |
| ២២ | បញ្ចូលប្រាក់មុខងារ | ០ | ០ | ០ | |
| ២៣ | លំហែមាតុភាព | ០ | ៤៥ | ៤៥ | |
| ២៤ | ប្តូរប្រអប់/កែតម្រូវព័ត៌មានមន្ត្រីរាជការ | ០ | ១៩ | ១៩ | |
| **សរុបរួម** | | **០** | **៦២២** | **៦២២** | |

- បានត្រួតពិនិត្យ និងតាមដានលើការបើកប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភប្រចាំខែរបស់ក្រុមប្រឹក្សា ការិយាល័យប្រជាពលរដ្ឋ មន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ក្នុងឆមាសទី១ ឆ្នាំ២០២៦។

### ២.២.១១-ការងារផ្សេងៗ

#### ២.២.១១.១-ការងារសាលាដំបូង

- **ផ្នែកចៅក្រមស៊ើបសួរ**
  - សំណុំរឿងសល់ពីមុន ចំនួន១៩០រឿង
  - សំណុំរឿងចូលថ្មី ចំនួន៧០រឿង
  - សំណុំរឿងចាត់ការរួច ចំនួន១៥៨រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន១០២រឿង
- **ផ្នែកចៅក្រមជំនុំជម្រះ**
  - សំណុំរឿងសល់ពីមុន ចំនួន១២៧រឿង
  - សំណុំរឿងចូលថ្មី ចំនួន៣៤រឿង
  - សំណុំរឿងចាត់ការរួច ចំនួន១៧៣រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន២៨រឿង។
- **ផ្នែកតុលាការរដ្ឋប្បវេណី**
  - សំណុំរឿងសល់ពីមុន ចំនួន២៤៥រឿង
  - សំណុំរឿងចូលថ្មី ចំនួន១៣៤រឿង
  - សំណុំរឿងចាត់ការរួច ចំនួន១៩៤រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន១៨៥រឿង។
- **ការងារអយ្យការអមសាលាដំបូង**
  - សំណុំរឿងសល់ពីមុន ចំនួន២១៤រឿង
  - សំណុំរឿងចូលថ្មី ចំនួន៥០រឿង
  - សំណុំរឿងចាត់ការរួច ចំនួន២២០រឿង
  - សំណុំរឿងកំពុងចាត់ការ ចំនួន៤៤រឿង។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បានទទួលកម្រៃសេវាសាធារណៈ (អង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត) ដូចខាងក្រោម ៖
  - ការងារសំណង់ ទទួលបានកម្រៃសេវាចំនួន៣៨.៩៩៨.២០០រៀល
    - ឯកសារចូលសរុប ចំនួន២១ច្បាប់
    - ឯកសារចេញសរុប ចំនួន១៥ច្បាប់
  - ការងារសុរិយោដី ទទួលបានកម្រៃសេវាចំនួន២០០.៤៨៨.៤០០រៀល
    - ឯកសារចូលសរុប ចំនួន៦៩៩ច្បាប់
    - ឯកសារចេញសរុប ចំនួន៦២៣ច្បាប់
  - ការងារសុរិយោដី តាមប្រព័ន្ធអនឡាញ ទទួលបានកម្រៃសេវាចំនួន៧០.៩៧០.០០០រៀល
    - ឯកសារចូលសរុប ចំនួន២៧១ច្បាប់
    - ឯកសារចេញសរុប ចំនួន២៣០ច្បាប់
- ការងារចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ៖
  - ក្រុមទី១ បំពេញការងារនៅភូមិព្រែកដីក ភូមិនាពិសី ភូមិអន់ឆ្អែត ឃុំដីឥក្រោម ស្រុកស្រែអំបិល
  - ក្រុមទី២ បំពេញការងារនៅភូមិព្រែកខ្សង ភូមិទួលពោធិ៍ និងភូមិបាក់រនាស់ ឃុំតានួន ស្រុកបូទុមសាគរ

- ក្រុមទី៣ បំពេញការងារនៅភូមិចំការលើ ភូមិស្រែត្រាវ និងភូមិថ្មស ឃុំថ្មស ស្រុកបូទុមសាគរ
- ក្រុមទី៤ បំពេញការងារនៅភូមិសាលាម្នាង ភូមិបឹងព្រាវ ភូមិទឹកប៉ោង និងភូមិជ្រោយ ឃុំបឹងព្រាវ ស្រុកស្រែអំបិល

– ការងារចុះបញ្ជីមានលក្ខណៈដាច់ដោយដុំ ៖
  - ដីឯកជនចំនួន២២៣ក្បាលដី

– ការងារចុះបញ្ជីដីបន្ត ៖
  - អចលនវត្ថុចុះបញ្ជីជាប្រព័ន្ធ
    - ចុះបញ្ជីផ្ទេរសិទ្ធិបានចំនួន ៦៧៨ក្បាលដី
    - ចុះបញ្ជីប្រាតិភោគបានចំនួន ១៧៩ក្បាលដី
  - អចលនវត្ថុចុះបញ្ជីដាច់ដោយដុំ
    - ចុះបញ្ជីប្រាតិភោគបានចំនួន១៧ក្បាលដី

– ក្រុមការងាររបស់មន្ទីរបានបំពេញការងារដូចខាងក្រោម៖
  - បានបំពេញទម្រង់បែបបទចំនួន ១៥.៥១៧ក្បាលដី
  - បានវាស់វែងចំនួន ៣.៧៨៥ក្បាលដី
  - គូសក្រាហ្វិកបានចំនួន ២.១៩៣ក្បាលដី
  - បញ្ចូលទិន្នន័យបានចំនួន ២.៦៧៣ក្បាលដី
  - ចេញបណ្ណបានចំនួន ១.៣០០បណ្ណ
  - ចែកបណ្ណបានចំនួន ៦០០បណ្ណ

– បានចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ និងមោឃភាពនៃប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ ឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ចំនួន១ភូមិ នៅភូមិស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ក្រុងខេមរភូមិន្ទ។

### ២.៣.២-ការងារបរិស្ថាន

– បានកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តកោះកុងចំនួន៣៤ករណី
– បានចាប់ឃាត់ត្រាក់ទ័រ១គ្រឿង អេស្កាវ៉ាទ័រ១គ្រឿង ម៉ាស៊ីនភ្លើង១គ្រឿង ម៉ាស៊ីនរណារយន្ត៣៥គ្រឿង កាំភ្លើងកែច្នៃ៨ដើម គ្រាប់រំសេវ២គ្រាប់ កាមេរ៉ាសុវត្ថិភាព២គ្រឿង កាំបិត៨ ពូថៅ២ ទោចក្រយានយន្ត៨គ្រឿង រថយន្ត៤គ្រឿង ទូរសព្ទ៩គ្រឿង ធ្យូងបាវ១៤៥បាវ និងវិទ្យុទាក់ទង១គ្រឿង
– បានរុះរើអន្ទាក់ចាប់សត្វព្រៃ៥.៩២៣ខ្សែ មងចាប់សត្វព្រៃ២៥៦១ម៉ែត្រ ផ្លែសន្ទូច៣៧០ ផ្លែដំរ៉៨ ខ្ទម១ តូបលក់ដូរខុសច្បាប់២៥តូប បន្ទប់ទឹកជាសំណង់រឹងមាំ២ខ្នង រោងអង្គុយកម្សាន្ត៧១រោង និងរោងស្នាក់នៅ ៣រោង
– បានបោះផ្លាកសញ្ញាហាមកាប់ទន្រ្ទានដីព្រៃចំនួន៣០ផ្លាក
– បានចុះពិនិត្យទីតាំងស្នើសុំធ្វើអាជីវកម្ម និងផ្តល់យោបល់លើការរៀបចំកិច្ចសន្យាការពារបរិស្ថានចំនួន៣៨លើក
– បានធ្វើកិច្ចសន្យាការពារបរិស្ថានចំនួន១២ទីតាំង
– បានរៀបចំយុទ្ធនាការផ្សព្វផ្សាយកាត់បន្ថយថង់ប្លាស្ទិក និងកម្ពុជាស្អាត ខ្មែរធ្វើបាន និង «ផ្លូវជាតិគ្មានសម្អាតប្លាស្ទិក» ចំនួន១៥លើក
– បានដាំស្តារព្រៃកោងកាងចំនួន១៥.៨៧៦កូន និងកូនដើមឈើចម្រុះចំនួន១៤៤៥កូន។

### ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

– គម្រោងផែនការការងារថែទាំផ្លូវថ្នល់ជាប្រចាំឆ្នាំ២០២៦៖
  - ការងារថែទាំផ្លូវក្រាលកៅស៊ូលើផ្លូវជាតិ ផ្លូវខេត្ត ចំនួន៧ខ្សែ ប្រវែង១៤១,៦៧គ.ម សម្រេចបាន៥១,២០%
  - ការងារថែទាំផ្លូវក្រាលដីល្បាយថ្មលើផ្លូវខេត្ត ចំនួន៣ខ្សែ ប្រវែង៥៥,៥៧គ.ម សម្រេចបាន៥១,២០%។

- គម្រោងផែនការការងារថែទាំខួបប្រចាំឆ្នាំ២០២៦៖
  - គម្រោងការងារថែទាំខួប លើកំណាត់ផ្លូវជាតិលេខ ៤៨-៥(៦១)
    - លើកំណាត់ផ្លូវជាតិលេខ ៤៨-៥ ដោយក្រាលកៅស៊ូពីរជាន់ (DBST) ប្រវែង ៨២០ម ទទឹង១៦ម និងចិញ្ចើមដីល្បាយថ្ម១,៥សងខាង គូសគំនូសចរាចរណ៍ទំហំ ៧៦៩ម២ ចន្លោះគ.ម ០១+៤០០ ដលគ.ម ០២+ ២២០ ស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ ខេត្តកោះកុង សម្រេចបាន៥៣,៤៦%។
  - គម្រោងការងារថែទាំខួបលើកំណាត់ផ្លូវជាតិលេខ៤៨-៥ (៦១) និងលើកំណាត់ផ្លូវខេត្តលេខ១៤៨៩a (៦១)
    - លើកំណាត់ផ្លូវជាតិលេខ ៤៨-៥ ដោយក្រាលកៅស៊ូពីរជាន់ DBST បន្ថែមពីលើ (Reseal DBST) ប្រវែង ១ ៨០០ម ទទឹង ១៦ម គូសគំនូសចរាចរណ៍ទំហំ ២០៣ម២ ចន្លោះគ.ម ០៤+៤០០ -គ.ម ០៥+៨០០ស្ថិតក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ និងលើកំណាត់ផ្លូវខេត្តលេខ ១៤៨៩a ដោយក្រាលកៅស៊ូពីរជាន់ DBST (Reseal DBST) ប្រវែង២.៦០០ម ទទឹង៧ម គូសគំនូសចរាចរណ៍ទំហំ ១.០៥៩ម$^២$ ដាក់ផ្លាកសញ្ញាចរាចរណ៍ចំនួន១៤ផ្លាក ចាប់ពីគ.ម ០៥+០០០ ដល់គ.ម ០៧+០០០ និងពីគ.ម ០៧+៩៥០ ដល់គ.ម ០៨+៥៥០ ស្ថិតក្នុង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ខេត្តកោះកុង សម្រេចលទ្ធផលបាន២១,៦១%។
  - គម្រោងស្ថាបនា លើកំណាត់ផ្លូវខេត្តលេខ១៤៨៥a (២១)៖
    - លើកំណាត់ផ្លូវខេត្តលេខ ១៤៨៥a ដោយក្រាលកៅស៊ូ DBST ប្រវែង១.៨០០ម ទទឹង៨ម និងចិញ្ចើមក្រាលដីល្បាយថ្ម ១មសងខាង ស្ថាបនាលូជ្រុង U-drain រំដោះទឹកតាមបណ្តោយផ្លូវ ទំហំ0,៨០ម x ១ម ប្រវែង៥០០ម និងគូសគំនូសចរាចរណ៍ទំហំ៧៣៥ម$^២$ ដាក់ផ្លាកសញ្ញាចរាចរណ៍ចំនួន២២ផ្លាកព្រមទាំងដាំបង្គោលនាំផ្លូវចំនួន៥៤ដើម ចាប់ពីគ.ម ៥៦+៦០០ ដល់ គ.ម ៥៨+៤០០ ស្ថិតក្នុងឃុំភ្ញីមាស ស្រុកគិរីសាគរ ខេត្តកោះកុង សម្រេចបាន 0,0% (មិនទាន់ទទួលបានបុរេប្រទាន)។
- ការងារដឹកជញ្ជូនផ្លូវគោក៖
  - ការងារចុះបញ្ជីរថយន្តបែនធុនធ្ងន់ចំនួន៣គ្រឿង គ្រឿងចក្របូម-បាញ់បេតុងចំនួន២គ្រឿង រថយន្តលាយស៊ីម៉ង់ត៍ចំនួន៧គ្រឿង និងរថយន្តដឹកទំនិញធុនធ្ងន់-ស្ទូចចំនួន១គ្រឿង
  - ការងារផ្ទេរកម្មសិទ្ធិក្នុងខេត្ត ប្រភេទរថយន្តគ្រឿងចក្រលាយស៊ីម៉ង់ចំនួន៥គ្រឿង ប្រភេទរថយន្តគ្រួសារចំនួន១គ្រឿង និងប្រភេទទោចក្រយានយន្ត១គ្រឿង
  - ការងារផ្ទេរកម្មសិទ្ធិក្រៅខេត្ត ប្រភេទរថយន្តគ្រួសារចំនួន៣គ្រឿង ប្រភេទរថយន្តដឹកទំនិញ(គ្រួសារ) ចំនួន៣គ្រឿង និងប្រភេទរថយន្តបែនធុនធ្ងន់ចំនួន២គ្រឿង
  - ប្តូរផ្លាកសម្គាល់រថយន្តធុនធំ(ម្នាង) ចំនួន១ផ្លាក
  - ការងារប្តូរបណ្ណសម្គាល់យានយន្ត ប្រភេទរថយន្តដឹកទំនិញធុនធ្ងន់ចំនួន១បណ្ណ
  - ការងារបណ្ណបើកបរ ទុតិយតាបណ្ណបើកបរប្រភេទ(គ) ចំនួន១បណ្ណ និងប្រភេទ(ឃ១) ចំនួន១បណ្ណ
  - ការងារបណ្ណបើកបរ ពន្យាសុពលភាពបណ្ណបើកបរប្រភេទ(គ) ចំនួន៦បណ្ណ ប្រភេទ(ឃ១) ចំនួន១បណ្ណ ប្រភេទ(ឃ២) ចំនួន១៥បណ្ណ និងប្រភេទ(ងគ) ចំនួន១បណ្ណ
  - ការងារត្រួតពិនិត្យលក្ខណបច្ចេកទេសយានយន្តចល័ត ចំនួន៨៩៦គ្រឿង
- ការងារដឹកជញ្ជូនផ្លូវសមុទ្រ និងកំពង់ផែ
  - ចុះបញ្ជីប្រភេទជលយានយន្តនេសាទចំនួន៧គ្រឿង និងប្រភេទជលយានយន្តដឹកទំនិញចំនួន៤គ្រឿង
  - ផ្តល់ច្បាប់អនុញ្ញាតធ្វើអាជីវកម្មជលយានយន្តដឹកទំនិញចំនួន៤គ្រឿង
  - ត្រួតពិនិត្យលក្ខណបច្ចេកទេសប្រភេទជលយានយន្តដឹកទំនិញចំនួន៥គ្រឿង និងប្រភេទជលយានយន្តនេសាទចំនួន៤៦គ្រឿង
  - ផ្ទេរកម្មសិទ្ធិប្រភេទជលយានយន្តនេសាទចំនួន៤គ្រឿង

- ការងារសុវត្ថិភាពចរាចរណ៍៖
  - បានចុះត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណបច្ចេកទេសចំនួន៤លើក ស្មើ៧៦គ្រឿង ក្នុងនោះ៖
    - រថយន្តត្រឹមត្រូវចំនួន៧គ្រឿង
    - រថយន្តដោះភ្លើងបំភ្លឺខុសលក្ខណៈបច្ចេកទេសចំនួន៤គ្រឿង
    - ប្រើបណ្ណបើកបរហួសសុពលភាពចំនួន១នាក់
  - បានចុះផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក ចំនួន២លើក បានផ្តល់ឯកសារសម្ភារសុវត្ថិភាពចរាចរណ៍ មានដូចជា៖
    - សៀវភៅច្បាប់ចរាចរណ៍ផ្លូវគោកចំនួន៤៥ក្បាល
    - សៀវភៅដែលអ្នកបើកបរទោចក្រយានយន្តត្រូវយល់ដឹងចំនួន១០០ក្បាល
    - ស្ទីកឃ័រចំណាំងផ្លាតចំនួន២០០សន្លឹក
    - ខិត្តបណ្ណសុវត្ថិភាពចរាចរណ៍ចំនួន៥០សន្លឹក
    - ខិត្តបណ្ណដែលអ្នកបើកបរត្រូវយល់ដឹងចំនួន៥០ក្បាល
    - ប្រការសំខាន់ៗដែលត្រូវចង់ចាំចំពោះអ្នកប្រើប្រាស់ផ្លូវចំនួន១០០សន្លឹក
    - ផ្ទាំងថ្ងៃនេះ ថ្ងៃស្អែកកុំឱ្យមានគ្រោះថ្នាក់ចរាចរណ៍ចំនួន២ផ្ទាំង
    - បដាអប់រំចំនួន២ផ្ទាំង
    - សីលធម៌១០ចំណុចសម្រាប់សុវត្ថិភាពចរាចរណ៍ចំនួន១០០សន្លឹក
    - សញ្ញាចរាចរណ៍សំខាន់ៗចំនួន១ផ្ទាំង
- ការងារលូទឹក និងស្ថានីយចម្រោះទឹកកខ្វក់
  - បានចូលរួមប្រជុំផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សា នៅក្នុងស្រុកមណ្ឌលសីមា
  - បានចូលរួមប្រជុំរៀបចំផែនការសវនកម្មលើកិច្ចប្រតិបត្តិការគ្រប់គ្រងសំរាម សំណល់រឹង ទីប្រជុំជន នៅរដ្ឋបាលក្រុងខេមរភូមិន្ទ រដ្ឋបាលស្រុកមណ្ឌលសីមា និងរដ្ឋបាលស្រុកកោះកុង។
- ការងារសណ្តាប់ធ្នាប់សាធារណៈ
  - បានចុះល្បាតតាមបណ្តោយផ្លូវជាតិលេខ៤៨ចាប់ពីគល់ស្ពានកោះកុងរហូតដល់ព្រំដែនអន្តរជាតិចាំយាម។

### ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

## ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

### ២.៤.១-ការងារអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

**១.ផ្តល់សេវាសាធារណៈ ជាពិសេសសេវារដ្ឋបាលប្រកបដោយគុណភាព តម្លាភាព និងទទួលបានជំនឿទុកចិត្ត ៖**

**ការពង្រឹងតួនាទី និងភារកិច្ច ៖** ការងារនេះថ្នាក់ដឹកនាំខេត្ត បានពង្រឹងតួនាទី និងភារកិច្ច តាំងពីថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក រហូតដល់ថ្នាក់មូលដ្ឋាន ពិសេសប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋឱ្យបានកាន់តែប្រសើរឡើង សំដៅឆ្លុះបញ្ចាំងពីគុណភាព ប្រសិទ្ធភាព និងតម្លាភាព។ បន្ទាប់ពីបានអនុវត្តកន្លងមកឃើញថា ប្រជាពលរដ្ឋមានការសប្បាយចិត្ត និងមានជំនឿទុកចិត្តកាន់តែច្រើនឡើង។

**២.សភាពការណ៍បទល្មើស និងលទ្ធផលកិច្ចប្រតិបត្តិការ ៖** បទល្មើសព្រហ្មទណ្ឌកើតឡើង ចំនួន៧២លើក ក្នុងនោះមាន៖

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ ៖**

- បទល្មើសឧក្រិដ្ឋ ៖ កើតឡើង៧លើក (បទល្មើសឃាតកម្ម៤ បទល្មើសរំលោភទារប្រាក់១ និងរំលោភសេពសន្ថវៈ២)
- បទល្មើសមជ្ឈិម ៖ កើតឡើង២៨លើក (បទល្មើសលួច១៧ បទល្មើសប្រើប្រាស់អាវុធខុសច្បាប់១ អំពើហិង្សា៦ និងអំពើហិង្សាក្នុងគ្រួសារ៤)

○ ការខូចខាតបាត់បង់ ៖ បណ្តាលឱ្យស្លាប់៤នាក់ របួស១៣នាក់ រងគ្រោះ២៥នាក់ និងបាត់ម៉ូតូ១៦គ្រឿង និងសម្ភារ មាស ប្រាក់មួយចំនួនទៀត។

○ **លទ្ធផលបង្ក្រាប ៖** បទល្មើសដែលបានកើតឡើងខាងលើ កម្លាំងមានសមត្ថកិច្ចបានបើកកិច្ចប្រតិបត្តិការយ៉ាងសកម្មបង្ក្រាបបានចំនួន៣៣ករណី នៃបទល្មើសដែលបានកើតឡើង។ ឃាត់ខ្លួនជនសង្ស័យបានចំនួន៥៧នាក់ ស្រី២នាក់ និងដកហូតរថយន្ត១គ្រឿង ម៉ូតូចំនួន២៤គ្រឿង ហើយបានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**ខ. បទល្មើសគ្រឿងញៀន៖** បានធ្វើការបង្ក្រាបបទល្មើសរក្សាទុក ជួញដូរ និងប្រើប្រាស់នូវសារធាតុញៀនខុសច្បាប់ចំនួន២២ករណី ឃាត់ខ្លួនជនសង្ស័យចំនួន៤៤នាក់ ស្រី៣នាក់។

○ ដកហូតវត្ថុតាង៖ ថ្នាំញៀនប្រភេទICE ៩៥៨,៩៩ក្រាម WY៩,៣៨ក្រាម រថយន្ត២គ្រឿង ម៉ូតូ៤គ្រឿង ជញ្ជីងថ្លឹងថ្នាំញៀន៣គ្រឿង កាំបិត១ដើម ទូរសព្ទដៃ៣៦គ្រឿង សម្ភារវេចខ្ចប់ និងឧបករណ៍ជក់ថ្នាំញៀនមួយចំនួន។ វត្ថុតាង និងមុខសញ្ញាជនសង្ស័យខាងលើ ត្រូវបានកសាងសំណុំរឿង បញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្ត។

**គ. ល្បែងស៊ីសងខុសច្បាប់៖** ពុំមានអ្វីកត់សម្គាល់។

**ឃ. បទល្មើសផ្សេងៗ ៖** ពុំមានអ្វីកត់សម្គាល់។

➢ *វិធានការបង្ការ ៖* កម្លាំងជំនាញនៅតាមបណ្តាប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ចុះធ្វើការអប់រំណែនាំប្រជាពលរដ្ឋ ក្នុងតំបន់ណាដែលមានការសង្ស័យថាមានយុទ្ធភណ្ឌមិនទាន់ផ្ទុះសល់ពីសម័យសង្គ្រាម ឱ្យមានការប្រុងប្រយ័ត្ន ហើយបើបានប្រទះឃើញត្រូវរាយការណ៍ជូនកម្លាំងមានសមត្ថកិច្ច ដើម្បីមានវិធានការការពារ។

**៣. សភាពការណ៍សណ្តាប់ធ្នាប់ និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. សភាពការណ៍គ្រោះថ្នាក់ចរាចរណ៍ ៖** កើតឡើង៥លើក បណ្តាលឱ្យស្លាប់៥នាក់ និងរបួស២នាក់។

➢ *វិធានការបង្ការ ៖* បានបញ្ចុះកម្លាំងជំនាញសហការជាមួយកម្លាំងពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយអប់រំណែនាំដល់អ្នកបើកបរយានយន្តគ្រប់ប្រភេទ នៅតាមទីប្រជុំជន តាមដងផ្លូវកែងសំខាន់ៗ និងចុះអប់រំអាជីវករលក់ដូរជុំវិញផ្សារលក់ដូរអមសងខាងផ្លូវឱ្យរៀបចំអីវ៉ាន់លក់ដូរឱ្យមានសណ្តាប់ធ្នាប់ល្អ សំដៅកាត់បន្ថយការកកស្ទះចរាចរណ៍ និងគ្រោះថ្នាក់ចរាចរណ៍ជាយថាហេតុ។

**៤. បទល្មើសជួញដូរមនុស្ស ជួញដូរផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងក្មេងទំនើង និងលទ្ធផលកិច្ចប្រតិបត្តិការ ៖**

**ក. បទល្មើសជួញដូរមនុស្ស និងជួញដូរផ្លូវភេទ ៖** កើតឡើង៦ករណី (បង្ក្រាបការដឹកជញ្ជូនដោយមានគោលដៅ១ករណី, បង្ក្រាបការដឹកនាំគ្រឹះស្ថានពេស្យាចារ១ករណី, បង្ក្រាបករណីរំលោភសេពសន្ថវៈ២ករណី, បង្ក្រាបអំពើប៉ះពាល់ដល់សិទ្ធិខាងរូបភាពនៃបុគ្គល១ករណី និងបង្ក្រាបអំពើអាសប្រថាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ១ករណី)

**ខ. អំពើហិង្សាក្នុងគ្រួសារ ៖** កើតឡើង៤លើក នៅក្នុងឃុំអណ្តូងទឹក១លើក, សង្កាត់ស្មាច់មានជ័យ១លើក, សង្កាត់ស្ទឹងវែង១លើក និងឃុំជីខក្រោម១លើក។ ករណីនេះ កម្លាំងជំនាញបានកសាងសំណុំរឿង និងបញ្ជូនជនសង្ស័យទៅអយ្យការអមសាលាដំបូងខេត្ត ដើម្បីអនុវត្តនីតិវិធីបន្ត។

**គ. សកម្មភាពក្មេងទំនើង ៖** បង្ក្រាបបានចំនួន១១លើក ឃាត់ខ្លួន១២នាក់ប្រុស ដែលបង្កសកម្មភាពវាយតប់គ្នាតាមទីសាធារណៈ និងបង្កការអុកឡុកក្នុងមូលដ្ឋាន មុខសញ្ញាទាំង១២នាក់ ត្រូវបានបំពេញសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្ត អនុវត្តនីតិវិធីបន្ត។

*វិធានការការពារ៖* បានពង្រឹងកម្លាំងនៅថ្នាក់មូលដ្ឋាន ចុះល្បាតត្រួតពិនិត្យឃ្លាំមើលជាប្រចាំក្នុងមូលដ្ឋាន ដើម្បីបង្ការទប់ស្កាត់ និងបង្ក្រាបសកម្មភាពបង្កឡើងដោយក្មេងទំនើង ឬជនទំនើង។

**៥. ការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការប្រកបដោយគុណភាព និងប្រសិទ្ធភាព ៖**

– រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានខិតខំយកចិត្តទុកដាក់ពិនិត្យ សម្របសម្រួល និងដោះស្រាយជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការ ដែលមានជម្លោះដីធ្លីនៅសេសសល់មួយចំនួនបន្តទៀត

– បានទទួលបណ្តឹងចំនួន១ករណី (សម្រុះសម្រួលបញ្ចប់)។

**៦. មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ ៖**

ការងារនេះត្រូវបានពង្រឹងពីថ្នាក់ខេត្ត រហូតដល់ថ្នាក់មូលដ្ឋាន សំដៅគ្រប់គ្រង ថែរក្សា ការពារធនធានធម្មជាតិ បរិស្ថាន និងអនាម័យក្នុងភូមិ ឃុំ សង្កាត់ ប្រកបដោយប្រសិទ្ធភាព ពិសេសយើងបានអប់រំប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍ និងវិធានការនានាក្នុងការថែរក្សាបរិស្ថាន សុខភាព អនាម័យ និងសុវត្ថិភាពចំណីអាហារ ដើម្បីធ្វើឱ្យមូលដ្ឋានខេត្តទាំងមូលមានសោភ័ណភាពស្អាត រមណីយដ្ឋានល្អ ទាក់ទាញភ្ញៀវទេសចរជាតិ អន្តរជាតិ មកកម្សាន្តបានកាន់តែច្រើន។

**៧. ឆ្លើយតបបានទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖**

**ក. សភាពការណ៍គ្រោះមហន្តរាយ ៖**

**១. ខ្យល់កន្ត្រាក់៖** កើតឡើងចំនួន៦លើក (នៅស្រុកបូទុមសាគរ២លើក ស្រុកកោះកុង២លើក និងស្រុកស្រែអំបិល២លើក បណ្តាលឱ្យរបើកដំបូលផ្ទះ២០៥ខ្នង។

**២. ទឹកជំនន់៖** ពុំមានអ្វីគួរកត់សម្គាល់។

**៣. អគ្គិភ័យ៖** កើតឡើងចំនួន៤លើក នៅស្រុកបូទុមសាគរ១លើក ស្រុកមណ្ឌលសីមា១លើក និងក្រុងខេមរភូមិន្ទ២លើក បណ្តាលឱ្យឆេះផ្ទះចំនួន៤ខ្នង បង្កឱ្យខូចខាតសម្ភារប្រើប្រាស់មួយចំនួន។

**៤. លង់ទឹក៖** ពុំមានអ្វីគួរកត់សម្គាល់។

**៥. អត្តឃាត៖** កើតឡើងចំនួន១១លើក បណ្តាលឱ្យស្លាប់មនុស្ស៩នាក់ របួស២នាក់ (ចងកស្លាប់៨នាក់ នៅឃុំកោះស្តេច១នាក់ សង្កាត់ដងទង់១នាក់ ឃុំដងពែង១នាក់ ឃុំកោះកាពិ១នាក់ ឃុំបឹងព្រាវ១នាក់ ឃុំជីខក្រោម១នាក់ ឃុំជីខលើ១នាក់ និងឃុំប៉ាក់ខ្លង១នាក់, លោតពីលើអគារស្លាប់១នាក់នៅឃុំប៉ាក់ខ្លង, មនុស្សសតិមិនប្រក្រតីចាក់សាំងដុតខ្លួនឯងរបួស១នាក់នៅឃុំបឹងព្រាវ និងអារកសម្លាប់ខ្លួនរបួស១នាក់នៅឃុំជីខក្រោម។

**ខ. ការឆ្លើយតប**

- សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានសហការជាមួយអនុសាខាកាកបាទក្រហមកម្ពុជា ស្រុកកោះកុង ចុះសួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌ដល់គ្រួសាររងគ្រោះដោយអគ្គិភ័យចំនួន ២គ្រួសារ នៅភូមិថ្មី ឃុំជ្រោយប្រស់ ស្រុកកោះកុង
- សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានសហការជាមួយអនុសាខាកាកបាទក្រហមកម្ពុជា ក្រុងខេមរភូមិន្ទ ចុះសួរសុខទុក្ខ និងផ្តល់អំណោយមនុស្សធម៌ ដល់គ្រួសាររងគ្រោះដោយអគ្គិភ័យចំនួន ១គ្រួសារ នៅភូមិ២ សង្កាត់ដងទង់ ក្រុងខេមរភូមិន្ទ
- អនុសាខាកាកបាទក្រហមកម្ពុជាស្រុកស្រែអំបិល បានផ្តល់អំណោយជូនគ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន៥៣គ្រួសារ នៅឃុំជីខលើ ស្រុកស្រែអំបិល
- សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានផ្តល់ថវិកាចំនួន៨.១៩០.០០០រៀល ជូនអនុសាខាកាកបាទក្រហមកម្ពុជាស្រុកស្រែអំបិល ដើម្បីផ្តល់ជូនគ្រួសាររងគ្រោះដោយសារខ្យល់កន្ត្រាក់ចំនួន៨៤គ្រួសារ
- អនុសាខាកាកបាទក្រហមកម្ពុជាស្រុកបូទុមសាគរ បានផ្តល់អំណោយជូនដល់គ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន៩៦គ្រួសារ នៅភូមិអណ្តូងទឹក ឃុំអណ្តូងទឹក ស្រុកបូទុមសាគរ
- អនុសាខាកាកបាទក្រហមកម្ពុជាស្រុកមណ្ឌលសីមា បានផ្តល់អំណោយជូនដល់គ្រួសាររងគ្រោះដោយខ្យល់កន្ត្រាក់ចំនួន១១គ្រួសារ នៅភូមិបឹងកាឆាង ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- អនុសាខាកាកបាទក្រហមកម្ពុជាស្រុកកោះកុង បានផ្តល់អំណោយជូនដល់គ្រួសាររងគ្រោះ ដោយសារខ្យល់កន្ត្រាក់ចំនួន៤គ្រួសារ នៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង
- សាខាកាកបាទក្រហមកម្ពុជាខេត្តកោះកុង បានសហការជាមួយអនុសាខាកាកបាទក្រហមកម្ពុជាស្រុកស្រែអំបិល នាំយកអំណោយមនុស្សធម៌ផ្តល់ជូនគ្រួសាររងគ្រោះ ដោយសារអគ្គិភ័យចំនួន១គ្រួសារ នៅឃុំដងពែង ស្រុកស្រែអំបិល។

**គ. ការត្រៀមបង្ការ៖**

– គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ បានត្រៀមលក្ខណៈជាប្រចាំ ដើម្បីជួយសង្គ្រោះប្រជាពលរដ្ឋនៅពេលមានគ្រោះមហន្តរាយកើតឡើង

– បានផ្សព្វផ្សាយអំពីបញ្ហាអាកាសធាតុ និងគ្រោះមហន្តរាយនានា ជូនប្រជាពលរដ្ឋតាមរយៈប្រព័ន្ធប្រកាសឱ្យដឹងមុន១២៩៤ (EWS1294) និងប្រព័ន្ធផ្សព្វផ្សាយនានារបស់រដ្ឋបាលខេត្ត

– កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ បានចុះបំផុសអប់រំប្រជាពលរដ្ឋឱ្យមានការប្រុងប្រយ័ត្ន ចំពោះគ្រោះថ្នាក់អគ្គិភ័យ និងខ្យល់កន្ត្រាក់ តាមរយៈវេទិកាផ្សព្វផ្សាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ក្នុងមូលដ្ឋាន។

**គ. ឆ្លើយតបរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវប្រកបដោយប្រសិទ្ធភាព ៖** បានត្រៀមសម្ភារ បរិក្ខារ និងកម្លាំងសមត្ថកិច្ច សហការជាមួយជំនាញ ក្នុងការចុះអន្តរាគមន៍ជួយសង្គ្រោះបន្ទាន់ ករណីមានការរីករាលដាលជំងឺឆ្លងកាចសាហាវណាមួយ។

## ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

- **សភាពការណ៍សន្តិសុខនៅតាមព្រំដែន ៖**
  - ទាហានជើងទឹកថៃបានបាញ់កាំភ្លើងធំ និងកាំភ្លើងត្បាល់ដេកា៧៦មីលីម៉ែត្រ ចេញពីនាវាចម្បាំងមកធ្លាក់តាមតំបន់ព្រំដែន ក្នុងភូមិសាស្ត្រឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ប្រមាណ៣៣គ្រាប់
  - យោធាថៃបានបាញ់កាំភ្លើងធំចេញពីនាវាចម្បាំង ធ្លាក់ចូលក្នុងសមុទ្រប្រហែល១០គ្រាប់ មុខភូមិសាស្ត្រកោះយ៉ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
  - មានឧទ្ធម្ភាគចក្រថៃ១គ្រឿង បានចុះដាក់ស្បៀងឱ្យកម្លាំងរបស់គេ នៅចំណុច៣២៩ ចំនួន១លើក
  - មានយន្តហោះF16 របស់ថៃ១គ្រឿងបានហោះឆ្លងកាត់ពីលើប៉ុស្តិ៍២០៧ ចំនួន១លើក
  - មាននាវាចម្បាំងកងទ័ពជើងទឹកថៃ ចំនួនពី១គ្រឿង ទៅ៥គ្រឿង បានល្បាតនៅមុខភូមិសាស្ត្រកោះគុត ទល់មុខភូមិសាស្ត្រកោះយ៉ ភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ចំនួន២៥លើក
  - ថៃបានបង្ហោះដ្រូនចំនួន៤លើក ដូចខាងក្រោម៖
    - ដ្រូន១គ្រឿង បានហោះចេញពីបន្ទាយរបស់គេ ឆ្លងកាត់ពីលើប៉ុស្តិ៍គិរីវង់ មានកម្ពស់ប្រហែល១៥០ម៉ែត្រ
    - ដ្រូន១គ្រឿង បានហោះពីលើប៉ុស្តិ៍គិរីវង់កម្ពស់ប្រហែល៥០០ម៉ែត្រ សំកាំងប្រហែល១នាទី
    - មានយន្តហោះស៊ើបការណ៍ (ដ្រូនប្រភេទធំ) ១គ្រឿង ហោះឆ្វែលពីលើទីបញ្ជាការវរៈ និងខាងមុខប៉ុស្តិ៍ពយកម្ពស់ប្រហែល៤០០ម៉ែត្រ
    - ដ្រូន១គ្រឿង បានហោះកម្ពស់ប្រហែល១០០ម៉ែត្រ នៅពីលើចម្ការកៅស៊ូរក្រោយប៉ុស្តិ៍ទាហាន (ស៊ើបការណ៍) ដែលមានលេខ និយាមការ E 270880, N 1302918
  - មានទាហានថៃឈុតប៉ារ៉ា១០នាក់ បានកាត់ស្មៅបរិវេណជុំវិញតម្រុយបង្គោលសីមាលេខ៧១ កម្លាំងប៉ុស្តិ៍គិរីវង់សហការជាមួយកម្លាំង(ខ.ម)ស៊ើបការណ៍វរៈ៣៣៧ បានធ្វើការហាមឃាត់ និងបានពិភាក្សាគ្នាប្រសិន បើមានការកាត់ស្មៅនៅចំណុចទីតាំងនេះសុំឱ្យភាគីខាងទាហានថៃជូនដំណឹងជាមុនភាគីថៃក៏បានឯកភាព
  - មានទាហានឈុតប៉ារ៉ាថៃចំនួន៣ក្រុមប្រហែល៤០នាក់ បានល្បាតពីគោលដៅក្រោយផ្ទះតាពៅ ដែលមានលេខនិយាមកា E.272049-N.1300370 មកដល់ចំណុចគោលដៅមុខអណ្តូងទឹក ដែលមានលេខនិយាមកា E.270843-N.1302970
  - ភាគីថៃបានបញ្ជូនប្រជានេសាទកម្ពុជា ដែលកងទ័ពជើងទឹកថៃបានចាប់ទូកនេសាទ១គ្រឿង និងប្រជានេសាទកម្ពុជា៤នាក់ប្រុស ឱ្យវិលត្រឡប់មកកម្ពុជាវិញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម។ ចំពោះទូកនេសាទខាងអាជ្ញាធរថៃមិនទាន់បានប្រគល់ឱ្យមកវិញទេដោយរង់ចាំដោះស្រាយពេលក្រោយ

- មានទូកនេសាទ១គ្រឿង របស់ប្រជាពលរដ្ឋរស់នៅភូមិ៣ ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ត្រូវបានកងទ័ពជើងទឹកថៃ ចាប់នៅចំណុចមុខមាត់ពាមប៉ាក់ខ្លង ចម្ងាយប្រមាណ៦,៥០ម៉ៃ ពីទីបញ្ជាការ វរសេនាតូចនគរបាលការពារព្រំដែនទឹកលេខ២៦៩ ក្នុងភូមិ-ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ នៅលើទូកមានមនុស្ស៣នាក់(ប្រុស)។ ករណីនេះ ត្រូវបានកងទ័ពជើងទឹកថៃចាប់អូសទូក និងមនុស្សយកទៅប្រទេសថៃ
- ទាហានជើងទឹកថៃ បានចាប់ទូកដឹកទំនិញ៥គ្រឿង(ទូកពលរដ្ឋកម្ពុជា២គ្រឿង និងទូកពលរដ្ឋថៃ៣គ្រឿង) នៅក្នុងស្រុកខ្លងយ៉ៃ ខេត្តត្រាត ប្រទេសថៃ។ ទូកដឹកទំនិញទាំង៥គ្រឿង មានគោលបំណងដឹកទំនិញពីប្រទេសថៃចូលមកប្រទេសកម្ពុជា នៅលើទូកមានមនុស្ស៧នាក់(ពលរដ្ឋកម្ពុជា៤នាក់ និងពលរដ្ឋថៃ៣នាក់) ក្នុងនោះមានពលរដ្ឋកម្ពុជាម្នាក់បានលោតទឹកគេចខ្លួន។ ហើយត្រូវបានទាហានជើងទឹកថៃឃាត់ខ្លួនបាន៦នាក់ (ពលរដ្ឋថៃ៣នាក់មិនស្គាល់អត្តសញ្ញាណ និងពលរដ្ឋកម្ពុជា៣នាក់)។ ចំពោះពលរដ្ឋខ្មែរដែលលោតទឹកគេចខ្លួន១នាក់ បានវិលត្រឡប់មកផ្ទះវិញក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ដោយសុវត្ថិភាព។ ហើយពលរដ្ឋខ្មែរទាំង៣នាក់ អាជ្ញាធរថៃកំពុងបន្តនីតិវិធីបញ្ជូន ទៅអនុវត្តច្បាប់អន្តោប្រវេសន៍របស់ប្រទេសថៃ។
- សត្វព្រាបបំពាក់ប្រព័ន្ធ GPS : ចំនួន២ក្បាល
  - កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រោយប្រស់ ស្រុកកោះកុង បានទទួលសត្វព្រាប១ក្បាល ពណ៌ប្រផេះ ពីប្រជាពលរដ្ឋដែលសង្ស័យថាមានបំពាក់ឧបករណ៍ (GPS) នៅជើងខាងស្តាំពាក់កងពណ៌បៃតង មានលេខ 0830288999 និង0830299888 និងជើងខាងឆ្វេងមានពាក់កងពណ៌ក្រហម។
  - កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ បានទទួលសត្វព្រាប១ក្បាល ពណ៌ប្រផេះលាយស ពីប្រជាពលរដ្ឋដែលសង្ស័យថា មានបំពាក់ឧបករណ៍ (GPS) ជើងខាងស្តាំពាក់កងលេខសម្គាល់ CHA 2025 THAILAND 11107 និង ជើងខាងឆ្វេង SK098-056-8401។ ឧបករណ៍ និងសត្វព្រាបទាំង២ក្បាលខាងលើ កម្លាំងប៉ុស្តិ៍បានធ្វើការកម្ទេចចោលអស់
- កម្លាំងជំនាញនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ សហការជាមួយកម្លាំងពាក់ព័ន្ធ បានចាប់បញ្ជូនជនជាតិថៃឱ្យត្រឡប់ ទៅប្រទេសថៃវិញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាមចំនួន៣លើក ស្មើនឹង៣១នាក់ ស្រី១៦នាក់ ពីបទលួចឆ្លងដែន និងស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់
- កម្លាំងជំនាញអនុវត្តនីតិវិធី និងស៊ើបអង្កេត នៃស្នងការដ្ឋាននគរបាលខេត្តកោះកុង និងកម្លាំងជំនាញនៃអធិការដ្ឋាននគរបាលស្រុកមណ្ឌលសីមា បានចាប់បញ្ជូនជនជាតិថៃ១២នាក់ ស្រី៧នាក់ ឱ្យត្រឡប់ទៅប្រទេសថៃវិញតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ដែលលួចឆ្លងដែនចូលប្រទេសកម្ពុជាដោយខុសច្បាប់ តាមរបៀងធម្មជាតិ ព្រៃភ្នំក្នុងភូមិសាស្ត្រឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- អាជ្ញាធរថៃ បានចាប់បញ្ជូនពលករខ្មែរមកពីប្រទេសថៃតាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម១៧លើក មានចំនួន១២១នាក់ ស្រី២៩នាក់ ពេលមកដល់ត្រូវបានអាជ្ញាធរមានសមត្ថកិច្ចទទួលសួរសុខទុក្ខលើកទឹកចិត្ត និងផ្តល់មធ្យោបាយដឹកជញ្ជូនទៅកាន់ស្រុកកំណើតរបស់ពួកគាត់
- ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការព្រំដែនថ្នាក់យោធភូមិភាគ កម្ពុជា-ថៃ (RBC) រវាងយោធភូមិភាគទី៣ ភាគីកម្ពុជា និងបញ្ជាការការពារព្រំដែនចន្ទបុរី-ត្រាត ភាគីថៃ បានជួបប្រជុំគ្នា នៅច្រកទ្វារព្រំដែនអន្តរជាតិចាំយាម-ហាតលិក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា ក្រោមការសង្កេតការណ៍ពីក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) របស់កម្ពុជា និងថៃផងដែរ។ ក្រុមលេខាធិការរបស់កម្ពុជាដឹកនាំដោយឧត្តមសេនីយ៍ទោ មុំ សាម៉ុឌី មេបញ្ជា ការរងយោធភូមិភាគទី៣ និងក្រុមលេខាធិការរបស់ថៃ ដឹកនាំដោយ វរនាវឹងក ឧត្តម គុន សិរិប៉ាន់យ៉ោ នាយសេនាធិការ បញ្ជាការ កងការពារព្រំដែនចន្ទបុរី-ត្រាត។ កិច្ចប្រជុំនេះ ដោយសារតែភាគីទាំងពីរមិនទាន់រកឃើញនូវចំណុចកណ្តាលរួមគ្នាមួយនៅឡើយ និងបានឯកភាពគ្នាដកឃ្លាវិលត្រឡប់ទៅ

ទីបញ្ហាការរៀងខ្លួនវិញដោយបន្តផ្លាស់ប្តូរឯកសារ និងពិភាក្សាគ្នា ឈានដល់ការឯកភាពគ្នានាពេលខាងមុខ ទើបមានការរៀបចំពិធីចុះហត្ថលេខា។

- **សកម្មភាពសហគមន៍-ពលរដ្ឋតវ៉ាផ្សេងៗ ៖** កើតឡើង១២លើក ដូចខាងក្រោម ៖
  - មានប្រជាពលរដ្ឋតវ៉ាដីធ្លី(ក្រុម៩៥៥គ្រួសារ) បានប្រមូលផ្តុំគ្នាប្រជុំ នៅក្នុងភូមិតាធង ឃុំដងពែង ស្រុកស្រែអំបិល សមាជិកចូលរួម៨៦នាក់ ស្រី៦០នាក់ ឡើងទៅសាលាស្រុកស្រែអំបិល ខាងសាលាស្រុកមិនឯកភាពសំណើរបស់ក្រុមពួកគាត់ទេ គឺសំណើសុំដីសម្បទានសង្គមកិច្ច
  - មានប្រជាពលរដ្ឋតវ៉ាដីធ្លី (ក្រុម១៩៧គ្រួសារ, ក្រុម៩៥៥គ្រួសារ និងក្រុម១៧៥គ្រួសារ) ៖
    - បានប្រមូលផ្តុំគ្នាប្រជុំនៅក្នុងភូមិតានី ឃុំជីខលើ ស្រុកស្រែអំបិល មានគ្នា៩៥នាក់ ស្រី៧៥នាក់ ដើម្បីប្រារព្ធទិវាសិទ្ធិមនុស្ស អន្តរជាតិខួបលើកទី៧៧ ជំរុញឱ្យមានការដោះស្រាយបញ្ហាផ្តល់ដីសម្បទានសង្គមកិច្ច ដល់ប្រជាពលរដ្ឋដែលខ្វះខាត និងផ្សព្វផ្សាយលើកទឹកចិត្តសហគមន៍ឱ្យថែរក្សាបរិស្ថាន និងស្តារជីវចម្រុះ
    - បានប្រមូលផ្តុំគ្នានៅភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ចំនួន៣៥នាក់ ស្រី២២នាក់ ដើម្បីធ្វើបុណ្យសហគមន៍ និងយុវជន រួមគ្នាថែរក្សាគ្រាប់ពូជ របៀបបុរាណ និងថែរក្សាធនធានធម្មជាតិ
  - មានកម្មករសំណង់ បានមកប្រមូលផ្តុំគ្នាបិទផ្លូវចូលក្រុមហ៊ុនផេនដា ចំនួន៤លើក ស្ថិតក្នុងភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ដើម្បីទាមទារប្រាក់ពលកម្ម ៖
    - លើកទី១ មានកម្មករសំណង់ប្រមាណ៣៥០នាក់ ដើម្បីទាមទារប្រាក់ពលកម្មរបស់ពួកគាត់រយៈពេល ៣ខែ ដោយក្រុមហ៊ុនបានសន្យាថានៅថ្ងៃទី០៧-១២-២០២៥ នឹងបើកជូនពួកគាត់ តែដល់ថ្ងៃទី៨ ហើយ មិនឃើញបើកប្រាក់ ទើបបណ្តាលឱ្យពួកគាត់បិទផ្លូវចូលក្រុមហ៊ុនតែម្តង។ ក្រោយមកតំណាងក្រុមហ៊ុនបានសម្របសម្រួលសុំបើកប្រាក់ខែជូនកម្មករ២ខែសិន និងសុំពន្យារពេលបើកប្រាក់ខែ១ខែទៀតនៅពេលក្រោយ
    - លើកទី២ មានកម្មករសំណង់ប្រមាណ៥០០នាក់ ដើម្បីទាមទារបើកប្រាក់ពលកម្មរបស់ពួកគាត់២ខែ ដែលក្រុមហ៊ុនទាំងពីរមិនបានបើកជូនពួកគាត់។ ក្រោយការសម្របសម្រួលពីអាជ្ញាធរឃុំ និងតំណាងក្រុមហ៊ុនទាំងពីរ បានយល់ព្រមបើកប្រាក់ពលកម្ម២ខែជូនកម្មករ (បើក២លើក) លើកទី១ ថ្ងៃទី២-០១-២០២៦, លើកទី២ ថ្ងៃទី២០-០១-២០២៦ លុះដល់ពេលវេលា កំណត់ពុំឃើញខាងក្រុមហ៊ុនបើកប្រាក់ឱ្យ
    - លើកទី៣ មានកម្មករសំណង់ប្រមាណ២០០នាក់ ដើម្បីទាមទារបើកប្រាក់ពលកម្មរបស់ពួកគាត់ ព្រោះគ្មានតំណាងក្រុមហ៊ុនណាមួយចេញមកសម្របសម្រួលទេ
    - លើកទី៤ មានក្រុមកម្មករប្រមាណ៣០០នាក់ ក្នុងនោះមានបុគ្គលិកកម្មករប្រមាណ៣០នាក់ បានកាន់ដំបង និងដុំថ្មចូលវាយកញ្ចក់អគារ ខ្លោងទ្វារផ្លូវចូលក្រុមហ៊ុនខូចខាតសម្ភារមួយចំនួន និងរថយន្ត ៣គ្រឿង ម៉ូតូ៤៦គ្រឿង របស់បុគ្គលិកកម្មករក្រុមហ៊ុន។ ក្រោយវាយបំផ្លិចបំផ្លាញរួចពួកគេក៏បាននាំគ្នាគេចខ្លួនបាត់អស់ និងក្រុមអ្នកតវ៉ាទាំងអស់បានរំសាយ។ ករណីនេះកម្លាំងកំពុងធ្វើការស្រាវជ្រាវបន្ត
  - មានប្រជាពលរដ្ឋចំនួន១៥នាក់ ស្រី១០នាក់ តំណាងប្រជាពលរដ្ឋ៥៤គ្រួសារ ប្រមូលផ្តុំគ្នាប្រជុំ នៅចំណុចសាលាឃុំថ្មស គោលបំណងដាក់ញត្តិនៅសាលាឃុំ ៖
    - ដើម្បីឱ្យអាជ្ញាធរជួយរកដំណោះស្រាយបញ្ហាដីធ្លីរបស់ពួកគាត់នៅ ចំណុចអូរយូយ៉ា ស្ថិតក្នុងភូមិចម្លងគោ ឃុំថ្មស ស្រុក បូទុមសាគរ
    - ដើម្បីដាក់ញត្តិតវ៉ាបញ្ហាដីធ្លី ប៉ុន្តែឯកសារមិនគ្រប់គ្រាន់ ទើបខាងសាលាស្រុកឱ្យពួកគាត់ទៅធ្វើឯកសារថ្មីឱ្យបានគ្រប់គ្រាន់សិន ទើបខាងសាលាស្រុកទទួល

- មានកម្មករចំនួន៣០នាក់ ស្រី៨នាក់ បានមកកាន់សាលាខេត្តកោះកុង ដើម្បីសុំឱ្យថ្នាក់ដឹកនាំខេត្តជួយអន្តរាគមន៍ចំពោះក្រុមហ៊ុន ផេនដា រ៉ូដប្រ៊ីដ មានទីតាំងស្ថិតនៅភូមិព្រែកខ្សាច់ ឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ដោយក្រុមហ៊ុនមិនបានបើកប្រាក់ឈ្នួលឱ្យពួកគាត់ចំនួន៤ខែមកហើយ។ ករណីនេះ តំណាងសាលាខេត្ត បានឱ្យពួកគាត់ត្រឡប់ទៅវិញសិន ដោយរង់ចាំដំណោះស្រាយនៅពេលក្រោយក្នុងរយៈពេល១៥ថ្ងៃទៀត
- មានសកម្មជនតវ៉ាដីធ្លី(ក្រុម១២៩គ្រួសារ, ក្រុម៦១គ្រួសារ និងក្រុម៨៤៣គ្រួសារ) រស់នៅក្នុងឃុំកណ្ដាល ស្រុកបូទុមសាគរ បានធ្វើដំណើរទៅរាជធានីភ្នំពេញ តាមមធ្យោបាយរថយន្តសាំងយ៉ុង៣គ្រឿង មានគ្នាចំនួន២៥នាក់ ស្រី១៧នាក់ ដើម្បីទៅចូលរួមទិវាពលកម្មអន្តរជាតិ នៅសាលមហាស្រពកោះពេជ្រ ប្រារព្ធឡើងថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៦
- មានសកម្មជនតវ៉ាដីធ្លី (ក្រុម១៩៧គ្រួសារ និងក្រុម៩៥៥គ្រួសារ) រស់នៅក្នុងឃុំជីខលើ ស្រុកស្រែអំបិល បានឡើងទៅរាជធានីភ្នំពេញ មានគ្នាចំនួន៣៩នាក់ ស្រី២០នាក់ ដោយមធ្យោបាយធ្វើដំណើររថយន្តសាំងយ៉ុង ៣គ្រឿង គោលបំណងឡើងទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីទៅតាមដានញត្តិស្នើសុំដីសម្បទានសង្គមកិច្ចរបស់ពួកគាត់ ដែលបានដាក់នៅសាលាខេត្តកោះកុងកន្លងមក ហើយខាងសាលាខេត្តបានប្រាប់គាត់ថាញត្តិរបស់ពួកគាត់បានបញ្ជូនទៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៅរាជធានីភ្នំពេញរួចហើយ។ ក្រែងមិនពិតប្រាកដ ទើបពួកគាត់នាំគ្នាឡើងទៅសុំជួបសួរនាំមន្ត្រីនៅក្រសួងដោយផ្ទាល់ តើញត្តិពួកគាត់ពិតជាបានបញ្ជូនមកមែនដែរទេ និងដើម្បីឱ្យក្រសួងជួយពន្លឿនការដោះស្រាយរឿងដីធ្លីនេះជូនពួកគាត់។

- **សកម្មភាពគណបក្សនយោបាយ ៖** គណបក្សឆន្ទៈខ្មែរ មានសកម្មភាពក្នុងមូលដ្ឋានចំនួន៦លើក ដូចខាងក្រោម៖
  - ថ្ងៃទី២៥-០១-២០២៦ បានធ្វើពិធីប្រជុំសំណេះសំណាលថ្នាក់ដឹកនាំ និងសមាជិកគណបក្ស នៅក្នុងភូមិតាំកន់ ឃុំកណ្ដាល ស្រុកបូទុមសាគរ ប្រកាសសេចក្តីសំរេចតែងតាំង ប្រគល់ត្រាជូនប្រធានគណបក្សស្រុក ដឹកនាំប្រជុំដោយ លោក គង់ ម៉ូលីកា អគ្គលេខាធិការគណបក្ស, លោក ឌី សុជីវ៉ាវុធ អគ្គលេខាធិការរងគណបក្ស និងសមាជិកគណបក្ស ចូលរួមចំនួន៧០នាក់ ស្រីចំនួន៥០នាក់។ និងបានធ្វើសកម្មភាពលើកស្លាកគណបក្ស១១ផ្ទាំង នៅក្នុងស្រុកបូទុមសាគរ ស្រុកកោះកុង ក្រុងខេមរភូមិន្ទ ស្រុកគិរីសាគរ និងស្រុកស្រែ-អំបិល សមាជិកចូលរួម៧៧នាក់ ស្រី១៦នាក់។

- **សកម្មភាពអង្គការ-សមាគម និងគ្រឹះស្ថានអប់រំ ៖** កើតឡើង១៣លើក ដូចខាងក្រោម ៖
  - ក្រុមការងារក្រុមហ៊ុន Climate+ptl. L.T.D បាន៖
    - បើកកិច្ចប្រជុំផ្សព្វផ្សាយអំពីការព្រមព្រៀងដោយសេរីជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់អំពីការអនុវត្តគម្រោងរេដបូក ដល់ប្រជាពលរដ្ឋរស់នៅភូមិ១ ឃុំកោះកាពិ ស្រុកកោះកុង មានអ្នកចូលរួម៥០នាក់ ស្រី៤០នាក់
    - បើកកិច្ចប្រជុំផ្សព្វផ្សាយអំពីការ ព្រមព្រៀងដោយសេរីជាមុន និងដោយមានព័ត៌មានគ្រប់គ្រាន់អំពីការអនុវត្តគម្រោងរេដបូកព្រៃកោងកាង ដល់ប្រជាពលរដ្ឋរស់នៅភូមិកោះកុងក្នុង ឃុំត្រពាំងរូង ស្រុកកោះកុង ដែលមានអ្នកចូលរួម ២៩នាក់ ស្រី២៣នាក់
  - នៅតំបន់សេដ្ឋកិច្ចពិសេស ចេដាង មានកម្មវិធីដំណើរទស្សនកិច្ចរបស់ក្រុមនិស្សិត មកពីសកលវិទ្យាល័យអាស៊ី អឺរ៉ុប ដើម្បីទស្សនកិច្ចសិក្សាក្នុងតំបន់សេដ្ឋកិច្ចពិសេសចេដាង ស្ថិតនៅភូមិអូរជ្រៅ ឃុំបឹងព្រាវ ស្រុកស្រែអំបិល សមាសភាពចូលរួមចំនួន១៤០នាក់ ស្រី៨០នាក់ ព្រះសង្ឃ៦អង្គ
  - ក្រុមការងារអង្គការ អេឌីប៊ី (ADB) បានចុះមកបើកវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យគុណភាពទឹក (ជាតិពុលក្នុងទឹក) ក្នុងការធ្វើវារីវប្បកម្មគ្រុំចំពុះទា និងអយស្ទ័រដល់សហគមន៍នេសាទជ្រោយប្រស់ ដោយមានការចូលរួមពីសមាជិកសហគមន៍ និងប្រជានេសាទចំនួន១៥នាក់ ស្រី១នាក់ នៅភូមិជ្រោយប្រស់ ឃុំជ្រោយប្រស់ ស្រុកកោះកុង

- ក្រុមការងារអង្គការ (CBN Cambodia) បាន៖
  - ចុះមកពិនិត្យជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅមណ្ឌលសុខភាពកោះកាពិ ក្នុងភូមិ១ ឃុំកោះកាពិ ស្រុកកោះកុង
  - ចុះមកពិនិត្យជំងឺជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ នៅវិហារពួកជំនុំមហាសម្រួតកោះស្រឡៅ ក្នុងភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង
- ក្រុមការងារអង្គការអាដហុក បានធ្វើការផ្សព្វផ្សាយអំពីអំពើហិង្សាក្នុងគ្រួសារទាក់ទងយេនឌ័រ អំពើជួញដូរមនុស្ស និងសុវត្ថិភាពក្នុងការចំណាកស្រុកដល់ប្រជាពលរដ្ឋតាំងជីវ្ហី (ក្រុម១៩៧គ្រួសារ) នៅភូមិតានី ឃុំជីខលើ ស្រុកស្រែអំបិល អ្នកចូលរួមស្តាប់៤៥នាក់ ស្រី៣០នាក់
- ក្រុមហ៊ុនរ៉ូតូមេនសីរៀចឹម(ខេមបូឌា)ខមភេនីលីមីធីត បានចុះមកចែកអំណោយដល់សិស្សានុសិស្ស នៅសាលាបឋមសិក្សាភូមិកោះចំនួន៥៩នាក់ ស្រី៣៥នាក់ ក្នុងម្នាក់ៗទទួលបានសម្ភារសិក្សាមួយចំនួន និងថវិកា៥ពាន់រៀល និងលោកគ្រូ អ្នកគ្រូ ៤នាក់ ក្នុងម្នាក់ៗទទួលបានថវិកា២០ម៉្មឺនរៀល និងផ្តល់ថវិកាជូនសាលាចំនួន ៣លានប្រាំពាន់រៀល ដើម្បីអភិវឌ្ឍន៍សាលា និងដាំកូនឈើចម្រុះក្នុងសាលា១០០ដើម ព្រមទាំងបានសម្អាតបរិស្ថានជុំវិញសាលា
- ក្រុមការងារអង្គការសម្ព័ន្ធសត្វព្រៃ បានសហការនិងក្រសួងបរិស្ថាន បានប្រជុំពិភាក្សាការសិក្សាវាយតម្លៃហានិភ័យជំងឺ (Disease Risk Assessment) នៅតំបន់ស្តារសេត្វខ្លាធំក្នុងតំបន់ជួរភ្នំក្រវាញ ខេត្តកោះកុង នៅសាលាឃុំតាតៃក្រោម ភូមិអន្លង់វ៉ាក់ ឃុំតាតៃក្រោម ស្រុកកោះកុង សមាសភាពរួលរួម១១នាក់ ស្រី៣នាក់
- ក្រុមហ៊ុនសប្បុរសធម៌ MEINHARDT Consultants(cambodia) (មេនហាដ ខនសាល់ធេន (ខេមបូឌា) ចុះចែកអំណោយ សម្ភារសិក្សាជូនសិស្សានុសិស្ស១៣២នាក់ នៅសាលាបឋមសិក្សាឧបសម្ព័ន្ធគងធា ក្នុងភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល
- ក្រុមការងារអង្គការ មេត្តាធម្មជាតិ បាននាំយកអំណោយមកចែកជូនប្រជាពលរដ្ឋចាស់ជរាចំនួន៤២គ្រួសារ ដោយក្នុង១គ្រួសារទទួលបានគ្រឿងឧបភោគ-បរិភោគ និងថវិកា៥ម៉ឺនរៀល និងបានសហការជាមួយក្រសួងបរិស្ថាន និងរដ្ឋបាលខេត្តកោះកុង រៀបចំប្រារព្ធពិធីបុណ្យកោងកាងសន្តិភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិត អ៊ាង សុផល្លែត រដ្ឋមន្ត្រីក្រសួងបរិស្ថាន នៅភូមិកោះស្រឡៅ ឃុំកោះកាពិ ស្រុកកោះកុង
- ក្រុមការងារអង្គការ (YCC) បានបើកកិច្ចប្រជុំផ្សព្វផ្សាយ ស្តីពីសេវាសាធារណៈសមភាពយេនឌ័រ និងបណ្ណសមធម៌ នៅសាលាឃុំជ្រោយប្រស់ មានអ្នកចូលរួមចំនួន៣៧នាក់ ស្រី២៦នាក់
- អង្គការសត្វព្រៃ និងរុក្ខជាតិ បានពិធីទម្លាក់ថ្មបេតុងសិប្បនិម្មិតក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះស្តេចចំនួន៣៨ប្រអប់ ស្ថិតក្នុងឃុំកោះស្តេច ស្រុកគិរីសាគរ មានការអញ្ជើញចូលរួមពីសមត្ថកិច្ច អាជ្ញាធរខេត្ត ស្រុក ឃុំ ប្រជានេសាទ និងគណៈកម្មការសហគមន៍នេសាទសម្រស់កោះស្តេច។

– **សកម្មភាពសហគមន៍ ពលរដ្ឋ និងសាសនា ៖** មានក្រុមសាសនាយេស៊ូគ្រិស្តចំនួន២នាក់ ស្រី១នាក់ បានចុះផ្សព្វផ្សាយវិស័យសាសនាព្រះយេស៊ូគ្រិស្ត និងបានចែកនំចំណីដល់ក្មេងៗ និងមនុស្សចាស់ នៅភូមិតានី ឃុំថ្មីមាស ស្រុកគិរីសាគរ ចំនួន១០លើក។

**តារាងទី២៣៖ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ និងចរាចរណ៍**

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គ្រោះថ្នាក់ចរាចរណ៍ | ០ | ៥ | ៥ |
| ២ | គ្រោះថ្នាក់ផ្សេងៗ | ០ | ៤០ | ៤០ |

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ៣ | បទល្មើសគ្រឿងញៀន | ០ | ២២ | ២២ |
| ៤ | បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | ០ | ៥ | ៥ |
| ៥ | បទល្មើសសេដ្ឋកិច្ច | ០ | ០ | ០ |
| ៦ | ល្បែងស៊ីសង | ០ | ០ | ០ |
| ៧ | ក្មេងទំនើង | ០ | ១១ | ១១ |
| ៨ | បទល្មើសផ្សេងៗ | ០ | ០ | ០ |

២.៤.៣-ការងារគ្រប់គ្រងជនអន្តោប្រវេសន្ត

- **ការគ្រប់គ្រងតាមកំពង់ផែសមុទ្រ (តាមច្រកកំពង់ផែសមុទ្រស្រែអំបិល និងប៉ាក់ខ្លង) ៖**
  - នាវិកជាជនបរទេសចូលចំនួន៤៨នាក់ ស្រី១៨នាក់ មាន១សញ្ជាតិថៃ ស្មើនឹងជលយានយន្ត៩គ្រឿង អូសស្រឡាង២៥គ្រឿង
  - នាវិកជាជនបរទេសចេញចំនួន៤៨នាក់ ស្រី១៨នាក់ មាន១សញ្ជាតិថៃ ស្មើនឹងជលយានយន្ត៩គ្រឿង អូសស្រឡាង២៥គ្រឿង
- **ការគ្រប់គ្រង ការស្នាក់នៅរបស់ជនបរទេសមិនមែនអន្តោប្រវេសន្ត ៖**
  - ជនបរទេសស្នាក់នៅរយៈពេលខ្លី មានចំនួន៣.០៧១នាក់ ស្រី១.៤៦៤នាក់ មាន៥៧សញ្ជាតិ
  - ជនបរទេសស្នាក់នៅរយៈពេលវែង មានចំនួន៣.០០៧នាក់ ស្រីចំនួន៧៦៥នាក់ មាន៣៣សញ្ជាតិ។
- **ការគ្រប់គ្រងប្រព័ន្ធវត្តមានជនបរទេស(FPCS)៖**

○ បានចុះត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS) ដល់ម្ចាស់ទីតាំងដែលមានជនបរទេសស្នាក់នៅ និងប្រកបអាជីវកម្មផ្សេងៗសរុបបានចំនួន២៨គោលដៅ មានដូចជាសហគ្រាសចំនួន៥គោលដៅ, ក្រុមហ៊ុនចំនួន២គោលដៅ, សណ្ឋាគារចំនួន១គោលដៅ, ផ្ទះសំណាក់ចំនួន៤គោលដៅ, ផ្ទះជួលចំនួន៣គោលដៅ, អាគារជួលចំនួន១១គោលដៅ, អាហារដ្ឋានចំនួន១គោលដៅ, ហាងលក់ទំនិញចំនួន១គោលដៅ។ ក្រុមការងារបានពិនិត្យឃើញមានជនបរទេសស្នាក់នៅប្រកបអាជីវកម្មផ្សេងៗសរុបចំនួន២៥២នាក់ ស្រី១១៤នាក់ មាន១៤សញ្ជាតិ(ចិន, វៀតណាម, ភូមា, ឡាវ, ហ្វីលីពីន, ម៉ាឡេស៊ី, ឥណ្ឌូនេស៊ី, បង់ក្លាដេស, នេប៉ាល់, មីយ៉ាន់ម៉ា, ថៃ, កូរ៉េខាងត្បូង, ម៉ាឡេស៊ី និងជប៉ុន) ម្ចាស់ទីតាំងមួយចំនួនមានប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS)រួចហើយ និងម្ចាស់ទីតាំងមួយចំនួនផ្សេងទៀត បានស្នើសុំបង្កើតប្រព័ន្ធថ្មី និងទទួលយកការបណ្ដុះបណ្ដាលបន្ថែមអំពីការគ្រប់គ្រងជនបរទេសក្នុងទីតាំងរបស់ខ្លួនតាមប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS)

○ បានចុះភ្ជាប់ប្រព័ន្ធ(FPCS) ជូនដល់ម្ចាស់ទីតាំងដែលមានជនបរទេសស្នាក់នៅ ប្រកបអាជីវកម្មផ្សេងៗសរុបបានចំនួន៨៤គោលដៅមានដូចជាសណ្ឋាគារចំនួន២គោលដៅ, ផ្ទះសំណាក់ចំនួន១៨គោលដៅ, ផ្សារទំនើបចំនួន១គោលដៅ, ហាងលក់ទូរសព្ទចំនួន១គោលដៅ, អាហារដ្ឋានចំនួន៤គោលដៅ, ក្លឹបស្នូកឃ័រចំនួន១គោលដៅ, ហាងលក់គ្រឿងសមុទ្រចំនួន១គោលដៅ, ផ្ទះជួលចំនួន៤៦គោលដៅ, រីស៊ត(?)ចំនួន៦គោលដៅ, សហគមន៍ទេសចរណ៍ចំនួន១គោលដៅ, វារីអគ្គីសនីចំនួន១គោលដៅ, ឃ្លាំងជួលចំនួន១គោលដៅ និងបឹងហ្គាឡូចំនួន១គោលដៅ ដោយពិនិត្យឃើញមានជនបរទេសសរុបចំនួន៦៥៥នាក់ស្រី៨៩នាក់ ស្មើនឹង១៥សញ្ជាតិរួមមានចិន៤៤០នាក់ ស្រី៤៧នាក់, ម៉ាឡេស៊ី១១នាក់ ស្រី២នាក់, មីយ៉ាន់ម៉ា១៨នាក់ ស្រី៩នាក់, វៀតណាម៦៦នាក់ ស្រី២២នាក់, កូរ៉េខាងត្បូង២៨នាក់ប្រុស, បង់ក្លាដេស១០នាក់ប្រុស, ម៉ាឡាកាស៊ី៣នាក់ប្រុស, នេប៉ាល៧នាក់ប្រុស, ឡាវ៦នាក់ ស្រី២នាក់, ព្រុយនេ១នាក់ប្រុស, ឥណ្ឌា៤នាក់ប្រុស, ប៊ូតង់១នាក់ប្រុស, ហ្វីលីពីន៦នាក់ ស្រី៥នាក់, ប៉ាគីស្ថាន៣០នាក់ ស្រី២នាក់ អេហ្សីប២៤នាក់ប្រុស

○ បានឱ្យម្ចាស់ទីតាំងដាក់ពាក្យសុំបង្កើតគណនីនិងមានកិច្ចសន្យាក្នុងការរាយការណ៍វត្តមានជនបរទេសចូលមកស្នាក់នៅចាប់ពី២៤ម៉ោងឡើងទៅស្កេនលិខិតឆ្លងដែនចូលប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេសក្នុងព្រះរាជាណាចក្រកម្ពុជា(FPCS)

○ ការិយាល័យគ្រប់គ្រងជនបរទេស បានធ្វើការផាកពិន័យចំពោះម្ចាស់លំនៅឋាន មិនបានបញ្ចូលព័ត៌មានក្នុងប្រព័ន្ធគ្រប់គ្រងវត្តមានជនបរទេស(FPCS) ដូចខាងក្រោម៖

- រីស៊ត (ថ្មដា) ដែលមានម្ចាស់ឈ្មោះ KANG SHUNLI ភេទប្រុស ជនជាតិ ស្ថិតនៅ ភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- រីស៊ត (សារ៉េត រីស៊ត) ដែលមានម្ចាស់ឈ្មោះ អៀម សុផាន់ណែត ភេទស្រី ជនជាតិខ្មែរ ស្ថិតនៅភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- ផ្ទះជួល ដែលមានម្ចាស់ឈ្មោះ ដួង ភារ៉ូត ភេទប្រុស ជនជាតិខ្មែរ ស្ថិតនៅភូមិ២ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- លំនៅឋាន (អាគារក្លឹបម៉ាស្សា ស្បា) ដែលមានម្ចាស់ឈ្មោះ GE JUNFENG ភេទប្រុស ជនជាតិចិន ស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- ទីតាំងរស់នៅប្រមូលផ្តុំ ជាប្រភេទអាគារក្លឹបម៉ាស្សា និងស្បា ដែលមានអាសយដ្ឋានស្ថិតនៅភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា
- ទីតាំងរស់នៅប្រមូលផ្តុំ ជាប្រភេទផ្ទះរនេសាទ បឹងកាឡូ ដែលមានអាសយដ្ឋានស្ថិតនៅភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ
- លំនៅឋាន ដែលមានរីស៊ត ឈ្មោះ(DIAMOND PENINSULA HOTEL RESORT) ដែលមានអ្នកតំណាងម្ចាស់ទីតាំងឈ្មោះ វ៉ាន់ ឧស្សា ភេទប្រុស ជនជាតិខ្មែរ ដែលមានទីតាំងស្ថិតនៅ ភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ។

- **ការងារអធិការកិច្ចហត្ថពលកម្មបរទេស៖** ពុំមាន។
- **ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត ៖**

○ បានទទួលបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ពីនាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត និងជនភៀសខ្លួន ចំនួន៤១បណ្ណ ស្រីចំនួន២១បណ្ណ ដែលមានដូចខាងក្រោម៖

- បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូងចំនួន២នាក់ស្រី
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី១ ចំនួន៥នាក់ ស្រី៣នាក់
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី២ ចំនួន២នាក់ប្រុស
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី៣ ចំនួន២៨នាក់ ស្រី១៤នាក់
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍បន្តសុពលភាពលើកទី៣ ចំនួន៤នាក់ ស្រី២នាក់

○ បានប្រគល់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ ដល់ជនបរទេសអន្តោប្រវេសន្ត សរុបចំនួន១២គ្រួសារ មនុស្សរួមចំនួន៣៣នាក់ ស្រី១៧នាក់ ស្មើនឹង៣៣បណ្ណ មាន២សញ្ជាតិ (វៀតណាម-ចិន) ដែលមានដូចខាងក្រោម៖

- បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំនួន២នាក់ស្រី ស្មើនឹង២បណ្ណ មាន១សញ្ជាតិ វៀតណាម
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ ចំនួន២នាក់ ស្រី២នាក់ ស្មើនឹង២បណ្ណ មាន១សញ្ជាតិ វៀតណាម
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី២ ចំនួន១នាក់ប្រុស ស្មើនឹង១បណ្ណ មាន១សញ្ជាតិ វៀតណាម
- បណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី៣ ចំនួន១១គ្រួសារ មនុស្សរួមចំនួន២៦នាក់ ស្រី១២នាក់ ស្មើនឹង២៦បណ្ណ មាន២សញ្ជាតិ វៀតណាម-ចិន

○ បានទទួលពាក្យស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍ ពីជនបរទេសអន្តោប្រវេសន្តសរុបចំនួន៣៨គ្រួសារ មនុស្សរួមចំនួន៦៩នាក់ ស្រី៣៧នាក់ ស្មើនឹង២សញ្ជាតិ វៀតណាម និងចិន ដែលមានដូចខាងក្រោម ៖

- ស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង សរុបចំនួន១ស្រី មាន១សញ្ជាតិវៀតណាម
- ស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ សរុបចំនួន២នាក់ប្រុស មាន១សញ្ជាតិវៀតណាម
- ស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី២ សរុបចំនួន២នាក់ ស្រី១នាក់ មាន១សញ្ជាតិវៀតណាម
- ស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី៣ សរុបចំនួន១៦គ្រួសារ មនុស្សរួម៣៤នាក់ ស្រី១៨នាក់ មាន២សញ្ជាតិវៀតណាម និងចិន
- ស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី៤ សរុបចំនួន២១គ្រួសារ មនុស្សរួម៣០នាក់ ស្រី១៧នាក់ មាន១សញ្ជាតិវៀតណាម

ថវិកាបង់អាករបានពីបណ្ណស្នាក់នៅអចិន្ត្រៃយ៍៦៩នាក់ ស្មើនឹង១៧.២៥០.០០០៛ ។

○ បានបញ្ជូនពាក្យស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍សរុបបានចំនួន១០នាក់ ស្រី៤នាក់ និងថវិកាចំនួន២.៥០០.០០០៛ ទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត និងជនភៀសខ្លួនរួចរាល់

○ បានបញ្ជូនពាក្យស្នើសុំប័ណ្ណស្នាក់នៅអចិន្ត្រៃយ៍ និងបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍សរុបបានចំនួន៣០នាក់ ស្រី១៤នាក់ និងថវិកាចំនួន៧.៥០០.០០០៛ ទៅនាយកដ្ឋានជនបរទេសអន្តោប្រវេសន្ត និងជនភៀសខ្លួនរួចរាល់

○ បានផាកពិន័យអន្តរការណ៍ចំពោះជនបរទេសអន្តោប្រវេសន្តសរុបចំនួន២នាក់ប្រុស ស្មើនឹង១សញ្ជាតិវៀតណាម ដែលបានប្រើប្រាស់បណ្ណស្នាក់នៅអចិន្ត្រៃយ៍ហួសសុពលភាពតាមមាត្រា២១ និងពិន័យតាមប្រកាសលេខ១៧៥០ចំណុច(៥) ចំនួន១.០០០.០០០៛

○ បានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ពីជនបរទេសអន្តោប្រវេសន្ត សរុបបានចំនួន៤ឯកសារ រួមមានសៀវភៅស្នាក់នៅ(ក២)ចំនួន១ច្បាប់ សៀវភៅគ្រួសារ (ក៤)ចំនួន១ច្បាប់ សំបុត្របញ្ជាក់កំណើតចំនួន១ច្បាប់ និងសំបុត្របញ្ជាក់កំណើត១ច្បាប់ បានធ្វើរបាយការណ៍ និងដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីចំនួន៤ឯកសារ បញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍

○ មានជនបរទេសអន្តោប្រវេសន្តស្លាប់ចំនួន១នាក់ប្រុស សញ្ជាតិវៀតណាម អាស័យដ្ឋានភូមិត្រពាំង ឃុំស្រែអំបិល ស្រុកស្រែអំបិល មូលហេតុស្លាប់ដោយសារ ជំងឺប្រចាំកាយ (មហារីកសួត) សពជនបរទេសអន្តោប្រវេសន្តខាងលើ ត្រូវបានក្រុមគ្រួសារធ្វើបុណ្យតាមប្រពៃណី។

- **ជនបរទេសរងគ្រោះដោយបទល្មើសផ្សេងៗ៖** មាន៣លើក មនុស្សរួមមានចំនួន៦នាក់ ស្រី២នាក់ មាន២សញ្ជាតិ (ចិន និងនេប៉ាល់ រងរបួសស្រាល-ធ្ងន់ចំនួន៥នាក់ ស្រី២នាក់ និងស្លាប់ចិន១នាក់ប្រុស)
- **ជនបរទេសល្មើសច្បាប់អន្តោប្រវេសន៍៖** មាន២៦លើក មនុស្សរួមមានចំនួន៤៨៦នាក់ ស្រី២៤នាក់ មាន១១សញ្ជាតិ រួមមានចិន៤៣០នាក់ ស្រី១១នាក់, ចិនតៃវ៉ាន់១នាក់ប្រុស, ម៉ាឡេស៊ី១០នាក់ ស្រី១នាក់, នេប៉ាល់៥នាក់ប្រុស វៀតណាម៣នាក់ ស្រី១នាក់, កូរ៉េ២នាក់ប្រុស, ឥណ្ឌូនេស៊ី៤នាក់ ស្រី១នាក់, ថៃ១២នាក់ ស្រី៧នាក់ ,មីយ៉ាន់ម៉ា៥នាក់ ស្រី២នាក់, ឡាវ១នាក់ ស្រី១នាក់ និងបង់ក្លាដេស១៣នាក់ប្រុស ទៅស្នាក់ការត្រៀមបណ្តេញចេញខេត្តព្រះសីហនុ ដើម្បីបន្តនីតិវិធីពីបទលួចឆ្លងដែនចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា និងលួចស្នាក់នៅធ្វើការងារដោយខុសច្បាប់។
- **ជនបរទេសបង្កបទល្មើសផ្សេងៗ៖** ពុំមាន។
- **ជនបរទេសប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ៖** ពុំមាន។
- **ជនបរទេសប្រព្រឹត្តបទល្មើសផ្សេងៗ ៖** មាន៥លើក មនុស្សរួមមានចំនួន១៨៨នាក់ ស្រី២៩នាក់ មាន៨សញ្ជាតិ ចិន១៤០នាក់ ស្រី១៤នាក់, វៀតណាម២នាក់ប្រុស, ហ្វីលីពីន១នាក់ស្រី, ឥណ្ឌូនេស៊ី៣៨នាក់ ស្រី១២នាក់, ឡាវ១នាក់ស្រី, ជប៉ុន១នាក់ប្រុស, ចិនតៃវ៉ាន់១នាក់ប្រុស និងមីយ៉ាន់ម៉ា៤នាក់ ស្រី១នាក់ ។
  - ○ បានធ្វើការត្រួតពិនិត្យរដ្ឋបាលស្របតាមអនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ស្ថិតនៅទីតាំងផ្ទះលេខ៩០ ភូមិ១សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ បានធ្វើ

ការត្រួតពិនិត្យទីតាំងខាងលើក្រុមការងារបានឃាត់ខ្លួនជនបរទេសមានចំនួន១២នាក់ស្រី ៥នាក់ ស្មើនឹង៣សញ្ជាតិ។ ដកហូតវត្ថុតាងរួមមានលិខិតឆ្លងដែនសរុបជាក់ស្តែងចំនួន១៤ក្បាល មានមនុស្សជាក់ស្តែងចំនួន១២នាក់ (គ្មានលិខិតឆ្លងដែន១នាក់ប្រុសជនជាតិវៀត-ណាម) កុំព្យូទ័រយួរដៃ២១គ្រឿង កុំព្យូទ័រលើតុ២គ្រឿង IPAD៣គ្រឿង និងទូរសព្ទ៦០គ្រឿង។ បច្ចុប្បន្នជនបរទេសទាំង១២នាក់រួមទាំងវត្ថុតាងខាងលើបានយកមកកាន់ស្នងការដ្ឋាននគរបាលខេត្តកោះកុង រក្សាទុកដើម្បីបន្តនីតិវិធី

- បានចុះបង្ក្រាបទីតាំងបើកការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (ONLINE SCAMS) ទីតាំងអគារឆាងនៃ៣មានចំនួន១៣អគារ ស្ថិតក្នុងភូមិ៣មកាយ ឃុំកោះស្តេច ស្រុកគិរីសាគរ។ នៅក្នុងនោះបានធ្វើការឃាត់ខ្លួនជនបរទេសសរុបចំនួន៩៧នាក់ ស្រី១៦នាក់ ស្មើនឹង៥សញ្ជាតិ។បច្ចុប្បន្នជនបរទេសទាំងអស់ខាងលើត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីបន្តនីតិវិធី។
- បានចុះបង្ក្រាបទីតាំង (Online Scams) ១កន្លែង មានចំនួន២អគារ នៅចំណុចពយស្វាវ ស្ថិតក្នុងភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ ដូចខាងក្រោម ៖
    - ទីតាំងអគារទី១ ចំណុចពយស្វាវ ស្ថិតក្នុងភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ។ ក្នុងនោះបានធ្វើការនាំខ្លួនជនបរទេសមកសាកសួរសរុបចំនួន៤៦នាក់ ស្រី៣នាក់ ស្មើនឹង២សញ្ជាតិ។ បច្ចុប្បន្នជនបរទេសទាំងអស់ខាងលើកំពុងស្នាក់នៅបណ្តោះអាសន្នស្នងការដ្ឋាននគរបាលខេត្តកោះកុង ដើម្បីធ្វើការសាកសួរបន្ត និងបានធ្វើការត្រួតពិនិត្យ ទីតាំងជាក់ស្តែងអគារទី១ខាងលើ ជាលទ្ធផលពិនិត្យបានរកឃើញមាន និងបានដកហូតវត្ថុតាង រួមមានទូរសព្ទ១.៦៨៣គ្រឿង IPAD ២.១៨២ គ្រឿង កុំព្យូទ័រលើតុ២១៨គ្រឿង ធុងCPU ២៥គ្រឿង រថយន្ត៥គ្រឿង និងសម្ភារមួយចំនួន
    - ទីតាំងអគារទី២ នៅចំណុចពយស្វាវ ស្ថិតក្នុងភូមិព្រែកស្មាច់ ឃុំកោះស្តេច ស្រុកគិរីសាគរ។ ក្រុមការងារបានរកឃើញមាន និងបានដកហូតវត្ថុតាងរួមមានទូរសព្ទ២៨៨គ្រឿង កុំព្យូទ័រលើតុ២៣៥គ្រឿង ធុង CPU ចំនួន៩គ្រឿង និងសម្ភារមួយចំនួន។ វត្ថុតាងខាងលើក្រុមការងារ សង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា(Online Scams)។ ចំពោះវត្ថុតាងទាំងអស់ ក្រុមការងារសម្រេចយកទៅស្នងការដ្ឋាននគរបាលខេត្តកោះកុង រក្សាទុកជាបណ្តោះអាសន្ន ដើម្បីបន្តនីតិវិធីតាមច្បាប់
- បានចុះធ្វើវិធានការរដ្ឋបាលចំនួន១ទីតាំងឈ្មោះ ផ្ទះនេសាទ បឹងកាឡូ អ្នកតំណាងឈ្មោះពេជ្រ ភារិទ្ធ ភេទប្រុស ជនជាតិខ្មែរ ស្ថិតនៅចំនុចស្មាច់ង៉ាមមាត់ទឹក ភូមិស្មាច់មានជ័យ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរ-ភូមិន្ទ។ ក្រោយពីបានត្រួតពិនិត្យតាមបន្ទប់ក៏សង្ស័យមានការជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) រួចបានធ្វើការនាំខ្លួនជនជាតិចិនមកសាកសួរសរុបចំនួន១៦នាក់ប្រុស ស្មើនឹង១សញ្ជាតិចិន។ ជនជាតិចិនទាំងអស់កំពុងស្នាក់នៅបណ្តោះអាសន្នស្នងការដ្ឋាននគរបាលខេត្តកោះកុង ដើម្បីធ្វើការសាកសួរបន្ត និងបានធ្វើការត្រួតពិនិត្យ ទីតាំងជាក់ស្តែងខាងលើ ជាលទ្ធផលពិនិត្យបានរកឃើញមាន និងបានដកហូតវត្ថុតាង រួមមានទូរសព្ទ៧២គ្រឿង Computer Macbook ៣គ្រឿង Asus Expertbook ១គ្រឿង និងសម្ភារមួយចំនួន។ ចំពោះវត្ថុតាងខាងលើក្រុមការងារសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា(OnlineScams)ក្រុមការងារសម្រេចយកទៅស្នងការដ្ឋាននគរបាលខេត្តកោះកុងរក្សាទុកជាបណ្តោះអាសន្ន ដើម្បីបន្តនីតិវិធីតាមច្បាប់
- បានធ្វើការត្រួតពិនិត្យរដ្ឋបាលអនុវត្តអនុក្រឹត្យលេខ ០៣អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំនៅទីតាំងផ្ទះសំណាក់ ភីអេស(PS) ដែលមានម្ចាស់ផ្ទះសំណាក់ឈ្មោះគឹម សេងភេទស្រី ជនជាតិខ្មែរ ស្ថិតនៅចំណុចជាប់ស្ថានីយប្រេងឥន្ធនៈតេលាភូមិ២ សង្កាត់ដងទង់ ក្រុងខេមរ-ភូមិន្ទ ក្រោយពីបានត្រួតពិនិត្យតាមបន្ទប់ក៏មានការសង្ស័យមានការជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) រួចបានធ្វើការនាំខ្លួនជនបរទេសមកសាកសួរសរុបចំនួន១៧នាក់ស្រី៥នាក់ ស្មើនឹង២សញ្ជាតិ។ ជនបរទេសទាំងអស់កំពុងស្នាក់នៅបណ្តោះអាសន្ននៅស្នងការដ្ឋាន

នគរបាលខេត្តកោះកុង ដើម្បីធ្វើការសាកសួរបន្តនិងបានធ្វើការត្រួតពិនិត្យទីតាំងជាក់ស្តែងខាងលើ ជាលទ្ធផលពិនិត្យបានរកឃើញមាន និងបានដកហូតវត្ថុតាងរួមមានកំព្យូទ័រយួរដៃ១៨គ្រឿង Tablet១៦គ្រឿង IPad១គ្រឿង MacBook ២គ្រឿង ទូរសព្ទដៃ៥៨គ្រឿង និងរថយន្ត១គ្រឿងម៉ាកGAC។ ចំពោះវត្ថុតាងខាងលើក្រុមការងារសង្ស័យថាមានជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ក្រុមការងារសម្រេចយកទៅស្នងការដ្ឋាននគរបាលខេត្តកោះកុង រក្សាទុកជាបណ្តោះអាសន្ន ដើម្បីបន្តនីតិវិធីតាមច្បាប់។

– **ជនបរទេសរងគ្រោះដោយឧបទ្ទវហេតុផ្សេងៗ៖** មាន១០លើក មនុស្សរួមមាន១០នាក់ប្រុស មាន៤សញ្ជាតិ (វៀតណាម១នាក់ប្រុស, អាល្លឺម៉ង់១នាក់ប្រុស, ចិន៥នាក់ប្រុស និងបង់ក្លាដេស១នាក់ប្រុស ស្លាប់ដោយសារគាំងបេះដូង និងចិន២នាក់ប្រុស ស្លាប់ដោយសារលង់ទឹក)

– **ជនបរទេសរងគ្រោះដោយគ្រោះថ្នាក់ចរាចរណ៍៖** ចំនួន៣លើក មនុស្សរួមមានចំនួន៤នាក់ ស្រី២នាក់ មាន៣សញ្ជាតិ (អ៊ីតាលី១នាក់ប្រុស, ចិន១នាក់ប្រុស និងវៀតណាម២នាក់ ស្រី២នាក់ រងរបួសស្រាល)

– **កិច្ចប្រតិបត្តិការ ៖** បានជួយសង្គ្រោះបាន១១លើក មនុស្សរួម៣៣នាក់ ស្រី៨នាក់ ស្មើនិង៦សញ្ជាតិ (ជនជាតិហ្វីលីពីន៨នាក់ ស្រី៥នាក់, ឥណ្ឌូនេស៊ី៩នាក់ ស្រី១នាក់, ម៉ាឡេស៊ី១នាក់ប្រុស, ជនជាតិវៀតណាម៨នាក់ ស្រី១នាក់ ,ចិន១នាក់ប្រុស និងប៉ាគីស្ថាន៦នាក់ ស្រី១នាក់ តាមបណ្តឹងលេខ២៥២, ៣៤៩, ៤១០, ៣៥៧, ៤០២, ៥៦៣, ០៤៧ , ០៦៦, ១០២ និង១២៦)

– **កិច្ចសហការ ៖**

○ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២៦ បានចុះត្រួតពិនិត្យឯកសារលិខិតឆ្លងដែនជនបរទេស និងបានពិនិត្យវ៉ាលីរបស់ជនជាតិថៃចំនួន៩៩នាក់ ស្រី៤៥នាក់ នៅចំណុចហាងបាយមួយកន្លែង ស្ថិតក្នុងឃុំបឹងព្រាវ ស្រុកស្រែអំបិល ក្រោយពីបានសួរនាំជនជាតិថៃទាំងនោះធ្វើការនៅតំបន់សេដ្ឋកិច្ចពិសេសខេត្តកោះកុង បានធ្វើដំណើរដោយជិះឡានក្រុងចំនួន៣គ្រឿង ដើម្បីឆ្ពោះទៅព្រលានយន្តហោះ

○ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៦ បានចុះដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីពីជនបរទេសចំនួន១នាក់ប្រុស សញ្ជាតិវៀតណាម ទីលំនៅភូមិស្ទឹងវែង សង្កាត់ស្ទឹងវែង ក្រុងខេមរភូមិន្ទ ឯកសារដែលបានដកហូតមានសៀវភៅស្នាក់នៅ(ក២) ចំនួន១ក្បាល។ កម្លាំងសមត្ថកិច្ចជំនាញនៃអធិការដ្ឋាននគរបាលក្រុងខេមរភូមិន្ទ បានដកហូតឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតីពីជនបរទេសខាងលើគឺមានការយល់ព្រមដោយស្ម័គ្រចិត្តពីសាមីខ្លួន។ ចំពោះឯកសារច្បាប់ដើមខាងលើកម្លាំងជំនាញបន្តបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ដើម្បីអនុវត្តនីតិវិធីបន្ត

○ នៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ បានចុះពិនិត្យ និងធ្វើរដ្ឋបាលដើម្បីស្វែងរកទីតាំងសង្ស័យបើកការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យាOline Scams បានចំនួន២អគារ ស្មើនឹង១៨ជាន់ គឺទីតាំងអគារក្លឹបម៉ាស្សា ស្បា មានចំនួន៩ជាន់ និងសណ្ឋាគារកោះកុង អគារA មានចំនួន៩ជាន់ ស្ថិតក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផល ទីតាំងត្រួតពិនិត្យខាងលើគឺជាទីតាំង ស្នាក់នៅនិងប្រកបអាជីវកម្មស្របច្បាប់ គឺមិនមានសង្ស័យបើកការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា Online Scams ឡើយ។

○ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ បានចុះពិនិត្យ និងធ្វើរដ្ឋបាល ដើម្បីស្វែងរក ទីតាំងសង្ស័យបើកការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា Online Scams បានចំនួន ១អគារ ស្មើនឹង២ជាន់ គឺទីតាំងអគារក្លឹបប៊ីយែខ្មៅ និងហាងអាហារសម្រន់ដំបូង ស្ថិតក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផលទីតាំងត្រួតពិនិត្យខាងលើមានចំនួន២០បន្ទប់ ជាប្រភេទបន្ទប់ស្នាក់នៅ និងស្តុកយ៉រ និងប្រកបអាជីវកម្មស្របច្បាប់ គឺមិនមានសង្ស័យបើកការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា Online Scams ឡើយ

○ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ បានចុះត្រួតពិនិត្យរដ្ឋបាលស្របតាមអនុក្រឹត្យលេខ០៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាព តាមទីតាំងរស់នៅប្រមូលផ្តុំបានចំនួន២ទីតាំង ក្នុងភូមិសាស្ត្រខេត្តកោះកុង ដូចខាងក្រោម ៖

- ទីតាំងទី១ សារ៉េត វីសត ស្ថិតក្នុងភូមិនាងកុក ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ជាលទ្ធផលពិនិត្យបាន

ចំនួន១៤បន្ទប់មានជនជាតិបរទេសសរុបចំនួន៤១នាក់ស្រី ៩នាក់ ស្មើនឹង៣សញ្ជាតិ លិខិតឆ្លងដែនមានសុពលភាពត្រឹមត្រូវ ក្រុមការងារមិនបានដកហូតវត្ថុតាងផ្សេងៗ និងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្វីនៅទីតាំងខាងលើឡើយ។

- ទីតាំងទី២ ថ្មដារ ស្ថិតក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ ក្រុមការងារបានធ្វើការពិនិត្យទីតាំងជាក់ស្តែងតាមបន្ទប់ក្នុងទីតាំងខាងលើមានចំនួន១១បន្ទប់ មានជនជាតិបរទេសចំនួន៨នាក់ ស្រី២នាក់ ស្មើនឹង១សញ្ជាតិចិនកាន់លិខិតឆ្លងដែនមានសុពលភាពត្រឹមត្រូវ។ ជាលទ្ធផលការពិនិត្យទីតាំងខាងលើ មិនមានជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (ONLINE SCAMS) ឡើយ ហើយក្រុមការងារមិនបានដកហូតវត្ថុតាងផ្សេងៗនិងធ្វើឱ្យខូចខាតទ្រព្យសម្បត្តិអ្វីនៅទីតាំងខាងលើឡើយ

  - នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦ បានចុះទៅដល់ទីតាំង និងបានធ្វើការពិនិត្យរដ្ឋបាលអនុវត្តតាមអនុក្រឹត្យលេខ ០៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខសុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ នៃទីតាំងអគារក្លឹបម៉ាស្សា ស្ប៉ា ស្ថិតក្នុងភូមិចាំយាម ឃុំប៉ាក់ខ្លង ស្រុកមណ្ឌលសីមា។ នៅក្នុងនោះក្រុមការងារបានធ្វើការត្រួតពិនិត្យ ជាក់ស្តែងតាមបន្ទប់ក្នុងទីតាំងខាងលើ ជាលទ្ធផលមានជនបរទេសសរុបចំនួន៥៩នាក់ ស្រី១៩នាក់ ស្មើនឹង៥សញ្ជាតិ ក្នុងនោះមានលិខិតឆ្លងដែន និងសុពលភាពទិដ្ឋាការត្រឹមត្រូវ ចំនួន៥៤នាក់។ ជនបរទេសដែលបានត្រួតពិនិត្យខាងលើរកឃើញមានបានបញ្ចូលក្នុងទិន្នន័យ App FPCS រាយការណ៍ស្របតាមមាត្រ ១៨ ស្តីពីច្បាប់អន្តោប្រវេសន៍ បានចំនួន១នាក់ ជនជាតិចិនភេទប្រុស។ ចំណែកឯតំណាងម្ចាស់ទីតាំងជាជនជាតិចិន ត្រូវបានអញ្ជើញមកស្នងការដ្ឋាននគរបាលខេត្តកោះកុង ដើម្បីធ្វើការផាកពិន័យស្របតាមនីតិវិធី ច្បាប់។ ជាលទ្ធផលក្នុងការត្រួតពិនិត្យទីតាំងខាងលើ គឺមិនជាប់ពាក់ព័ន្ធនឹងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ONLINE SCAMS ឡើយ។ ដោយឡែកជនជាតិចិនចំនួន ៥នាក់ប្រុស ដែលរកឃើញថាគ្មានលិខិតឆ្លងដែន ត្រូវបានយកមកស្នងការដ្ឋាននគរបាលខេត្តកោះកុង ដើម្បីបន្តនីតិវិធី
  - នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៦ បានបញ្ជូនជនបរទេសចំនួន១០៣នាក់ ស្រី១៦នាក់ ស្មើនឹង៦សញ្ជាតិ ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន ដើម្បីបន្តនីតិវិធី
  - នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦ បានបញ្ជូនជនបរទេសចំនួន១២នាក់ ស្រី៥នាក់ ស្មើនឹង៣សញ្ជាតិ ទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ដើម្បីបន្តនីតិវិធី។

### ២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ

- បានអប់រំមន្ត្រីឱ្យយល់ដឹងពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារចំនួន៦លើក
- បានអប់រំជនជាប់ឃុំឱ្យយល់ដឹងពីក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាលចំនួន១២លើក
- បានបង្រៀនថ្នាក់អក្ខរកម្មដល់ទណ្ឌិត ចំនួន១៥នាក់ប្រុស (គ្រូបង្គោលជាមន្ត្រីពន្ធនាគារ) ក្រោមការគាំទ្រពីមន្ទីរអប់រំ យុវជននិងកីឡាខេត្ត ចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ រយៈពេល១០ខែ
- បានបណ្តុះបណ្តាលជនជាប់ឃុំឱ្យមានជំនាញកាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ ជាងជួសជុលរថយន្តនិងដេរលបក្លាម ជារៀងរាល់ថ្ងៃ
- បានលើកគោលការណ៍ពិនិត្យ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសការអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្គត់ផ្គង់ជីវភាព សេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារជារៀងរាល់ថ្ងៃ
- បានសម្របសម្រួលជូនក្រុមគ្រូពេទ្យអង្គការលើកាដូមកពិនិត្យព្យាបាល និងផ្តល់ឱសថដល់ជនជាប់ឃុំចំនួន៦លើក និងផ្តល់ប្រឹក្សាច្បាប់ដល់ជនជាប់ឃុំចំនួន៣៥នាក់ ស្ត្រីចំនួន១៣នាក់ ចំនួន៦លើក
- បានសម្របសម្រួលជូនអង្គការលើកាដូមកចែកអំណោយដល់ជនជាប់ឃុំជាស្ត្រីមានផ្ទៃពោះ និងកូនតាមម្តាយចំនួន៦លើក
- គិតត្រឹមថ្ងៃទី១០/៦/២០២៦ ជនជាប់ឃុំជាក់ស្តែងមានចំនួន១.០៤៧នាក់ ស្ត្រី៦៨នាក់ ក្នុងនោះមាន៖
  - ជនត្រូវទោស ចំនួន១១៣នាក់ ស្ត្រី៤នាក់

- ជនជាប់ចោទ ចំនួន៨៥នាក់ ស្ត្រី៩នាក់
- ពិរុទ្ធជន ចំនួន៣៥៣នាក់ ស្ត្រី២៥នាក់
- ទណ្ឌិត ចំនួន៤៩៦នាក់ ស្ត្រី៣០នាក់

ក្នុងនោះក៏មានៈ

- ជនជាតិបរទេស មានចំនួន១០១នាក់ ស្ត្រីចំនួន៨នាក់ (វៀតណាមចំនួន២០នាក់ ស្ត្រីចំនួន៧នាក់ ចិនចំនួន៧១នាក់ស្ត្រីចំនួន១នាក់ .ចិនតៃវ៉ាន់ចំនួន២នាក់ ម៉ាឡេស៊ីចំនួន១នាក់ និងប៉ាគីស្ថានចំនួន៧នាក់ប្រុស)
- អនីតិជនចំនួន៣៤នាក់ ស្ត្រី១នាក់
- កូនតាមម្តាយចំនួន៣នាក់ប្រុស

- ជនជាប់ឃុំត្រូវបានចាប់ចូលថ្មីមានចំនួន៣៤៥នាក់ ស្ត្រីចំនួន១២នាក់
- ជនជាប់ឃុំត្រូវបានដោះលែងមានចំនួន២០៧នាក់ ស្ត្រី១២នាក់។

### ២.៤.៥-ការងារផ្សេងៗ

- (ពុំមាន)។

## ផ្នែកទី៣÷បញ្ហាប្រឈម និងសំណើដោះស្រាយ

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| ១ | -ក្រុមហ៊ុនមួយចំនួន ទទួលសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាល ដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ (ទំនាស់រ៉ាំរ៉ៃ) | -ស្នើឲ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀតជូនប្រជាពលរដ្ឋ<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| ២ | -ក្រោយពីដាក់ដំណើរការនៃការផ្តល់សេវាអនឡាញ (Online) លើវិស័យ៩វិស័យ មិនទាន់មានស្នើសុំនៅឡើយ<br>-ការផ្តល់សេវាសំណង់មិនទាន់ពេលវេលា | -ជម្រុញ និងផ្សព្វផ្សាយបន្ថែមទៀតពីការផ្តល់សេវាអនឡាញ ដើម្បីឱ្យប្រជាពលរដ្ឋបានដឹង និងងាកមកប្រើប្រាស់សេវាអនឡាញឱ្យបានច្រើន<br>-ស្នើសុំមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ជួយពន្លឿនឱ្យបានទាន់ពេលវាលា |
| ៣ | ក្រុមហ៊ុនមួយចំនួនទទួលសិទ្ធិសម្បទានដីពីរាជរដ្ឋាភិបាលដើម្បីវិនិយោគ ហើយមានទំនាស់ដីធ្លីជាមួយប្រជាពលរដ្ឋ | -ស្នើឱ្យក្រុមហ៊ុនបន្តសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីដែលនៅសេសសល់បន្តទៀត<br>-ពង្រឹងការសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បីសម្របសម្រួល និងដោះស្រាយទៅតាមលិខិតបទដ្ឋានគតិយុត្ត |
| ៤ | **វិស័យធម្មការនិងសាសនាៈ**<br>-ខ្វះមន្ត្រីជាច្រើននាក់ដើម្បីបម្រើការងារ<br>-គណៈសង្ឃខេត្ត ក្រុង ស្រុក ខ្វះសមាសភាពមន្ត្រីសង្ឃជាច្រើនដើម្បីគ្រប់គ្រងអនុវត្តការងារក្នុងវិស័យព្រះពុទ្ធសាសនា | -ស្នើសូមក្រសួងបន្តប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការបន្ថែមទៀត<br>-ស្នើសូមគណៈសង្ឃនាយកព្រះមេត្តាជួយជំរុញព្រះមេគណខេត្តទាំង២គណៈឱ្យស្នើសុំតែងតាំងព្រះមន្ត្រីសង្ឃ ខេត្ត ក្រុង ស្រុក បន្ថែមទៀត |

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| | -អគារមន្ទីរសម្រាប់បម្រើការងារសព្វថ្ងៃមានសភាពចាស់ដែលមានអាយុកាលតាំងពីសម័យទសវត្សរ៍ទី៦០<br>-ការអនុវត្តលិខិតបទដ្ឋានពាហិរសាសនានៅមិនទាន់មានភាពច្បាស់លាស់និងគ្រប់ជ្រុងជ្រោយនៅឡើយ<br>-ខ្វះមធ្យោបាយធ្វើដំណើររបស់មន្ត្រីរាជការក្នុងការបំពេញការងារ | -ស្នើសូមក្រសួងជួយសាងសង់អគារមន្ទីរធម្មការ និងសាសនាខេត្តថ្មី<br>-ស្នើសូមក្រសួងធ្វើបច្ចុប្បន្នភាពលើលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធនិងការអនុវត្តការងារពាហិរសាសនា<br>-ស្នើសូមក្រសួងជួយផ្តល់មធ្យោបាយដំណើរបន្ថែម |
| ៥ | **មន្ទីរអប់រំ យុវជន និងកីឡា៖**<br>-អគារសិក្សាមួយចំនួននៅតាមគ្រឹះស្ថានសិក្សាមានសភាពចាស់ទ្រុឌទ្រោម និងគ្រឹះស្ថានសិក្សាមួយចំនួនទៀតមានតម្រូវការអគារសិក្សាជាចាំបាច់សម្រាប់ដំណើការបង្រៀន និងរៀន<br>-ប្រព័ន្ធអ៊ិនធឺណែតរអាក់រអួល ពិបាករៀបចំ និងដំណើរការការងារតាមប្រព័ន្ធព័ត៌មានវិទ្យា<br>-សាលាបឋមសិក្សាចំនួន៧៧=៦៣.១២%មិនទាន់បានចូលធ្វើស្វ័យវាយតម្លៃស្តង់ដាសាលាបឋមសិក្សាគំរូ<br>-ថវិកាដំណើរការសកម្មភាពការងារ និងការចូលរួមកិច្ចប្រជុំផ្សេងៗមិនសមាមាត្រ | -ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រម និងផ្សព្វផ្សាយកៀរគរស្វែងរកសប្បុរសជនជួយជួសជុល ឬសាងសង់ថ្មី<br>-ចុះជួយផ្ទាល់ និងតាមប្រព័ន្ធផ្សព្វផ្សាយ<br>-ជំរុញ និងលើកទឹកចិត្តដល់បុគ្គលិកអប់រំដោះស្រាយរកទីតាំងដែលមានសេវាអ៊ិនធឺណែត<br>-ស្នើសុំជូនក្រសួងអប់រំ យុវជន និងមន្ទីរប្រៃសណីយ៍ទូរគមនាគន៍ជួយដោះស្រាយ<br>-ជំរុញ និងលើកទឹកចិត្តអ្នកពាក់ព័ន្ធចូលរួមអនុវត្ត<br>-កៀរគរសប្បុរសជនចូលរួមឧបត្ថម្ភ |
| ៦ | **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖**<br>-មន្ត្រីបង្គោលអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មជនពិការភាពភ្លេចលេខកូដចូលកម្មវិធី | -ជួយសម្របសម្រួល និងផ្តល់លេខកូដថ្មីដល់មន្ត្រីបង្គោលអនុវត្តកម្មវិធីកំណត់អត្តសញ្ញាណកម្មជនមានពិការភាព |
| ៧ | **មន្ទីរសាធារណការ និងដឹកជញ្ជូន៖**<br>-ភ្លៀងធ្លាក់ស្ទើរាល់ថ្ងៃ រំខានដល់ការងារការដ្ឋាន<br>-យានដ្ឋានជួសជុលយានយន្តមួយចំនួនមិនទាន់ចុះបញ្ជី និងបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋាន | -សូមការិយាល័យសុវត្ថិភាពចរាចរណ៍ផ្លូវគោក ជួយសហការជាមួយអាជ្ញាធរខេត្ត ស្រុកដើម្បីជម្រុញ ឱ្យម្ចាស់យានដ្ឋានមកចុះបញ្ជី និងបន្តលិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋាន។ |
| ៨ | **មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ៖**<br>-ខ្វះមន្ត្រីក្របខណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាបម្រើការងារតាមបណ្តាខណ្ឌរដ្ឋបាល និងការិយាល័យជំនាញក្រោមឱវាទមន្ទីរ | -ស្នើសុំក្រសួងជ្រើសរើសមន្ត្រីក្របខ័ណ្ឌ និងមន្ត្រីជាប់កិច្ចសន្យាបន្ថែមសម្រាប់បម្រើការងារតាមបណ្តាខណ្ឌ និងការិយាល័យជំនាញ |

# ផ្នែកទី៤÷ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅឆមាសបន្ទាប់

## ៤.១-រដ្ឋបាលខេត្ត

### ៤.១.១-ការងាររដ្ឋបាល

- ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញ វិសាមញ្ញ សម្ងាត់ និងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត
- ត្រៀមរៀបចំប្រជុំការងារគណៈអភិបាលប្រចាំអឌ្ឍមាស និងប្រចាំខែ
- ត្រៀមរៀបចំពិធីបុណ្យចូលព្រះវស្សា
- ត្រៀមរៀបចំពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ
- ត្រៀមរៀបចំប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណា ព្រះបាទសម្ដេច ព្រះនរោត្តមសីហនុ (ព្រះបរមរតនកោដ្ឋ)
- ត្រៀមរៀបចំពិធីអបអរសាទរទិវាបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា
- ត្រៀមរៀបចំអបអរសាទរព្រះរាជពិធីបុណ្យអុំទូក បណ្ដែតប្រទីប និងអកអំបុក  សំពះព្រះខែ
- ប្រមូលចងក្រងរបាយការណ៍អនុវត្តការងាររបស់គណៈអភិបាលខេត្ត
- រៀបចំសេចក្ដីព្រាងរបាយការណ៍ប្រចាំខែ និងប្រចាំឆ្នាំ២០២៦ ស្ដីពីការអនុវត្តការងាររបស់ រដ្ឋបាលខេត្ត
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋដែលបានចុះបញ្ជីអត្រានុកូលដ្ឋានរួចហើយ តែត្រូវបាត់បង់ ឬ ខូចខាត ដោយយថាហេតុ តាមការស្នើសុំរបស់សាមីខ្លួន
- ស្រាវជ្រាវត្រួតពិនិត្យឈ្មោះប្រជាពលរដ្ឋ ដែលមកចុះបញ្ជីអត្រានុកូលដ្ឋានក្នុងពេលបច្ចុប្បន្នតាមរយៈរដ្ឋបាលឃុំ សង្កាត់
- បញ្ចូលទិន្នន័យឯកសារកែតម្រូវ និងមោឃភាពអត្រានុកូលដ្ឋានគ្រប់ប្រភេទ ក្នុងប្រព័ន្ធគ្រប់គ្រងឯកសារ (www.cdepart.net) រួចបញ្ជូនទៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចធ្វើការកែតម្រូវ និងមោឃភាព ជូនប្រជាពលរដ្ឋ
- ត្រៀមរៀបចំសេចក្ដីជូនដំណឹង ស្ដីពីពិធីដង្ហែទានព្រះវស្សាទៅតាមបណ្ដាវត្តអារាមក្នុងខេត្តកោះកុង។

### ៤.១.២-ការងារគណៈកម្មាធិការនានា

#### ក-គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

- ត្រៀមរៀបចំកិច្ចប្រជុំសាមញ្ញ ក្នុងខែ ឆ្នាំ២០២៦
- ត្រៀមរៀបចំសេចក្ដីព្រាងរបាយការណ៍ប្រចាំខែ ឆ្នាំ២០២៦។

#### ខ-គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

- ត្រៀមរៀបចំកិច្ចប្រជុំពិនិត្យ និងផ្ដល់យោបល់លើបញ្ជីគម្រោងអាទិភាពដែលគ្រោងប្រើប្រាស់ថវិកាខេត្ត ២០២៦-២០២៨
- ត្រៀមរៀបចំកិច្ចប្រជុំពិនិត្យ និងផ្ដល់យោបល់លើផែនការយុទ្ធសាស្ត្រថវិកា ២០២៦-២០២៨
- ត្រៀមរៀបចំកិច្ចប្រជុំពិនិត្យ និងផ្ដល់យោបល់លើគម្រោងចំណូល ចំណាយ ២០២៦-២០២៨។

#### គ-គណៈកម្មាធិការលទ្ធកម្ម

- ត្រៀមបើកកិច្ចប្រជុំឯកសារដេញថ្លៃលទ្ធកម្មទំនិញឆ្នាំ២០២៦
- បើកកិច្ចប្រជុំលទ្ធកម្មសំណង់ឆ្នាំ២០២៦។

#### ឃ-គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្ត

- ត្រៀមរៀបចំដំណើរការសម្រាប់នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីក្នុងសង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ។

### ៤.១.៣-ការងារផែនការ និងវិនិយោគ

- បន្តសហការរៀបចំរបាយការណ៍រីកចម្រើនទំនាក់ទំនងនឹងការងារផែនការ កម្មវិធីវិនិយោគ

- បន្តចុះសិក្សាគម្រោង រៀបចំប្លង់ ប៉ាន់ស្មានតម្លៃ និងរៀបចំសំណើគម្រោងអភិវឌ្ឍន៍មូលនិធិក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ២០២៦
- បន្តចុះត្រួតពិនិត្យ និងវាយតម្លៃគម្រោងមូលនិធិឃុំ ឆ្នាំ២០២៥
- បន្តពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍន៍របស់ក្រុមប្រឹក្សាក្រុង ស្រុក ឃុំ សង្កាត់
- បន្តចងក្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យពាក់ព័ន្ធនឹងគម្រោងអភិវឌ្ឍន៍នានា
- បន្តចូលរួមសម្របសម្រួលសិក្សាគម្រោងក្រុង ស្រុក ឃុំ សង្កាត់ ឆ្នាំ២០២៦
- រៀបចំប្រជុំគណៈអភិបាល និងគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត២០២៦-២០២៨ និងប្រតិទិនការងារ ព្រមទាំងសេចក្តីណែនាំស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល២០២៧-២០២៩។

### ៤.១.៤-ការគ្រប់គ្រងធនធានមនុស្ស

- ត្រៀមរៀបចំដាក់ចេញដីកាដំឡើងថ្នាក់ និងឋានន្តរស័ក្តិ តាមកម្រិតសញ្ញាបត្រជូនដល់មន្ត្រីរាជការនៃរដ្ឋបាលខេត្ត និងមន្ត្រីរាជការមន្ទីរសុខាភិបាល នៃរដ្ឋបាលខេត្ត
- ត្រៀមរៀបចំសំណើស្នើសុំតែងតាំងអភិបាលរងខេត្ត សម្រាប់អាណត្តិទី២ ក្នុងដែនសមត្ថកិច្ចដដែល និងផ្ទេរភារកិច្ចអភិបាលរងក្រុង ស្រុក
- ត្រៀមរៀបចំដាក់ចេញដីកាស្តីពីការតែងតាំង និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ នៃមន្ទីរ អង្គភាពជុំវិញខេត្ត
- សហការជាមួយគ្រូបង្គោលថ្នាក់ក្រុង ស្រុក ចុះត្រួតពិនិត្យតាមដានការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គមតាមបណ្តាអង្គភាពផ្តល់សេវាទាំង៣
- ត្រៀមរៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការរៀបចំតាក់តែងដីកា ជូនរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់
- ត្រៀមរៀបចំកិច្ចប្រជុំប្រចាំឆមាសទី១ ស្តីពីការអនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម។

### ៤.១.៥-ការងារអន្តរវិស័យ

- បន្តសហការជាមួយក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ ដើម្បីសម្របសម្រួល និងដោះស្រាយទំនាស់ដីធ្លីនៅសេសសល់ជូនប្រជាពលរដ្ឋ
- បន្តសហការជាមួយក្រសួង មន្ទីរ អង្គភាព និងអាជ្ញាធរពាក់ព័ន្ធចុះពិនិត្យទីតាំងគម្រោង និងទីតាំងសេវាកម្មនានាតាមការដាក់ស្នើ
- ចុះតាមក្រុង ស្រុកដើម្បីជំរុញការរៀបចំទីលានទុកដាក់សំរាម និងពិនិត្យទីតាំងដីទុកដាក់សំរាមដែលមានស្រាប់។

### ៤.១.៦-ការងារអង្គភាពច្រកចេញចូលតែមួយ

- បន្តផ្សព្វផ្សាយការផ្តល់សេវា Online លើវិស័យចំនួន៩វិស័យបន្ថែមទៀត
- បន្តផ្តល់សេវាជូនប្រជាពលរដ្ឋ ឱ្យកាន់តែល្អប្រសើរ
- បន្តជំរុញផ្សព្វផ្សាយជូនម្ចាស់អាជីវកម្ម សេវាកម្ម ដាក់ពាក្យស្នើសុំសេវាបើកថ្មី ឬបន្តសុពលភាពអាជ្ញាប័ណ្ណដែលផុតកំណត់ឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវតាមច្បាប់កំណត់។

### ៤.១.៧-ការងារការិយាល័យប្រជាពលរដ្ឋ

- បន្តប្រចាំការនៅគុពិសេស ក្នុងអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្តចំនួន១២ម៉ោង ក្នុង១សប្តាហ៍
- បន្តចុះបើកប្រអប់សំបុត្រការិយាល័យប្រជាពលរដ្ឋខេត្ត នៅតាមមុខមន្ទីរមួយចំនួន និងក្រុង ស្រុក ឃុំ សង្កាត់
- បន្តទទួលពាក្យបណ្តឹង និងព័ត៌មានផ្សេងៗ តាមមធ្យោបាយទាំង៥ (១.ជួបផ្ទាល់ ២.ប្រអប់សំបុត្រ ៣.ប្រព័ន្ធតេឡេក្រាម ៤.តាមទូរសព្ទ និង៥ កម្មវិធីទូរសព្ទដៃ "មតិយើង")
- បន្តចាត់វិធានការដោះស្រាយបណ្តឹងក្នុងសមត្ថកិច្ចឱ្យបានឆាប់បំផុត ដើម្បីបង្កើនទំនុកចិត្តពីប្រជាពលរដ្ឋ
- រៀបចំកិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ ឱ្យបានទាន់ពេលវេលា

- បើកវគ្គបណ្តុះបណ្តាលផ្សព្វផ្សាយ ស្តីពីរចនាសម្ព័ន្ធ តួនាទី ភារកិច្ច សិទ្ធិអំណាច របស់ការិយាល័យប្រជាពលរដ្ឋខេត្ត និងការប្រើប្រាស់កម្មវិធីទូរសព្ទដៃ " មតិយើង "ជូនដល់ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ មន្ត្រីប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ ជំនួយការឃុំ មេភូមិ ជំនួយការភូមិ សមាជិកភូមិ ប្រជាការពារភូមិ និងប្រជាពលរដ្ឋ នៅតាមបណ្តាឃុំក្នុងស្រុក សែ្រអំបិល ស្រុកបូទុមសាគរ និងស្រុកគិរីសាគរ ចំនួន១៣វគ្គ។

### ៤.១.៨-ការងារក្រុមមេធាវីប្រចាំរដ្ឋបាលខេត្ត

- បន្តពិនិត្យ និងផ្តល់ប្រឹក្សាយោបល់ផ្នែកច្បាប់ជូនដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់
- បន្តសហការរៀបចំពាក្យបណ្តឹងឱ្យរដ្ឋបាលខេត្ត និងបំពេញតួនាទីជាមេធាវីតំណាង និងការពារផលប្រយោជន៍ស្របច្បាប់ជូនរដ្ឋបាលខេត្ត។

### ៤.១.៩-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

- បន្តពង្រឹងកិច្ចសហការទប់ស្កាត់នូវរាល់អំពើរត់គេចពន្ធតាមច្រកទ្វារ ដូចជា ទំនិញគ្រប់ប្រភេទ និងការជួញដូរមនុស្សឆ្លងដែន ជួញដូរគ្រឿងញៀន អាវុធជាតិផ្ទុះ និងវត្ថុបុរាណផ្សេងៗ
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយសមត្ថកិច្ចពាក់ព័ន្ធនៃប្រទេសជិតខាង ដោយឈរលើគោលជំហរ គោរពបូរណភាពទឹកដី នៃប្រទេសទាំងពីរ ក្នុងតំបន់ព្រំដែន
- បន្តពង្រឹងការយាមល្បាតការពារគ្រប់គោលដៅ ដើម្បីរក្សាសុវត្ថិភាពក្នុងភូមិសាស្ត្រ ឱ្យបានល្អប្រសើរ
- បន្តពង្រឹងការអនុវត្តជាប្រចាំ នូវការងារសន្តិសុខ សណ្តាប់ធ្នាប់ និងថែរក្សាអនាម័យបរិស្ថាន
- បន្តត្រួតពិនិត្យលិខិតស្នាម មនុស្ស មធ្យោបាយ ទំនិញចេញចូល និងទប់ស្កាត់បទល្មើសជ្រៀតចូលដោយខុសច្បាប់។

### ៤.១.១០-ការគ្រប់គ្រងហិរញ្ញវត្ថុ

- បន្តរៀបចំអាណត្តិបើកប្រាក់បៀវត្សប្រចាំខែ ឆ្នាំ២០២៦ ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ត្រៀមរៀបចំឯកសារសម្រាប់ទូទាត់ប្រាក់បេសកកម្មជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា
- ត្រៀមបើកប្រាក់រង្វាន់ជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា។

### ៤.១.១១-ការងារលទ្ធកម្ម

- ត្រៀមអនុវត្តនីតិវិធីលទ្ធកម្មទំនិញ និងសេវា ឆ្នាំ២០២៦ ចំនួន៧គម្រោង
- ត្រៀមអនុវត្តនីតិវិធីលទ្ធកម្មសំណង់ ឆ្នាំ២០២៦ ចំនួន៦គម្រោង។

### ៤.១.១២-ការងារសុខាភិបាល

- បន្តផ្តល់សេវាពិនិត្យ ពិគ្រោះព្យាបាលជំងឺ និងពង្រឹងការថែទាំ ព្យាបាលជំងឺដោយការយកចិត្តទុកដាក់នៅគ្រប់មូលដ្ឋានសុខាភិបាល
- បន្តចុះអប់រំផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ ការព្យាបាល ការបង្ការជំងឺឆ្លង និងជំងឺមិនឆ្លងតាមកម្មវិធីជាយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល
- បន្តអនុវត្តតាមគោលការណ៍យុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល និងរាជរដ្ឋាភិបាលដែលបានដាក់ចេញថ្មីៗ
- បន្តចុះអភិបាលកិច្ចការងារសុខាភិបាល នៅតាមមូលដ្ឋានសុខាភិបាលតាមផែនការគ្រោងទុក
- បន្តផ្តល់កិច្ចសហការជាមួយអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធវិស័យសុខាភិបាលក្នុងខេត្ត
- ត្រៀមប្រជុំក្រុមការងារបច្ចេកទេសសុខាភិបាល (Pro.TWGH) ដែលមានអង្គការដៃគូចូលរួម
- បន្តអប់រំ ផ្សព្វផ្សាយអំពីវិធីការពារការចម្លងមេរោគអេដស៍ ធ្វើតេស្តដើម្បីស្វែងរកអ្នកផ្ទុកមេរោគអេដស៍ និងពង្រឹងការព្យាបាលប្រកបដោយប្រសិទ្ធភាពខ្ពស់
- បន្តផ្តល់សេវាជូនដល់ស្ត្រីមានផ្ទៃពោះឱ្យមកពិនិត្យផ្ទៃពោះមុន-ក្រោយសម្រាលកូន និងមកសម្រាលកូន នៅតាមមណ្ឌលសុខភាព ឬមន្ទីរពេទ្យ

- បន្តផ្តល់សេវាផ្តល់ថ្នាំបង្ការជំងឺ១១មុខដល់កុមារ និងផ្តល់ថ្នាំបង្ការជំងឺតេតាណុសដល់ស្ត្រីមានផ្ទៃពោះ នៅតាមមណ្ឌលសុខភាព
- បន្តផ្តល់សេវាពន្យារកំណើតនៅតាមមណ្ឌលសុខភាពទូទាំងខេត្ត
- បន្តចាត់ក្រុមការងារចត្តាឡីស័កប្រចាំការនៅទីស្នាក់ការច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម ដើម្បីពិនិត្យកម្តៅលើអ្នកធ្វើដំណើរ អ្នកបើកបររថយន្តចេញចូលច្រកព្រំដែនជារៀងរាល់ថ្ងៃ ព្រមទាំងបាញ់ថ្នាំសម្លាប់មេរោគទៅលើរថយន្តដឹកទំនិញចេញ-ចូល
- បន្តអប់រំសុខភាព ស្តីពីវិធានការការពារជំងឺគ្រុនឈាមតាមរយៈបុគ្គលិកសុខាភិបាល នៅពេលប្រជាពលរដ្ឋមកទទួលសេវានៅមូលដ្ឋាន និងសិស្សានុសិស្សនៅតាមសាលារៀន។

### ៤.១.១៣-ការងារក្រុមការងាររាជរដ្ឋាភិបាល

- បន្តជំរុញក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក ទាំង៧ នៃខេត្តកោះកុង រៀបចំរបាយការណ៍ ស្តីពីលទ្ធផលការងារមកលេខាធិការដ្ឋានសម្រាប់រៀបចំបូកសរុបជូនក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន នៃទីស្តីការគណៈរដ្ឋមន្ត្រី
- បន្តចុះសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីដោះស្រាយ និងស្វែងយល់អំពីកង្វល់នានា នៅក្នុងមូលដ្ឋាន
- ត្រៀមរៀបចំវេទិកាសាធារណៈនៅតាមបណ្តាក្រុង ស្រុក ដើម្បីដោះស្រាយ និងប្រមូលចងក្រងរាល់សំណួរ និងសំណូមពរទាំងអស់របស់ប្រជាពលរដ្ឋ
- ប្រមូលចងក្រងរាល់សំណួរ និងសំណូមពរទាំងអស់របស់ប្រជាពលរដ្ឋ ដែលមានការពាក់ព័ន្ធជាមួយនឹងក្រសួង ស្ថាប័នសាមី ដែលក្រុមការងារ និងអាជ្ញាធរមូលដ្ឋានក្រុង ស្រុក ខេត្ត ពុំមានសមត្ថកិច្ច និងលទ្ធភាពដោះស្រាយ ដើម្បីផ្តល់ជូនក្រសួង ស្ថាប័នពាក់ព័ន្ធ រាជរដ្ឋាភិបាល មានវិធានការដោះស្រាយជូនប្រជាពលរដ្ឋទាន់ពេលវេលា និងសមស្រប
- បន្តជំរុញការដោះស្រាយឱ្យកាន់តែសកម្មថែមទៀតនូវសំណើ និងសំណូមពរចាំបាច់របស់ប្រជាពលរដ្ឋ
- បន្តជំរុញការផ្តល់សេវារដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ជូនប្រជាពលរដ្ឋឱ្យកាន់តែមានគុណភាព តម្លាភាព ប្រសិទ្ធភាព និងឆាប់រហ័ស។

### ៤.១.១៤-ការងារផ្សេងៗ

- (ពុំមាន)។

## ៤.២-មន្ទីរ និងអង្គភាពជំនាញ

## ៤.២.១-ផ្នែកសេដ្ឋកិច្ច

### ៤.២.១.១-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ត្រៀមចុះផ្សព្វផ្សាយ បណ្តុះបណ្តាល និងគាំទ្របច្ចេកទេសកសិកម្មតាមបណ្តាក្រុង/ស្រុក
- ត្រៀមអន្តរាគមន៍ពីការបំផ្លាញ របស់សត្វល្អិតចង្រៃ និងជម្ងឺលើដំណាំតាមបណ្តាក្រុង/ស្រុក
- ពង្រឹងការត្រួតពិនិត្យអនាម័យសត្វ ចលនាដឹកជញ្ជូនសត្វ និងផលិតផលមានដើមកំណើតពីសត្វទូទាំងខេត្ត
- បន្តត្រួតពិនិត្យ និងទប់ស្កាត់ការរីករាលដាលជម្ងឺឆ្លងសត្វតាមបណ្តាក្រុង/ស្រុក
- ចុះបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វជាលក្ខណៈគ្រួសារដល់កសិករនៅឃុំដងពែង ស្រុកស្រែអំបិល
- ចុះផ្សព្វផ្សាយពង្រឹងការអនុវត្តច្បាប់ស្តីពី សុខភាពសត្វ និងផលិតកម្មសត្វ ដល់អាជីវករ នៅឃុំស្រែអំបិល ស្រុកស្រែអំបិល
- បន្តតាមដានត្រួតពិនិត្យទីតាំងអាជីវកម្ម និងការធ្វើចរាចរណ៍ថ្នាំកសិកម្ម ជីកសិកម្មក្នុងខេត្ត
- បន្តជំរុញការអប់រំ ផ្សព្វផ្សាយពីវិធានបច្ចេកទេសនៃការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ព្រមទាំងវិធាន សុវត្ថិភាពដល់អាជីវករ និងកសិករ

- ចុះបណ្តុះបណ្តាលបច្ចេកទេសបើកមុខចៀរជ័រកៅស៊ូដំបូង ដល់កសិករតាមបណ្តាក្រុង/ស្រុក
- ចុះតាមដាន និងត្រួតពិនិត្យជម្ងឺជ្រុះស្លឹកលើដំណាំកៅស៊ូគ្រួសារតាមបណ្តាក្រុង/ស្រុក
- ចុះស្រង់ទិន្នន័យគ្រឿងយន្តកសិកម្ម ឧបករណ៍កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធបន្លែតាមបណ្តាក្រុង/ស្រុក
- បន្តតាមដានពង្រឹងសមត្ថភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការ
- ចុះពិនិត្យតាមដាន និងវាយតម្លៃវឌ្ឍនភាពរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចក្នុងខេត្ត
- បន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន អង្គភាពពាក់ព័ន្ធ និងកម្លាំងល្បាតរបស់សហគមន៍ ដើម្បីទប់ស្កាត់ និងបង្ក្រាបបទល្មើសធនធានធម្មជាតិឱ្យបានទាន់ពេលវេលា
- ចុះផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការធ្វើអាជីវកម្មពាក់ព័ន្ធវិស័យជលផល និងការបង់ថ្លៃឈ្នួលដែននេសាទសម្រាប់រដូវនេសាទឆ្នាំ២០២៦ នៅតាមបណ្តាក្រុង/ស្រុកនានាក្នុងខេត្ត
- អនុវត្តគម្រោង (SCMF) ចុះតាមដាន បណ្តុះបណ្តាលបច្ចេកទេស និងពង្រឹងសមត្ថភាពសហគមន៍នេសាទគោលដៅ នានាក្នុងខេត្ត
- បន្តចុះតាមដាន ត្រួតពិនិត្យ និងទប់ស្កាត់ករណីរំលោភទន្ទ្រានកាន់កាប់ ពីសំណាក់ប្រជាពលរដ្ឋ លើដីកម្មសិទ្ធិរបស់រដ្ឋដែលគ្រប់គ្រងដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត និងដីសម្បទានសេដ្ឋកិច្ចនានាក្នុងខេត្ត។

### ៤.២.១.២-ការងារធនធានទឹក និងឧតុនិយម

- បន្តពង្រឹងសហគមន៍កសិករប្រើប្រាស់ទឹកខ្លុង ស្ថិតនៅភូមិខ្លុង ឃុំស្រែអំបិល ស្រុកស្រែអំបិល និងសហគមន៍កសិករប្រើប្រាស់ទឹកកណ្តោល ស្ថិតនៅភូមិធ្នង់ និងភូមិកណ្តោល ឃុំកណ្តោល ស្រុកបូទុមសាគរ
- បន្តពង្រឹងការងារប្រមូលទិន្នន័យឧតុនិយម តាមបណ្តាស្រុកដែលមានស្ថានីយឧតុនិយមឱ្យកាន់តែឆាប់រហ័ស និងសុក្រឹតដើម្បីចងក្រងបញ្ជូនទៅក្រសួងធនធានទឹក និងឧតុនិយម
- បន្តជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃបឹងព្រាវ ក្នុងឃុំបឹងព្រាវ ទំនប់ការពារទឹកប្រៃជ្រោយស្វាយ ក្នុងឃុំជ្រោយស្វាយ ទំនប់ការពារទឹកប្រៃដងពែង១ ក្នុងឃុំដងពែង និងទំនប់ការពារទឹកប្រៃតានី ក្នុងឃុំដីខលើ ស្រុកស្រែអំបិល
- បន្តជួសជុល និងថែទាំជាប្រចាំទំនប់ការពារទឹកប្រៃកណ្តោល ក្នុងឃុំកណ្តោល ទំនប់ការពារទឹកប្រៃតាំកន់ ក្នុងឃុំកណ្តោល ទំនប់ការពារទឹកប្រៃជីមាល ក្នុងឃុំអណ្តូងទឹក និងទំនប់ការពារទឹកប្រៃជីត្រេះ ក្នុងឃុំអណ្តូងទឹក ស្រុកបូទុមសាគរ។

### ៤.២.១.៣-ការងារអភិវឌ្ឍជនបទ

- បន្តចុះធ្វើបច្ចុប្បន្នភាពផ្លូវ និងសំណង់សិល្បៈការ្យ ដើម្បីរៀបចំបញ្ជីសារពើភណ្ឌ និងមូលដ្ឋានទិន្នន័យផ្លូវជនបទតាមបណ្តាឃុំ ស្រុក
- បន្តចុះស្រង់ទិន្នន័យសារពើភណ្ឌផ្លូវជនបទ និងរាប់ចរាចរណ៍យានយន្តលើដងផ្លូវតាមបណ្តាឃុំ និងស្រុក
- បន្តចុះធ្វើបច្ចុប្បន្នភាព អណ្តូងលូ អណ្តូងស្នប់ ស្រះទឹក និងប្រព័ន្ធចែកចាយទឹកសហគមន៍ នៅក្នុងឃុំ ស្រុកគោលដៅ។

### ៤.២.១.៤-ការងារឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បន្តចុះអនុវត្តការងារ ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ឧបករណ៍មាត្រាសាស្ត្រដៃបាញ់ប្រេង ទំនិញផលិតផល ទំនិញវេចខ្ចប់ និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ នៅក្នុងស្រុកថ្មបាំង និងស្រុកមណ្ឌលសីមា
- បន្តអនុវត្តការងារយន្តការច្រកចេញចូលតែមួយរបស់មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ខេត្តកោះកុង លើការផ្តល់សេវាសាធារណៈជូនម្ចាស់ សហគ្រាស/សិប្បកម្ម
- បន្តជំរុញម្ចាស់សហគ្រាស/សិប្បកម្ម ឱ្យយកសំណាកផលិតផល ទៅវិភាគគុណភាព នៅមន្ទីរពិសោធន៍ជាតិ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រាជធានីភ្នំពេញ

- បន្តជំរុញផ្សព្វផ្សាយច្បាប់ បទបញ្ញត្តិ និងសេចក្តីណែនាំផ្សេងៗ ជាសាធារណៈ ជាពិសេសម្ចាស់រោងចក្រ សហគ្រាស/សិប្បកម្ម នៅក្នុងខេត្តកោះកុង។

### ៤.២.១.៥-ការងាររ៉ែ និងថាមពល

- បន្តផ្សព្វផ្សាយដល់អាជីវករឱ្យយល់ដឹងអំពីច្បាប់ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មធនធានរ៉ែ (ខ្សាច់ និងអាចម៍ដី)
- បន្តផ្សព្វផ្សាយសារាចរ និងសេចក្តីណែនាំ ស្តីពីការគ្រប់គ្រងស្ថានីយប្រេង និងឧស្ម័នឥន្ធនៈ ជូនដល់អាជីវករពាក់ព័ន្ធ
- បន្តជំរុញ និងគាំទ្រដល់ក្រុមហ៊ុនផលិត ផ្គត់ផ្គង់ និងចែកចាយថាមពលអគ្គិសនីទាំងអស់ឱ្យបន្តពង្រីកបណ្តាញជូនប្រជាពលរដ្ឋដើម្បីប្រើប្រាស់
- បន្តតាមដាន និងត្រួតពិនិត្យលើហេដ្ឋារចនាសម្ព័ន្ធបណ្តាញអគ្គិសនីឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ទាំងគុណភាព ប្រសិទ្ធភាព និងសោភណ្ឌភាពនៅទីប្រជុំជន ក្នុងក្រុងខេមរភូមិន្ទ ដើម្បីជៀសវាងកើតឧបទ្ទវហេតុផ្សេងៗ
- បន្តខិតខំកៀរគរចំណូលសួយសារធនធានរ៉ែ ដើម្បីបង់ចូលថវិការដ្ឋ។

### ៤.២.១.៦-ការងារពាណិជ្ជកម្ម

- បន្តផ្តល់ប្រឹក្សាយោបល់ និងសម្របសម្រួលការចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីម៉ាក និងបំពេញប្រតិវេទន៍ប្រចាំឆ្នាំតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម
- បន្តតាមដានស្តីពីសន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពលើទីផ្សារ ចំនួន១១៩មុខប្រចាំថ្ងៃ
- បន្តតាមដានការផ្គត់ផ្គង់ តម្រូវការ និងតម្លៃទំនិញប្រើប្រាស់ចាំបាច់សម្រាប់ជីវភាពប្រចាំថ្ងៃ រៀងរាល់២ដងក្នុងមួយសប្តាហ៍
- បន្តចុះត្រួតពិនិត្យ និងចែកសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយទូទាំងខេត្ត
- បន្តចុះសិក្សាផលិតផលសក្តានុពលនៅបណ្តាក្រុង ស្រុកទូទាំងខេត្ត
- បន្តរៀបចំដំណើរការផ្សារចុងសប្តាហ៍ខេត្តកោះកុង
- ត្រៀមចូលរួមការតាំងពិព័រណ៍ពាណិជ្ជកម្មថ្នាក់ជាតិ និងថ្នាក់តំបន់
- បន្តតាមដានស្ថានភាពជួញដូរទំនិញនៅច្រកទ្វារត្រួតពិនិត្យព្រំដែនអន្តរជាតិចាំយាម
- បន្តចូលរួមសហការជាមួយសាខាការពារអ្នកប្រើប្រាស់កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត ដើម្បីចុះត្រួតពិនិត្យគុណភាពទំនិញ និងសុវត្ថិភាពម្ហូបអាហារ។

### ៤.២.១.៧-ការងារហិរញ្ញវត្ថុ ពន្ធដារ គយ និងរដ្ឋាករ

#### ៤.២.១.៧.១-ការងារហិរញ្ញវត្ថុ

- បន្តពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ និងគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ
- បន្តពង្រឹងការត្រួតពិនិត្យចំណូល ចំណាយតាមបណ្តាអង្គភាព ក្រុង និងស្រុក ឱ្យបានត្រឹមត្រូវ
- ត្រៀមបណ្តុះបណ្តាលមន្ត្រីហិរញ្ញវត្ថុតាមបណ្តាអង្គភាពអនុវត្តថវិកានូវនីតិវិធីអនុវត្តថវិកា និងកិច្ចលទ្ធកម្មសាធារណៈ
- បន្តពង្រឹងការត្រួតពិនិត្យប្រគល់ ទទួល ចំពោះកិច្ចលទ្ធកម្មសាធារណៈ
- បន្តពង្រឹងការរៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុសាធារណៈ (FMIS) ឱ្យបានល្អប្រសើរ
- បន្តជំរុញរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ធ្វើបញ្ជីសារពើភណ្ឌ (ទាំងដីមានកម្មសិទ្ធិ និងដីបម្រុងរដ្ឋ)។

#### ៤.២.១.៧.២-ការងារពន្ធដារ

- បន្តកៀរគរចំណូលពន្ធ ដើម្បីសម្រេចបានតាមផែនការចំណូលពន្ធសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ របស់សាខាពន្ធដារខេត្តកោះកុង ដែលបានកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ និងបន្តអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល

២០២៤-២០២៨ ផែនការយុទ្ធសាស្ត្រ និងផែនការប្រតិបត្តិ ២០២៤-២០២៨ របស់អគ្គនាយកដ្ឋានពន្ធដារ។

**៤.២.១.៧.៣-ការងារគយ និងរដ្ឋាករ**

- បន្តពង្រឹងការងារគ្រប់គ្រងការប្រមូលពន្ធឱ្យបានតាមផែនការកំណត់ និងពង្រឹងការអនុវត្តវិមជ្ឈការតម្លៃឱ្យបានល្អ
- បន្តធ្វើប្រតិបត្តិការបង្ក្រាបរថយន្តចង្កូតឆ្វេង និងចង្កូតស្តាំដែលគ្មានពន្ធ
- បន្តបង្កើនប្រសិទ្ធភាពការងារបង្ការ បង្ក្រាបអំពើរត់គេចពន្ធ និងបន្លំពន្ធ ជាពិសេសតាមរយៈការអនុវត្តឱ្យបានហ្មត់ចត់ និងប្រកបដោយការទទួលខុសត្រូវខ្ពស់នូវបទបញ្ជាលេខ ០១បប ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០២២ របស់រាជរដ្ឋាភិបាលស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការទប់ស្កាត់ និងបង្ក្រាបអំពើរត់គេចពន្ធ
- បន្តពង្រឹងប្រសិទ្ធភាពនៃការបំពេញបែបបទបញ្ចេញទំនិញពីគយ ជាមួយក្រុមអន្តរាគមន៍ពិសេស និងក្រុមអនុលោមភាព ដើម្បីចូលរួមប្រសិទ្ធភាពការងារនៅតាមការិយាល័យមាត់ច្រកក្រោមឱវាទ និងបន្តកែលម្អ និងខិតខំប្រមូលចំណូលពីក្រុមទំនិញចម្រុះបន្ថែមឱ្យអស់តាមសក្តានុពលជាក់ស្តែង
- បន្តសម្របសម្រួលពាណិជ្ជកម្មអន្តរជាតិឱ្យបានសមស្របតាមបទប្បញ្ញត្តិជាធរមាន និងចាត់វិធានការគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនចេញ និងចូលឱ្យកាន់តែសុក្រឹត
- បន្តជំរុញសកម្មភាពគ្រប់គ្រងផលនេសាទនាំចេញនាំចូលឱ្យមកបង់ពន្ធតាមនីតិវិធីគយ
- បន្តពង្រឹងអភិបាលកិច្ច គុណភាពសេវារបស់អង្គភាពគយ និងរដ្ឋាករ និងបន្តបំពេញការងារឱ្យបានឆាប់រហ័ស និងមានប្រសិទ្ធភាពទាំងការងាររដ្ឋបាល និងការងារប្រតិបត្តិការគយ ពិសេសកែសម្រួលកម្លាំងដើម្បីបំពេញភារកិច្ចមានការទទួលខុសត្រូវច្បាស់លាស់តាមបទដ្ឋានគយ និងរដ្ឋាករ។

**៤.២.១.៨-ការងារទេសចរណ៍**

- បន្តផ្សព្វផ្សាយអំពីសក្តានុពល និងគោលដៅទេសចរណ៍ទាក់ទាញសំខាន់ៗក្នុងខេត្តដល់ភ្ញៀវទេសចរ
- បន្តផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ សារាចរណែនាំ សេចក្តីជូនដំណឹង និងជំរុញឱ្យអាជីវករមកធ្វើ និងបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបានទាន់ពេលវេលាទូទាំងខេត្ត
- បន្តជំរុញឱ្យអាជីវករមកធ្វើ និងបន្តអាជ្ញាបណ្ណទេសចរណ៍ឱ្យបានទាន់ពេលវេលា តាមរយៈអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក
- ត្រៀមចុះថតរូបភាពនិងវីដេអូនៅតំបន់គោលដៅទាក់ទាញទេសចរណ៍ នៅតាមបណ្តាក្រុងស្រុក សម្រាប់ផលិតជាវីដេអូ និងសម្ភារផ្សព្វផ្សាយសក្តានុពលទេសចរណ៍ក្នុងខេត្ត
- សហការរៀបចំ ទិវាទេសចរណ៍ពិភពលោក និងទិវាពិភពលោកស្អាត
- រៀបចំសិក្ខាសាលាផ្សព្វផ្សាយពង្រឹងគុណភាពសេវាកម្មទេសចរណ៍
- ត្រៀមសហការចុះសិក្សាស្រាវជ្រាវ ត្រួតពិនិត្យ និងវាយតម្លៃតំបន់ឆ្នេរក្នុងខេត្ត។

**៤.២.១.៩-ការងារផែនការ**

- បន្តប្រមូលទិន្នន័យរដ្ឋបាលមន្ទីរអង្គភាពសាខាជុំវិញខេត្ត
- បន្តសម្របសម្រួលប្រមូលតារាងតម្រូវអាទិភាពឃុំ/សង្កាត់ ក្រុង/ស្រុក តារាង១.១ក-១.១ខ-១.១គ សម្រាប់ដំណើរការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ឆ្នាំ២០២៧-២០២៩ ថ្នាក់ក្រោមជាតិ និងបញ្ចូលក្នុង SPD Program
- សហការជាមួយទីចាត់ការផែនការ និងវិនិយោគរដ្ឋបាលខេត្ត រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០២៧-២០២៩
- រៀបចំវេទិកាពិគ្រោះយោបល់ថ្នាក់ខេត្ត និងដំណើរការសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ២០២៧-២០២៩ តាមបណ្តាក្រុងស្រុក
- រៀបចំវគ្គបណ្តុះបណ្តាលការប្រមូលទិន្នន័យមូលដ្ឋានឃុំសង្កាត់ ឆ្នាំ២០២៦
- បន្តពិនិត្យនិងផ្ទៀងផ្ទាត់ការប្រមូលទិន្នន័យមូលដ្ឋានឃុំសង្កាត់ ឆ្នាំ២០២៦ និងបញ្ចូលក្នុងប្រព័ន្ធ CDB Online

- បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ និងចុះតាមដានត្រួតពិនិត្យតាមបណ្តាឃុំ/សង្កាត់
- រៀបចំកិច្ចប្រជុំផ្សព្វផ្សាយ វឌ្ឍនភាពការងារ និងជម្រុញការអនុវត្តទិន្នន័យគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ តាមបណ្តាក្រុង/ស្រុក
- បន្តចុះតាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់ចំនួនគ្រួសារមិនប្រក្រតីតាមបណ្តាឃុំ/សង្កាត់
- បន្តប្រមូល និងបញ្ចូលទិន្នន័យថ្លៃទំនិញតាមទីផ្សារ (ផ្សារដងទង់) តាមតាប្លេត (CAPI) ប្រចាំខែ
- បន្តចូលរួមអង្កេតនានារបស់វិទ្យាស្ថានជាតិស្ថិតិ
- បន្តចុះប្រមូលទិន្នន័យចំណូលចំណាយមន្ទីរ អង្គភាព សាខា ជុំវិញខេត្ត សម្រាប់គណនាផលិតផលក្នុងស្រុកសរុបGDP
- បន្តចុះប្រមូលធាតុចូល សម្រាប់រៀបចំចងក្រងសេចក្តីព្រាងផែនការសកម្មភាពអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រកម្ពុជាឆ្នាំ២០២៤-២០៣០ ខេត្តកោះកុង នៅតាមបណ្តាមន្ទីរ អង្គភាព សាខាជុំវិញខេត្ត
- រៀបចំរបាយការណ៍បម្រែបម្រួលប្រជាជន ឆ្នាំ២០១៥-២០២៥ (ផ្អែកតាមទិន្នន័យCDB)។

## ៤.២.១.១០-ការងារផ្សេងៗ

### ៤.២.១.១០.១-ការងារសាខាធនាគារជាតិនៃកម្ពុជា

- បន្តផ្តល់សេវាបើក និងបង់ប្រាក់ជូនអតិថិជន
- បន្តប្តូរប្រាក់ចាស់ ទក់ រហែក ជូនអតិថិជន
- បន្តស្រាល់ជ្រើសក្រដាសប្រាក់ចាស់ ទក់ រហែក
- បន្តរៀបចំកម្មវិធីផ្សព្វផ្សាយការទូទាត់ឌីជីថល (KHQR) និងប្រព័ន្ធបាគង នៅតាមទីប្រជុំជន។

### ៤.២.១.១០.២-ការងាររតនាគារ

- បន្តអនុវត្តកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធFMIS នូវជំហានបន្តបន្ទាប់
- បន្តពង្រឹងការកត់ត្រាចំណូល ចំណាយ តាមប្រព័ន្ធFMIS ឱ្យកាន់តែប្រសើរ
- បន្តអនុវត្តសារាចរលេខ ០៧ សរ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់ប្រាក់បៀវត្សរៀងរាល់២សប្តាហ៍ម្តង ក្នុងខែនីមួយៗ
- បន្តពង្រឹងការអនុវត្តប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ដល់រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ឱ្យបានកាន់តែប្រសើរ
- បន្តពិនិត្យផ្ទៀងផ្ទាត់របាយការណ៍ចំណូល ចំណាយ និងតារាងតុល្យភាពឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

### ៤.២.១.១០.៣-ការងារសាខាការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំខេត្ត

- បន្តចុះត្រួតពិនិត្យទំនិញនៅទីផ្សារ តាមផ្ទះ និងហាងលក់ទំនិញ(ម៉ាត) ដើម្បីទប់ស្កាត់ឱ្យទាន់ពេលវេលា ចំពោះការប្រព្រឹត្តទំនិញតាមទីផ្សារខុសពីលក្ខខណ្ឌ នៃច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា និងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងៗទៀតជាធរមាន
- បន្តចុះអង្កេតជាប្រចាំនូវតម្លៃតាមសេចក្តីជូនដំណឹងស្តីពីតម្លៃលក់រាយប្រេងឥន្ធនៈរបស់ក្រសួងពាណិជ្ជកម្មតាមបណ្តាស្ថានីយ/ដេប៉ូ ក្នុងខេត្តកោះកុង ដើម្បីមានវិធានការណ៍បន្ទាន់ចំពោះស្ថានីយ/ដេប៉ូណាដែលមិនគោរពតាមសេចក្តីជូនដំណឹងរបស់ក្រសួងពាណិជ្ជកម្ម
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីសុវត្ថិភាពម្ហូបអាហារដល់លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សតាមបណ្តាសាលារៀនក្នុងខេត្តកោះកុង
- បន្តណែនាំអាជីវករអំពីរបៀបតាំងលក់ទំនិញឱ្យបានសមស្របជៀសវាងខូច និងប្រែប្រួលគុណភាពមុនកាលបរិច្ឆេទកំណត់។

### ៤.២.២-ផ្នែកសង្គមកិច្ច

#### ៤.២.២.១-ការងារអប់រំ យុវជន និងកីឡា

- ត្រៀមរៀបចំដំណើការ និងកំណត់មណ្ឌលប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ
- បន្តចុះពិនិត្យតាមដាន ណែនាំ និងវាយតម្លៃលើការងារបច្ចេកទេសផ្សេងៗ ជាពិសេសចុះជួយគាំទ្រការអនុវត្តស្តង់ដាសាលារៀនគំរូ នៅតាមគ្រឹះស្ថានសិក្សាគោលដៅ
- បន្តផ្តល់ជំនួយបច្ចេកទេសក្នុងការជួយសិស្សរៀនយឺត និងពិនិត្យដំណើរការបណ្ណាល័យតាមគ្រឹះស្ថានសិក្សា
- ត្រៀមរៀបចំយុទ្ធនាការផ្សព្វផ្សាយប្រមូលកុមារគ្រប់អាយុចូលរៀន និងសិស្សនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ
- ត្រៀមរៀបចំប្រារព្ធពិធីបើកបវេសនកាល ឆ្នាំសិក្សា២០២៦-២០២៧។

#### ៤.២.២.២-ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តចុះសហការ និងផ្តល់បច្ចេកទេសជូនប្រធានសមាគមមនុស្សចាស់តាមភូមិ ឃុំ សង្កាត់
- បន្តចុះជម្រុញដល់សមាគមមនុស្សចាស់ដែលបានបង្កើតរួចឱ្យដំណើរការ
- បន្តចុះសួរសុខទុក្ខជនចាស់ជរាក្រីក្រ និងកុមារងាយរងគ្រោះក្នុងសហគមន៍
- បន្តចុះសួរសុខទុក្ខកុមារកំព្រាក្នុងមជ្ឈមណ្ឌលកុមារកំព្រារដ្ឋខេត្តកោះកុង
- បន្តចុះសម្របសម្រួល និងជំរុញដល់មន្ត្រីបង្គោលកាន់កម្មវិធីកំណត់អត្តសញ្ញាណកម្មជនមានពិការភាពតាមក្រុង/ស្រុកទាំង៧ ដើម្បីកែសម្រួលទិន្នន័យ និងសម្ភាសន៍ឡើងវិញ
- បន្តចូលរួមស្តាប់ចម្លើយអនីតិជនទំនាស់នឹងច្បាប់ចំនួន១នាក់ ភេទប្រុស អាយុ១៥ឆ្នាំ ករណីលួច នៅសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកោះកុង ។

#### ៤.២.២.៣-ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបេឡាជាតិសន្តិសុខសង្គម

##### ៤.២.២.៣.១-ការងារ ការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តជំរុញដល់នាយកសហគ្រាស/គ្រឹះស្ថាន ដែលប្រើប្រាស់កម្មករ និយោជិតខ្មែរ និងបរទេសមុនចូលបម្រើការងារ និងកំពុងបម្រើការងារឱ្យមកធ្វើសៀវភៅ និងបណ្ណការងារឱ្យស្របតាមច្បាប់
- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ និងលក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង
- បន្តពង្រឹងយន្តការដោះស្រាយវិវាទការងាររួម និងវិវាទបុគ្គល
- បន្តពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារតាមបណ្តាសហគ្រាស/គ្រឹះស្ថានក្នុងខេត្ត
- បន្តពង្រឹងប្រសិទ្ធភាព និងគុណភាពសេវារដ្ឋបាលសាធារណៈរបស់មន្ទីរ
- បន្តពង្រឹងភាពសុខដុមរមនា នៃទំនាក់ទំនងវិជ្ជាជីវៈរវាងកម្មករ និយោជិត និងនិយោជកឱ្យបានល្អប្រសើរ។

##### ៤.២.២.៣.២-ការងារបេឡាជាតិសន្តិសុខសង្គម

- បន្តផ្សព្វផ្សាយគោលនយោបាយសន្តិសុខសង្គម ដល់ស្ថាប័នពាក់ព័ន្ធ ទាំងវិស័យសាធារណៈ និងឯកជន
- បន្តស្រាវជ្រាវ និងចុះបញ្ជិកាសហគ្រាសថ្មីៗក្នុងខេត្តកោះកុង។

#### ៤.២.២.៤-ការងារវប្បធម៌ និងវិចិត្រសិល្បៈ

- បន្តតាំងបង្ហាញវត្ថុសិល្បៈដែលស្រង់ចេញពីសំពៅលិច និងវត្ថុដែលមាននៅតាមជួរភ្នំក្រវាញ ក្នុងសាលពិព័រណ៍ខេត្តកោះកុង និងបោសសម្អាតឃ្លាំងដាក់បំណែកកុលាលភាជន៍
- បន្តពង្រឹងការគ្រប់គ្រង ថែរក្សា និងការពារស្ថានីយ ចេតិយ និងបូជនីយដ្ឋានប្រវត្តិសាស្ត្រនានា ក្នុងភូមិសាស្ត្រខេត្តកោះកុង
- បន្តបណ្តុះបណ្តាលរបាំបុរាណ និងរបាំប្រពៃណី ដល់សិស្សានុសិស្ស និស្សិត និងយុវជននានា

- បន្តត្រៀមរៀបចំមហោស្រពសិល្បៈថ្នាក់ខេត្តឆ្នាំ២០២៦
- បន្តត្រៀមបើកវគ្គបណ្តុះបណ្តាលគំនូរដល់សិស្ស
- បន្តចុះស្រង់សាស្ត្រាស្លឹករិត នៅក្នុងស្រុកបូទុមសាគរ និងស្រុកគិរីសាគរ។

### ៤.២.២.៥-ការងារព័ត៌មាន

- បន្តជំរុញការផ្សព្វផ្សាយផ្នែកឯកជននានាឱ្យគោរពច្បាប់ និងបទដ្ឋានបច្ចេកទេសវិស័យព័ត៌មាន
- បន្តផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីការដាក់ពាក្យស្នើសុំបើក និងបន្តសុពលភាពអាជ្ញាបណ្ណវិស័យព័ត៌មាន ជូនដល់ម្ចាស់អាជីវកម្ម សេវាកម្មនៅក្នុងខេត្តទាំងអស់ដែលពុំទាន់មានអាជ្ញាបណ្ណ និងអាជ្ញាបណ្ណផុតសុពលភាព ត្រូវមកស្នើសុំអាជ្ញាបណ្ណរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមច្បាប់កំណត់ និងទាន់ពេលវេលា
- បន្តជំរុញការចុះយកព័ត៌មានតាមរយៈថតវីដេអូ និងបង្កើនទំនាក់ទំនងតាមបណ្តាក្រុង ស្រុកដើម្បីទទួលបានព័ត៌មាន
- បន្តស្រាវជ្រាវលើបច្ចេកវិទ្យា និងកម្មវិធីថ្មីៗស្របតាមកាលៈទេសៈសង្គម
- បន្តជំរុញ និងបង្កើនការផ្សព្វផ្សាយតាមរយៈវិទ្យុជាតិ ទូរទស្សន៍បាយ័ន និងទូរទស្សន៍ផ្សេងៗទៀត
- បន្តជំរុញ និងបង្កើនការផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម ឱ្យកាន់តែទូលំទូលាយជាងមុន
- បន្តជំរុញការយកចិត្តទុកដាក់កែលម្អកម្មវិធីផ្សាយរបស់វិទ្យុផ្សាយសំឡេង
- បន្តផ្សព្វផ្សាយព័ត៌មាន ស្ប៉ូតអប់រំផ្សេងៗ ពិសេសស្ប៉ូតស្តីពីជំងឺកូវីដ-១៩
- បន្តផ្សព្វផ្សាយរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំជាតិ និងខេត្តឱ្យកាន់តែទូលំទូលាយ។

### ៤.២.២.៦-ការងារកិច្ចការនារី

- បន្តចុះគាំទ្រដល់ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម ក្នុងការបញ្ជ្រាបយេនឌ័រ បរិយាបន្ន និងសមធម៌សង្គម ទាក់ទងនឹងការអនុវត្តតួនាទី ភារកិច្ច របស់ គ.ក.ស.ក និង គ.ក.ន.ក ឃុំ/សង្កាត់ ស្តីពី ការផ្តល់សេវាសង្គមដល់ប្រជាពលរដ្ឋ និងការផ្ទេរមុខងារដល់រដ្ឋបាល ក្រុង/ស្រុក នៅស្រុកបូទុមសាគរ និងស្រុកស្រែអំបិល
- ត្រៀមរៀបចំការផ្សព្វផ្សាយស្តីពី ការលើកកម្ពស់សុខភាពអាហារូបត្ថម្ភសម្រាប់ស្ត្រី និងក្មេងស្រី ដល់ការិយាល័យពាក់ព័ន្ធថ្នាក់ស្រុក នៅស្រុកបូទុមសាគរ
- ចុះតាមដានការធ្វើផែនការអាជីវកម្មខ្នាតតូចរបស់អាជីវករ និងកសិករ នៅឃុំជីខលើ ស្រុកស្រែអំបិល
- ត្រៀមរៀបចំកិច្ចប្រជុំស្តីពី ការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន សមធម៌សង្គម ជាមួយមន្ត្រីបង្គោល យេនឌ័រតាមមន្ទីរវិស័យ
- ត្រៀមផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ដល់ការិយាល័យពាក់ព័ន្ធថ្នាក់ក្រុង ស្រុក នៅក្រុងខេមរភូមិន្ទ
- ត្រៀមរៀបចំកិច្ចប្រជុំស្តីពីការលើកកម្ពស់សមភាពយេនឌ័រ បរិយាប័ន្ន និងសមធម៌សង្គមជាមួយមន្ត្រីបង្គោលយេនឌ័រ តាមមន្ទីរវិស័យ
- ត្រៀមរៀបចំយុទ្ធនាការ ១៦ថ្ងៃ (២៥-១២-២៦ ដល់ ១០-១២-២៦) ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី និងក្មេងស្រីនៅក្រុងខេមរភូមិន្ទ។

### ៤.២.២.៧-ការងារអធិការកិច្ច

- បន្តសហការជាមួយមន្ទីរជំនាញចុះតាមដានការអនុវត្តច្បាប់ របស់រាជរដ្ឋាភិបាលនៅតាមក្រុង ស្រុក ទូទាំងខេត្តកោះកុង
- បន្តទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋ និងមជ្ឈដ្ឋាននានា ដើម្បីពិនិត្យដោះស្រាយតាមនីតិវិធី
- បន្តសម្របសម្រួល និងទំនាក់ទំនងរាល់ការងាររវាងអាជ្ញាធរខេត្ត និងទីស្នាក់ការរដ្ឋសភាមណ្ឌលខេត្តកោះកុង
- បន្តចុះធ្វើអធិការកិច្ចតាមផែនការនិងត្រៀមចុះធ្វើអធិការកិច្ចតាមហានិភ័យ។

### ៤.២.២.៨-ការងារធម្មការនិងសាសនា

- ត្រៀមចូលរួមសហការរៀបចំចូលព្រះវស្សា ពិធីបុណ្យកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ពិធីបុណ្យចេញព្រះវស្សា ពិធីបុណ្យកឋិនទាន
- ត្រៀមសហការរៀបចំប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះករុណាព្រះបាទ សម្ដេចព្រះនរោត្តម សីហនុ "ព្រះបរមរតនកោដ្ឋ" ពិធីបុណ្យឯករាជ្យជាតិ ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក
- ត្រៀមរៀបចំបោះឆ្នោតជ្រើសរើសអាចារ្យ គណៈកម្មាធិការវត្តនានាក្នុងខេត្ត
- បន្តពិនិត្យលិខិតអនុញ្ញាតច្បាប់ចុះបញ្ជីសាសនាតាម ព្រះវិហារ និងស្នាក់ការថ្វាយបង្គំ
- ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈដើម្បីរៀបចំអបអរសាទរពិធីគ្រងរាជព្រះបរមរាជសម្បត្តិព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- បន្តជំរុញឱ្យស្នាក់ការថ្វាយបង្គំ ស្នើសុំបន្តសុពលភាពឱ្យបានគ្រប់ស្នាក់ការ
- ត្រៀមសហការជាមួយព្រះមន្ត្រីសង្ឃ ដើម្បីចូលរួមទប់ស្កាត់អធិករណ៍តាមបណ្ដាវត្ត
- ត្រៀមសហការជាមួយសាលាគណទាំងពីរគណៈ ដើម្បីជម្លៀសព្រះសង្ឃ លោកអាចារ្យ គណៈកម្មាធិការ សីលវន្ត សីលវតី ពីតំបន់ជម្លោះព្រំដែន
- បន្តពិនិត្យ និងសម្របសម្រួលសំណើសុំបង្កើតសាលាពុទ្ធិកសិក្សា។

### ៤.២.២.៩-ការងារប្រៃសណីយ៍ និងទូរគមនាគមន៍

- បន្តចុះត្រួតពិនិត្យ និងពង្រឹងការគ្រប់គ្រងគោលនយោបាយលើការប្រើប្រាស់ និងការធ្វើសេវាលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ និងបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងខេត្ត
- បន្តផ្សព្វផ្សាយប្រកាសរួម លេខ ៤៩៨ សហវ.ប្រក ចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៨ របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវាសាធារណៈដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជូនដល់អាជីវករពាក់ព័ន្ធការបើកធ្វើសេវាអាជីវកម្មលើវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានក្នុងខេត្ត។

### ៤.២.២.១០-ការងារមុខងារសាធារណៈ

- បន្តត្រួតពិនិត្យ និងផ្តល់ទិដ្ឋាការលើសំណើសុំទូទាត់ប្រាក់បៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្ដាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តពិនិត្យផ្ទៀងផ្ទាត់ រៀបចំរបាយការណ៍ និងបែងចែកតារាងបៀវត្សប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលនៅតាមបណ្ដាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុក
- បន្តត្រួតពិនិត្យ ផ្តល់ទិដ្ឋាការលើសំណុំឯកសារផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការស៊ីវិលនៅតាមបណ្តាមន្ទីរ អង្គភាព និងរដ្ឋបាលខេត្ត ក្រុង ស្រុកជុំវិញខេត្តឱ្យបានត្រឹមត្រូវ
- បន្តផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារមន្ត្រីរាជការ និងបន្តត្រួតពិនិត្យ តាមដាន និងជំរុញការបង្វែរប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យាដែលបើកមិនប្រក្រតីចូលថវិការដ្ឋវិញ។

### ៤.២.២.១១-ការងារផ្សេងៗ

#### ៤.២.២.១១.១-ការងារសាលាដំបូង

- ជំរុញ និងបង្កើនប្រសិទ្ធភាពការងារអនុវត្តតាមច្បាប់
- ពង្រឹងការចុះបញ្ជី សំណុំរឿងក្តីព្រហ្មទណ្ឌ និងសំណុំរឿងរដ្ឋប្បវេណី
- បន្តត្រួតពិនិត្យការឃុំខ្លួនបណ្តោះអាសន្ន ចៀសវាងការឃុំខ្លួនលើសនីតិវិធីច្បាប់កំណត់

- ជំរុញការងារស៊ើបសួរ សំណុំរឿងព្រហ្មទណ្ឌឱ្យលឿន និងឆាប់រហ័ស និងមានភាពត្រឹមត្រូវស្របតាមច្បាប់ជូនប្រជាពលរដ្ឋ
- ធ្វើការរៀបចំរចនាសម្ព័ន្ធលេខាធិការដ្ឋានរដ្ឋបាលសាលាដំបូងឱ្យស្របទៅតាមច្បាប់រៀបចំអង្គភាពតុលាការ
- ពង្រឹងការប្រជុំមន្ត្រីនគរបាលយុត្តិធម៌ឱ្យបានញឹកញាប់ ដើម្បីឱ្យមានការស្វែងយល់ឱ្យស៊ីជម្រៅតាមក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមព្រហ្មទណ្ឌ និងច្បាប់ពាក់ព័ន្ធ ឱ្យបានត្រឹមត្រូវហើយមានប្រសិទ្ធភាពខ្ពស់
- រៀបចំផែនការចុះអធិការកិច្ចបណ្តាអង្គភាពនគរបាលយុត្តិធម៌ពាក់ព័ន្ធ ក្នុងដែនសមត្ថកិច្ច និងរៀបចំកិច្ចប្រជុំដើម្បីដោះស្រាយបញ្ហាប្រឈមផ្សេងៗជូនដល់មន្ត្រីនគរបាលយុត្តិធម៌
- បន្តចំណាត់ការរឿងក្តីដោយផ្តល់ជាអាទិភាពចាត់ការឱ្យបានឆាប់រហ័សទាន់ពេលវេលាចំពោះ រឿងក្តីព្រហ្មទណ្ឌទាក់ទិនកុមារ និងស្ត្រី ជាពិសេសរឿងបទល្មើសសម្អាតប្រាក់ បទល្មើសជួញដូរមនុស្ស បទល្មើសគ្រឿងញៀន បទល្មើសចរាចរណ៍ និងអគ្រានុកូលដ្ឋាន។

## ២.៣-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ២.៣.១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី

- បន្តពង្រឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរ និងប្រមូលចំណូលជូនរដ្ឋ
- បន្តអនុវត្តការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងដាច់ដោយដុំ
- បន្តពង្រឹង និងយកចិត្តទុកដាក់ការងារគ្រប់គ្រងសំណង់
- បន្តចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ។

### ២.៣.២-ការងារបរិស្ថាន

- ត្រៀមរៀបចំបណ្តុះកូនដើមឈើចំនួន៥០.០០០ដើម
- ត្រៀមរៀបចំប្រារព្ធទិវាអនាម័យបរិស្ថានជាតិ ២៣វិច្ឆិកា
- បន្តចុះយុទ្ធនាការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក កម្ពុជាស្អាត និងខ្មែរធ្វើបាន និងសម្អាតផ្លូវជាតិគ្មានសំរាមប្លាស្ទិក
- បន្តចុះពិនិត្យទីតាំងនិងស្រង់ស្ថិតិផ្ទះចិញ្ចឹមសត្វត្រចៀកកាំ នៅតាមក្រុងស្រុកនិងផ្តល់យោបល់លើការរៀបចំកិច្ចសន្យាការពារបរិស្ថានលើអាជីវកម្ម សិប្បកម្ម និងជំរុញការបង់មូលនិធិទាយជ្ជទានបរិស្ថានប្រចាំឆ្នាំ
- បន្តចុះធ្វើយុទ្ធនាការ អប់រំ ផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដល់ប្រជាពលរដ្ឋ
- បន្តចុះល្បាតទប់ស្កាត់បង្ក្រាបរាល់បទល្មើសធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបញ្ឈប់ការទន្ទ្រានដីព្រៃយកធ្វើជាកម្មសិទ្ធិ ការបរបាញ់ ការដាក់អន្ទាក់និងការចាប់សត្វព្រៃក្នុងតំបន់ការពារធម្មជាតិ
- បន្តចុះផ្សព្វផ្សាយទប់ស្កាត់ និងបង្ការភ្លើងឆេះព្រៃ
- បន្តចុះផ្សព្វផ្សាយលិខិតបទដ្ឋានការគ្រប់គ្រងសមុទ្រ តំបន់ឆ្នេរ និងកោះ សិក្សាពីជីវចម្រុះនិងពិនិត្យតាមដានប្រភេទសត្វ រុក្ខជាតិសំខាន់ៗនៅក្នុង សមុទ្រតំបន់ឆ្នេរ និងកោះ
- បន្តចុះពិនិត្យតាមដានរាល់សកម្មភាពរំលោភចាក់យកដីចំណីឆ្នេរ សមុទ្រធ្វើជាកម្មសិទ្ធិ
- បន្តចុះផ្សព្វផ្សាយអំពីគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រងសមុទ្រ តំបន់ឆ្នេរ និងកោះ
- បន្តចុះសិក្សាស្រាវជ្រាវរៀបចំទិន្នន័យប្រភេទសត្វ និងរុក្ខជាតិដែលកម្រងាយ រងគ្រោះនិងជិតផុតពូជក្នុងដែនសមុទ្រ តំបន់ឆ្នេរ និងកោះ
- ត្រៀមបើកវគ្គផ្សព្វផ្សាយស្តីពីការរៀបចំ និងការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិ
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពីនីតិវិធីក្នុងការល្បាត និងរបៀបសរសេររបាយការណ៍ និងកំណត់ហេតុ
- បន្តផលិតផ្លាកសញ្ញាអប់រំផ្សព្វផ្សាយបរិស្ថានចំនួន១០០ផ្លាក

- បន្តចុះល្បាតជាប្រចាំនៅតាមចំណុចទីតាំងកាប់រានដីព្រៃ ដែលបានដាក់ពាក្យបណ្តឹងរួចនៅក្នុងតំបន់ការពារធម្មជាតិ និងបន្តកិច្ចសហការជាមួយតំបន់ការពារធម្មជាតិដទៃទៀត ភូមិសាស្ត្រខេត្តកោះកុង
- បន្តរៀបចំកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តកោះកុង
- បន្តរៀបចំបណ្តុះកូនឈើ និងដាំស្តារព្រៃរេចរឹលឡើងវិញ
- ត្រៀមរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិតាទៃលើ និងឫស្សីជ្រុំ
- បន្តសម្របសម្រួលការងារគណៈកម្មការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិតាមការចាំបាច់
- បន្តសម្របសម្រួលរៀបចំសហគមន៍តំបន់ការពារធម្មជាតិ (ពោធិ៍បឹង ស្ទឹងវែង និងរៀបចំបង្កើតថ្មី សហគមន៍តំបន់ការពារធម្មជាតិទឹកធ្លាក់សិលាមានជ័យ)
- ត្រៀមរៀបចំផែនការគ្រប់គ្រងសហគមន៍តំបន់ការពារធម្មជាតិពាមក្រសោប កោះស្រឡៅ និងកោះកាពិ។

## ២.៣.៣-ការងារសាធារណការ និងដឹកជញ្ជូន

- បន្តអនុវត្តការងារថែទាំជាប្រចាំជួសជុលសំបុកមាន់ និងស្រោចកៅស៊ូលើស្នាមប្រេះ សម្រាប់ឆ្នាំ២០២៦
- បន្តអនុវត្តគម្រោងថែទាំខួបឆ្នាំ២០២៦ ផ្លូវជាតិលេខ៤៨-៥ (ជំពូក៦១)
- បន្តអនុវត្តគម្រោងការងារ Reseal DBST ឆ្នាំ២០២៦ ផ្លូវជាតិលេខ៤៨-៥ (ជំពូក៦១)
- បន្តចូលរួមសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធចុះត្រួតពិនិត្យយានយន្តគ្រប់ប្រភេទ ដែលធ្វើចរាចរណ៍តាមដងផ្លូវសាធារណៈឲ្យគោរពច្បាប់ចរាចរណ៍ ពិសេសឱ្យអនុវត្ត ច្បាប់ចរាចរណ៍ផ្លូវគោកថ្មី និងរឹតបន្តឹងគ្រប់អ្នកបើកបររថយន្តទាំងអស់ត្រូវមានបណ្ណបើកបរ និងបន្តចុះផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកតាមសាលារៀន ទីប្រជុំជន និងស្រង់ស្ថិតិយានដ្ឋានជួសជុលក្នុងក្រុង និងតាមស្រុក ខេត្តកោះកុង
- បន្តការត្រួតពិនិត្យយានយន្តកែច្នៃខុសលក្ខណបច្ចេកទេសតាមច្បាប់កំណត់ និងរថយន្តដឹកជញ្ជូន ដឹកដី ខ្សាច់ថ្ម ដែលអាចបង្កគ្រោះថ្នាក់ចរាចរណ៍ និងខូចខាតផ្លូវថ្នល់។

## ២.៣.៤-ការងារផ្សេងៗ

- (ពុំមាន)។

# ២.៤-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

## ២.៤.១-ការងារអនុវត្តគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"

- បន្តផ្សព្វផ្សាយគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" លេខ ០១ គ.ន.ប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ ២០២១ របស់រាជរដ្ឋាភិបាលឱ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋ គ្រប់ភូមិ ឃុំ សង្កាត់ និងបណ្តាអង្គការសង្គមស៊ីវិលទូទាំងខេត្ត
- បន្តរៀបចំកសាងផែនការ និងកម្មវិធីការងារប្រចាំខែសម្រាប់ចុះអនុវត្តគោលនយោបាយនៅតាមមូលដ្ឋានភូមិ ឃុំ សង្កាត់ ដែលក្រុមនីមួយៗទទួលខុសត្រូវ
- បន្តបង្កើនកម្មវិធីធ្វើវេទិកាសាធារណៈឱ្យបានគ្រប់ភូមិ ឃុំ សង្កាត់ ទូទាំងខេត្ត ដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋចូលរួមយោបល់ដោះស្រាយបញ្ហាផ្សេងៗ ដែលបានកើតឡើងក្នុងមូលដ្ឋានរបស់ខ្លួន និងទិតៀនកែលម្អរាល់សកម្មភាពអសកម្មរបស់សមត្ថកិច្ច និងអាជ្ញាធរមូលដ្ឋានដែលមានកន្លងមក សំដៅបង្កើនសកម្មភាពអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យកាន់តែមានប្រសិទ្ធភាព
- បន្តដឹកនាំអនុវត្តឱ្យបានទៀងទាត់នូវរបបប្រជុំប្រចាំខែដើម្បីត្រួតពិនិត្យលទ្ធផលកិច្ចប្រតិបត្តិការ និងដាក់ចេញផែនការវិធានការ អនុវត្តជាក់ស្តែងក្នុងរង្វង់សមត្ថកិច្ចទទួលខុសត្រូវរបស់ខ្លួន
- បន្តយកចិត្តទុកដាក់ចាត់តាំងអនុវត្តនូវបណ្តាវិធានការស្តីពីការលុបបំបាត់បទល្មើស និងគ្រោះថ្នាក់សង្គម ពាក់ព័ន្ធនឹងលក្ខណៈសម្បត្តិទាំង៧យ៉ាង នៃគោលនយោបាយ"ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តជំរុញចលនាប្រឡងប្រណាំងបង្កើតស្នាដៃនៅតាមភូមិ ឃុំ សង្កាត់ ឱ្យបានផុលផុសក្នុងការអនុវត្តគោលនយោបាយ

“ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព” សម្រាប់ទទួលការសរសើរ និងជូនរង្វាន់ប្រចាំឆ្នាំនីមួយៗ។

### ២.៤.២-ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងចរាចរណ៍

- បន្តស្រាវជ្រាវក្តាប់សភាពការណ៍ ឧបាយកលរបស់បណ្តាភាគីអមិត្ត និងចលនាប្រឆាំងផ្សេងៗចំពោះរាជរដ្ឋាភិបាល ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- បន្តពង្រឹងការងារត្រួតពិនិត្យវត្តមានជនបរទេសឆ្លងកាត់ និងស្នាក់នៅក្នុងខេត្តដើម្បីទប់ស្កាត់ការលួចជ្រៀតចូលរបស់ក្រុមភេរវជន
- បន្តក្តាប់សភាពការណ៍បាតុកម្ម កូដកម្ម និងអំពើភេរវកម្មផ្សេងៗ ដើម្បីមានវិធានការទប់ស្កាត់ និងបង្ក្រាបឱ្យបានទាន់ពេលវេលា
- បន្តក្តាប់រាល់សភាពការណ៍ បទល្មើសព្រហ្មទណ្ឌទូទាំងខេត្ត និងធ្វើការវិភាគវាយតម្លៃឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីដាក់ចេញនូវវិធានការបង្ការ និងបង្ក្រាបឱ្យមានប្រសិទ្ធភាព
- បន្តជំរុញវិធានការ និងបង្ក្រាបក្រុមក្មេងទំនើងនៅទូទាំងខេត្តឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីរក្សាសណ្តាប់ធ្នាប់របៀបរៀបរយ និងកាត់បន្ថយបទល្មើសក្នុងសង្គម
- បន្តពង្រឹងបំប៉នជំនាញដល់មន្ត្រីនគរបាលយុត្តិធម៌គ្រប់លំដាប់ថ្នាក់ ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាព
- បន្តសហការជាមួយអាជ្ញាធរដែនដី ដើម្បីបំផុសចលនាប្រជាពលរដ្ឋឱ្យចូលរួមប្រឆាំងទប់ស្កាត់បទល្មើសគ្រឿងញៀន
- បន្តកិច្ចសហប្រតិបត្តិការល្អជាមួយភ្នាក់ងារប្រឆាំងគ្រឿងញៀនភាគីថៃ ដើម្បីដកបទពិសោធន៍ និងផ្តល់ព័ត៌មានជូនគ្នាទៅវិញទៅមក សំដៅធ្វើការបង្ក្រាបបទល្មើសគ្រឿងញៀនឆ្លងដែនឱ្យមានប្រសិទ្ធភាព
- បន្តផ្សព្វផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកថ្មី ដើម្បីអប់រំឱ្យស៊ីជម្រៅដល់ប្រជាពលរដ្ឋ សំដៅកាត់បន្ថយនូវអត្រាគ្រោះថ្នាក់ចរាចរណ៍ និងមានវិធានការផាកពិន័យតាមច្បាប់កំណត់
- បន្តពង្រឹងការគ្រប់គ្រងបណ្តាគោលដៅដែលពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស អំពើកេងប្រវ័ញ្ច ដូចជា គោលដៅតាមសណ្ឋាគារ និងផ្ទះសំណាក់។ល។ ដោយធ្វើកិច្ចសន្យា និងតាមដានកុំឱ្យគោលដៅទាំងនោះ ក្លាយជាកន្លែងប្រព្រឹត្តបទល្មើស
- បន្តចុះស្រង់ទិន្នន័យ និងស្រាវជ្រាវប្រជាពលរដ្ឋធ្វើចំណាកស្រុកទៅរកការងារធ្វើនៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់។

### ២.៤.៣-ការងារគ្រប់គ្រងជនបរទេសអន្តោប្រវេសន្ត

- បន្តទទួលពាក្យស្នើសុំបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកដំបូង ចំពោះអ្នកគ្រប់អាយុ និងស្នើសុំបន្តសុពលភាពបណ្ណស្នាក់នៅអចិន្ត្រៃយ៍លើកទី១ តាមនីតិវិធី
- បន្តរៀបចំបញ្ជីទទឹងជនបរទេសអន្តោប្រវេសន្ត ដែលមិនមកបន្តសុពលភាពបណ្ណស្នាក់នៅ
- បន្តសហការជាមួយបណ្តាម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ និងផ្ទះជួល ប្រមូលព័ត៌មាននិងទិន្នន័យជនបរទេសស្នាក់នៅរយៈពេលខ្លី និងរយៈពេលវែង ដើម្បីអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់
- បន្តសហការជាមួយអធិការនគរបាលក្រុង ស្រុក និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងវត្តមានជនបរទេស និងត្រួតពិនិត្យស្រាវជ្រាវរកជនបរទេសដែលលួចចូលស្នាក់នៅ និងប្រកបមុខរបរមិនស្របច្បាប់
- បន្តចែកប្រកាសទទួលស្គាល់ជនបរទេសអន្តោប្រវេសន្ត និងបណ្ណស្នាក់នៅអចិន្ត្រៃយ៍ដល់ជនបរទេសអន្តោប្រវេសន្តប្រើប្រាស់តាមនីតិវិធីច្បាប់
- បន្តសហការជាមួយអង្គភាពពន្ធនាគារ ដើម្បីគ្រប់គ្រង និងប្រមូលទិន្នន័យជនបរទេសឱ្យបានជាប់ជាប្រចាំ
- បន្តជំរុញអធិការនគរបាលក្រុង ស្រុក អនុវត្តផែនការលេខ ០៩៥៨.ក របស់ស្នងការដ្ឋាននគរបាលខេត្ត ស្តីពីការគ្រប់គ្រងវត្តមានជនបរទេសស្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន និងធ្វើការស្រាវជ្រាវរកឯកសារលិខិតឆ្លងដែនរបស់ជនបរទេសដែលស្នាក់នៅលើសទិដ្ឋាការ ដើម្បីបញ្ជូនទៅអគ្គនាយកដ្ឋានអន្តោប្រវេសន៍ធ្វើការផាកពិន័យ និងបន្ត

នីតិវិធីបណ្តេញចេញពីប្រទេស។

២.៤.៤-ការងារគ្រប់គ្រងពន្ធនាគារ

- បន្តអប់រំមន្ត្រីឱ្យយល់ដឹងអំពីច្បាប់ ក្រមសីលធម៌ និងបទវិន័យរបស់មន្ត្រីពន្ធនាគារ
- បន្តអប់រំជនជាប់ឃុំឱ្យយល់ដឹងពីក្រមព្រហ្មទណ្ឌ ច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់ស្តីពីគ្រឿងញៀន និងបទល្មើសមិនរាងចាល
- បន្តរៀបចំវគ្គបណ្តុះបណ្តាលជូនដល់ជនជាប់ឃុំឱ្យមានជំនាញ កាត់សក់ ដេរប៉ាក់ ជាងឈើ ជាងសំណង់ និងជាងជួសជុលរថយន្ត
- បន្តពិនិត្យរៀបចំកម្មវិធីផែនការកសិកម្ម និងឧស្សាហកម្មក្នុងពន្ធនាគារ
- បន្តលើកគោលការណ៍ ណែនាំដល់មន្ត្រីពន្ធនាគារ ពិសេសអនុវត្តកម្មវិធីគ្រប់គ្រងពន្ធនាគារ និងការផ្តត់ផ្គង់ជីវភាពសេវាថែទាំសុខភាពរបស់ជនជាប់ឃុំ និងអនាម័យក្នុងពន្ធនាគារ
- បន្តពិនិត្យ និងឆែកឆេរយ៉ាងហ្មត់ចត់ក្នុងតំបន់ឃុំឃាំង
- បន្តសហការជាមួយអង្គការលីកាដូ ក្នុងការប្រឹក្សាយោបល់ផ្នែកច្បាប់ ការពិនិត្យព្យាបាលជំងឺ និងផ្តល់ថ្នាំពេទ្យជូនជនជាប់ឃុំ និងចែកអំណោយជូនកូនតាមម្តាយក្នុងពន្ធនាគារខេត្ត។

របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០២៦ ត្រូវបានពិនិត្យ និងអនុម័តនៅក្នុងកិច្ចប្រជុំសាមញ្ញលើកទី២៦ អាណត្តិទី៤ របស់ក្រុមប្រឹក្សាខេត្តកោះកុង នាថ្ងៃព្រហស្បតិ៍ ១០រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០ ត្រូវនឹងថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០២៦។

**ចម្លងជូន:**
- ក្រសួងមហាផ្ទៃ
- មន្ទីរជំនាញ និងអង្គភាពពាក់ព័ន្ធ
- ឯកសារកាលប្បវត្តិ

**អភិបាល**

**ឈើ ឆ័រ**

## ឧបសម្ព័ន្ធទី១៖ ស្ថិតិប្រជាពលរដ្ឋខេត្ត ប្រចាំឆមាសទី១ ឆ្នាំ២០២៦

| ល.រ | ឈ្មោះ ក្រុង/ស្រុក | ចំនួនគ្រួសារ | | | ចំនួនប្រជាពលរដ្ឋទូទៅ | | | | | | ចំនួនប្រជាពលរដ្ឋអាយុ ១៨ ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ក្នុងនោះ | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | ប.អាសន្ន | | | |
| | | | អចិន្ត្រៃយ៍ | ប.អាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| ១ | ក្រុងខេមរភូមិន្ទ | 8,104 | 6,873 | 1,231 | 38,254 | 19,727 | 33,742 | 17,284 | 4,512 | 2,443 | 22,874 | 12,443 | 19,984 | 10,902 | 2,890 | 1,541 | 168 | 45 |
| ២ | ស្រុកមណ្ឌលសីមា | 4,559 | 4,344 | 215 | 19,440 | 9,739 | 18,810 | 9,421 | 630 | 318 | 17,217 | 8,795 | 16,780 | 8,565 | 437 | 230 | 421 | 450 |
| ៣ | ស្រុកកោះកុង | 2,495 | 2,474 | 21 | 9,471 | 4,518 | 9,354 | 4,486 | 117 | 32 | 6,495 | 3,140 | 6,396 | 3,115 | 99 | 25 | 713 | 405 |
| ៤ | ស្រុកគីរីសាគរ | 2,553 | 2,430 | 123 | 9,505 | 4,478 | 8,647 | 4,159 | 858 | 319 | 6,454 | 3,037 | 5,774 | 2,787 | 680 | 250 | 524 | 330 |
| ៥ | ស្រុកបូទុមសាគរ | 6,513 | 6,491 | 22 | 25,054 | 12,350 | 25,019 | 12,333 | 35 | 17 | 16,147 | 8,163 | 16,131 | 8,158 | 16 | 5 | 1,293 | 120 |
| ៦ | ស្រុកថ្មបាំង | 2,173 | 2,130 | 43 | 8,551 | 4,230 | 8,398 | 4,171 | 153 | 59 | 5,413 | 2,641 | 5,292 | 2,599 | 121 | 42 | 456 | 46 |
| ៧ | ស្រុកស្រែអំបិល | 10,936 | 10,889 | 47 | 48,481 | 24,742 | 47,870 | 24,255 | 611 | 487 | 30,963 | 15,851 | 30,596 | 15,577 | 367 | 274 | 2,882 | 181 |
| **សរុបទូទាំងខេត្ត** | | **37,333** | **35,631** | **1,702** | **158,756** | **79,784** | **151,840** | **76,109** | **6,916** | **3,675** | **105,563** | **54,070** | **100,953** | **51,703** | **4,610** | **2,367** | **6,457** | **1,577** |

## ឧបសម្ព័ន្ធទី២៖ ការលើកកម្ពស់វិស័យសេវាសង្គមនៃរដ្ឋបាលខេត្ត ប្រចាំខែឆមាសទី១ ឆ្នាំ២០២៦

- ថវិកាគ្រោងសម្រាប់សកម្មភាពសេវាសង្គមនៅក្នុងគម្រោងថវិកាប្រចាំឆ្នាំចំនួន៣៧.៣២៤.០០០រៀល ស្មើនឹង១០០% នៃថវិកាសរុប
- ចំណាយជាក់ស្តែងដែលបានបូកយោងសម្រាប់សកម្មភាពសេវាសង្គមចំនួន២០.៧៤០.០០០រៀល ស្មើនឹង៥៦% (គិតត្រឹមថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២៦)

| ល.រ. | ឈ្មោះសកម្មភាព | ថវិកាគ្រោង | %សកម្មភាពសម្រេចបាន | អ្នកទទួលផល | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| ក)-សុខភាពមាតា កុមារ និងអាហារូបត្ថម្ភ | | | | | |
| ១.១ | បានចុះប្រជុំផ្សព្វផ្សាយ ដល់សហគមន៍ស្តីពីសុខភាពនិងអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ចំនួន១លើក នៅភូមិដីទំនាប១លើក | ១.៨០០.០០០ | ១០០ | ៥០ | ៤៥ |
| ១.២ | បានចុះប្រជុំផ្សព្វផ្សាយ ដល់សហគមន៍ស្តីពីសុខភាពនិងអាហារូបត្ថម្ភរបស់ស្ត្រីនិងកុមារ ចំនួន២លើក ដែលមានអ្នកចូលរួមចំនួន១០០នាក់ ស្រី៨៤នាក់(នៅភូមិដីទំនាប១លើក និងភូមិអន្លង់វ៉ាក់១លើក | ១.៨០០.០០០ | ១០០ | ៥០ | ៣៩ |
| ខ)-ទឹកស្អាតនិងអនាម័យ | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| គ)-ការអប់រំកុមារតូច | | | | | |
| ១.១ | | | | | |
| ១.២ | | | | | |
| ឃ)-ការអប់រំបឋមសិក្សា និងមធ្យមសិក្សា | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |
| ១.២ | | | | | |
| ង)-ការការពារស្ត្រី និងកុមារ | | | | | |
| ១.១ | បានចុះផ្តល់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពដល់គ.ក.ស.ក ក្រុង ស្រុកនិងសមាជិក គ.ក.ន.ក ឃុំ សង្កាត់ស្តីពីនីតិវិធីប្រតិបត្តិកិច្ចការពារកុមារ សម្រាប់រដ្ឋបាលក្រុង ស្រុកចំនួន៧ក្រុង/ស្រុក | ៨.៨៩០.០០០ | ១០០ | ២១០ | ១២៧ |
| ១.២ | បានចុះប្រជុំផ្សព្វផ្សាយដល់សហគមន៍ស្តីពីកិច្ចការពារកុមារ"ចំនួន២លើក(នៅភូមិកោះប៉ោ១លើក និងភូមិចាំយាម១លើក) | ៣.៦០០.០០០ | ១០០ | ១០០ | ៨៩ |
| ច)-កិច្ចគាំពារសង្គម | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១.១ | បានចុះប្រជុំប្រឹក្សាយោបល់ជាមួយស្ត្រីនិងកុមារដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារកំព្រាឪពុកម្ដាយ កុមារដែលមានឪពុកម្ដាយជាប់ពន្ធនាគារ កុមារដែលមានឪពុកម្ដាយផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នៅមជ្ឈមណ្ឌលថែទាំកុមារកំព្រារបស់រដ្ឋ ខេត្តកោះកុង ចំនួន១លើក | ១.១២៥.០០០ | ១០០ | ៣០ | ១៣ |
| ១.២ | បានចុះប្រជុំប្រឹក្សាយោបល់ជាមួយស្ត្រី និងកុមារដែលរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ កុមារកំព្រាឪពុកម្ដាយ កុមារដែលមានឪពុកម្ដាយជាប់ពន្ធនាគារ កុមារដែលមានឪពុកម្ដាយផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ នៅមណ្ឌលលជីវិតថ្មីចំនួន១លើក | ១.១២៥.០០០ | ១០០ | ៣០ | ១៣ |
| ឆ)-លំនៅឋាន | | | | | |
| ១.១ | ពុំទាន់មានសកម្មភាព | | | | |